Safe Child THAILAND



# ការជួញដូរកុមារនៅអនុតំបន់ទន្លេមគង្គ

## របាយការណ៍របស់អង្គការ Safe Child Thailand

Safe Child THAILAND

# ការជួញដូរកុមារនៅអនុតំបន់ទន្លេមេគង្គ
## របាយការណ៍របស់អង្គការ Safe Child Thailand

ស្រាវជ្រាវ និងចងក្រងដោយ C. Rouse
អ្នកស្រាវជ្រាវរង៖ Darin S.
កែសម្រួលដោយ C. Drury, L. Jansury & A. Scadding
©Safe Child Thailand 2017
ឥណទានរូបថត * Simon Elwell; † Sam Gregg

អង្គការ Safe Child Thailand ធ្វើការដើម្បីបង្កើតបាននូវប្រទេសថៃមួយ
ដែលកុមារគ្រប់រូបត្រូវបាន
គោរព ការពារ និងទទួលបានសិទ្ធិ និងឱកាសស្មើៗគ្នា។

អង្គការ Safe Child Thailand
បានបោះពុម្ពផ្សាយរបាយការណ៍នេះដើម្បីលើកកម្ពស់ការយល់ដឹង
បន្ថែមទៀតអំពី បញ្ហាជួញដូរកុមារ និងលើកកម្ពស់កិច្ចសន្ទនាបែបសហការ
និងស្ថាបនារវាងបណ្ដាទី
ភ្នាក់ងារ អ្នកផ្ដល់សេវា និងអ្នកបង្កើត គោលនយោបាយក្នុងស្រុកដែលពាក់ព័ន្ធនឹងការប្រយុទ្ធប
ឆាំងនឹងការជួញដូរមនុស្ស និងការប្រយុទ្ធបឆាំងដើម្បីមាតុភូមិនិវត្តន៍បែបកបដោយសុវត្ថិភាព
និងយុត្តិធម៌
សម្រាប់ជនរងគ្រោះ។

ស្រាប់ព័ត៌មានបន្ថែម សូមមើល៖
safechildthailand.org/trafficking-report

Safe Child Thailand 72 Venn Street, London SW4 0AT, UK
safechildthailand.org | info@safechildthailand.org |+44 (0) 207 602 6203
អង្គការមនុស្សធម៌ដែលបានចុះបញ្ជីនៅប្រទេសអង់គ្លេស និងវេលស៍៖ 1085407.
លេខ DCHY នៅអៀកឡង់ ៖ DCY00028

សូមថ្លែងអំណរគុណចំពោះ៖

**អង្គការសកម្មភាពដើម្បីកុមារអនាថា (Action for Street Kids) ៖** ធ្វើការនៅទូទាំងពិភពលោក
ជាមួយដៃគូក្នុងស្រុកដើម្បីជួយដល់កុមារដែលរស់នៅ និងធ្វើការនៅតាមចិញ្ចើមថ្នល់។

**មូលនិធិ Evan Cornish Foundation ៖** តស៊ូដើម្បីសមភាព និងយុត្តិធម៌សម្រាប់ទាំងអស់គ្នា
ដោយគាំទ្រដល់អ្នកដែលនៅឯកោបំផុត និងលើកកម្ពស់សិទ្ធិមនុស្ស។

**អង្គការ Balcombe Trust អង់គ្លេស**

ម្ចាស់ជំនួយឯកជនសម្រាប់ការចូលរួមវិភាគទានដល់ការស្រាវជ្រាវ បកប្រែ និងបោះពុម្ពផ្សាយ។

ask Action for Street Kids

ECF EVAN CORNISH FOUNDATION

បទ្ទបកាសបដិសេធ៖ ការជួញដូរមនុស្សនៅប្រទេសថៃ គឺជាកម្មវត្ថុដែលមានភាពស្មុគស្មាញ និងមានភាពរសើបផ្នែកនយោបាយបំផុត។ ទិន្នន័យត្រូវបានប្រមូលពីវិស័យផ្សេងៗជាច្រើន៖ ក្រសួង និងការិយាល័យប្រចាំតំបន់នានារបស់រដ្ឋាភិបាល នគរបាល អង្គការជាតិ និងអន្តរជាតិ អ្នកធ្វើការខាងក្រៅឯករាជ្យ ជនរងគ្រោះពីការជួញដូរ និងក្រុមគ្រួសាររបស់ពួកគេ និងសមាជិកមហាជននៅប្រទេសថៃ កម្ពុជា ឡាវ និងមីយ៉ាន់ម៉ា។ អ្នកផ្ដល់ព័ត៌មាន និងអ្នកចូលរួមជាច្រើននាក់បានស្នើសុំឲ្យ រក្សាភាពអនាមិក។ ដើម្បីការពារអត្តសញ្ញាណ និងការងាររបស់អង្គការពួកគេ ព័ត៌មានផ្ទាល់ខ្លួនត្រូវបានដកចេញពីសេចក្ដីព្រាងនេះ។

# មាតិកា


អក្សរកាត់ ៣
សេចក្តីសង្ខេប ៦
និយមន័យទាំងឡាយនៅក្នុងរបាយការណ៍ស្តីពីការជួញដូរមនុស្ស ( TiP ) ៧

**ជំពូក ១៖ សេចក្តីផ្តើម ៨**
សនិទានភាព ៩
គោលបំណងនៃការស្រាវជ្រាវ ៩
ការប្រមូលទិន្នន័យ ៩
វិសាលភាពផ្នែកភូមិសាស្ត្រ ១០
និយមន័យ ១៤
ក្របខ័ណ្ឌច្បាប់ ១៦

**ជំពូក ២៖ ការជួញដូរក្នុងប្រទេស ២២**

**ជំពូក ៣៖ ការជួញដូរព្រំប្រទេសកម្ពុជា ២៨**

**ជំពូក ៤៖ ការជួញដូរព្រំប្រទេសមីយ៉ាន់ម៉ា ៣៦**

**ជំពូក ៥៖ ការជួញដូរព្រំប្រទេសឡាវ ៤៦**

**ជំពូក ៦៖ សេចក្តីសន្និដ្ឋាន និងអនុសាសន៍ ៥០**
សេចក្តីសន្និដ្ឋាន
អនុសាសន៍

**ឯកសារយោង ៥៦**


# អក្សរកាត់

| | |
|---|---|
| AEC | សហគមន៍សេដ្ឋកិច្ចអាស៊ាន |
| ASA | សមាគមន៍អាស៊ីអាគ្នេយ៍ |
| ASEAN | សមាគមន៍ប្រជាជាតិអាស៊ីអាគ្នេយ៍ |
| AAPTIP | កម្មវិធីអូស្ត្រាលី-អាស៊ីដើម្បីប្រយុទ្ធប្រឆាំងនឹងការជួញដូរមនុស្ស |
| BATWC | ការិយាល័យប្រឆាំងការជួញដូរស្ត្រី និងកុមារ នៃក្រសួងអភិវឌ្ឍន៍សង្គម និងសន្តិសុខមនុស្សជាតិ |
| BCATIP | កិច្ចសហប្រតិបត្តិការព្រំដែននៃលើការប្រឆាំងនឹងការជួញដូរមនុស្ស |
| CBO | អង្គការសហគមន៍មូលដ្ឋាន |
| COMMIT | ការស្រមបស្រមួលគំនិតផ្តួចផ្តើមថ្នាក់រដ្ឋមន្ត្រីប្រឆាំងការជួញដូរមនុស្សនៅមហាអនុតំបន់ទន្លេមេគង្គ |
| CPPCR | គណៈកម្មការដើម្បីការពារ និងលើកកម្ពស់សិទ្ធិកុមារ |
| CRC | អនុសញ្ញាស្តីពីសិទ្ធិកុមារ |
| CWCC | អង្គការកម្ពុជាដើម្បីជួយស្ត្រីមានវិបត្តិ |
| ETIP | កម្មវិធីបញ្ឈប់ការជួញដូរមនុស្ស ( អង្គការទស្សនៈពិភពលោក ) |
| DKBA | យោធាការ៉ែននេបេនវ៉ូឡង់ (Karen Benevolent) ប្រជាធិបតេយ្យ |
| DSI | នាយកដ្ឋានស៊ើបការណ៍ពិសេស |
| ILO | អង្គការពលកម្មអន្តរជាតិ |
| IOM | អង្គការអន្តរជាតិអន្តោប្រវេសន៍ |
| LAK | រូបិយប័ណ្ណ គីប របស់ប្រទេសឡាវ |
| LAPTU | អង្គភាពប្រឆាំងការជួញដូរមនុស្សរបស់ប្រទេសឡាវ |
| Lao PDR/Laos | សាធារណរដ្ឋប្រជាមានិតឡាវ |
| MLSW | ក្រសួងការងារ និងសុខុមាលភាពសង្គម |
| MLoSW | ក្រសួងការងារ និងសង្គមកិច្ច ( ឡាវ ) |
| MoU | អនុស្សរណៈនៃការយោគយល់គ្នា |
| MSDHS | ក្រសួងអភិវឌ្ឍន៍សង្គម និងសន្តិសុខមនុស្សជាតិ |
| NGO | អង្គការមិនមែនរដ្ឋាភិបាល |
| NOCHT | មជ្ឈមណ្ឌលប្រតិបត្តិការជាតិទប់ស្កាត់ និងប្រង្កាបការជួញដូរមនុស្ស ) |
| PTC | មជ្ឈមណ្ឌលសំចតប៉ាយប៉ែត |
| SEZ | តំបន់សេដ្ឋកិច្ចពិសេស |
| THB | ថៃបាត |
| TIP | ការជួញដូរមនុស្ស ( របាយការណ៍ ) |
| UN | អង្គការសហប្រជាជាតិ |
| UN–ACT | អង្គការសហប្រជាជាតិស្រមាប់ប្រឆាំងការជួញដូរមនុស្ស |
| UNIAP | គម្រោងអន្តរភ្នាក់ងារ នៃអង្គការសហប្រជាជាតិ លើការជួញដូរមនុស្ស |
| UNICEF | មូលនិធិអង្គការសហប្រជាជាតិដើម្បីកុមារ |
| UNODC | អង្គការសហប្រជាជាតិទទួលបន្ទុកផ្នែកគ្រឿងញៀន និងឧក្រិដ្ឋកម្ម |
| WHO | អង្គការសុខភាពពិភពលោក |





"នៅប្រទេសថៃ ក្នុងគ្រប់ឧស្សាហកម្មទាំងអស់ លោកអ្នកតែងតែឃើញមានកុមារ។ ដើម្បីឲ្យលោកអ្នកអាចកំណត់ថាតើមានការកេងប្រវ័ញ្ច ឬភាពធ្ងន់ធ្ងរកម្រិតណានោះ វាគឺជារឿងខុសប្លែកគ្នា។ នេះគឺជាកន្លែងដែលនិយមន័យនៃពាក្យ □ការជួញដូរ□ ចូលមក។ តើអ្នកចង់គូសបន្ទាត់វិសាលគមនៃការរំលោភបំពាននៅកន្លែងណា? ប្រទេសថៃពុំទាន់បានគូសបន្ទាត់នេះនៅឡើយទេ។ នេះគឺជាមូលហេតុដែលធ្វើឲ្យបញ្ហាការជួញដូរកុមារពិបាកយល់។"

**បុគ្គលិកអង្គការមិនែមនរដ្ឋាភិបាល ទ្រីកុងបាងកក**

## ការជួញដូរកុមារនៅអនុតំបន់ទន្លេមេគង្គ

» ប្រទេសថៃមានសេដ្ឋកិច្ចធំជាងគេបំផុតនៅអនុតំបន់ទន្លេមេគង្គ ហើយ ជាទឹកដីនៃឱកាសទាំងឡាយរបស់បណ្តាប្រទេសក្រីក្រជាច្រើន ដែលរស់នៅជិតខាង ដូចជា ឡាវ មីយ៉ាន់ម៉ា និងកម្ពុជា។ ទីផ្សារដែលមានសន្ទុះដ៏គំហុក និងនគរូបនីយកម្មដ៏ឆាប់រហ័សរបស់ថៃ បង្កើតបាននូវតម្រូវការទីផ្សារការងារតម្លៃថោកឥតឈប់ឈរ។ ដើម្បីជាការឆ្លើយតប កម្មករនិយោជិករាប់លាននាក់បានធ្វើចំណាកស្រុកមកពីបណ្តាប្រទេសជិតខាងដើម្បីបំពេញនូវតម្រូវការនេះ។

» តាមការប៉ាន់ស្មាន មានជនចំណាកស្រុកចំនួន ៣.៧ លាននាក់ដែលកំពុងរស់នៅប្រទេសថៃ និងមានអ្នកស្វែងរកការផ្តល់សិទ្ធិជ្រកកោន និងជនភៀសខ្លួនចំនួន ១៣០.០០០ នាក់បន្ថែមទៀត។[១] ភាគច្រើននៃជនចំណាកស្រុកដែលកំពុងរស់នៅប្រទេសថៃសុទ្ធតខុសច្បាប់ និងពុំបានចុះបញ្ជី។ ការនេះធ្វើឲ្យការធ្វើចំណាកស្រុកពិបាកក្នុងការគ្រប់គង ហើយបញ្ហាអន្តោប្រវេសន៍ខុសច្បាប់ ការរត់ពន្ធមនុស្ស និងការជួញដូរមនុស្សក្លាយទៅជារឿងដែលមិនអាចកែប្រែកបាន និងត្រូវបានគេមើលរំលង។

» ដោយមានការចាប់ខ្លួន និងការកាត់ទោសតិចតួចក្រោមច្បាប់ជួញដូរ ការជួញដូរមនុស្សឆ្លងព្រំដែនក្លាយទៅជារឿងដែលកាន់តែមានការទទួលយក និងជារឿងទូទៅនៅទូទាំងតំបន់នេះ។

» មានការយល់ច្រឡំជាទូទៅថា ការជួញដូរមនុស្សគឺជាគោលគំនិតស្របច្បាប់មួយ ពីព្រោះអ្នកជួញដូរមនុស្សអាចត្រូវបានកាត់ទោសក្រោមច្បាប់ស្តីពីការងារ ដោយសារតែការជួលកុមារមិនទាន់គប់អាយុ ឬជាអ្នករំលោភបំពានកុមារក្រោមច្បាប់ការពារកុមារ។ ស្ថិតិអំពីការជួញដូរមនុស្សដែលអាចរកបានជាទូទៅបញ្ជាក់ពុំបានគ្រប់គាន់អំពីបញ្ហា ពីព្រោះស្ថិតិទាំងនោះផ្តោតទៅលើការធ្វើមាតុភូមិនិវត្តន៍ជាផ្លូវការក្រោមពិធីសារស្របច្បាប់ ដែលតាមពិតទៅកុមារភាគច្រើនត្រូវបាននិរទេសចេញភ្លាមៗដោយពុំមានការចាទប្រកាន់ ឬកំណត់ត្រា។

» តម្រូវការកុមារសម្រាប់ការងារនៅក្នុងវិស័យសំណង់ រោងចក្រ វេចខ្ចប់ត្រី និងទេសចរណ៍ផ្លូវភេទ មានកម្រិតខ្ពស់នៅក្នុងប្រទេសថៃ។ ការជួញដូរកុមារគឺជារឿងខុសច្បាប់ ហើយខ្វះទិន្នន័យចំនួន។ ពុំមានមូលដ្ឋានទិន្នន័យអំពីកុមារដែលត្រូវបានកំណត់អត្តសញ្ញាណថាត្រូវបានជួញដូរ ដែលត្រូវបានរក្សាទុកដោយនគរបាលភូមិន្ទថៃ ឬអាជ្ញាធរដទៃទៀតទេឡើយ ទោះបីជាមានទិន្នន័យមួយដែលគេដឹងថាស្ថិតក្រោមការអភិវឌ្ឍដោយក្រសួងអភិវឌ្ឍន៍សង្គម និងសន្តិសុខមនុស្សជាតិ (MSDHS) ក៏ដោយ។

» ខណៈដែលកុមារជាច្រើនត្រូវបានជួញដូរពីបណ្តាប្រទេសជិតខាង ការជួញដូរផ្ទៃក្នុង ការផ្លាស់ទីកុមារពីតំបន់ជនបទដើម្បីយកទៅធ្វើការនៅតាមទីក្រុងគឺជារឿងទូទៅនៅក្នុងប្រទេសថៃ។ចំនួនយុវជនយុវនារីជនជាតិថៃនៅក្នុងទីជម្រកសម្រាប់ជនរងគ្រោះពីការជួញដូរមនុស្សហាក់ដូចជាមានច្រើន ទោះបីជាមិនច្រើនជាងចំនួនជនបរទេសក៏ដោយ តាមការសន្មត់ជាទូទៅរបស់អាជ្ញាធរថៃឃើញថា កុមារជនជាតិថៃពុំសូវងាយរងគ្រោះពីការជួញដូរទេ។

» ជនក្រីក្រនៅតាមទីជនបទរបស់ប្រទេសថៃ គឺជាគោលដៅសម្រាប់អ្នកជួញដូរមនុស្ស និងមេខ្យល់ដែលផ្តល់លុយច្រើនសម្រាប់ជាការដោះដូរជាមួយនឹងពលកម្មកុមារ។ កុមារដែលត្រូវបានជួញដូរតាមមធ្យោបាយនេះ នៅទីបំផុតតែងតែធ្វើការនៅក្នុងវិស័យពេស្យាចារ ទេសចរណ៍ផ្លូវភេទ ឬនៅក្នុងការងារដែលរងការរំលោភបំពាន និងមានគ្រោះថ្នាក់។

» វាគឺជារឿងខុសច្បាប់នៅក្នុងប្រទេសថៃ សម្រាប់ជនដែលមានអាយុក្រោម ១៨ ឆ្នាំ ដែលប្រកបរបរពេស្យាចារ។ ទោះបីជាយ៉ាងណា ការផ្តោតការយកចិត្តទុកដាក់នៃកិច្ចប្រឹងប្រែងរបស់នគរបាលក្នុងរយៈពេលប៉ុន្មានឆ្នាំថ្មីៗនេះ គឺផាត់ចេញកុមារអាយុក្រោម ១៥ ឆ្នាំពីការងារផ្លូវភេទ។ នេះគឺដោយសារតែមានចំនួនដ៏ច្រើននៃយុវវ័យក្មេងៗ ដែលគេរកឃើញថាកំពុងធ្វើការនៅក្នុងឧស្សាហកម្មផ្លូវភេទនៅទូទាំងប្រទេស។ ជនរងគ្រោះពីការជួញដូរកុមារថៃ ក៏ឃើញមាននៅក្នុងវិស័យផ្សេងៗទៀតផងដែរ រួមមានដូចជា វិស័យនេសាទ សំណង់ ការងាររោងចក្រ កសិកម្ម និងផលិតកម្មជ័រកៅស៊ូ និងប្រេងដូងជាដើម។

» មានតម្រូវការខ្ពស់នូវកុមារកម្ពុជាដើម្បីធ្វើជាអ្នកសុំទាន ឬអ្នកលក់ផ្កានៅតាមតំបន់ទេសចរណ៍របស់ប្រទេសថៃ។ ប្រព័ន្ធដែលបានបង្កើតឡើងយ៉ាងល្អរបស់មេខ្យល់ និងអ្នកនាំមនុស្ស បានបញ្ជូនកុមារទៅកាន់ទីក្រុងបាងកក ប៉ាត់តាយ៉ា និងភូកេត។ ជាទូទៅកុមារបញ្ចប់ការងារជាអ្នកលក់ផ្កាទៅជាឧក្រិដ្ឋកម្មកំប៉ិកកំប៉ុក និងពេស្យាចារ ហើយក៏ក្លាយជាអ្នកជួញដូរមនុស្សដោយខ្លួនឯងផងដែរ។

» ប្រព័ន្ធជួលកុមារមកពីឪពុកម្តាយរបស់ពួកគេ គឺជារឿងទូទៅនៅប្រទេសកម្ពុជា ហើយ មានន័យថាកុមារខ្លះដែលត្រូវបានយកមកកាន់ប្រទេសថៃត្រូវបានធ្វើមាតុភូមិនិវត្តន៍។ ដោយសារតែមានឱកាសតិចតួចសម្រាប់ទទួលការអប់រំ និងការងារនៅប្រទេសកម្ពុជា ពួក គេត្រឡប់មកប្រទេសថៃវិញ ដែលជាកន្លែងដែលគេចាត់ទុកថាងាយស្រួលរកលុយ។ ពុំ មានការស្តារនីតិសម្បទា ឬការថែទាំបន្ត្របកបដោយប្រសិទ្ធភាពសម្រាប់ជនរងគ្រោះពី ការជួញដូរ ដែលត្រឡប់មកកាន់ប្រទេសកម្ពុជាវិញក្រៅពីការថែទាំដែលផ្តល់ជូនដោយ អង្គការមិនមែនរដ្ឋាភិបាលមួយចំនួនតូចទេឡើយ។

» ព្រំដែនដើរងអន្លាយដែលមានច្រកចេញចូលជាច្រើនរវាងប្រទេសថៃ និងមីយ៉ាន់ម៉ា និងរដ្ឋាភិបាលយោធាអស់ជាច្រើនទសវត្សរ៍ ធ្វើឲ្យរាំងស្ទះដល់សេដ្ឋកិច្ច និងសង្គមរបស់មីយ៉ាន់ម៉ា បានធ្វើឲ្យមានចំណាកស្រុកផ្នែកសេដ្ឋកិច្ចជាច្រើនរបស់មីយ៉ាន់ម៉ា។មេសត (Mae Sot) និងរ៉ាន់ណុង (Ranong) គឺជាចំណុចឆ្លងកាត់ពីរដ៏សំខាន់ចូលទៅក្នុងប្រទេសថៃសម្រាប់ជនអន្តោប្រវេសន៍ស្របច្បាប់ និងខុសច្បាប់មកពីមីយ៉ាន់ម៉ា។ ច្រកទាំងពីរនេះក៏ត្រូវបានប្រើប្រាស់ដោយអ្នកជួញដូរមនុស្ស និងមេខ្យល់ដែលនាំកុមារចូលទៅកាន់ប្រទេសថៃផងដែរ។

» កុមារចំណាកស្រុកមកពីប្រទេសមីយ៉ាន់ម៉ា ឃើញមាននៅពាសពេញប្រទេសថៃ ហើយមាននៅគ្រប់ឧស្សាហកម្មស្ទើរតែទាំងអស់។ មានក្តីកង្វល់ជាពិសេសទៅលើស្ថានភាពលំបាករបស់ជនជាតិរ៉ូហ៊ីងយ៉ា (Rohingya) ដែលបាត់បង់ភាពជាពលរដ្ឋ ហើយត្រូវបានបណ្តេញចេញពីផ្ទះសម្បែងរបស់ពួកគេ ដោយរដ្ឋាភិបាលមីយ៉ាន់ម៉ា។ បុរស និង ក្មេងប្រុសជនជាតិរ៉ូហ៊ីងយ៉ាជាច្រើន ត្រូវបានជួញដូរទៅកាន់កងនាវានេសាទដែល ប្រតិបត្តិការនៅក្នុងដែនទឹកភាគខាងត្បូងប្រទេសថៃ និងម៉ាឡេស៊ី។

» មានការរាយការណ៍មកថា ថៃនិរទេសជនចំណាកស្រុកខុសច្បាប់របស់មីយ៉ាន់ម៉ាប្រមាណជា ៤០០ នាក់ជារៀងរាល់ថ្ងៃតាមទីក្រុងជាប់ព្រំដែនភាគពាយព្យតំបន់មេសត ហើយខណៈពេលនោះដែរ មានកិច្ចប្រឹងប្រែងដែលផ្តោតការយកចិត្តទុកដាក់ជាពិសេសទៅលើការកំណត់អត្តសញ្ញាណជនរងគ្រោះពីការជួញដូរ ឹងការធ្វើមាតុភូមិនិវត្តន៍ដោយសុវត្ថិភាព និងស្តារនីតិសម្បទាពួកគេ មានការថែទាំបន្តតិចតួចនៅមីយ៉ាន់ម៉ា។ ជនរងគ្រោះដែលជាកុមារ តែងតែត្រូវបានជួញដូរម្តងទៀតទៅកាន់ប្រទេសថៃក្នុងរយៈពេលមិនដល់មួយខែក្រោយពីបានធ្វើមាតុភូមិនិវត្តន៍។

» ឱកាសការងារនៅមានកម្រិតក្នុងប្រទេសឡាវ ហើយជនជាតិឡាវជាច្រើនឆ្លងដែនចូលទៅធ្វើការនៅប្រទេសថៃ ដែលនៅទីនោះសេដ្ឋកិច្ចមានភាពរឹងមាំខ្លាំងជាង។ ការធ្វើចំណាកស្រុក និងការជួញដូរមនុស្សខុសច្បាប់ក៏កើតមានឡើងផងដែរ ជាពិសេសការជួញដូរស្ត្រី និងកុមារីឡាវដែលជាអ្នករកប្រាក់នៅក្នុងឧស្សាហកម្មផ្លូវភេទ ដែលមានតម្រូវការខ្ពស់ពីអតិថិជនក្នុងស្រុក និងភ្ញៀវទេសចរណ៍។

» ភាពស្រដៀងគ្នាផ្នែកភាសា និងវប្បធម៌រវាងថៃ និងឡាវ ធ្វើឲ្យការជ្រើសរើសកុមារពីប្រទេសឡាវ មានការទាក់ទាញជាពិសេសពីអ្នកជួញដូរ។ ជនរងគ្រោះកាន់តែមានភាពស៊ាំ ហើយត្រូវបានចាត់ទុកថាកាន់តែចុះបតែបន និងជាអ្នកបម្រើការដែលកាន់តែមាន ប្រសិទ្ធភាព។ ជាមធ្យម មានការនិរទេសជនរងគ្រោះពីការជួញដូរប្រហែល ១៥០ នាក់ត្រូវ ឡប់ទៅកាន់ប្រទេសឡាវវិញក្នុងមួយឆ្នាំ។ ជាង ៩៥% **គឺជាស្ត្រី ហើយ ៨០%** នៃស្ត្រីទាំង នោះមានអាយុក្រោម ១៨ ឆ្នាំ។

» ប្រទេសអាស៊ីអាគ្នេយ៍ទាំងអស់ សុទ្ធតែបានចុះហត្ថលេខា និងផ្តល់សច្ចាប័នលើពិធីសារអង្គការសហប្រជាជាតិស្តីពីការទប់ស្កាត់ ការបង្ក្រាប និង ការផ្តន្ទាទោសការជួញដូរមនុស្សឆ្នាំ ២០០០ (ពិធីសារ Palermo)។ ពិធីសារនេះផ្តល់នូវក្របខ័ណ្ឌច្បាប់ជារួមដែលក្នុងនោះ អ្នកជួញដូរអាចត្រូវបានផ្តន្ទាទោសនៅទូទាំងតំបន់។ ការងារនេះអាចសម្រេចបានតែក្នុងករណីដែលកាតព្វកិច្ចផ្លូវច្បាប់ ដែលបានទទួលយកក្រោមពិធីសារត្រូវបានប្រែក្លាយទៅជាច្បាប់ជាធរមាននៅក្នុងប្រទេសនីមួយៗ។ ប៉ុន្តែកិច្ចការនេះត្រូវតែសម្រេចឲ្យបាន។



## និយមន័យរបាយការណ៍ស្តីពីការជួញដូរមនុស្ស (TIP)

ចំណាត់ថ្នាក់ទី ១៖ បណ្តាប្រទេសដែលរដ្ឋាភិបាលគោរពបានពេញលេញទៅតាមបទដ្ឋានអប្បបរិមារបស់ច្បាប់ការពារ ជនរងគ្រោះពីការជួញដូរ ( TVPA ) ។

ចំណាត់ថ្នាក់ទី ២៖ បណ្តាប្រទេសដែលរដ្ឋាភិបាលមិនគោរពបានពេញលេញទៅតាមបទដ្ឋានអប្បបរិមារបស់ TVPA ប៉ុន្តែកំពុងខិតខំប្រឹងប្រែងជាដុំកំភួនដើម្បីធ្វើឲ្យពួកគេគោរពតាមបទដ្ឋានទាំងនោះ។

ចំណាត់ថ្នាក់ទី ២ ក្នុងបញ្ជីតាមដាន៖ បណ្តាប្រទេសដែលរដ្ឋាភិបាលមិនគោរពបានពេញលេញទៅតាមបទដ្ឋាន
អប្បបរិមារបស់ TVPA ប៉ុន្តែកំពុងខិតខំប្រឹងប្រែងជាដុំកំភួនដើម្បីធ្វើឲ្យពួកគេគោរពតាមបទដ្ឋានទាំងនោះ

និង៖

- ចំនួនដាច់ខាតនៃជនរងគ្រោះពីការជួញដូរទម្រង់ធ្ងន់ធ្ងរ មានច្រើន ឬមានការកើនឡើងច្រើន
- មានភាពបរាជ័យក្នុងការផ្តល់ភស្តុតាងអំពីកិច្ចខិតខំប្រឹងប្រែងក្នុងការប្រយុទ្ធប្រឆាំងនឹងការជួញដូរមនុស្សទម្រង់ទាយធ្ងន់ធ្ងរកាលពីឆ្នាំកន្លងមក

ឬ៖

- ការកំណត់ដែលថា ប្រទេសមួយកំពុងខិតខំប្រឹងប្រែងជាដុំកំភួនដើម្បីធ្វើឲ្យពួកគេគោរពតាមបទដ្ឋានអប្បបរិមា គឺផ្អែកទៅលើការប្តេជ្ញាចិត្តរបស់ប្រទេសនោះ ដើម្បីចាត់វិធានការបន្ថែមសម្រាប់ឆ្នាំបន្ទាប់។

ចំណាត់ថ្នាក់ទី ៣៖ បណ្តាប្រទេសដែលរដ្ឋាភិបាលមិនគោរពបានពេញលេញទៅតាមបទដ្ឋានអប្បបរិមា ហើយពុំ បានខិតខំប្រឹងប្រែងជាដុំកំភួនដើម្បីគោរពតាមបទដ្ឋាននោះឡើយ។

» ច្បាប់ប្រឆាំងការជួញដូរមនុស្សឆ្នាំ ២០០៨ គឺជាឯកសារច្បាប់ជាតិស្តីពីការជួញដូរ មនុស្សដំបូងរបស់ប្រទេសថៃ។ ចាប់តាំងពីពេលនោះមក ច្បាប់ជាត្រិសេដៀងគ្នានេះ ត្រូវ បានអនុម័តដោយបណ្តាប្រទេសផ្សេងៗទៀតនៅក្នុងតំបន់។ ទោះបីជាបែបនេះក៏ដោយ កិត្តិសព្ទរបស់អាស៊ីអាគ្នេយ៍ដោយសារតែការជួញដូរមនុស្ស និងការធ្វើអាជីវកម្មលើមនុស្សនៅ តែមិនបាត់បង់ ហើយតថភាព និងភាពធ្ងន់ធ្ងរនៃស្ថានភាពទាំងនោះពុំបានឆ្លុះបញ្ចាំង ត្រឹមត្រូវអំពីភាសាច្បាប់របស់តំបន់ដែលពាក់ព័ន្ធនឹងការជួញដូរមនុស្សឡើយ។

» នៅឆ្នាំ ២០១៤ ប្រទេសថៃថយមកនៅចំណាត់ថ្នាក់ទី ៣ តាមរបាយការណ៍ស្តីពីការ ជួញដូរមនុស្ស (TIP) របស់ក្រសួងការបរទេស ស.រ.អា។ ចំណាត់ថ្នាក់ទី ៣ គឺសម្រាប់ បណ្តាប្រទេស ដែលរដ្ឋាភិបាលមិនគោរពបានពេញលេញទៅតាមបទដ្ឋានអប្បបរិមានៃពិធី សារអង្គការសហប្រជាជាតិស្តីពីការទប់ស្កាត់ការបង្ក្រាប និង ការផ្តន្ទាទោសការជួញដូរ មនុស្សជាពិសេសស្ត្រី និងកុមារ (ពិធីសារ Palermo) ហើយហើយពុំបានខិតខំប្រឹងប្រែង ជាដុំកំភួនដើម្បីគោរពតាមបទដ្ឋាននោះឡើយ។ ការថយចំណាត់ថ្នាក់នេះជំរុញឲ្យ អាជ្ញាធរថៃនាំយកបញ្ហាជួញដូរមនុស្ស មកដាក់ជាបញ្ហាសំខាន់ជាងគេនៅក្នុងរបៀបវារៈ ការអភិវឌ្ឍរបស់ប្រទេស។

» ក្រោយពីស្ថិតនៅក្នុងចំណាត់ថ្នាក់ទី ៣ នៃរបាយការណ៍ TIP អស់រយៈពេលពីរឆ្នាំ ប្រទេសថៃបានឡើងទៅកាន់ចំណាត់ថ្នាក់ទី ២ ក្នុងបញ្ជីតាមដាននៅឆ្នាំ ២០១៦។ ការ ផ្លាស់ទីមកកាន់បញ្ជីតាមដាននេះបញ្ជាក់ឲ្យឃើញថា ប្រទេសថៃបានខិតខំប្រឹងប្រែងជាដុំ កំភួន ដើម្បីឆ្លើយតបទៅនឹងបទដ្ឋានអប្បបរិមាដែលត្រូវការសម្រាប់ប្រយុទ្ធប្រឆាំងនឹងការ ជួញដូរមនុស្ស ដែលមានរៀបរាប់នៅក្នុងច្បាប់ការពារជនរងគ្រោះពីការជួញដូរឆ្នាំ ២០០០។ ទោះជាយ៉ាងណា នៅតែមានកង្វល់ធំៗសម្រាប់ប្រទេសថៃ ដែលបានលើកឡើងនៅក្នុង របាយការណ៍ TIP រួមមានដូចជាចំនួនស្ត្រីដ៏ច្រើន និងកុមារមកពីបណ្តាប្រទេសជិតខាង ដែលកំពុងត្រូវបានគេធ្វើអាជីវកម្មនៅក្នុងឧស្សាហកម្មជាច្រើន រួមមានដូចជា ឧស្សាហកម្មផ្លូវភេទ បុរស និងកុមារដែលត្រូវបានគេធ្វើអាជីវកម្មនៅក្នុង ការនេសាទបែបពាណិជ្ជកម្ម និងជនជាតិរ៉ូហ៊ីងយ៉ាដែលត្រូវបានគេលក់ដូរធ្វើជាទាសករ ទៅឲ្យទូកនេសាទនៅប្រទេសថៃភាគខាងត្បូង។

» ការជួញដូរមនុស្ស បានធ្វើឲ្យខូចកិត្តិសព្ទរបស់ប្រទេសថៃ ហើយក្លាយជាឧក្រិដ្ឋកម្ម មានការរៀបចំឆ្លងប្រទេស។ វាគឺជាអត្ថប្រយោជន៍ល្អបំផុតរបស់ថៃក្នុងការប្រយុទ្ធប្រឆាំង នឹងឧក្រិដ្ឋកម្មនេះ តាមរយៈការអប់រំរបស់នគរបាល សមាជិកសភា មន្ត្រីរដ្ឋាភិបាល និង មហាជនទូទៅ និងតាមរយៈការរារាំងបណ្តាញមេខ្យល់។ ការពិន័យផ្នែកហិរញ្ញវត្ថុចំពោះ ថៅកែដែលធ្វើអាជីវកម្មលើកុមារតាមរយៈពលកម្ម គឺជាប្រភពមូលនិធិដែលមាន សក្តានុពលសម្រាប់យុទ្ធនាការប្រឆាំងនឹងការជួញដូរគ្រប់ជុំជ្រោយ។

» កិច្ចខិតខំប្រឹងប្រែងបែបសហការរបស់រដ្ឋាភិបាលនៃសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ (ASEAN) និងអង្គការមិនមែនរដ្ឋាភិបាល (NGOs) អាចបំបែកវង្វែនជនរងគ្រោះដែល ត្រូវបានធ្វើមាតុភូមិនិវត្តន៍មិនឲ្យត្រឡប់មកកាន់ប្រទេសថៃវិញ។ ត្រូវមានកិច្ចសហ ប្រតិបត្តិការឆ្លងដែនដើម្បីជួយដល់ការឧបត្ថម្ភគាំទ្រដល់ការអប់រំ និងពង្រឹងការប្រតិបត្តិ ច្បាប់។

» របាយការណ៍នេះសូមផ្តល់ជាអនុសាសន៍ជាពិសេសនៅក្នុងប្រទេសថៃថា ពលកម្ម កុមារនៅគ្រប់ឧស្សាហកម្មទាំងអស់គួរតែត្រូវបានប្រកាសថាខុសច្បាប់។ ច្បាប់ដែល ហាមឃាត់កុមារអាយុក្រោម ១៨ ឆ្នាំ ដែលប្រកបរបរពេស្យាចារគួរតែត្រូវបានប្រតិបត្តិ ជាមួយនឹងការរារាំងសកម្មភាពជាសកម្ម ហើយការអនុវត្តន៍ហៅថា tok khiew ដែល មានន័យថា លក់ក្មេងស្រីទៅឲ្យផ្ទះបនដើម្បីយកលុយដោះបំណុលរបស់ឪពុកម្តាយនាង គួរត្រូវបានចាត់ទុកថាជាបទឧក្រិដ្ឋ។



# ជំពូក ១៖ សេចក្តីផ្តើម

*

# សេចក្តីផ្តើម

## សនិទានភាព

អង្គការ Safe Child Thailand បានធ្វើការនៅប្រទេសថៃអស់រយៈពេល ៣៥ ឆ្នាំ ហើយបានឃើញផ្ទាល់ភ្នែកនូវផលប៉ះពាល់បំផ្លិចបំផ្លាញ ដែលការជួញដូរ និងការធ្វើអាជីវកម្មលើមនុស្សមានទៅលើកុមារ និងក្រុមគ្រួសាររបស់ពួកគេ។ ការស្រាវជ្រាវនេះ ត្រូវបានជ្រើសរើសយកដើម្បីជួយឲ្យមានការស្វែងយល់កាន់តែប្រសើរអំពីយន្តការ និងលក្ខណៈនៃការជួញដូរកុមារនៅក្នុងតំបន់ទន្លេមេគង្គ ដែលនៅតំបន់នេះ ប្រទេសថៃធ្វើជាប្រភព គោលដៅ និងចំណុចសំចតស្រមាប់ការជួញដូរមនុស្ស។

ប្រទេសថៃគឺជាមជ្ឈមណ្ឌលសេដ្ឋកិច្ចដ៏សំខាន់របស់អាស៊ីអាគ្នេយ៍។ ដោយមានប្រទេសជិតខាងដែលក្រីក្រជាងជាច្រើនដូចជា ឡាវ មីយ៉ាន់ម៉ា និងកម្ពុជានោះ ប្រទេសថៃ និងម៉ាឡេស៊ីនៅភាគខាងត្បូង គឺជាមេដែកស្រូបទាញមួយស្រមាប់កម្មករចំណាកស្រុកដែលស្វែងរកចំណែកប្រមុងប្រម៉ើនៃផ្នែកសេដ្ឋកិច្ចរបស់ពួកគេ។ នៅប្រទេសថៃ ទ្រព្យសម្បត្តិប្រមូលផ្តុំនៅកណ្តាលតំបន់ទីក្រុង ដែលទាក់ទាញការធ្វើចំណាកស្រុកក្នុងស្រុកដែលមកពីតំបន់ជនបទក្រីក្រ។ ដូច្នេះហើយ ការជួញដូរក្នុងប្រទេសឬការជួញដូរក្នុងស្រុក ក៏ជាបាតុភូតជាទូទៅមួយផងដែរ ហើយកាន់តែពិបាកក្នុងការកំណត់ និងដោះស្រាយ។

ការជួញដូរមនុស្សឆ្លងប្រទេស បង្កជាបញ្ហាស្រមាប់ការកំណត់អត្តសញ្ញាណ និងការផ្តន្ទាទោសអ្នកប្រព្រឹត្តល្មើសក្រោមវង្វង់ច្បាប់តែមួយ។ កិច្ចសហប្រតិបត្តិការឆ្លងដែននៅគ្រប់វិស័យទាំងអស់ត្រូវតែមានដើម្បីឲ្យការងារនេះទទួលជោគជ័យ។ ភ័ស្តុតាងបានបង្ហាញថា នៅខ្វះកិច្ចសហប្រតិបត្តិការបែបនេះ។

នៅឆ្នាំ ២០១៤ នៅពេលដែលរបាយការណ៍នេះត្រូវបានជ្រើសរើសយក ប្រទេសថៃធ្លាក់ចំណាត់ថ្នាក់មកនៅចំណាត់ថ្នាក់ទី ៣ តាមរបាយការណ៍ប្រចាំឆ្នាំស្តីពីការជួញដូរមនុស្ស (TIP) របស់ក្រសួងការបរទេស ស.រ.អា។ ២ មានការលើកឡើងនូវកង្វល់ជាក់លាក់ជុំវិញរបាយការណ៍អំពីស្ត្រី និងកុមារមកពីបណ្តាប្រទេសជិតខាង ដែលកំពុងត្រូវបានគេធ្វើអាជីវកម្មនៅក្នុងឧស្សាហកម្មជាច្រើន រួមមានដូចជា ឧស្សាហកម្មផ្លូវភេទបុរស និងកុមារាដែលត្រូវបានគេធ្វើអាជីវកម្មនៅក្នុងការនេសាទបែបពាណិជ្ជកម្ម និងជនជាតិរ៉ូហ៊ីងយ៉ាដែលត្រូវបានគេលក់ដូរធ្វើជាទាសករទៅឲ្យទូកនេសាទ។

នៅឆ្នាំ ២០១៥ ប្រទេសថៃនៅតែស្ថិតក្នុងចំណាត់ថ្នាក់ទី ៣។ ការរកឃើញរណ្តៅសាកសពជាច្រើននៅតាមបណ្តោយព្រំដែនថៃ-ម៉ាឡេស៊ី បានផ្តល់ជាយោបល់ថា ប្រទេសថៃបានបរាជ័យក្នុងការការពារបុរស ស្ត្រី និងកុមារជនជាតិរ៉ូហ៊ីងយ៉ាពីអង្គការចាត់តាំងឧក្រិដ្ឋកម្មជួញដូរមនុស្ស។ ៣ ការនេះធ្វើឲ្យបញ្ហាជួញដូរមនុស្សមានលំដាប់ខ្ពស់នៅលើរបៀបវារៈនយោបាយរបស់ប្រទេសថៃ។

នៅឆ្នាំ ២០១៦ ប្រទេសថៃបានឡើងទៅកាន់ចំណាត់ថ្នាក់ទី ២ ក្នុងបញ្ជីតាមដានរបស់របាយការណ៍ TIP ដែលបញ្ជាក់ឲ្យឃើញថា រដ្ឋាភិបាលថៃបានខិតខំប្រឹងប្រែងជាដុំកំភួន ដើម្បីប្រយុទ្ធប្រឆាំងនឹងការជួញដូរមនុស្ស។ ៤ វិធានការទាំងឡាយរបស់រដ្ឋាភិបាលថៃដែលធ្វើឡើងដើម្បីលុបបំបាត់ការជួញដូរមនុស្ស និងបំពេញតាមកាតព្វកិច្ចទាំងឡាយនៅក្នុងគោលការណ៍ណែនាំរបស់អង្គការសហប្រជាជាតិរួមមានដូចជា៖ ការព្រងឹងការស៊ើបអង្កេតរបស់នគរបាល ការបង្កើនចំនួននៃការចោទប្រកាន់ និងការផ្តន្ទាទោសក្រោមច្បាប់ប្រឆាំងនឹងការជួញដូរមនុស្ស និងធ្វើវិសោធនកម្មច្បាប់ប្រឆាំងការជួញដូរមនុស្សឆ្នាំ ២០០៨ ការផ្តល់ការអនុញ្ញាតដល់អាជ្ញាធរក្នុងការបិទអាជីវកម្មដែលពាក់ព័ន្ធនឹងពលកម្មដោយបង្ខំ និងការធ្វើអាជីវកម្មលើជនរងគ្រោះពីការជួញដូរមនុស្ស។ ទោះបីជាបែបនេះក៏ដោយ របាយការណ៍ TIP នៅតែគូសបញ្ជាក់ភ័ស្តុតាងការជួញដូរ មនុស្សនៅក្នុងឧស្សាហកម្មស្ទើរតែទាំងអស់ក្នុងប្រទេស។ ការឡើងចំណាត់ថ្នាក់ត្រូវបាន ការជំទាស់ដោយក្រុមសិទ្ធិមនុស្សអន្តរជាតិជាច្រើន ដែលនៅតែរឹងរូសថា ប្រទេសថៃគួរតែស្ថិតនៅក្នុងចំណាត់ថ្នាក់ទី ៣ ដដែល ហើយថាការផ្លាស់ទីនេះគឺស្ថិតក្រោមហេតុផលនយោបាយ ហើយពុំមាននិរន្តរភាពទេ។ ៥

> TIP [ការជួញដូរមនុស្ស] គឺជាបញ្ហាថ្មីមួយ ហើយថ្មីៗនេះមានប្រជាប្រិយភាពក្នុងរយៈពេល ១០ ឆ្នាំចុងក្រោយនេះ ហើយច្បាប់ប្រឆាំងការជួញដូរមនុស្សមានត្រឹមតែ ៦ ឆ្នាំ ប៉ុណ្ណោះ។ ច្បាប់ភាគច្រើនផ្សារភ្ជាប់បញ្ហានេះតែជាមួយ នឹងអំពើពេស្យាចារ ឬជនចំណាកស្រុកដែលធ្វើការក្នុងស្ថានភាពអាក្រក់ប៉ុណ្ណោះ។
>
> បុគ្គលិកកាន់សំណុំរឿងស្រមាប់កុមារកុលសម្ព័ន្ធភ្នំ ប្រទេសថៃ

របាយការណ៍នេះ មានគោលបំណងរួមចំណែកក្នុងការផ្តល់ចំណេះដឹងអំពីប្រធានបទការជួញដូរមនុស្ស។ វាត្រូវបានបោះពុម្ពផ្សាយដើម្បីបម្រើជាប្រភព និងឧបករណ៍មួយស្រមាប់រដ្ឋាភិបាល និងអង្គការ NGOs ដែលធ្វើការដើម្បីប្រយុទ្ធប្រឆាំងការជួញដូរមនុស្សនៅក្នុងតំបន់។

## គោលបំណងនៃការស្រាវជ្រាវ

ដើម្បីស្វែងយល់ និងស៊ើបអង្កេតអំពីបាតុភូតនៃការជួញដូរកុមារ របាយការណ៍នេះមានគោលបំណងឆ្លើយតបនឹងសំណួរស្រាវជ្រាវទាំងឡាយដូចតទៅ៖

» ត្រើប្រទេសថៃធ្វើជា ប្រភព គោលដៅ និងប្រទេសសំចតស្រមាប់ការជួញដូរកុមារដូចម្តេចខ្លះ ?

» តើជនរងគ្រោះពីការជួញដូរមកពីកន្លែងណាខ្លះ ?

» ហេតុអ្វីបានជាកុមារ និងសហគមន៍មួយចំនួនមានហានិភ័យជាពិសេស ?

» តើឪពុកម្តាយ និងក្រុមគ្រួសារមានតួនាទីអ្វីខ្លះនៅក្នុងដំណើរការជួញដូរ ?

» តើមានផ្លូវសំខាន់ៗណាខ្លះចូលទៅកាន់ប្រទេសថៃ និងជាគោលដៅចុងក្រោយស្រមាប់ក្រុមខុសៗគ្នា ?

» តើមានយុទ្ធសាស្ត្ររួមអ្វីខ្លះស្រមាប់គេចវេះពីការត្រួតពិនិត្យតាមព្រំដែន ?

» តើរបាយការណ៍ស្តីពីការជួញដូរមនុស្ស (TIP) របស់រដ្ឋាភិបាល ស.រ.អា ឆ្លុះបញ្ចាំង អំពីស្ថានភាពនេះបានត្រឹមត្រូវដែរឬទេ ?

» តើមានការិយាល័យ និងអង្គការណាខ្លះដែលកំពុងធ្វើការនៅគ្រប់សទាប់វណ្ណៈដើម្បី ប្រយុទ្ធប្រឆាំងនឹងការជួញដូរមនុស្ស ?

» តើមានឧបសគ្គធំៗអ្វីខ្លះដែលរារាំងដល់ការប្រយុទ្ធប្រឆាំងនឹងការជួញដូរកុមារនៅក្នុងអនុតំបន់ទន្លេមេគង្គ ?

## ការប្រមូលទិន្នន័យ

ពុំមានប្រព័ន្ធជាសាកលក្នុងការចែករំលែកទិន្នន័យ និងកម្មសិទ្ធិបញ្ញាស្រមាប់រឿងក្តីជួញដូរកុមារឡើយ។ ប៉ុន្តែ ទោះបីជាមានប្រព័ន្ធនេះក៏ដោយ ក៏ពុំមានមូលដ្ឋានទិន្នន័យថ្នាក់ជាតិនៅក្នុងប្រទេសថៃ កម្ពុជា មីយ៉ាន់ម៉ា ឬឡាវដែលជះឥទ្ធិពលទៅលើរបាយការណ៍នេះដែរ។ ទិន្នន័យ និងស្ថិតិដែលគួរឲ្យជឿទុកចិត្តបានអំពីសកម្មភាពខុសច្បាប់នេះមានកង្វះខាតយ៉ាងខ្លាំង ដោយសារតែមានការលំបាកក្នុងការទទួលស្ថិតិនៅថ្នាក់តំបន់ និងថ្នាក់ជាតិ។

ដោយសារគ្មានទិន្នន័យបែបស្ថិតិ របាយការណ៍នេះផ្តល់នូវការប៉ាន់ស្មាន និងការវិភាគដោយផ្អែកទៅលើទិន្នន័យ ដែលប្រមូលបានតាមរយៈការចុះដល់មូលដ្ឋានផ្ទាល់នៅក្នុងប្រទេសថៃ កម្ពុជា ឡាវ និងមីយ៉ាន់ម៉ា។ ការជួញដូរមនុស្សមានភាពស្រពេចស្រពិលជាច្រើន។ ភាពច្របូកច្របល់កើតឡើងតបណ្តាលមកពីការមិនបានញែកឲ្យដាច់ពីគ្នារវាងពាក្យថា ពលកម្មកុមារ ការជួញដូរកុមារ និងការរត់ពន្ធកុមារ។ ពាក្យនីមួយៗ គឺជាបញ្ហាដាច់ដោយឡែកមួយ ហើយរបាយការណ៍នេះព្យាយាមរក្សាការផ្តោតការយកចិត្តទុកដាក់ទៅលើការជួញដូរមនុស្សខ្លាំងបំផុតតាមដែលអាចធ្វើបាន។

ការចុះស្រាវជ្រាវដល់មូលដ្ឋាន គឺជាមធ្យោបាយតែមួយគត់ក្នុងការប្រមូលព័ត៌មានអំពីបញ្ហានោះនៅកម្រិតមួយដែលអាចអនុវត្តបាន។ ដោយសារគ្មានព័ត៌មានបែបស្ថិតិដែលអាចជឿទុកចិត្តបាន និងដោយគ្មានមធ្យោបាយណាមួយក្នុងការទទួលព័ត៌មាននោះ យើងពឹងផ្អែកមួយភាគធំទៅលើភ័ស្តុតាងជារឿងខ្លីៗ និងបទពិសោធន៍ផ្ទាល់ខ្លួន។

ការស្រាវជ្រាវនេះដាក់បញ្ចូលព័ត៌មានដែលទទួលបានតាមរយៈ ៖ ការពិនិត្យឯកសារ និងការវិភាគទៅលើបរិបទបន្ទាប់បន្សំ ការសម្ភាសន៍អ្នកផ្តល់ព័ត៌មានសំខាន់ៗជាមួយអាជ្ញាធររដ្ឋ រួមមានដូចជា មន្ត្រីរដ្ឋាភិបាល មន្ត្រីអន្តោប្រវេសន៍ នាយកដ្ឋានស៊ើបអង្កេតពិសេស (DSI) និងនគរបាលភូមិន្ទថៃ ការពិនិត្យឯកសារច្បាប់ និងឯកសាររដ្ឋាភិបាល ពោលគឺ ទម្រង់បែបបទអត្តសញ្ញាណជនរងគ្រោះ កំណត់ត្រា

និរទេស និងរបាយការណ៍ប្រចាំឆ្នាំ ការសម្ភាសន៍អ្នកផ្តល់ព័ត៌មានសំខាន់ៗជាមួយទីភ្នាក់ងារផ្តល់ជំនួយអន្តរជាតិ អ្នកមានវិជ្ជាជីវៈផ្នែកច្បាប់ បុគ្គលិកអង្គការ NGOs បុគ្គលិកេសវាសង្គមកិច្ច និងបុគ្គលិកកាន់សំណុំរឿង ការសម្ភាសន៍ជាមួយអាជ្ញាធរមូលដ្ឋាន ក្រុមគ្រួសារ និងឪពុកម្តាយ និងការអង្កេតអ្នកជួញដូរ និងជនរងគ្រោះដែលជាកុមារ និងបន្លាស់ទីរបស់ពួកគេនៅទូទាំងប្រទេសថៃ មីយ៉ាន់ម៉ា ឡាវ និងកម្ពុជា។

## វិសាលភាពភូមិសាស្ត្រ

ទិន្នន័យត្រូវបានប្រមូលនៅក្នុងតំបន់ទាំងឡាយដូចតទៅ៖

### ថៃ

**បាងកក៖** អង្គការអន្តរជាតិ និងការិយាល័យរដ្ឋាភិបាលជាច្រើនមានមូលដ្ឋាននៅទីក្រុងបាងកក។ ការសម្ភាសន៍ជាមួយមន្ត្រីរដ្ឋាភិបាល នគរបាល ក្រសួង និងអង្គការ NGOs នានាត្រូវបានធ្វើឡើងនៅបាងកក ដើម្បីទទួលបានពន្លឺអំពីគោលនយោបាយ និងប្រភពទិន្នន័យដែលមានស្រាប់អំពីការជួញដូរកុមារ។

**ខេត្តឈុនប៊ុរី៖** ប៉ាត់តាយ៉ាគឺជាទីប្រជុំជនធំជាងគេបំផុតនៅក្នុងខេត្តឈុនប៊ុរី និងជាគោលដៅទេសចរណ៍ដ៏ល្បីខាងរឿងមិនល្អមួយរបស់ថៃ ជាពិសេសទេសចរណ៍ផ្លូវភេទ។ ស្រុកដែលមានភ្លើងភ្លឺក្រហមដ៏ល្បីនេះ គឺជាទីជ្រកកោនរបស់បុរស ស្ត្រី និងកុមាររាប់ពាន់នាក់ដែលបានក្លាយជាជនរងគ្រោះពីការជួញដូរផ្លូវភេទ។ ការសម្ភាសន៍ដំបូងនៅបាងកក ជួយដល់ការកំណត់បានថា ប៉ាត់តាយ៉ា គឺជាគោលដៅសំខាន់មួយសម្រាប់ជនរងគ្រោះកុមារដែលធ្វើការនៅក្នុងឧស្សាហកម្មផ្លូវភេទ។

**ខេត្តតាក៖** តាក មានទីតាំងនៅតាមព្រំដែនរវាងប្រទេសថៃ និងមីយ៉ាន់ម៉ា។ នៅតាកមានជំរុំជនភៀសខ្លួនធំៗចំនួន ៣ កន្លែង ដែលជារួមផ្តល់នូវទីជ្រកដល់ជនភៀសខ្លួនជនជាតិមីយ៉ាន់ម៉ាចំនួន ៦០,០០០ នាក់។ ២៥៦ មេសត គឺជាស្រុកមួយនៅក្នុងខេត្តតាកដែលមានព្រំដែនឆ្លងទៅកាន់ មីយ៉ាវ៉ាត់ឌី ដែលធ្វើឲ្យវាក្លាយទៅជាមជ្ឈមណ្ឌលមួយសម្រាប់សហគមន៍ចំណាកស្រុកភូមា។ ខេត្តតាក គឺជាខេត្តមួយក្នុងចំណោមតំបន់សេដ្ឋកិច្ចពិសេស (SEZ) របស់ថៃ ដែលជាតំបន់មួយដែលមានគោលដៅលើកស្ទួយការអភិវឌ្ឍសេដ្ឋកិច្ចតំបន់រវាងបណ្តារដ្ឋអាស៊ាន។[៦]

មេសត បម្រើជាចំណុចសំចតមួយសម្រាប់ជនរងគ្រោះកុមារ ដែលបាននាំចូលមកកាន់ប្រទេសថៃពីមីយ៉ាន់ម៉ា។ លើសពីនេះទៀត របាយការណ៍នេះ បានកំណត់ថា មេសតគឺជាសហគមន៍ប្រភពដ៏សំខាន់សម្រាប់ជនរងគ្រោះពីការជួញដូរដែលជាកុមារភូមា។ គេតែងតែឃើញពួកគេដើរលក់ផ្កានៅបាងកក ឬធ្វើការងារជាកទាបនៅតាមគោលដៅទេសចរណ៍ផ្សេងទៀតរបស់ថៃ។ តំបន់នេះគឺជាទីតាំងល្អសម្រាប់អ្នកជួញដូរដែលឆ្លៀតកេងប្រយោជន៍ពីភាពងាយរងគ្រោះរបស់កម្មករចំណាកស្រុក និងកូនៗរបស់ពួកគេ។

**ខេត្តរ៉ាក់ណង៖** រ៉ាក់ណង លាតសន្ធឹងនៅតាមបណ្តោយព្រំដែនរវាងប្រទេសថៃ និងមីយ៉ាន់ម៉ា ឆ្ពោះទៅភាគខាងត្បូងច្រើនជាងខេត្តតាក។ ដោយសារតែមានទីតាំងនៅជិតប្រទេសថៃ កម្មករចំណាកស្រុកភូមាខុសច្បាប់ជាច្រើន ចូលមកកាន់ប្រទេសនេះនៅតាមច្រកដែលពុំមានសញ្ញាសម្គាល់នៅតាមបណ្តោយព្រំដែន។ រ៉ាក់ណង គឺជាគោលដៅដ៏សំខាន់មួយសម្រាប់ជនជាតិរ៉ូហ៊ីងយ៉ា ហើយជាចំណុចសំចតសម្រាប់កុមារដែលត្រូវបានគេធ្វើអាជីវកម្មនៅលើទូកនេសាទនៅប្រទេសថៃភាគខាងត្បូង និងប្រទេសម៉ាឡេស៊ី។

**ខេត្តណងខៃ៖** ណងខៃ គឺជាខេត្តភាគឦសានមួយរបស់ថៃនៅតាមបណ្តោយមាត់ទន្លេមេគង្គ ដែលស្ពានមិត្តភាពបានតភ្ជាប់គ្នារវាងប្រទេសថៃ និងឡាវ។ ណងខៃ បម្រើជាចំណុចគោលដៅដំបូងសម្រាប់កុមារឡាវ ជារឿយៗគឺជាកុមារី ដែលចូលមកកាន់ប្រទេសថៃតាមរយៈរាជធានីរបស់ឡាវ គឺទីក្រុងវៀងច័ន្ទ។ នៅខេត្តណងខៃ មានផ្ទះបនរាប់រយកន្លែង ដែលជួលក្មេងស្រីមិនទាន់គ្រប់អាយុរបស់ឡាវ និងថៃដើម្បីបម្រើអតិថិជនឡាវ ថៃ និងបរទេស។ ណងខៃ ក៏ដើរតួជាចំណុចសំចតសម្រាប់កុមារដែលត្រូវបានគេជួញដូរទៅកាន់គោលដៅទេសចរណ៍ធំៗរបស់ថៃផងដែរ រួមមានដូចជា ទីក្រុងបាងកក ប៉ាត់តាយ៉ា និងភូកេត។

**ឈៀងម៉ៃ៖** ឈៀងម៉ៃ គឺជាទីក្រុងធំបំផុតទីពីររបស់ថៃ ហើយជាមួយបណ្តាខេត្តជុំវិញក្រុងនេះ វាបម្រើជាចំណុចសំចតសម្រាប់បុរស ស្ត្រី និងកុមារភូមា ដែលចូលមកកាន់ប្រទេសថៃពីសហគមន៍ជនបទ តាមផ្លូវក្នុងព្រៃ និងដានផ្លូវដែលគ្មានសញ្ញាសម្គាល់។ ឈៀងម៉ៃស្ថិតនៅជិតសហគមន៍កុលសម្ព័ន្ធភ្នំជាច្រើន ដែលរងគ្រោះដោយអ្នកជួញដូរនៅក្នុងតំបន់នោះ។

ដូចគ្នានឹងខេត្តណងខៃដែរ ឈៀងម៉ៃមានផ្ទះបនជាច្រើន ដែលជួលកុមារកុលសម្ព័ន្ធ និងកុមាររបស់ភូមា ភាគច្រើនគឺដើម្បីបំពេញតម្រូវការពាណិជ្ជកម្មទេសចរណ៍ផ្លូវភេទរបស់ឈៀងម៉ៃ។ ឈៀងម៉ៃ គឺជាគោលដៅទេសចរណ៍ដ៏ពេញនិយមមួយ ដែលហ៊ុំព័ទ្ធដោយសហគមន៍ជនជាតិដើមនៅទីជនបទ ហើយបានក្លាយទៅជាគោលដៅដ៏សំខាន់មួយសម្រាប់កុមារដែលត្រូវបានគេជួញដូរ ដែលនៅទីបំផុតធ្វើការនៅក្នុងពាណិជ្ជកម្មផ្លូវភេទ ឬធ្វើជាអ្នកសុំទាន ឬអ្នកលក់ផ្កា។

**ខេត្តភូកេត៖** ភូកេត គឺជាខេត្តដើកោះមួយនៅក្នុងសមុទ្រអាន់ដាម៉ាន់ នៅភាគខាងលិចនៃប្រទេសថៃ។ ភូកេត តភ្ជាប់ទៅកាន់ដីគោកដោយផ្លូវថ្នល់។ វាគឺជាកំពង់ផែនេសាទដ៏មមាញឹកមួយ និងជាគោលដៅសម្រាប់ជួញដូរជនរងគ្រោះដែលត្រូវបាននាំមកកាន់ប្រទេសថៃដើម្បីធ្វើការនៅលើទូកនេសាទ និងនៅក្នុងឧស្សាហកម្មវេចខ្ចប់ត្រី។ ភូកេត ក៏ជាចំណុចក្តៅផ្នែកទេសចរណ៍ដ៏ពេញនិយមមួយផងដែរ ហើយមានទិដ្ឋភាពពេលរាត្រីដ៏ល្បីល្បាញមួយ ដែលនៅទីបំផុតក្មេងប្រុស និងក្មេងស្រីត្រូវបានគេកេងប្រវ័ញ្ចយកទៅធ្វើការនៅក្នុងបារ និងផ្ទះបន។

### កម្ពុជា

ប៉ោយប៉ែត៖ ប៉ោយប៉ែត គឺជាក្រុងមួយនៅក្នុងខេត្តបន្ទាយមានជ័យ នៅតាមបណ្តោយព្រំដែនរវាងកម្ពុជា និងថៃ។ ប៉ោយប៉ែត បម្រើជាចំណុចផ្លូវការមួយសម្រាប់ធ្វើមាតុភូមិនិវត្តន៍ជនរងគ្រោះពីការជួញដូរ និងនិរទេសជនចំណាកស្រុកខុសច្បាប់ទៅកាន់ប្រទេសកម្ពុជាវិញ។ ជាង ៩០% នៃកុមារកម្ពុជាដែលត្រូវបានគេជួញដូរនៅក្នុងប្រទេសថៃ និងម៉ាឡេស៊ី សុទ្ធតែមកពីតំបន់អនាធិបតេយ្យ និងភូមិទាំងឡាយនៅក្នុងតំបន់នេះ។[៧]

**ម៉ាឡៃ៖** ម៉ាឡៃ គឺជាស្រុកមួយនៅភាគនិរតីនៃខេត្តបន្ទាយមានជ័យ ស្ថិតក្នុងភាគពាយព្យនៃប្រទេសកម្ពុជា។ ម៉ាឡៃ បម្រើជាចំណុចចូលខុសច្បាប់ទៅកាន់ប្រទេសថៃ ហើយត្រូវបានប្រើជាជម្រើសនៅពេលមានការរឹតបន្តឹងសន្តិសុខនៅប៉ោយប៉ែត។ កុមារមកពីស្រុកម៉ាឡៃ ជាញឹកញាប់តែងតែជាគោលដៅរបស់អ្នកជួញដូរ ដែលសង្ឃឹមថាធ្វើការរៀបចំជាមួយឪពុកម្តាយពួកគេក្នុងរឿងបំណុល។

### មីយ៉ាន់ម៉ា

**មីយ៉ាវ៉ាត់ឌី៖** មីយ៉ាវ៉ាត់ឌី គឺជាក្រុងមួយនៅភាគអាគ្នេយ៍ប្រទេសមីយ៉ាន់ម៉ា ស្ថិតនៅក្នុងរដ្ឋកាយិននៅតាមបណ្តោយព្រំដែនជាមួយប្រទេសថៃ។ មីយ៉ាវ៉ាត់ឌី ខណ្ឌចែកពីប្រទេសថៃ (មេសត) ដោយទន្លេម (Moei River)។ ក្រុងនេះគឺជាចំណុចពាណិជ្ជកម្មសំខាន់ជាងគេរវាងមីយ៉ាន់ម៉ា និងថៃ ហើយគឺជាទីតាំងច្រកខុសច្បាប់រាប់សិប ដែលមេខ្យល់ និងជនចំណាកស្រុកធ្វើដំណើរទៅមករវាងប្រទេសទាំងពីរ។ នៅពេលជនរងគ្រោះដែលជាកុមារភូមាត្រូវបានធ្វើមាតុភូមិនិវត្តន៍ ពួកគេត្រូវបានបញ្ជូនទៅកាន់ទីជ្រកកោនមីយ៉ាវ៉ាត់ឌី។ ក្នុងករណីជាច្រើន ការធ្វើមាតុភូមិនិវត្តន៍ដំណើរការក្រៅផ្លូវការតាមច្រកខុសច្បាប់ ដែលជាញឹកញាប់ត្រូវបានធ្វើឲ្យស្របច្បាប់សម្រាប់ការរៀបចំពាណិជ្ជកម្មមួយចំនួន។

### ឡាវ

**វៀងច័ន្ទ៖** វៀងច័ន្ទ គឺជារាជធានីរបស់ប្រទេសឡាវ ហើយលាតសន្ធឹងនៅតាមព្រំដែនភាគខាងជើងប្រទេសថៃ។ ទីក្រុងនេះត្រូវបានតភ្ជាប់ទៅកាន់ខេត្តណងខៃរបស់ប្រទេសថៃដោយស្ពានមិត្តភាព។ កុមារជាច្រើនមកពីតាមភូមិតូចៗទូទាំងប្រទេស ធ្វើដំណើរមកកាន់ទីក្រុងវៀងច័ន្ទដើម្បីស្វែងរកការងារធ្វើ។ នៅពេលទៅដល់ទីនោះ ពួកគេត្រូវបានល្បួងឲ្យទៅកាន់ប្រទេសថៃដោយមេខ្យល់ ដែលបញ្ចុះបញ្ចូលពួកគេថាពួកគេនឹងរកលុយបានច្រើននៅប្រទេសថៃ។ វៀងច័ន្ទ ក៏ជាចំណុចផ្លូវការមួយសម្រាប់ធ្វើមាតុភូមិនិវត្តន៍ និងនិរទេសជនរងគ្រោះឡាវ និងជាតំបន់ដែលមានអង្គការ NGOs ជាច្រើនធ្វើការខាងសេវាជួយជនរងគ្រោះផងដែរ។


វៀតណាម
មីយ៉ាន់ម៉ា
ឡាវ
ថៃ
កម្ពុជា
ម៉ាឡេស៊ី
6
11
5
3
10
1
8
9
2
4
7
គន្លឹះ
១. បាងកក ប្រទេសថៃ
២. ប៉ាត់តាយ៉ា ឈុនប៊ុរី ប្រទេសថៃ
៣. មេសត តាក ប្រទេសថៃ
៤. រ៉ាក់ណង ប្រទេសថៃ
៥. ណងៃខ ប្រទេសថៃ
៦. ឈៀងម៉ៃ ប្រទេសថៃ
៧. ភូកេត ប្រទេសថៃ
៨. ប៉ោយប៉ែត ប្រទេសកម្ពុជា
៩. ម៉ាឡៃ ប្រទេសកម្ពុជា
១០. មីយ៉ាវ៉ាត់ឌី ប្រទេសមីយ៉ាន់ម៉ា
១១. វៀងច័ន្ទ ប្រទេសឡាវ


433031
B.O.T
รฟท SRT

"រដ្ឋាភិបាលថៃចង់ដឹងថាតើមានជនរងគ្រោះសរុបប៉ុន្មាននាក់ ដូច្នេះហើយទើបមានរបាយការណ៍ជាច្រើន ដែលកំណត់អត្តសញ្ញាណជនរងគ្រោះក្នុងចំនួនដ៏ច្រើន ហើយធ្វើឲ្យប្រទេសថៃខូចមុខមាត់។ តាមការពិត ពុំមានទិន្នន័យដែលអាចជឿទុកចិត្តបានទេ។ អង្គការប្រឆាំងការជួញដូរមនុស្សនៅក្នុងប្រទេសនេះប្រើបទដ្ឋានខុសៗគ្នាក្នុងការកំណត់ករណីជួញដូរមនុស្ស។ ពុំមានការប្រាស្រ័យទាក់ទង ឬប្រព័ន្ធជាក់ស្តែងក្នុងការប្រៀបធៀបព័ត៌មានដែលបានដំណើរការពិនិត្យឡើយ។"

បុគ្គលិកអង្គការ NGO ទ្រីកុងបាងកក



## តើកុមារជាអ្វី?

និយមន័យដែលមានការទទួលយកយ៉ាងទូលំទូលាយជាងគេបំផុត ដែលបានផ្តល់ដោយអនុសញ្ញាអង្គការសហប្រជាជាតិស្តីពីសិទ្ធិកុមារឆ្នាំ ១៩៨៩ គឺ ជនណាម្នាក់ដែលមានអាយុក្រោម ១៨ ឆ្នាំ។ [៨]

ទោះបីជាមាននិយមន័យនេះក៏ដោយ ប្រទេសជាច្រើន ជាពិសេសនៅអាស៊ីអាគ្នេយ៍ មាននិយមន័យតាមទម្លាប់ខុសៗគ្នា និងមិនស្របគ្នាអំពី "កុមារ" និងមានប្រភេទជាច់ដាយឡែកសម្រាប់ "អនីតិជន" ដែលធ្វើឲ្យពិបាកយល់តាមផ្លូវឧទាហរណ៍ច្បាប់អំពីអ្វី ដែលផ្សំបានជាពាក្យ "ការជួញដូរកុមារ"។

ឧទាហរណ៍ មីយ៉ាន់ម៉ា កំណត់និយមន័យ "កុមារ" ថាជាជនណាម្នាក់ដែលមានអាយុក្រោម ១៦ ឆ្នាំ។ ៩ ការនេះមានន័យថា ការជួញដូរកុមារអាយុក្រោម ១៦ ឆ្នាំ ទំនងជាត្រូវបានផ្តន្ទាទោសពីបទជួញដូរកុមារ។ អនីតិជន ដែលអ្នកដែលមានអាយុចាប់ពី ១៦ ឆ្នាំដល់ ១៨ ឆ្នាំ មិនសូវត្រូវបានកំណត់ថាជាជនរងគ្រោះពីការជួញដូរទេ ផ្ទុយទៅវិញគឺជាពលករកុមារចំណាក្រសុក។

## តើការជួញដូរជាអ្វី?

មកទល់នឹងឆ្នាំ ២០០០ ពុំមាននិយមន័យរួមដែលអាចទទួលយកបានជាសាកលអំពីពាក្យថាការជួញដូរនៅឡើយទេ ដែលធ្វើឲ្យការជួញដូរមានភាពរីកចម្រើន មិន អាចចាប់បាន និងមិនអាចកំណត់ថាជាអំពើឧក្រិដ្ឋកម្មនៅទូទាំងពិភពលោក។

និយមន័យអន្តរជាតិអំពីការជួញដូរ ដែលផ្តល់ដោយមាត្រា ៣ (ក) នៃពិធីសារ Palermo គឺ៖

"ការជ្រើសរើស ដឹកជញ្ជូន ផ្ទេរ ផ្តល់កន្លែងស្នាក់នៅ ឬទទួលមនុស្ស ដោយមធ្យោបាយគំរាមកំហែង ឬប្រើកម្លាំងបាយ ឬការចាប់បង្ខំ ការចាប់ព្រង់ត់ ការឆបោក ការបន្លំ ការរំលោភអំណាច ឬការដាក់ឲ្យស្ថិតក្នុងភាពងាយរងគ្រោះ ឬការផ្តល់ ឬទទួលប្រាក់ ឬអត្ថប្រយោជន៍ដើម្បីទទួលបានការអនុញ្ញាតពីជនដែលមានការគ្រប់គ្រងលើជនម្នាក់ផ្សេងទៀត សម្រាប់ជាគោលបំណងនៃការកេងប្រវ័ញ្ច តាម រូបភាពផ្សេងៗ។ ការកេងប្រវ័ញ្ច រួមមានជាអប្បបរិមាដូចជា ការកេងប្រវ័ញ្ចដោយ ពេស្យាចារទៅលើអ្នកដទៃ ឬការកេងប្រវ័ញ្ចផ្លូវភេទតាមរូបភាពផ្សេងៗ ការងារ ឬ សេវាដោយបង្ខំ ទាសភាព ឬការអនុវត្តន៍ស្រដៀងនឹងទាសភាព ភាពជាខ្ញុំបម្រើ ឬ ការកាត់យកសរីរាង្គ។" [១០]

តាមនិយមន័យនេះ ពិធីសារនេះយល់ថា ការជួញដូរត្រូវតែរួមបញ្ចូលសមាសភាពស្នូលបីគឺ៖

**សកម្មភាព៖** ការជ្រើសរើស ការដឹកជញ្ជូន ការផ្ទេរ ឬការផ្តល់កន្លែងស្នាក់នៅដល់មនុស្ស។

**មធ្យោបាយ៖** ការប្រើប្រាស់កម្លាំងបាយ ការចាប់បង្ខំ ការចាប់ព្រង់ត់ ការឆបោក ឬការបោកបញ្ឆោត ការរំលោភបំពានលើភាពរងគ្រោះ ឬការផ្តល់ប្រាក់ដល់ជនដែលមានការគ្រប់គ្រងលើជនរងគ្រោះ

**គោលបំណង៖** គោលបំណងគឺកេងប្រវ័ញ្ច (កេងប្រវ័ញ្ចផ្លូវភេទ ពេស្យាចារ ពលកម្មដោយបង្ខំ។ល។) [១១]

ពិធីសារ Palermo ក៏បានថ្លែងផងដែរថា ករណីជួញដូរកុមារត្រូវការសមាសភាពតែពីរប៉ុណ្ណោះក្នុងចំណោមសមាសភាពទាំងបីគឺ៖ បន្លាស់ទី និងការកេងប្រវ័ញ្ច។ តាមរយៈនិយមន័យនេះ នេះគឺដោយសារតែកុមារមិនអាចផ្តល់ការអនុញ្ញាត្រស្របច្បាប់ដើម្បីផ្លាស់ទីបានទេ។

## តើការជួញដូរកុមារជាអ្វី?

ពិធីសារ Palermo ចាត់ទុកការជួញដូរកុមារថាជាការជ្រើសរើស ការដឹកជញ្ជូន ការ ផ្តល់កន្លែងស្នាក់នៅ ឬការទទួលជនណាម្នាក់ដែលមានអាយុក្រោម ១៨ ឆ្នាំ សម្រាប់ជាគោលបំណងនៃការកេងប្រវ័ញ្ច ទោះបីវាពុំមានពាក់ព័ន្ធនឹងមធ្យោបាយណាមួយដែលបានចែងនៅក្នុងកថាខណ្ឌរង (ក) នៃមាត្រានោះក៏ដោយ។ [១២]

ប្រទេសថៃប្រើប្រាស់និយមន័យនេះ ជាមូលដ្ឋានមួយសម្រាប់ការធ្វើចំណាត់ថ្នាក់ផ្លូវការទៅលើការជួញដូរកុមាររបស់ខ្លួន៖

"ជនណាក៏ដោយ សម្រាប់ជាគោលបំណងនៃការកេងប្រវ័ញ្ច សញ្ជារកម្ម ទិញ លក់ ដើរលក់ នាំយកមកពី ឬបញ្ជូនទៅកាន់ ឬបង្ខាំងទុក ផ្តល់កន្លែងស្នាក់នៅ ឬទទួលកុមារ ត្រូវជាប់ ពិរុទ្ធពីបទជួញដូរមនុស្ស។" [១៣]

កិច្ចប្រឹងប្រែងនៅថ្នាក់តំបន់ និងអន្តរជាតិក្នុងការផ្តល់និយមន័យតាមបទដ្ឋានអំពីការជួញដូរកុមារ មានឥទ្ធិពលមួយចំនួន ដែលវាគ្មានន័យខ្លឹមសារអ្វីឡើយប្រសិនបើគ្មានការជួយឧបត្ថម្ភពីច្បាប់ជាតិនៅគ្រប់បណ្តាប្រទេសពាក់ព័ន្ធទាំងអស់ ដែលមានការគាំទ្រលើនិយមន័យដែលមានភាពស្របគ្នានៃពាក្យ "ការជួញដូរ" និង "កុមារ"។

ដោយសារអវត្តមាននេះ ករណីជួញដូរមនុស្សជាច្រើនពុំត្រូវបានកំណត់អត្តសញ្ញាណទទួលស្គាល់ និង/ឬផ្តន្ទាទោសឡើយ។ នៅក្នុងករណីមួយចំនួន ជនរងគ្រោះពីការជួញដូរអាចត្រូវបានផ្តន្ទាទោសថាជាជនចំណាកស្រុកខុសច្បាប់ ដោយសារតែស្ថានភាព និងឋានៈជាជនរងគ្រោះរបស់ពួកគេពុំត្រូវបានបង្កើតច្បាស់លាស់នៅក្នុងច្បាប់។ កុមារដែលមានអាយុក្រោម ១៨ ឆ្នាំ អាចត្រូវបានផ្តន្ទាទោសដូចមនុស្សពេញវ័យដែរ ប្រសិនបើប្រទេសកំណើតរបស់ពួកគេប្រើប្រាស់និយមន័យខុសពីនិយមន័យនៃអ្វីដែលរួមផ្សំបានជាអាយុកុមារ និង/ឬអាយុគ្រប់ការ។

## តើការជួញដូរផ្ទៃក្នុងជាអ្វី?

ការជួញដូរក្នុងប្រទេសដែលគេហៅម្យ៉ាងទៀតថាការជួញដូរក្នុងស្រុក គឺជាការជួញដូរបុគ្គល (ដោយមិនគិតពីភាពជាពលរដ្ឋ ឬសញ្ជាតិ) នៅក្នុងរង្វង់ព្រំដែនរបស់ប្រទេសណាមួយ។១៤ ឧទាហរណ៍ កុមារដែលត្រូវបានជួញដូរមកពីភូមិណាមួយនៅប្រទេសថៃភាគ ខាងកើតទៅកាន់ទីក្រុងបាងកក សម្រាប់គោលបំណងកេងប្រវ័ញ្ច គឺជាករណីជួញដូរផ្ទៃក្នុង។

## តើការរំលោភបំពានកុមារជាអ្វី?

អង្គការសុខភាពពិភពលោក (WHO) កំណត់និយមន័យការរំលោភបំពានកុមារថា *"គ្រប់ រូបភាពទាំងអស់នៃប្រព្រឹត្តចេលើសេបើសមកលើផ្លូវកាយ ផ្លូវចិត្ត ការរំលោភបំពានផ្លូវភេទ ការមិនយកចិត្តទុកដាក់ និងការកេងប្រវ័ញ្ចដែលជាលទ្ធផលបណ្តាលឲ្យមានគ្រោះថ្នាក់ ជាក់ស្តែង ឬជាសក្តានុពលទៅលើសុខភាព ការលូតលាស់ ឬសេចក្តីថ្លៃថ្នូររបស់កុមារ។ ស្ថិតក្នុងនិយមន័យដ៏ទូលំទូលាយនេះ គេអាចបែងចែកចេញពីគ្មានប្រភេទរងចំនួនប្រាំគឺ ការរំលោភបំពានផ្លូវកាយ ការរំលោភបំពានផ្លូវភេទ ការមិនយកចិត្តទុកដាក់ និងការប្រព្រឹត្ត មកលើដោយមិនយកចិត្តទុកដាក់ ការរំលោភបំពានផ្លូវចិត្ត និងការកេងប្រវ័ញ្ច។"*[១៥]

នៅប្រទេសថៃ មានការរំលោភបំពានកុមារជាច្រើនដែលត្រូវទទួលខុសត្រូវចំពោះក្តីកង្វល់នេះ។ នៅឆ្នាំ ២០១៣ អង្គការ UNICEF បានរាយការណ៍ថា កុមារជាង ១៩,០០០ នាក់បានមកទទួលការព្យាបាលនៅមន្ទីរពេទ្យខេត្តទូទាំងប្រទេសថៃ ដែលជាលទ្ធផលនៃការរំលោភបំពានតាមរូបភាពមួយចំនួន។ ក្នុងចំណោមកុមារទាំង ១៩,០០០ នាក់នេះ ៧០% ទទួលការព្យាបាលសម្រាប់ករណីរំលោភបំពានផ្លូវភេទ។ [១៦]

ការជួញដូរកុមារ គឺជារូបភាពមួយនៃការរំលោភបំពានកុមារ។ លើសពីនេះ កុមារដែលត្រូវបានគេជួញដូរ ដែលស្ថិតនៅក្នុងប្រទេសថៃដោយគ្មានអាណាព្យាបាល ឬអ្នកថែទាំសុវត្ថិភាព ប្រឈមនឹងហានិភ័យធ្ងន់ធ្ងរពីការរំលោភបំពានផ្លូវកាយ ផ្លូវភេទ និងផ្លូវចិត្ត និងការមិនយក ចិត្តទុកដាក់។

នៅប្រទេសថៃ រឿងក្តីជួញដូរកុមារអាចត្រូវបានបញ្ជូនទៅកាន់តុលាការដូចគ្នាទៅវិញទៅមកនឹងរឿងក្តីរំលោភបំពានកុមារដែរ។ យោងតាមនគរបាលភូមិន្ទថៃ ការរំលោភបំពានកុមារគឺជាអ្វីមួយដែលបំពានទៅលើកុមារ។ ដោយសារតែមានភាពច្របូកច្របល់ជុំវិញនិយមន័យនៃពាក្យ "ការជួញដូរ" ារឿយៗមានភាពងាយស្រួលសម្រាប់នគរបាលក្នុងការទទួលបាននូវការផ្តន្ទាទោសដោយបន្តសំណុំរឿងក្តីថាជា "ការរំលោភបំពានកុមារ" ជាជាង ស៊ើបអង្កេត និងកំណត់រឿងក្តីនោះថាជា "ការជួញដូរកុមារ" ទៅវិញ ទោះបីជានៅពេល ដែលកំពុងជួញដូរនោះគឺជាការរំលោភបំពានក៏ដោយ។

## តើពលកម្មកុមារគឺជាអ្វី ?

ពលកម្មកុមារ គឺជាការជួលកុមារនៅក្នុងការងារណាមួយដែលដកកុមារចេញពីកុមារភាពរបស់ពួកគេ ជ្រៀតជ្រែកសមត្ថភាពពួកគេក្នុងការទៅរៀនឲ្យបានទៀងទាត់ ហើយវាមាន គ្រោះថ្នាក់ដល់ផ្លូវកាយ ផ្លូវចិត្ត ផ្លូវសង្គម ឬសីលធម៌ ហើយបង្កគ្រោះថ្នាក់។[១៧]

ទោះជាយ៉ាងណា ពលកម្មកុមារ ពុំមែនជានិច្ចកាលសុទ្ធតែជាលទ្ធផលនៃការជួញដូរឡើយ កុមារតែងត្រូវបានគេជួញដូរទៅក្នុងស្ថានភាពពលកម្មដោយបង្ខំ ទាសភាព និងភាពជាខ្ញុំបម្រើនៅតាមផ្ទះ។

ពលកម្មកុមារ ត្រូវបានប្រកាសថាខុសច្បាប់នៅក្នុងប្រទេសថៃ ហើយវាជាអំពើខុសច្បាប់ក្នុងការជួលជនណាម្នាក់ដែលមានអាយុក្រោម ១៥ ឆ្នាំ។[១៨]

តាមប្រពៃណីនៅប្រទេសថៃ ពលកម្មកុមារបានចូលរួមចំណែកយ៉ាងច្រើនដល់សេដ្ឋកិច្ចជនបទ ជាពិសេសក្នុងវិស័យកសិកម្ម។ ដូច្នេះ មានរឿងអាស្រូវសង្គមតិចតួច ឬគ្មានទាល់តែសោះទាក់ទងនឹងការរំពឹងកុមារឲ្យធ្វើការ។

សព្វថ្ងៃនេះ មានកុមារដែលកំពុងធ្វើការកាន់តែតិចតួច ពីព្រោះសិទ្ធិទទួលបានការអប់រំមានការកែលម្អយ៉ាងច្រើនគួរឲ្យកត់សម្គាល់។១៩
ខណៈដែលរឿងនេះតំណាងឲ្យការផ្លាស់ ប្តូរជាវិជ្ជមានសម្រាប់កុមារថៃក៏ដោយ នៅតែមានតម្រូវការពលកម្មកុមារដដែល ដែល តម្រូវការនេះត្រូវបានបំពេញជំនួសដោយកុមារចំណាកស្រុក និងកុមារមកពីសហគមន៍ ជនជាតិដើមភាគតិចមកពីភាគខាងជើងប្រទេសថៃ ដែលជាទូទៅពុំមានសិទ្ធិជាពលរដ្ឋ ថៃ ឬពុំមានសិទ្ធិទទួលបានការសិក្សាឡើយ។

សំណុំរឿងពលកម្មកុមារជាច្រើន តែងត្រូវបានផ្តន្ទាទោសក្រោមច្បាប់ស្តីពីការរំលោភបំពានកុមារ។ នៅពេលកុមារត្រូវបានបង្ខំឲ្យសុំទាននៅតាមដងផ្លូវដោយឪពុកម្តាយរបស់ពួកគេ បញ្ហានេះអាចជាលទ្ធផលនៃការជួញដូរកុមារ ពលកម្មកុមារ ឬការរំលោភបំពានកុមារ ដែលឪពុកម្តាយពួកគេអាចត្រូវបានផ្តន្ទាទោសក្រោមច្បាប់ការពារកុមារឆ្នាំ ២០០៣។

## តើមានភាពខុសគ្នាអ្វីខ្លះរវាងការជួញដូរ និងការរត់ពន្ធ ?

ក្រសួងការបរទេស ស.រ.អា កំណត់និយមន័យនៃពាក្យ "ការរត់ពន្ធមនុស្ស" ថា *"ការស្រមបស្រមួល ការដឹកជញ្ជូន ការប៉ុនប៉ងដឹកជញ្ជូន ឬការចូលដោយខុសច្បាប់របស់ជនណាម្នាក់កាត់តាមព្រំដែនអន្តរជាតិ ដែលជាការបំពានទៅលើច្បាប់ប្រទេសរបស់ប្រទេសមួយ ឬច្រើន ទោះដោយលួចលាក់ក្តី ឬដោយការលួចលាក់ក្តី ឬការឆបោកក្តីដូចជា ការប្រើប្រាស់ឯកសារក្លែងក្លាយជាដើម។"*[២០]

ការរត់ពន្ធមនុស្ស ជាទូទៅផ្តល់ផលចំណេញដល់អ្នករត់ពន្ធ ពីព្រោះជនដែលត្រូវបានគេរត់ពន្ធបង់លុយដើម្បីឲ្យគេដឹកជញ្ជូនឆ្លងព្រំដែន ( ឧ. នៅផ្នែកខាងក្រោយនៃឡានដឹកទំនិញ )។ ទោះជាយ៉ាងណា និយមន័យនេះ ពុំទាមទារអត្ថប្រយោជន៍ហិរញ្ញវត្ថុឡើយ។

ការរត់ពន្ធ ពុំមានពាក់ព័ន្ធនឹងការរៀបចំឯកសារ ឬការប្រកាសជាផ្លូវការអ្វីមួយឡើយ ដូច្នេះហើយបុគ្គលដែលត្រូវបានគេរត់ពន្ធ គឺជាជនអន្តោប្រវេសន៍ខុសច្បាប់ដោយស្ម័យប្រវត្តិ។ ពួកគេពុំមែនជាជនរងគ្រោះពីការជួញដូរទេ ប៉ុន្តែស្ថានភាពរបស់ពួកគេក្នុងនាមជាជនអន្តោប្រវេសន៍ខុសច្បាប់ ធ្វើឲ្យពួកគេងាយរងគ្រោះដោយសារការជួញដូរ និងការកេងប្រវ័ញ្ចតាមរូបភាពផ្សេងៗ។

នៅប្រទេសថៃ ករណីរត់ពន្ធជាច្រើនក្លាយទៅជាករណីជួញដូរមនុស្ស។ បុគ្គលម្នាក់អាចនឹងត្រូវបង់លុយឲ្យអ្នករត់ពន្ធ ដើម្បីនាំពួកគេចូលទៅកាន់ប្រទេសថៃ ហើយនៅពេលមកដល់ ពួកគេត្រូវបានគេនាំទៅកាន់កន្លែងធ្វើការក្នុងគោលបំណងកេងប្រវ័ញ្ច។ ឧក្រិដ្ឋកម្មនេះ ពុំត្រូវបានចាត់ថ្នាក់ កំណត់អត្តសញ្ញាណ ឬចោទប្រកាន់ក្រោមច្បាប់ស្តីពីការជួញដូរមនុស្សដូចគ្នាឡើយ។

បុគ្គលដែលត្រូវបានគេរត់ពន្ធ គឺជាអ្នកដែលបានផ្តល់ការអនុញ្ញាតឲ្យគេនាំពួកគេឆ្លងព្រំដែនជាតិដោយខុសច្បាប់។ ប្រសិនបើពុំមានការផ្តល់ការអនុញ្ញាត ឬទទួលបានការអនុញ្ញាតដោយការឆបោកនោះ មានន័យថាបុគ្គលនោះត្រូវបានគេជួញដូរហើយ។

ដូច្នេះ ករណីដែលបុគ្គលដែលត្រូវបានគេរត់ពន្ធគឺជាកុមារ ជានិច្ចកាលវាជាករណីជួញដូរ ពីព្រោះកុមារពុំមានសមត្ថភាពស្របច្បាប់ ដើម្បីផ្តល់ការអនុញ្ញាតឲ្យគេរត់ពន្ធខ្លួនឡើយ។ ទោះជាយ៉ាងណា ពុំមានភាពខុសគ្នាក្នុងផ្លូវច្បាប់ជាក់ស្តែងរវាងកុមារដែលត្រូវបានរត់ពន្ធ និងកុមារដែលជាជនរងគ្រោះនៃការជួញដូរមនុស្សឡើយ។

## តើអ្នកជួញដូរជាអ្វី ?

អង្គការ UNICEF បានថ្លែងបញ្ជាក់ថា ជនណាម្នាក់ដែលដឹងថា រាល់សកម្មភាពរបស់ខ្លួនអាចជានឹងនាំទៅរកការកេងប្រវ័ញ្ចកុមារណាម្នាក់ គឺជាអ្នកជួញដូរ ចំណែកអ្នកដែលពុំមានចេតនា ពុំបានដឹង ឬពុំមានការសង្ស័យថាកុមារនោះនឹងត្រូវបានគេកេងប្រវ័ញ្ច ពុំត្រូវបានចាត់ទុកថាជាអ្នកជួញដូរឡើយ។[២១]

ការជួញដូរ តែងតែពាក់ព័ន្ធជាមួយនឹងបណ្តាញឧក្រិដ្ឋកម្មស្មុគស្មាញ ឧក្រិដ្ឋកម្មឆ្លងប្រទេសដោយមានការរៀបចំ ហើយអ្នកជួញដូរ និងឧក្រិដ្ឋជន គឺជាអ្នកឃុបឃិតគ្នាធ្វើអំពើខុសច្បាប់។ ទោះជាយ៉ាងណា ក្នុងបរិបទមួយចំនួន ការជួញដូរកើតឡើងក្នុងរង្វង់ជញ្ជាំងទាំងបួននៃផ្ទះរបស់គ្រួសារមួយ។ សាច់ញាតិ និងសូម្បីតែឪពុកម្តាយ ក៏អាចជាអ្នករួមគំនិតនៅក្នុងការជួញដូរកូនរបស់ខ្លួនផងដែរ ដែលគ្រួសារខ្លះថែមទាំងដឹងទៀតថាកូនរបស់ខ្លួននឹងត្រូវធ្លាក់ចូលទៅក្នុងរណ្តៅគ្រោះថ្នាក់ និងត្រូវបានគេកេងប្រវ័ញ្ច។

> *អ្នកជួញដូរមនុស្ស អាចជាបុគ្គលតែម្នាក់ ឬអាចជាបណ្តាញឧក្រិដ្ឋកម្មដ៏ធំទូលាយមួយ។ អ្នកគួរកេជរស្រី ជើងកាង សមាជិកគ្រួសារ មេខ្យល់ពលករ ចៅកែខ្ញុំបម្រើក្នុងស្រុក ម្ចាស់អាជីវកម្មខ្នាតតូច និងម្ចាស់រោងចក្រធំៗ សុទ្ធតែត្រូវបានគេរកឃើញថាជាប់ពិរុទ្ធពីបទជួញដូរមនុស្ស។ ដំណើររឿងរបស់ពួកគេគឺ ចេតនាចង់កេងប្រវ័ញ្ចមនុស្សដទៃទៀតដើម្បីរកផលចំណេញ។*
>
> ប៉ូឡារី[២២]

## សូមពិចារណាលើករណីទាំងឡាយដូចតទៅ៖

ករណីទាំងពីរសុទ្ធតែពាក់ព័ន្ធនឹងការកេងប្រវ័ញ្ចកុមារ ពលកម្មកុមារ និងការរំលោភបំពានកុមារ។ ទោះជាយ៉ាងណា មានតែករណីមួយប៉ុណ្ណោះដែលជាករណីជួញដូរ។ ទាំងនេះគឺជាសេណារីយ៉ូទូទៅនៅប្រទេសថៃ ហើយបង្ហាញឲ្យឃើញនូវភាពលំបាកក្នុងការកំណត់និយមន័យការជួញដូរកុមារ ពិបាកក្នុងការកំណត់អត្តសញ្ញាណករណីជួញដូរកុមារ និងពិបាកក្នុងការផ្តន្ទាទោសអ្នកជួញដូរកុមារក្រោមច្បាប់ស្តីពីការជួញដូរមនុស្ស។ រាល់ករណីជួញដូរទាំងអស់ សុទ្ធតែខុសៗគ្នា ហើយគុណតម្លៃ វប្បធម៌ និងជំនឿរបស់ប្រទេស និងសហគមន៍នីមួយៗជះឥទ្ធិពលទៅលើនិយមន័យ និងច្បាប់បន្តបន្ទាប់ស្តីពីការជួញដូរមនុស្ស និងពលកម្មកុមារ។

**ករណីទី ១៖** ក្មេងប្រុសអាយុ ១៣ ឆ្នាំម្នាក់ រស់នៅជាមួយឪពុកម្តាយជាជនចំណាកស្រុករបស់ខ្លួននៅក្នុងភូមិមួយនៃប្រទេសថៃ។ គាត់តាមឪពុកម្តាយរបស់គាត់ទៅធ្វើការនៅក្នុងរោងចក្រវាយណត្ឋ័ណមួយនៅក្នុងក្រុងជិតនោះ។ ការធ្វើការជាមួយឪពុកម្តាយរបស់គាត់ក្នុងរោងចក្ររយៈពេល ១០ ម៉ោងក្នុងមួយថ្ងៃ គាត់រកប្រាក់កម្រៃបានបន្តិចបន្តួចដែលជួយសម្រាលស្ថានភាពសេដ្ឋកិច្ចគ្រួសារ។

**នេះមិនមែនជាករណីជួញដូរទេ។** គ្រួសារចំណាកស្រុកនេះធ្វើការនៅប្រទេសថៃតាមជម្រើសរបស់ខ្លួន ហើយទោះបីជាសិទ្ធិក្នុងការទទួលការអប់រំរបស់កុមារនេះត្រូវបានបដិសេធ ហើយត្រូវបានរំពឹងថានឹងធ្វើការច្រើនម៉ោង និងខុសច្បាប់ក៏ដោយ គាត់នៅពុំទាន់ត្រូវបានជួញដូរទៅក្នុងស្ថានភាពកេងប្រវ័ញ្ចនៅឡើយទេ។

**ករណីទី ២៖** ក្មេងស្រីអាយុ ១៥ ឆ្នាំម្នាក់ ដែលមកពីភាគឦសានប្រទេសថៃ ត្រូវបានបញ្ជូនដោយឪពុកម្តាយរបស់នាងមកកាន់ទីក្រុងបាងកក ដើម្បីធ្វើការនៅក្នុងបារមួយដែលកាន់កាប់ដោយបងប្អូនជីដូនមួយសាច់ឆ្ងាយម្នាក់។ ឪពុករបស់នាងអមដំណើរមកជាមួយនាងមកកាន់ទីក្រុងបាងកក ហើយទុកឲ្យនាងស្ថិតក្រោមការថែទាំរបស់បងប្អូនជីដូនមួយរបស់នាង ដែលនាងពុំធ្លាប់បានជួបពីមុនមកសោះ។ នាងត្រូវបានរំពឹងថានឹងធ្វើការរាល់យប់នៅក្នុងបារ និងផ្ញើលុយមកផ្ទះឲ្យឪពុកម្តាយនាង។

**នេះគឺជាករណីជួញដូរមួយ។** កុមារនេះបានធ្វើដំណើរមកកាន់ទីក្រុងបាងកក ហើយពេលទៅដល់ទីនោះ មានគេ *"ផ្តល់កន្លែងឲ្យស្នាក់នៅ និងទទួលយក"* ក្នុងគោលបំណងកេងប្រវ័ញ្ច។ កុមារនេះធ្វើដំណើរមកឆ្ងាយពីមជ្ឈដ្ឋានមានសុវត្ថិភាព និងធ្លាក់ចូលទៅក្នុងស្ថានភាពកេងប្រវ័ញ្ច។

# ក្របខណ្ឌច្បាប់

## ច្បាប់អន្តរជាតិ

ការជួញដូរមនុស្ស គឺជាឧក្រិដ្ឋកម្មមួយដែលមានវិសាលគមទូទាំងសាកលលោក។ ច្បាប់អន្តរជាតិ បានបម្រើជាឧបករណ៍ដ៏មានអំណាចមួយ នៅក្នុងការប្រយុទ្ធប្រឆាំងនឹងការជួញដូរមនុស្ស ប៉ុន្តែទោះបីជាមានការអនុម័តលិខិតុបករណ៍អន្តរជាតិស្តីពីសិទ្ធិមនុស្សបច្ចុប្បន្នហើយក៏ដោយ ក៏មានបណ្តាប្រទេសនានាដែលប្រឈមនឹងបញ្ហាជាបន្តបន្ទាប់ នៅក្នុងការអនុវត្តន៍គោលនយោបាយ និងបំពេញកាតព្វកិច្ចតាមសន្ធិសញ្ញាអន្តរជាតិផងដែរ។

ជំហានដំបូងក្នុងការគោរពតាមច្បាប់អន្តរជាតិគឺ ការផ្តល់សច្ចាប័ន* និង/ឬ ការចូលជាភាគី† នៃអនុសញ្ញា និងពិធីសាររបស់អនុសញ្ញាទាំងនោះ។ ការផ្តល់សច្ចាប័នព្រមទាំងសម្ព័ន្ធ ធ្វើឲ្យមានការត្រួតពិនិត្យជាផ្លូវការពីគណៈកម្មការអង្គការសហប្រជាជាតិ (UN) ដែលត្រូវបានបង្កើតឡើងដើម្បីរៀបចំការស្រាវជ្រាវ និងប្រមូលព័ត៌មានទិន្នន័យពីអង្គការនានា ដែលធ្វើការនៅគ្រប់ប្រសព្វវិស័យ។

ប្រជាជាតិដែលបានផ្តល់សច្ចាប័ននៅលើអនុសញ្ញា និងពិធីសារជាក់លាក់មួយចំនួន ត្រូវដាក់ស្នើរបាយការណ៍ដែលបញ្ជាក់ច្បាស់ពីក្រមិតនៃការគោរពរបស់ខ្លួន។ មានបណ្តាប្រទេសជាច្រើន ដែលយឺតយ៉ាវជាញឹកញាប់ក្នុងការផ្តល់សច្ចាប័ននៅលើអនុសញ្ញា ឬពិធីសារមួយ រហូតទាល់តែប្រទេសខ្លួនបានឆ្លងច្បាប់ជាតិដែលធ្វើឲ្យ ពួកគេអាចបំពេញតាមកាតព្វកិច្ចទាំងឡាយរបស់សន្ធិសញ្ញានោះ។

នៅឆ្នាំ ២០០០ លិខិតុបករណ៍ច្បាប់សំខាន់ៗចំនួនបី ត្រូវបានធ្វើព្រាងដោយការិយាល័យអង្គការសហប្រជាជាតិទទួលបន្ទុកផ្នែកគ្រឿងញៀន និងឧក្រិដ្ឋកម្ម (UNODC)។ លិខិតុបករណ៍ទាំងនេះរួមមានដូចជា៖

- អនុសញ្ញាអង្គការសហប្រជាជាតិប្រឆាំងនឹងឧក្រិដ្ឋកម្មឆ្លងប្រទេសដោយមានការរៀបចំ
- ពិធីសារអង្គការសហប្រជាជាតិស្តីពីការទប់ស្កាត់ ការបង្ក្រាប និងការផ្តន្ទាទោសការជួញដូរមនុស្ស ជាពិសេសស្ត្រី និងកុមារ (ពិធីសារ Palermo)
- ពិធីសារអង្គការសហប្រជាជាតិប្រឆាំងនឹងការរត់ពន្ធជនចំណាកស្រុកតាមផ្លូវគោក ផ្លូវទឹក និងផ្លូវអាកាស

តារាងនៅទំព័រទី ១៩ បង្ហាញពីការប្តេជ្ញាចិត្តដែលបានធ្វើឡើងដោយប្រទេសថៃ កម្ពុជា មីយ៉ាន់ម៉ា និងឡាវ ចំពោះច្បាប់អន្តរជាតិសំខាន់ៗដែលទាក់ទងនឹងឧក្រិដ្ឋកម្មដែលមានការរៀបចំ និងការជួញដូរមនុស្ស។

## ពិធីសារ Palermo

ពិធីសារអង្គការសហប្រជាជាតិស្តីពីការទប់ស្កាត់ ការបង្ក្រាប និង ការផ្តន្ទាទោសការជួញដូរមនុស្ស ជាពិសេសស្ត្រី និងកុមារ ហៅម្យ៉ាងទៀតថា ពិធីសារ Palermo គឺជាសន្ធិសញ្ញាដ៏សំខាន់ និងមានឥទ្ធិពលជាងគេបំផុតដោះស្រាយបញ្ហាជួញដូរមនុស្ស។ វាគឺជាសំណុំកាតព្វកិច្ចដ៏ធ្ងន់ធ្ងរ ដែលមានសក្តានុពលក្នុងការធ្វើឲ្យមានការផ្លាស់ប្តូរពិត្រប្រាកដ ចំពោះវិធីដែលពិភពលោកដើរឆ្ពោះទៅរកការជួញដូរមនុស្ស។

ពិធីសារនេះ កំណត់និយមន័យការជួញដូរមនុស្សក្នុងបរិបទជាសាកលមួយ ហើយកំណត់នូវបទដ្ឋានលម្អិតសម្រាប់ការទប់ស្កាត់ និងការផ្តន្ទាទោសជាភាសាកាតព្វកិច្ចច្បាប់មួយ ដែលប្រជាពលរដ្ឋក្នុងស្រុកអាចយល់បាន។

កាតព្វកិច្ចរបស់បណ្តាប្រទេសហត្ថលេខីនៃអនុសញ្ញា Palermo រួមមាន ប៉ុន្តែមិនកំណត់ចំពោះ៖

- កាតព្វកិច្ចក្នុងការប្រកាសថា ការជួញដូរមនុស្សគឺជាឧក្រិដ្ឋកម្ម និងដាក់ទោសអ្នកប្រព្រឹត្តល្មើសតាមរយៈការអនុវត្តន៍ និងការប្រតិបត្តិច្បាប់ជាតិ
- កាតព្វកិច្ចក្នុងការកំណត់អត្តសញ្ញាណជនរងគ្រោះយ៉ាងសកម្ម និងផ្តល់ឋានៈដល់ជនរងគ្រោះ
- កាតព្វកិច្ចក្នុងការស៊ើបអង្កេតរឿងក្តីប្រកបដោយការយកចិត្តទុកដាក់ និងផ្តន្ទាទោសអ្នកប្រព្រឹត្តល្មើសជួញដូរមនុស្ស
- កាតព្វកិច្ចក្នុងការធ្វើមាតុភូមិនិវត្តន៍ជនរងគ្រោះ ដែលពុំមានឯកសារត្រឹមត្រូវ ដោយជួយសម្របសម្រួលឲ្យពួកគេបានវិលត្រឡប់ទៅប្រទេសកំណើតរបស់ខ្លួនវិញ
- កាតព្វកិច្ចក្នុងការការពារ គាំទ្រ និងផ្តល់ការគាំពារព្យាបាល និងស្តារនីតិសម្បទាជនរងគ្រោះ
- កាតព្វកិច្ចក្នុងការផ្តល់វិធានការពិសេសសម្រាប់ជនរងគ្រោះដែលជាកុមារ
- កាតព្វកិច្ចក្នុងការកំណត់វិធីសាស្ត្រទប់ស្កាត់ការជួញដូរយ៉ាងសកម្ម
- កាតព្វកិច្ចក្នុងការចូលរួមក្នុងការដោះដូរព័ត៌មាន និងការបណ្តុះបណ្តាលដើម្បីទប់ស្កាត់ការជួញដូរ និងសម្របសម្រួលការធ្វើមាតុភូមិនិវត្តន៍ប្រកបដោយសុវត្ថិភាព។[២៣]

ពិធីសារ Palermo មានប្រសិទ្ធភាព និងប្រសិទ្ធផលតែនៅពេលដែលវាត្រូវបានដាក់ បញ្ចូលដោយជោគជ័យទៅក្នុងច្បាប់ជាតិប៉ុណ្ណោះ។ ពិធីសារនេះបង្កើតបាននៃតលក្ខខណ្ឌអប្បបរិមាសម្រាប់រដ្ឋនានា ដែលផ្តល់សេរីភាពដល់ពួកគេក្នុងការបំពេញបន្ថែមទៅលើបទបញ្ញត្តិទាំងឡាយណា ដែលពួកគេយល់ថាចាំបាច់ត្រូវដាក់ចូលទៅក្នុងច្បាប់ជាតិរបស់ពួកគេប៉ុណ្ណោះ។[២៤] ដើម្បីប្រយុទ្ធប្រឆាំងនឹងការជួញដូរមនុស្សប្រកបដោយប្រសិទ្ធភាព ប្រជាជាតិទាំងឡាយត្រូវតែកែតម្រូវ ឬបង្កើតច្បាប់ជាតិយ៉ាងសកម្មដើម្បីប្រកាន់ខ្ជាប់តាមលក្ខខណ្ឌរបស់ពិធីសារនេះ។ រដ្ឋទាំងនោះក៏គួរតែដាក់បញ្ចូលបទដ្ឋានទាំងឡាយរបស់ពិធីសារឲ្យបាននៅពេលញៀវទៅក្នុងច្បាប់ និងនីតិវិធីជាធរមានផងដែរ។

អង្គការសហប្រជាជាតិ ខ្វះអំណាចក្នុងការប្រតិបត្តិពិធីសារ Palermo ហើយមិនអាចធានាថា ប្រជាជាតិទាំងឡាយដែលចុះហត្ថលេខា និងផ្តល់សច្ចាប័ននៅលើពិធីសារនេះ នឹង ប្រកាន់ខ្ជាប់តាមកាតព្វកិច្ចទាំងឡាយតាមរយៈវិធានការដែលអាចអនុវត្តបាន និង/ឬ វិធានការច្បាប់បាននោះឡើយ។

នៅពេលវាយតម្លៃថាតើ ប្រទេសមួយបានបំពេញតាមបទដ្ឋាន និងកាតព្វកិច្ចសមរម្យសម្រាប់ការទប់ស្កាត់ និងការពារការជួញដូរមនុស្ស យើងក៏គួរតែយល់ថា សមត្ថភាពរបស់ ប្រទេសនីមួយៗក្នុងការបំពេញតាមកាតព្វកិច្ច នឹងខុសប្លែកគ្នាយ៉ាងខ្លាំងអាស្រ័យទៅលើអេថេរច្បាប់ និងសង្គម-នយោបាយ។ កត្តាទាំងនេះនឹងកំណត់នូវវិសាលភាពដែលរដ្ឋនីមួយៗអាចអនុវត្តបច្ចេកទេស វិធានការការពារ និងការផ្តល់ជំនួយជនរងគ្រោះសម្រាប់ជនរងគ្រោះពីការជួញដូរដែលជាកុមារ។

បណ្តាប្រទេសគោលដៅដូចជា ប្រទេសថៃជាដើម តែងតែមានសមត្ថភាពសេដ្ឋកិច្ចខ្លាំងជាងប្រទេសជិតខាងរបស់ខ្លួន ដែលជាញឹកញាប់ដើរតួជាប្រទេសប្រភព។ ខណៈដែល កត្តាទាំងនេះមិនកាត់បន្ថយកាតព្វកិច្ចរបស់ប្រទេសក្រីក្រ ក្នុងការចាត់វិធានការការពារ និងផ្តន្ទាទោសបាននោះទេ វិសាលភាពសម្រាប់ការបំពេញតាមបទដ្ឋានរបស់ពិធីសារនេះត្រូវបានកំណត់ និងអាស្រ័យទៅលើធនធានដែលអាចរកបាន។ ជាការសំខាន់ ណាស់ ដែលត្រូវពិចារណាសមត្ថភាពរបស់ប្រទេសនីមួយៗ ក្នុងការបំពេញតាម កាតព្វកិច្ចទាំងនោះ នៅពេលវិភាគអំពីប្រសិទ្ធភាពរបស់ច្បាប់ជាតិ និងអន្តរជាតិ។

## ក្របខណ្ឌថ្នាក់តំបន់

នៅឆ្នាំ ២០០៤ ប្រទេសថៃ ព្រមជាមួយប្រទេសឡាវ កម្ពុជា មីយ៉ាន់ម៉ា វៀតណាម និងចិន បានបង្កើតនូវការសម្របសម្រួលគំនិតផ្តួចផ្តើមថ្នាក់រដ្ឋមន្ត្រីប្រឆាំងនឹងការជួញដូរមនុស្សនៅមហាអនុតំបន់ទន្លេមេគង្គ (COMMIT) ដែលជាក្របខ័ណ្ឌច្បាប់ថ្នាក់តំបន់សម្រាប់ទទួលស្គាល់ និងដោះស្រាយបញ្ហាការជួញដូរមនុស្សនៅក្នុងអនុតំបន់ទន្លេមេគង្គ។[២៥]

នៅក្នុងកិច្ចប្រឹងប្រែងលើកកម្ពស់ការយល់ដឹង និងកិច្ចសហប្រតិបត្តិការរួមគ្នាប្រទេស

* ការផ្តល់សច្ចាប័ន - ច្បាប់អន្តរជាតិ ដែលតាមរយៈច្បាប់នេះរដ្ឋមួយបញ្ជាក់អំពីការយល់ព្រមរបស់ខ្លួនចំពោះការភ្ជាប់កាតព្វកិច្ចអនុវត្តតាមសន្ធិសញ្ញា ប្រសិនបើបណ្តាភាគីទាំងនោះមានចេតនាចង់បង្ហាញពីការយល់ព្រមរបស់ខ្លួនតាម ច្បាប់នេះ។ ស្ថាប័នផ្តល់សច្ចាប័ន ផ្តល់ជូនរដ្ឋនីមួយៗនូវក្របខ័ណ្ឌពេលវេលាដែលចាំបាច់ក្នុងការស្វែងរកការអនុញ្ញាតដែលត្រូវការសម្រាប់សន្ធិសញ្ញាស្តីពីក្រមិតក្នុងស្រុក និងអនុម័តច្បាប់ដែលចាំបាច់ក្នុងការផ្តល់ប្រសិទ្ធភាពក្នុងស្រុកចំពោះសន្ធិសញ្ញានោះ។[២]

† ការចូលជាភាគី - ច្បាប់មួយ ដែលតាមរយៈច្បាប់នេះ រដ្ឋមួយទទួលយកការផ្តល់ជូន ឬឱកាសក្លាយជាភាគីនៃសន្ធិសញ្ញាដែលបានចរចារ និងចុះហត្ថលេខារួចដោយរដ្ឋផ្សេងទៀត។ វាមានប្រសិទ្ធភាពច្បាប់ដូចការផ្តល់សច្ចាប័ននែដរ។[៣]

COMMIT បានប្រកាសអនុស្សរណៈនៃការយោគយល់គ្នាទៅលើកិច្ចសហប្រតិបត្តិការ ប្រឆាំងនឹងការជួញដូរមនុស្សនៅក្នុងមហាអនុតំបន់ទន្លេមេគង្គ។ អនុស្សរណៈនេះ គឺជា ជំហានដំបូងនៅក្នុងការត្រឹមនិយមន័យពាក្យបច្ចេកទេសនៅក្នុងច្បាប់ជាតិ ដូចជា "ការជួញដូរមនុស្ស" និង "អាយុគ្រប់ការ" មុនពេលដែលពិធីសារ Palermo ត្រូវបានអនុម័តដោយគ្រប់ប្រទេសទាំងអស់។ អនុស្សរណៈនេះ បានជួយបង្កើនកិច្ចសហប្រតិបត្តិការឆ្លងដែន ទោះបីជាក្នុងភាពជាក់ស្តែង នៅតែមានការយល់ច្រឡំជាទូទៅអំពីគោល គំនិតដែលទាក់ទងនឹងការជួញដូរនៅក្នុងបរិបទច្បាប់ក៏ដោយ។

ក្នុងចំណោមបណ្តាប្រទេសនៅក្នុងអនុតំបន់ទន្លេមេគង្គ ប្រទេសថៃមានក្របខ័ណ្ឌច្បាប់គ្រប់ជ្រុងជ្រោយទាក់ទងនឹងការជួញដូរ។ វិធានការរបស់ប្រទេសថៃនៅក្នុងច្បាប់ស្តីពីការទប់ស្កាត់ និងបង្ក្រាបការជួញដូរស្ត្រី និងកុមារ ត្រូវបានលុបចោលនៅឆ្នាំ ២០០៨ ហើយត្រូវបានជំនួសមកវិញដោយ ច្បាប់ប្រឆាំងការជួញដូរមនុស្សជាលើកដំបូងរបស់ប្រទេសនេះ។ ច្បាប់ជាត្រីសដៀងគ្នានេះ ដែលមានមូលដ្ឋានលើពិធីសារ Palermo របស់អង្គការសហប្រជាជាតិ ត្រូវបានអនុម័តដោយបណ្តាប្រទេសអាស៊ានផ្សេងទៀតទាំងអស់ចាប់តាំងពីពេលនោះមក។ ទោះជាយ៉ាងណា អត្ថិភាពនៃច្បាប់នេះពុំបានបញ្ជាក់ជាចាំបាច់អំពីការប្រតិបត្តិច្បាប់នោះឡើយ ទោះដោយសារការខ្វះសមត្ថភាពក្តី ឬដោយសារខ្វះថាមពលក្តី ឬតាមពិតទៅដោយសារខ្វះឆន្ទៈក្តី។

## សមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ (អាស៊ាន)

សមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ (អាស៊ាន) ត្រូវបានបង្កើតឡើង នៅឆ្នាំ ១៩៦៧ ដោយប្រទេសហ្វីលីពីន ម៉ាឡេស៊ី ថៃ ឥណ្ឌូនេស៊ី និងសិង្ហបុរី ដែលបានរួមគ្នាចុះហត្ថលេខាលើសេចក្តីថ្លែងការណ៍មួយហៅថាសេចក្តីថ្លែងការណ៍ក្រុងបាងកក។

គំនិតផ្តួចផ្តើមបង្កើតសមាមាគមអាស៊ាន ត្រូវបានជំរុញទឹកចិត្តដោយសារការភ័យខ្លាចលទ្ធិកុម្មុយនីស្តរួមគ្នា និងមហិច្ឆតាចង់បានការអភិវឌ្ឍសេដ្ឋកិច្ចឆាប់រហ័សក្នុងតំបន់។ បច្ចុប្បន្ននេះ អាស៊ាន ដែលបានពង្រីកបន្ថែមដើម្បីបញ្ចូលប្រទេសវៀតណាម ប្រ៊ុយណេ ឡាវ មីយ៉ាន់ម៉ា និងកម្ពុជា ស្វែងរកការជំរុញសន្ទុះនៃភាពរីកចម្រើនសេដ្ឋកិច្ច វឌ្ឍនភាពសង្គម និងការអភិវឌ្ឍវប្បធម៌នៅក្នុងតំបន់ និងដើម្បីលើកស្ទួយការសិក្សាអាស៊ីអាគ្នេយ៍នៅទូទាំងពិភពលោក។

នៅឆ្នាំ ២០១៥ អនុសញ្ញាអាស៊ានប្រឆាំងនឹងការជួញដូរមនុស្សជាពិសេសស្ត្រី និងកុមារ ដែលប្រើប្រាស់សេចក្តីថ្លែងការណ៍អាស៊ានឆ្នាំ ២០០៤ ដែលមានឈ្មោះដូចគ្នានេះ។ ខុសប្លែកពីកាតព្វកិច្ចទាំងឡាយដែលមាននៅក្នុងលិខិតុបករណ៍ជាតិ និងអន្តរជាតិ សេចក្តីថ្លែងការណ៍នេះដំបូងឡើយស្វែងរកការលើកទឹកចិត្តឲ្យមានកិច្ចសហប្រតិបត្តិការ ថ្នាក់តំបន់តាមរយៈការចែករំលែកព័ត៌មាន ការពង្រឹងព្រំដែន និងការការពារកុំឲ្យមានការក្លែងបន្លំឯកសារធ្វើដំណើរ។[២៦]

ប្រវ៉ាឡង់នៃការជួញដូរមនុស្សនៅទូទាំងតំបន់អាស៊ាន មានន័យថា វាបានក្លាយទៅជាអាទិភាពខ្ពស់បំផុតនៅក្នុងសហគមន៍សន្តិសុខអាស៊ាន ដែលជាចលនាមួយបង្កើតឡើងដើម្បីកសាងសហគមន៍អាស៊ានដែលមានការសហការគ្នា រាប់បញ្ចូលគ្នា និងចេះធន់ទ្រាំ។[២៧]

តាមរយៈការចូលរួមនៅក្នុងការប្រឈមនឹងបញ្ហា រដ្ឋសមាជិកអាស៊ានបង្ហាញពីការប្តេជ្ញាចិត្តរបស់ខ្លួនក្នុងការការពារ និងលើកកម្ពស់សិទ្ធិមនុស្ស និងការលុបបំបាត់ការជួញដូរមនុស្ស។ ទោះជាយ៉ាងណា បញ្ហាមួយក្នុងចំណោមបញ្ហាធំៗជាច្រើនដែលសហគមន៍អាស៊ានកំពុងប្រឈមគឺ ភាពមិនស៊ីគ្នាយ៉ាងខ្លាំងផ្នែកទ្រព្យសម្បត្តិ និងការអភិវឌ្ឍរវាងប្រជាជាតិដែលចូលរួមសមាគមនេះ។ កន្លងមក មានការធ្វើចំណាកស្រុកយ៉ាងខ្លាំងមក ពីបណ្តាប្រទេសដែលមានប្រាក់ចំណូលទាប ចូលទៅកាន់ប្រទេសដែលមានប្រាក់ចំណូលមធ្យម ដូចជា ប្រទេសថៃជាដើម។

សហគមន៍សេដ្ឋកិច្ចអាស៊ាន (AEC) ដែលត្រូវបានបង្កើតឡើងនៅឆ្នាំ ២០១៥ ត្រូវបានដកស្រង់សម្តីមកថាជា *"គោលដៅសំខាន់នៅក្នុងរបៀបវារៈសមាហរណកម្មសេដ្ឋកិច្ចតំបន់នៅក្នុងសមាគមអាស៊ាន ដែលផ្តល់នូវឱកាសជាច្រើនតាមរូបភាពទីផ្សារធំទូលាយដែលមានទីក្រុបាក់ ២.៦ សែនកោដិដុល្លារអាមេរិក និងមានប្រជាជនជាង ៦២២ លាននាក់។"*[២៨] សហគមន៍សេដ្ឋកិច្ចអាស៊ានកំពុងស្ថិតក្នុងភាពទើបនឹងចាប់ផ្តើមឡើងរបស់ខ្លួន ប៉ុន្តែរួមគ្នាមក គឺជាសេដ្ឋកិច្ចធំជាងគេទីបីនៅអាស៊ី និងធំជាងគេទីប្រាំពីរនៅក្នុងពិភពលោក។[២៩] សហគមន៍ AEC លើកកម្ពស់ឲ្យមានព្រំដែនដែលកាន់តែមានការបន្ធូរបន្ថយ និងមានចលនាកាន់តែ សេរីរវាងប្រជាជនរបស់រដ្ឋជាសមាជិក។
ចលនាកាន់តែសេរីរបស់ពលករជំនាញ នឹងសម្រួលដល់ការ ធ្វើចំណាកស្រុកកើនឡើង ហើយអាចបណ្តាលឲ្យមានកំណើនការជួញដូរមនុស្ស។

អ្នកអនុវត្តន៍ ដែលនៅធ្វើការជាប្រចាំជាមួយជនរងគ្រោះពីការជួញដូរនៅអាស៊ីអាគ្នេយ៍ មានការភ័យបារម្ភថា ការបន្ធូរបន្ថយព្រំដែននាពេលអនាគតនៅក្នុងសហគមន៍ AEC នឹងបណ្តាលឲ្យមានការពង្រីកបណ្តាញជួញដូរមនុស្ស ដែលកំពុងតែមានស្រាប់។ សម្រាប់របាយការណ៍នេះ Rouse បានស្ទង់មតិបុគ្គលិកអង្គការ NGO អ្នកកាន់សំណុំរឿង នគរបាល អាជ្ញាធររដ្ឋាភិបាល និងមន្ត្រីអន្តោប្រវេសន៍ ដែលអ្នកទាំងអស់គ្នាសុទ្ធតែធ្វើការជាមួយនឹងរឿងក្តីជួញដូរមនុស្ស។ ការទស្សន៍ទាយរបស់ពួកគេអំពីផលប៉ះពាល់នៃការបន្ធូរបន្ថយព្រំដែនសហគមន៍ AEC អាចឃើញមាននៅទំព័រទី ១៩។

## ប្រទេសថៃ

ច្បាប់ជាតិនៃប្រទេសថៃ ដែលពាក់ព័ន្ធនឹងឧក្រិដ្ឋកម្មដោយមានការរៀបចំ និងការជួញដូរមនុស្ស៖

- **ច្បាប់ស្តីពីការទប់ស្កាត់ និងបង្ក្រាបឧក្រិដ្ឋកម្មឆ្លងប្រទេសដោយមានការរៀបចំ ឆ្នាំ ២០១៣**
- **ច្បាប់ប្រឆាំងនឹងការជួញដូរមនុស្សឆ្នាំ ២០០៨**
- **ច្បាប់ប្រឆាំងការលាងលុយកខ្វក់ (លេខ ២) ឆ្នាំ ២០០៨**
- **ច្បាប់ការពារសាក្សី ឆ្នាំ ២០០៣**
- **ច្បាប់ការពារកុមារឆ្នាំ ២០០៣**
- **ច្បាប់ធ្វើវិសោធនកម្មក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ១៩៩៩**
- **ច្បាប់គ្រប់គ្រងការលាងលុយកខ្វក់ឆ្នាំ ១៩៩៩**

ប្រទេសថៃបានខិតខំប្រឹងប្រែងយ៉ាងខ្លាំង ក្នុងការពង្រឹងច្បាប់ជាតិប្រឆាំងនឹងការជួញដូរមនុស្ស និងដើម្បីជាគុណប្រយោជន៍ដល់កិច្ចការពារកុមារដើម្បីបំពេញតាមកាតព្វកិច្ចអន្តរជាតិរបស់ខ្លួន។

ប្រទេសថៃបានផ្តល់សច្ចាប័នលើអនុសញ្ញា និងពិធីសារអន្តរជាតិសំខាន់ៗទាំងអស់ដែលពាក់ព័ន្ធនឹងការជួញដូរមនុស្ស និងកិច្ចការពារកុមារ ហើយកុមារថៃទទួលបាននូវការលើកកម្ពស់ផ្លូវច្បាប់ និងកិច្ចការពារសិទ្ធិរបស់ពួកគេបានល្អបំផុតនៅក្នុងប្រទេសណាមួយដែលស្ថិតនៅក្នុងតំបន់អាស៊ាន។

ច្បាប់ការពារកុមារឆ្នាំ ២០០៣ របស់ប្រទេសថៃ បានដាក់បញ្ចូលនិយមន័យអន្តរជាតិស្តីពី "អនីតិជន" និងច្បាប់ទាំងឡាយដែលចែងអំពីការរំលោភបំពានលើសិទ្ធិកុមារ។ ប្រទេសថៃបានពង្រឹងសិទ្ធិកុមារ តាមរយៈការកែលម្អសិទ្ធិទទួលបានការគាំពារសុខភាពមូលដ្ឋាន ការអប់រំ អាហារូបត្ថម្ភ សន្តិភាព សន្តិសុខ និងកិច្ចការពារពីការរំលោភបំពាន ការមិនយកចិត្តទុកដាក់ ការជួញដូរ ពលកម្មកុមារ និងការកេងប្រវ័ញ្ច និងអំពើហិង្សាតាមរូបភាពផ្សេងៗ។[៣០]

ច្បាប់នេះក៏បង្កើតនូវគណៈកម្មការជាតិការពារកុមារផងដែរ ដែលមានភារកិច្ចក្នុងការត្រួតពិនិត្យលើការប្រតិបត្តិ និងការអនុវត្តន៍ច្បាប់នេះផងដែរ។

កិច្ចការពារដែលស្ថិតក្រោមច្បាប់នេះ នៅពុំទាន់បានពង្រីកបន្ថែមឲ្យស្មើគ្នានឹងចំនួនកុមារយ៉ាងច្រើន ដែលនៅពុំទាន់ទទួលបានសញ្ជាតិថៃ ឬឯកសារណាមួយ ហើយអាចជាកំពុងស្ថិតនៅក្នុងប្រទេសថៃដោយខុសច្បាប់។ ច្បាប់ស្តីពីសញ្ជាតិឆ្នាំ ១៩៦៥ ចែងថា ពាក់ព័ន្ធនឹងកុមារ សញ្ជាតិថៃអាចទទួលបានតែតាមរយៈពង្សាវលីប៉ុណ្ណោះ។ ការនេះធ្វើឲ្យមានការលំបាកកាន់តែខ្លាំងសម្រាប់ជនចំណាកស្រុក ជនភៀសខ្លួន និងជនជាតិដើមភាគតិច ដែលពុំមានឯកសារបញ្ជាក់កំណើតដើម្បីទទួលបានកិច្ចការពារក្រោមច្បាប់របស់ថៃ។[៣១]

ច្បាប់ប្រឆាំងការជួញដូរឆ្នាំ ២០០៨ ហាមប្រាមមិនឲ្យមានការជួញដូរគ្រប់រូបភាពទាំងអស់ ហើយអ្នកជួញដូរដែលមានពិរុទ្ធ ត្រូវបានផ្តន្ទាទោសឲ្យជាប់ពន្ធនាគាររយៈពេលចាប់ពី ៤-១០ ឆ្នាំ។ ច្បាប់នេះក៏កំណត់បទដ្ឋានខ្ពស់សម្រាប់ការស៊ើបអង្កេតរឿងក្តីជួញដូរមនុស្ស ការកំណត់អត្តសញ្ញាណជនរងគ្រោះពីការជួញដូរ ការផ្តន្ទាទោសអ្នកប្រព្រឹត្តល្មើស និងការស្តារនីតិសម្បទា និងការធ្វើមាតុភូមិនិវត្តន៍បុគ្គលដែលត្រូវបានគេជួញដូរ

ផងដែរ។[៣២] ច្បាប់នេះបានបង្កើតនូវគណៈកម្មការនៃមជ្ឈមណ្ឌលប្រតិបត្តិការជាតិទទួលបន្ទុកលើការទប់ស្កាត់ និងការបង្រ្កាបការជួញដូរមនុស្ស (NOCHT) ដែលធ្វើ និងមើលការខុសត្រូវលើការកែសម្រួលច្បាប់ទាំងអស់ ដែលពាក់ព័ន្ធនឹងការប្រឆាំងការជួញដូរ។

## ប្រទេសកម្ពុជា

ច្បាប់ជាតិរបស់កម្ពុជា ដែលពាក់ព័ន្ធនឹងឧក្រិដ្ឋកម្មដោយមានការរៀបចំ និងការជួញដូរមនុស្ស៖

- **ច្បាប់ប្រឆាំងអំពើពុករលួយឆ្នាំ ២០១០**
- **ច្បាប់ស្តីពីការបង្រ្កាបអំពើជួញដូរមនុស្ស និងអាជីវកម្មផ្លូវភេទឆ្នាំ ២០០៧**
- **ច្បាប់ស្តីពីការបង្រ្កាបអំពើព្រងត់ និងលក់ដូរមនុស្ស និងអំពើធ្វើអាជីវកម្មលើមនុស្សឆ្នាំ ១៩៩៦**

មុនពេលអនុម័តពិធីសារ Palermo ភាគច្រើននៃការផ្តោតការយកចិត្តទុកដាក់ទៅលើការជួញដូរមនុស្សនៅកម្ពុជា គឺទៅលើការជួញដូរស្រ្តី និងកុមារកម្ពុជាទៅក្នុងពេស្យាចារ។[៣៣]

ជាមួយនឹងការផ្តល់សច្ចាប័នលើពិធីសារនេះ កម្ពុជាបានស្វែងរកការរុះរើយន្តការជាតិរបស់ខ្លួន ដើម្បីកែលម្អច្បាប់ជាធរមាន និងពង្រឹងប្រសិទ្ធភាពច្បាប់ប្រឆាំងការជួញដូរមនុស្សទាំងក្នុងប្រទេសនិងឆ្លងដែន។ ក្រោមពិធីសារនេះ មានដាក់បញ្ចូលនូវវិធានការទាំងឡាយក្នុងការទប់ស្កាត់ការជួញដូរមនុស្ស ផ្តន្ទាទោសអ្នកជួញដូរមនុស្ស និងការពារជនរងគ្រោះពី ការជួញដូរ។

កម្ពុជាបានអនុម័តនិយមន័យជាសាកលស្តីពីការជួញដូរមនុស្ស ហើយបានរៀបចំការដាក់ទោសទណ្ឌតាមផ្លូវច្បាប់សម្រាប់ជនដែលប្រព្រឹត្តការជួញដូរមនុស្ស និងឧក្រិដ្ឋកម្មឆ្លងប្រទេស។ ទោះបីជាបានផ្តល់សច្ចាប័នលើសន្ធិសញ្ញាទាំងនេះក៏ដោយ កម្ពុជានៅតែស្ថិតនៅចំណាត់ថ្នាក់ទី ២ នៃរបាយការណ៍ស្តីពីការជួញដូរមនុស្ស (TIP) របស់ក្រសួងការបរទេសសហរដ្ឋអាមេរិកដដែល។

កម្ពុជាបានផ្តល់សច្ចាប័នពិធីសារ ដែលជាជម្រើសបន្ថែមលើអនុសញ្ញាស្តីពីសិទ្ធិកុមារឆ្នាំ ២០០២ ដែលហាមឃាត់ការលក់ដូរកុមារ ពេស្យាចារកុមារ និងរូបភាពអាសអាភាសកុមារ។ ទោះជាយ៉ាងណា ក្នុងនាមជាប្រទេសហត្ថលេខីនច្បាប់ការពារកុមារ និងច្បាប់ស្តី ពីសិទ្ធិកុមារអន្តរជាតិជាច្រើន កម្ពុជានៅតែខ្វះច្បាប់ជាត្រិគប់ជុងជ្រាយដើម្បីការពារសិទ្ធិ កុមារដដែល។

បើប្រៀបធៀបជាមួយនឹងបទដ្ឋានអន្តរជាតិនានា ដែលមានពន្យល់នៅក្នុងពិធីសារ Palermo បន្ថែមពីលើច្បាប់ជាធរមានរបស់កម្ពុជា បានបង្ហាញឲ្យឃើញពីចំណុចខ្វះចន្លោះនៅក្នុងបទដ្ឋានជាត្រិបឆាំងនឹងការជួញដូរ ជាពិសេសត្រង់ផ្នែកកិច្ចការពារជនរងគ្រោះ។ ចំណុចខ្វះចន្លោះទាំងនេះ បណ្តាលឲ្យមានលំហូរឥតឈប់ឈរនៃអ្នកដែលត្រូវបានគេជួញដូរម្តងទៀតពីកម្ពុជាទៅកាន់ប្រទេសថៃ ដែលកុមារនៅពុំទាន់មានគេជួយ និងស្តារនីតិសម្បទាទៅកាន់មជ្ឈដ្ឋានដែលមានការគាំទ្រ និងមានស្ថេរភាពនៅឡើយទេ។

## ប្រទេសមីយ៉ាន់ម៉ា

ច្បាប់ជាតិរបស់មីយ៉ាន់ម៉ាដែលពាក់ព័ន្ធនឹងឧក្រិដ្ឋកម្មដោយមានការរៀបចំ និងការជួញដូរមនុស្ស៖

- **ច្បាប់ប្រឆាំងការជួញដូរមនុស្សឆ្នាំ ២០០៥**
- **ច្បាប់ស្តីពីកុមារឆ្នាំ ១៩៩៣**

ដូចគ្នានឹងប្រទេសថៃ និងកម្ពុជាដែរ ប្រទេសមីយ៉ាន់ម៉ាបានបង្កើតច្បាប់ជាត្រិបឆាំងនឹងការជួញដូរមនុស្ស ដើម្បីបង្ហាញពីការប្តេជ្ញាចិត្តរបស់ពួកគេក្នុងការបំពេញតាមបទដ្ឋានអន្តរជាតិ។

បន្ថែមពីលើច្បាប់ប្រឆាំងនឹងការជួញដូរមនុស្សឆ្នាំ ២០០៥ របស់ខ្លួន រដ្ឋាភិបាលមីយ៉ាន់ម៉ាបានបង្កើត ក្រុមការងារប្រឆាំងការជួញដូរមនុស្ស ដើម្បីអនុវត្តច្បាប់ជាតិ និងផ្តន្ទាទោសអ្នកប្រព្រឹត្តល្មើស។

មីយ៉ាន់ម៉ា បានឆ្លងច្បាប់ស្តីពីកុមារនៅឆ្នាំ ១៩៩៣ ដើម្បីបំពេញកាតព្វកិច្ចនៅក្នុងអនុសញ្ញាអង្គការ សហប្រជាជាតិស្តីពីសិទ្ធិកុមារ (CRC)។ ទោះជាយ៉ាងណា ជម្លោះដ៏សកម្មរវាងរដ្ឋាភិបាល និងក្រុម ជនជាតិភាគតិចដែលប្រដាប់ដោយអាវុធ ដែលកាន់កាប់ពំដែនភាគខាងកើតជាមួយថៃ បណ្តាលឲ្យ មានបញ្ហាដែលពិបាកនិយាយគ្នា នៅក្នុងការប្រតិបត្តិច្បាប់ប្រឆាំងការជួញដូរ។ មនុស្ស គ្រឿងញៀន សព្វាវុធ និងត្បូងត្រូវបានគេរត់ពន្ធដោយសេរី។ ជម្លោះប្រដាប់អាវុធ បានបង្កើតនូវលំហូរឥតឈប់ឈរនៃជនចំណាកស្រុក ដែលស្វែងរកឱកាសសេដ្ឋកិច្ចកាន់តែប្រសើរនៅបរទេស ដែលកម្រិតសមត្ថភាព របស់រដ្ឋាភិបាលក្នុងកិច្ចការពារសហគមន៍ងាយរងគ្រោះពីការជួញដូរ ។□

មីយ៉ាន់ម៉ា បានកំណត់តាមផ្លូវច្បាប់នូវអាយុរបស់កុមារថា ជាជនដែលមានអាយុក្រោម ១៦ ឆ្នាំ។[៣៤] និយមន័យនេះ ល្មើសនឹងអនុសញ្ញា CRC និងនិយមន័យទាំងឡាយដែលប្រើប្រាស់ដោយប្រទេស ដទៃទៀតនៅក្នុងតំបន់។ ការនេះធ្វើឲ្យមានភាពមិនស្របគ្នា និងភាពច្របូកច្របល់ នៅពេលកំណត់ និយមន័យ និងកំណត់អត្តសញ្ញាណការជួញដូរកុមារនៅក្នុងប្រទេសមីយ៉ាន់ម៉ា ឬពលរដ្ឋមីយ៉ាន់ម៉ា នៅក្នុងប្រទេសដទៃទៀត។ នេះជាឧទាហរណ៍អំពីរបៀបដែលច្បាប់ជាតិអាចជំនួសឲ្យនិយមន័យជា សាកល ដែលបណ្តាលឲ្យមានភាពមិនប្រក្រតី និងរារាំងដល់ការគោរពតាមច្បាប់អន្តរជាតិ។

## ប្រទេសឡាវ

ច្បាប់ជាតិរបស់ឡាវ ដែលពាក់ព័ន្ធនឹង នឹងឧក្រិដ្ឋកម្មដោយមានការរៀបចំ និងការជួញដូរមនុស្ស៖

- **ច្បាប់ប្រឆាំងការជួញដូរមនុស្សឆ្នាំ ២០១៥**
- **ច្បាប់ស្តីពីកិច្ចការពារសិទ្ធិកុមារឆ្នាំ ២០០៧**
- **ច្បាប់ស្តីពីកិច្ចអភិវឌ្ឍ និងកិច្ចការពារស្រ្តីឆ្នាំ ២០០៤**

កុមារត្រូវបានការពារក្រោមច្បាប់ស្តីពីកិច្ចការពារសិទ្ធិកុមារឆ្នាំ ២០០៧ ដែលមានបទបញ្ញត្តិស្តីពីកិច្ច គាំពារសុខភាព ការចុះបញ្ជីគ្រួសារ កិច្ចការពារកុមារ ជំនួយផ្នែកសង្គម ព្រមទាំងការត្រួតពិនិត្យ និងការ ប្រតិបត្តិសិទ្ធិកុមារ។

រដ្ឋាភិបាលឡាវ មានការពាក់ព័ន្ធជាពិសេសជាមួយនឹងការជួញដូរមនុស្សនៅឆ្នាំ ២០០៣ នៅពេល ដែលពួកគេកត់សម្គាល់ឃើញនូវកំណើនចំនួនពលរដ្ឋដែលរងការរំលោភបំពាន និងកេងប្រវ័ញ្ចនៅ ប្រទេសថៃ។ ប្រទេសឡាវស្ថិតក្រោមសម្ពាធពីអន្តរជាតិយ៉ាងធ្ងន់ធ្ងរ ដោយសារតែមានក្តីកង្វល់អំពីការ ជួញដូរមនុស្ស ភាពគ្មានប្រសិទ្ធផលនៃការឆ្លើយតបរបស់ខ្លួន និងការយល់ឃើញថា ដោយសារតែគ្មានវិធានការដែលមានប្រសិទ្ធភាព ស្ថានភាពនៃការជួញដូរមនុស្សនឹងកាន់តែអាក្រក់ទៅៗ។

ជាការឆ្លើយតប ប្រទេសឡាវបានធ្វើការប្តេជ្ញាចិត្តចំពោះកិច្ចការពារកុមារពីការជួញដូរមនុស្សដោយ ផ្តល់សច្ចាប័នលើច្បាប់អន្តរជាតិសំខាន់ៗទាំងអស់។ ឡាវគឺជាប្រទេសមួយស្ថិតក្នុងចំណោមប្រទេស ដំបូងគេនៅក្នុងតំបន់ ដែលផ្តល់សច្ចាប័នលើពិធីសារ Palermo ។ ទោះបីជាមានការផ្លាស់ប្តូរដ៏ខ្លាំងក្លា ដោយរដ្ឋាភិបាលឡាវក៏ដោយ ក៏នៅតែមានការផ្តន្ទាទោសតិចតួចចំពោះអ្នកជួញដូរដដែល។

មុនពេលដែលច្បាប់ប្រឆាំងការជួញដូរឆ្នាំ ២០១៥ របស់ឡាវត្រូវបានអនុម័តរួច ពុំមានច្បាប់ជាត្រិគប់ ជ្រុងជ្រោយ ដែលដោះស្រាយជាពិសេសបញ្ហាជួញដូរមនុស្ស ឬនិយមន័យច្បាប់ច្បាស់លាស់ឡើយ។ ការជួញដូរមានលើកឡើងដោយផ្ទាល់ ឬដោយប្រយោលនៅក្នុងផ្នែកទាំងឡាយនៃក្រមព្រហ្មទណ្ឌ ជាតិប៉ុន្តែគោលវិធីជាផ្នែកៗនេះ ផលិតបាននូវច្បាប់គ្មានសង្គតិភាព និងមិនអាចជឿទុកចិត្តបាន ។[៣៥] ឧទាហរណ៍ ច្បាប់ស្តីពីកិច្ចអភិវឌ្ឍ និងកិច្ចការពារស្រ្តីឆ្នាំ ២០០៤ ផ្តល់នូវនិយមន័យផ្នែកច្បាប់ស្តីពីការជួញដូរមនុស្ស និងស្ត្រី និងកុមារដែលត្រូវបានការពារពីការជួញដូរ និងរំលោភបំពានតាមរូបភាពមួយ ចំនួន ប៉ុន្តែពុំបានរាប់បញ្ចូលការជួញដូរបុរស និងក្មេងប្រុសទេ។

# ច្បាប់អន្តរជាតិដែលបានអនុម័តដោយប្រទេសថៃ កម្ពុជា មីយ៉ាន់ម៉ា និងឡាវ

| ច្បាប់ និងសន្ធិសញ្ញាអន្តរជាតិ | អនុម័តនៅឆ្នាំ | ថៃ | កម្ពុជា | មីយ៉ាន់ម៉ា | ឡាវ |
|---|---|---|---|---|---|
| អនុសញ្ញាស្ដីពីពលកម្មដោយបង្ខំរបស់អង្គការពលកម្មអន្តរជាតិ | ១៩៣០ | កុម្ភៈ - ១៩៦៩ (R) | កុម្ភៈ - ១៩៦៩ (R) | មីនា - ១៩៥៥ (R) | មករា - ១៩៦៤ (R) |
| អនុសញ្ញាស្ដីពីការលុបបំបាត់ពលកម្មដោយបង្ខំរបស់អង្គការពលកម្មអន្តរជាតិ | ១៩៥៧ | ធ្នូ -១៩៦៩(R) | សីហា - ១៩៩៩ (R) | មីនា - ១៩៥៥ (R) | មិនចុះហត្ថលេខា មិនផ្ដល់សច្ចាប័ន |
| អនុសញ្ញាស្ដីពីការលុបបំបាត់គប់រូបភាពនៃការរើសអើងបនាំងស្ដ្រី | ១៩៧៩ | សីហា - ១៩៨៥ (A) | តុលា - ១៩៨០ (S)<br>តុលា - ១៩៩២ (R) | កក្កដា - ១៩៩៧ (A) | កក្កដា - ១៩៨០ (S)<br>សីហា - ១៩៨១ (R) |
| អនុសញ្ញាអង្គការសហប្រជាជាតិស្ដីពីសិទ្ធិកុមារ | ១៩៩០ | មីនា - ១៩៩២ (A) | តុលា - ១៩៩២ (A) | កក្កដា - ១៩៩១ (A) | ឧសភា - ១៩៩១ (A) |
| អនុសញ្ញាស្ដីពីរូបភាពអាក្រក់បំផុតនៃពលកម្មកុមាររបស់អង្គការពលកម្មអន្តរជាតិ | ១៩៩៧ | កុម្ភៈ - ២០០១ (R) | មីនា - ២០០៦ (R) | ធ្នូ - ២០១៣ (R) | មិថុនា - ២០០៥ (R) |
| ពិធីសារអង្គការសហប្រជាជាតិប្រឆាំងការរត់ពន្ធជនចំណាកស្រុកតាមផ្លូវគោក | ២០០០ | ធ្នូ - ២០០១ (S)<br>មិនផ្ដល់សច្ចាប័ន | វិច្ឆិកា - ២០០១ (S)<br>ធ្នូ - ២០០៥ (R) | មីនា - ២០០៤ (A) | កញ្ញា - ២០០៣ (A) |
| ពិធីសារអង្គការសហប្រជាជាតិប្រឆាំងការផលិត និងការជួញដូរដោយខុសច្បាប់នូវអាវុធ គ្រឿងបន្លាស់ និងសមាសភាគ និងគ្រឿងរំសេវរបស់វា | ២០០១ | មិនចុះហត្ថលេខា មិនផ្ដល់សច្ចាប័ន | ធ្នូ - ២០០៥ (A) | មិនចុះហត្ថលេខា មិនផ្ដល់សច្ចាប័ន | កញ្ញា - ២០០៣ (A) |
| ពិធីសារអង្គការសហប្រជាជាតិស្ដីពីការទប់ស្កាត់ បង្ក្រាប និងផ្ដន្ទាទោសការជួញដូរមនុស្ស ជាពិសេសស្ត្រី និងកុមារ (ពិធីសារ Palermo) | ២០០០ | ធ្នូ - ២០០១ (S)<br>តុលា - ២០១៣ (R) | វិច្ឆិកា - ២០០១ (S)<br>កក្កដា - ២០០៧ (R) | មីនា - ២០០៤ (R) | កញ្ញា - ២០០៣ (R) |
| អនុសញ្ញាអង្គការសហប្រជាជាតិប្រឆាំងឧក្រិដ្ឋកម្មឆ្លងដែនដោយមានការរៀបចំ | ២០០០ | ធ្នូ - ២០០១ (S)<br>តុលា - ២០១៣ (R) | វិច្ឆិកា - ២០០១ (S)<br>ធ្នូ - ២០០៥ (R) | មីនា - ២០០៤ (R) | កញ្ញា - ២០០៣ (R) |

(S) = បានចុះហត្ថលេខាស្ថិតក្រោមការផ្ដល់សច្ចាប័នឬចូលជាភាគី - នៅពេលហត្ថលេខាស្ថិតក្រោមការផ្ដល់សច្ចាប័ន ទទួលយក ឬឯកភាព ហត្ថលេខានោះពុំបង្កើតបាននូវមាតិកាដែលត្រូវភ្ជាប់កាតព្វកិច្ចអនុវត្តឡើយ។ ទោះជាយ៉ាងណា វាគឺជាមធ្យោបាយមួយក្នុងការបញ្ជាក់ហត្ថលេខា និងសម្ដែងនូវឆន្ទៈរបស់រដ្ឋហត្ថលេខីក្នុងការបន្តដំណើរការបង្កើតសន្ធិសញ្ញា។ ហត្ថលេខាផ្ដល់គុណវុឌ្ឍិដល់រដ្ឋហត្ថលេខីដើម្បីបាត់ចងផ្ដល់សច្ចាប័ន ទទួលយក ឬឯកភាព។ វាក៏បង្កើតផងដែរនូវកាតព្វកិច្ចក្នុងការទប់ស្កាត់ដោយស្មោះត្រង់ពីច្បាប់ទាំងឡាយដែលនឹងធ្វើឲ្យខូចខាតដល់កម្មវត្ថុ និងគោលបំណងនៃសន្ធិសញ្ញា។[1]

(R) = បានផ្ដល់សច្ចាប័នដោយប្រទេស - ការផ្ដល់សច្ចាប័នកំណត់នូវច្បាប់អន្តរជាតិ ដែលតាមរយៈនេះរដ្ឋមួយបង្ហាញពីការយល់ព្រមរបស់ខ្លួនចំពោះការភ្ជាប់កាតព្វកិច្ចអនុវត្តតាមសន្ធិសញ្ញា ប្រសិនបើបណ្ដាភាគីមានចេតនាចង់បង្ហាញពីការយល់ព្រមរបស់ខ្លួនដោយច្បាប់នោះ។ ករណីជាសន្ធិសញ្ញាទ្វេភាគី ជាធម្មតាការផ្ដល់សច្ចាប័នសម្រេចបានដោយការដោះដូរលិខិតុបករណ៍ដែលតម្រូវឲ្យមាន ចំណែកករណីសន្ធិសញ្ញាពហុភាគី នីតិវិធីជាធម្មតាគឺសម្រាប់ឲ្យអ្នកទទួលបញ្ញើប្រមូលសច្ចាប័នព្រឹត្តិប់រដ្ឋទាំងអស់ ដោយរក្សាការជូនដំណឹងអំពីស្ថានភាពដល់ភាគីទាំងអស់។ ស្ថាប័នផ្ដល់សច្ចាប័ន ផ្ដល់ជូនរដ្ឋនីមួយៗនូវក្របខ័ណ្ឌពេលវេលាដែលចាំបាច់ក្នុងការស្វែងរកការអនុញ្ញាតដែលត្រូវការសម្រាប់សន្ធិសញ្ញាស្ដីពីក្រមិតក្នុងស្រុក និងអនុម័តច្បាប់ដែលចាំបាច់ក្នុងការផ្ដល់ប្រសិទ្ធភាពក្នុងស្រុកចំពោះសន្ធិសញ្ញានោះ។[2]

(A) = ការចូលជាភាគី - ការចូលជាភាគីគឺជាច្បាប់មួយ ដែលតាមរយៈច្បាប់នេះ រដ្ឋមួយទទួលយកការផ្ដល់ជូន ឬឱកាសក្លាយជាភាគីនៃសន្ធិសញ្ញាដែលបានចរចារ និងចុះហត្ថលេខារួចដោយរដ្ឋផ្សេងទៀត។ វាមានប្រសិទ្ធភាពច្បាប់ដូចការផ្ដល់សច្ចាប័នដែរ។ ជាធម្មតា ការចូលជាភាគីតែងតែកើតឡើងបន្ទាប់ពីសន្ធិសញ្ញាបានចូលជាធរមាន។ អគ្គលេខាធិការនៃអង្គការសហប្រជាជាតិ នៅក្នុងមុខងាររបស់ខ្លួនជាអ្នកទទួលបញ្ញើ ក៏បានទទួលការចូលជាភាគីនៃអនុសញ្ញាមួយចំនួនផងដែរ មុនពេលអនុសញ្ញាទាំងនោះចូលជាធរមាន។ លក្ខខណ្ឌទាំងឡាយដែលការចូលជាសមាជិកស្ថិតក្រោម អាចកើតមាន ហើយនីតិវិធីដែលពាក់ព័ន្ធអាស្រ័យទៅលើបទបញ្ញត្តិនៃសន្ធិសញ្ញានោះ។ សន្ធិសញ្ញាមួយអាចនឹងចងអំពីការចូលជាភាគីរបស់រដ្ឋទាំងអស់ ឬអំពីចំនួនរដ្ឋដែលមានក្រមិត ឬមានកំណត់។ ប្រសិនបើគ្មានបទបញ្ញត្តិនេះទេនោះ ការចូលជាសមាជិកអាចកើតឡើងបាតែនៅពេលដែលរដ្ឋសុំចរចារទទួលបានការឯកភាព ឬឯកភាពជាបន្តបន្ទាប់លើសន្ធិសញ្ញានោះនៅក្នុងករណីរដ្ឋបច្ចុប្បន្ន។[3]

----

១ មាត្រា ១០ និង ១៨ នៃអនុសញ្ញាទីក្រុងវីយែនស្ដីពីច្បាប់នៃសន្ធិសញ្ញាឆ្នាំ ១៩៦៩
២ មាត្រា ២ (១) (ខ) ១៤ (១) និង ១៦ នៃអនុសញ្ញាទីក្រុងវីយែនស្ដីពីច្បាប់នៃសន្ធិសញ្ញាឆ្នាំ ១៩៦៩
៣ មាត្រា ២ (១) (ខ) និង ១៥ នៃអនុសញ្ញាទីក្រុងវីយែនស្ដីពីច្បាប់នៃសន្ធិសញ្ញាឆ្នាំ ១៩៦៩

## តើការបង្កើតសហគមន៍សេដ្ឋកិច្ចអាស៊ាននឹងប៉ះពាល់ដល់ការជួញដូរកុមារដែរឬទេ?

៦២.៥% ការជួញដូរនឹងកើនឡើង
១២.៥% គ្មានអ្វីប្រែប្រួលទេ
៩.៣៧% អ្នកជួញដូរនឹងមានភាពងាយស្រួលក្នុងការឆ្លងដែន ប៉ុន្តែការវិនិយោគនៅមីយ៉ាន់ម៉ា និងកម្ពុជាអាចកាត់បន្ថយចំនួនដែលចង់ចាកចេញ
៦.២៥% មិនប្រាកដ
៦.២៥% ការជួញដូរនឹងថយចុះ
៣.១៣% អាស៊ាននឹងក្លាយជាផ្នែកមួយនៃដំណោះស្រាយ




## តើលទ្ធផលអវិជ្ជមានអ្វីខ្លះដែលអាចបណ្ដាលមកពីការបង្កើតសហគមន៍សេដ្ឋកិច្ចអាស៊ាន?




៤៥% នឹងមានកំណើនជនចំណាកស្រុកមកកាន់ប្រទេសថៃ
២០% បញ្ហានឹងកាន់តែស្មុគស្មាញថែមទៀត
១០% និន្នាការជួញដូរថ្មីនឹងផុសឡើង
៥% ស្ថានភាពនៃជនចំណាកស្រុកខុសច្បាប់នឹងបន្តយ៉ាប់យ៉ឺន
៥% បញ្ហានឹងកាន់តែរីកសុះសាយទូទាំងតំបន់
៥% វានឹងក្លាយទៅជារឿងកាន់តែទូទៅសម្រាប់កុមារក្នុងការផ្លាស់ទី និងគ្រូបង្រៀននៅជាប់
៥% រដ្ឋាភិបាលនឹងមិនប្រកាន់កម្មជាប់រហ័សចំពោះនិន្នាការថ្មីៗនៅក្នុងការជួញដូរមនុស្សឡើយ
៥% មេខ្យល់/អ្នកជួញដូរមនុស្សនឹងអាចឆ្លងដែនបានកាន់តែងាយស្រួល

*ប្រមូលពីការស្ទង់មតិមួយទៅលើអ្នកអនុវត្តដែលធ្វើការលើរឿងក្ដីជួញដូរមនុស្សទូទាំងប្រទេសថៃ មីយ៉ាន់ម៉ា កម្ពុជា និងឡាវ។[3]



“ប្រសិនបើរឿងក្តីនោះមិនអាចរកភ័ស្តុតាងមកបញ្ជាក់ថា ជាការកេងប្រវ័ញ្ចទេនោះ យើងមិនអាចបញ្ជាក់ថារឿងនោះជាការជួញដូរបានឡើយ។ ឧទាហរណ៍៖ សូម្បីតែឪពុកម្តាយលក់កូនៗរបស់ពួកគេក៏ដោយ ក៏យើងមិនអាចបង្ហាញថាកុមារនោះកំពុងត្រូវបានគេកេងប្រវ័ញ្ចបានឡើយ ដូច្នេះនៅទីបំផុត យើងមិនអាចនិយាយបានថា វាជាការជួញដូរបានឡើយ។”

នគរបាលភូមិន្ទ្រ





# ជំពូក ២៖ ការជួញដូរក្នុងប្រទេស

*

ការជួញដូរក្នុងប្រទេស

## ការជួញដូរកុមារថៃ

ការជួញដូរក្នុងប្រទេសគឺជាការជួញដូរមនុស្សក្នុងរង្វង់ព្រំដែននៃប្រទេសមួយ។ នៅប្រទេសថៃមានការផ្តោតការយកចិត្តទុកដាក់ជាពិសេសទៅលើជនរងគ្រោះពីការជួញដូរជាជនបរទេស និងជនចំណាកស្រុកដែលងាយរងគ្រោះ។ ទោះជាយ៉ាងណា នៅក្នុងការស្ទង់មតិទៅលើទីជម្រករបស់រដ្ឋាភិបាលសម្រាប់ជនរងគ្រោះពីការជួញដូរ ដែលដំណើរការដោយក្រសួងអភិវឌ្ឍន៍សង្គម និងសន្តិសុខមនុស្សជាតិបស់ថៃបានឲ្យដឹងថា ជាង ៨០% នៃជនរងគ្រោះនៅក្នុងទីជម្រកនោះគឺជាកុមារ ហើយប្រហែលពាក់កណ្តាលនៃកុមារទាំងនោះជាជនជាតិថៃ។[៣៧]

ប្រសិនបើយុវវ័យថៃត្រូវបានគេឃើញថាធ្វើការនៅកន្លែងពេស្យាចារ ជាញឹកញាប់គេតែងតែសន្មត់ថា ពួកគេធ្វើបែបនោះតាមជម្រើសរបស់ពួកគេ។ ករណីទាំងនេះកម្រត្រូវបានស៊ើបអង្កេតដោយនគរបាលថាជាករណីជួញដូរណាស់។ ដូច្នេះ ការជួញដូរកុមារក្នុងប្រទេសពុំមានរៀបរាប់គប់គាន់នៅក្នុងកំណត់ត្រាអំពីការចាប់ ខ្លួន និងផ្តន្ទាទោសឡើយ។

ការសន្មត់ជាទូទៅគឺថា ការជួញដូរផ្ទៃក្នុងកុមារថៃមានការថយចុះ ដោយសារមានឱកាសសេដ្ឋកិច្ចប្រសើរជាងមុន សម្រាប់ឪពុកម្តាយ និងមានការកែលម្អនូវសិទ្ធិទទួលបានការអប់រំ។ ប្រធានការិយាល័យប្រឆាំងការជួញដូរមនុស្សនៃ MSDHS បានរាយការណ៍ថា ចំនួនកុមារដែលពាក់ព័ន្ធនឹងការជួញដូរមានការថយចុះ ដោយសារមានកិច្ចប្រឹងប្រែងរបស់រដ្ឋាភិបាលថៃ ក្នុងការពង្រីកឱកាសនៅក្នុងការ អប់រំ ដើម្បីជំនះបញ្ហាកុមារថៃនៅបនពេស្យាចារ។[៣៨]

មានការសង្កត់ធ្ងន់តិចតួចទៅលើកិច្ចការពារការជួញដូរក្នុងប្រទេសដោយសារតែមានជំនឿថាមានកំណើនលំហូរកុមារបរទេសមកកាន់ប្រទេសថៃ ដែលគេកត់សម្គាល់ឃើញថា កុមារភាគច្រើនមកពីប្រទេសកម្ពុជា មីយ៉ាន់ម៉ា និងឡាវ ដែលបានបំបាត់តម្រូវការជួញដូរផ្ទៃក្នុង។ កុមារថៃត្រូវបានគេដឹងថាងាយរងគ្រោះតិចតួចជាងកុមារដែលមកពីក្រុមទាំងនេះ ហើយប្រសិនបើគេឃើញមានកុមារថៃនៅក្នុងស្ថានភាពកេងប្រវ័ញ្ចនោះ គេតែងតែសន្មត់ទុកជាមុនថាជាជម្រើសរបស់ពួកគេ។

នាយកដ្ឋានស៊ើបអង្កេតពិសេស (DSI) របស់រដ្ឋាភិបាលថៃបានអះអាងថា ភាគច្រើននៃកុមារដែលត្រូវបានគេជួញដូរ ដែលពួកគេបានកំណត់អត្តសញ្ញាណគឺជាជនបរទេស ដោយមានជនជាតិថៃតែមួយក្តាប់តូចប៉ុណ្ណោះដែលត្រូវបានចុះបញ្ជីជារៀងរាល់ឆ្នាំ។៣៩ ផ្ទុយមកវិញ MSDHS បានរាយការណ៍ថា នៅក្នុងទីជម្រក របស់រដ្ឋាភិបាលសម្រាប់ជនរងគ្រោះពីការជួញដូរនៅប្រទេសថៃ ចំនួនជនរងគ្រោះ ដែលជាជនជាតិថៃ និងជនបរទេសមានស្មើរតែស្មើគ្នា។[៤០]

ការអភិវឌ្ឍមិនស្មើគ្នា និងភាពក្រីក្រនៅទីជនបទ គឺជាកត្តាលើករសំខាន់មួយសម្រាប់ការជួញដូរកុមារផ្ទៃក្នុងនៅប្រទេសថៃ។ តំណាង UN-ACT ប្រចាំនៅប្រទេសថៃបានពន្យល់ថា៖

“វាមិនមែនជាបញ្ហាភាពក្រីក្រទេ ប៉ុន្តែវាជាបញ្ហាវិសមភាពទៅវិញទេ ជាពិសេសនៅប្រទេសថៃ។ វាមិនចាំបាច់ទាល់តែថាពួកគេទាំងនោះជាជនក្រីក្របំផុតដែលត្រូវបានគេជួញដូរទេ ដូច្នេះការទម្លាក់កំហុសទៅលើភាពក្រីក្រគឺជាការព្រងើយកន្តើយនឹងភាពខុសប្លែកគ្នា។” [៤១]

ការអភិវឌ្ឍមិនស្មើគ្នា និងវិសមភាពសង្គមដែលជាចលករនៃការជួញដូរក្នុង ប្រទេស អាចត្រូវបានគេមើលឃើញនៅក្នុងកំណើនចំនួនករណីក្មេងស្រីថៃ ដែល ត្រូវបានគេជួញដូរផ្ទៃក្នុងមកពីគ្រួសារដែលមានប្រាក់ចំណូលមធ្យម។ ក្មេងស្រីទាំងនេះមកពីភាគឦសាននៃប្រទេសថៃ។ អ្នកជួញដូរកេងប្រវ័ញ្ចលើស្ត្រីទាំងនេះតាមរយៈការល្បួងពួកគេឲ្យធ្លាក់ចូលទៅក្នុងអំពើពេស្យាចារ ដោយសន្យាថានឹងផ្តល់ទំនិញប្រណិតៗ សម្លៀកបំពាក់ម៉ូតទាន់សម័យ ទូរស័ព្ទប្រភេទស្មាតហ្វូន ។ល។ ពួកគេទទួលបានការអប់រំ ដែលជាញឹកញាប់បានយល់ដឹងពីហានិភ័យ ប៉ុន្តែមើលឃើញថា អំពើពេស្យាចារគឺជាអាជីពមួយដែលរកបានចំណូលខ្ពស់ ដែលធ្វើឲ្យ ជីវភាពរស់នៅមានភាពល្អប្រណិត។[៤២]

> “ប្រទេសថៃដឹងពីវិសាលភាពនៃបញ្ហា
> នៅពេលនិយាយអំពីការជួញ ដូរមនុស្ស។
> ពួកគេមានការយល់ដឹង។ នៅពេលនិយាយអំពីការ ជួញដូរក្នុងប្
> រទេសបញ្ហានោះពុំមែនជាបញ្ហាសាធារណៈទេ។ ពួក
> គេតែងតែប្រើច្បាប់ផ្សេងជំនួសវិញ ដូចជា ច្បាប់ស្តីពីអំពើពេស្យាចារ
> ឬ ច្បាប់ស្តីពីពលកម្មជាដើម។ ពួកគេមិនប្រើច្បាប់ស្តីពីការជួ
> ញដូរ មនុស្សទេ ពីព្រោះពួកគេយល់ថាវាគ្រាន់តែជាករណីឆ្លង
> ដែន ប៉ុណ្ណោះ។”
>
> អ្នកជំនាញផ្នែកជនចំណាកស្រុក ទីក្រុងបាងកក

## ការជួញដូរក្នុងប្រទេសនិងអំពើពេស្យាចារ

រាប់ទសវត្សរ៍មកហើយ ប្រទេសថៃមានឈ្មោះល្បីដោយសារទេសចរណ៍ផ្លូវភេទ ហើយអំពើ ពេស្យាចារគឺជាបញ្ហាសង្គមដែលកំពុងតែបន្តមាននៅក្នុងប្រទេស ទោះបីជាវាបានរួម ចំណែកមួយភាគធំដល់សេដ្ឋកិច្ចរបស់ប្រទេសក៏ដោយ។

ទសវត្សរ៍ឆ្នាំ ១៩៩០ គឺជាពេលដែលរដ្ឋាភិបាលបានចាប់ផ្តើមអនុម័តច្បាប់ការពារអ្នកដែលធ្វើការនៅក្នុងបនពេស្យាចារ ជាពិសេសកុមារ។ អតីតនាយករដ្ឋមន្ត្រីថៃ គឺលោក ឈួន លីកែផ (Chuan Leekpai) (១៩៩២-១៩៩៥) បានប្រកាសអំពីការចាត់វិធានការ ដែលដឹកនាំដោយរដ្ឋាភិបាលទៅលើបនពេស្យាចារ។ ខណៈដែលអំពើពេស្យាចារនៅតែ ស្របច្បាប់ក្នុងប្រទេសថៃ លោក លីកែផ បានអនុម័តច្បាប់ដើម្បីបង្រ្កាប និងទប់ស្កាត់ការ កេងប្រវ័ញ្ចលើស្ត្រី និងបុរសដែលប្រកបរបរពេស្យាចារ និងលុបបំបាត់អំពើពេស្យាចាររបស់ជនណាម្នាក់ដែលមានអាយុក្រោម ១៨ ឆ្នាំ។[៤៣] ក្រោមគោលការណ៍ទាំងនេះ គ្មានក្មេងស្រីណាម្នាក់អាចត្រូវបានបង្ខំ ឬប្រើអំណាចបង្រ្កាបឲ្យចូលធ្លាក់ក្នុងអំពើពេស្យាចារ ធ្វើទារុណកម្ម ឬរំលោភបំពាន ហើយនឹងមានការផ្តន្ទាទោសកាន់តែខ្លាំងចំពោះអ្នកគួរជ្រេសី។

នៅអំឡុងពេលនេះ នាយការិយាល័យរបស់អតីតនាយករដ្ឋមន្ត្រី និងជាអ្នកតស៊ូមតិសិទ្ធិកុមារ គឺលោក សៃស៊ូរី ឈុតទីគល់ (Saisuree Chutikul) បានផ្តល់បទសម្ភាសន៍មួយ ដោយអះអាងថា៖

“បុរសថៃយល់ថា ការរួមភេទជាមួយស្ត្រីពេស្យាចារគឺដូចគ្នានឹងការផឹកកាហ្វេមួយពែងក្រោយពេលបាយដែរ។ ពួកគេមិនយល់ថាទាស់ខុសអីទាល់តែសោះ [...] ឪពុកម្តាយមួយចំនួនខ្ជិលច្រអូស ហើយចង់ឲ្យកូនៗរបស់ខ្លួនរកលុយឲ្យបានច្រើនសម្រាប់ពួកគេ។ ពួកគេមិនខ្វល់ថាតើកូនៗពួកគេធ្វើការងារអ្វីឡើយ [...] ប៉ុន្តែ ទោះបីជាការចៀសវាងពីអំពើពេស្យាចារមិនគ្រប់អាយុគឺជាគោលនយោបាយរបស់រដ្ឋាភិបាលក៏ដោយ ក៏មានមន្ត្រីរដ្ឋាភិបាលជាច្រើននាក់ ដែលពុំផ្តល់កិច្ចសហប្រតិបត្តិការនៅក្នុងបញ្ហានេះឡើយ។” [៤៤]

នគរបាលបានចាត់វិធានការនៅទូទាំងប្រទេសថៃ ដោយធ្វើការត្រួតពិនិត្យអត្តសញ្ញាណទៅលើក្មេងស្រីដែលធ្វើការនៅក្នុងបារ ក្លឹបរាត្រី និងផ្ទះបន។ នៅប្រទេសថៃ ច្បាប់តម្រូវឲ្យ ពលរដ្ឋទាំងអស់ដែលមានអាយុចាប់ពី ១៥ ឆ្នាំឡើងទៅត្រូវកាន់អត្តសញ្ញាណប័ណ្ណ។ ប្រសិនបើពួកគេពុំមានអត្តសញ្ញាណប័ណ្ណទេនោះ គេសន្មត់ទុកជាមុនថាពួកគេមាន អាយុក្រោម ១៥ ឆ្នាំ ដែលមានន័យថា ក្មេងស្រីនោះត្រូវបានចាត់ទុកថាធ្វើការជាស្ត្រី ពេស្យាចារខុសច្បាប់។

ដោយសារតែបញ្ហានេះ និងរឿងដែលថា អាយុ ១៥ ឆ្នាំ គឺជាអាយុគ្រប់ការនៅប្រទេសថៃ មានការទទួលយកយ៉ាងឆាប់រហ័ស សម្រាប់ក្មេងស្រីក្នុងការប្រឡូកក្នុងអំពើពេស្យាចារ ដោយបើកចំហ ឲ្យតែពួកគេមានអាយុចាប់ពី ១៥ ឆ្នាំឡើងទៅ។[៤៥] បញ្ហានេះកើតឡើង ទោះបីជាច្បាប់ស្តីពីការទប់ស្កាត់ និងបង្រ្កាបអំពើពេស្យាចារឆ្នាំ ១៩៩៦ បានចែងយ៉ាងច្បាស់ថា វាគឺជារឿងខុសច្បាប់សម្រាប់ជនណាម្នាក់អាយុក្រោម ១៨ ឆ្នាំ ដែលធ្វើការនៅ ក្នុងបនពេស្យាចារក៏ដោយ។
នៅឆ្នាំ ២០១៥ តំណាងមួយរូបរបស់នគរបាលភូមិន្ទថៃ បានអះអាងថា៖

"ភាគច្រើននៃកុមារដែលត្រូវបានគេជួញដូរដែលយើងរកឃើញគឺជាជនជាតិថៃ ហើយធ្វើការនៅក្នុងតំបន់មានបនពេស្យាចារ ប៉ុន្តែបញ្ហាធំបំផុតគឺការរកភ័ស្តុតាងអំពីការកេងប្រវ័ញ្ចនោះ - ទោះបីជាភាគច្រើននៃក្មេងស្រីដែលស្ថិតក្នុងបនពេស្យាចារទាំងនេះមានអាយុ ១៣-១៤ ឆ្នាំក៏ដោយ។ ពួកគេខ្លះ ធ្វើការក្រៅម៉ោង ហើយខ្លះទៀតធ្វើការដើម្បីចិញ្ចឹមជីវិត។ មានក្មេងស្រីថៃច្រើនជាងក្មេងៗដែលជាជនអន្តោប្រវេសន៍ក្នុងឧស្សាហកម្មនេះ។"[៤៦]

ទិន្នន័យបានផ្តល់ជាយោបល់ថា កុមារថៃដែលត្រូវបានគេជួញដូរ ជាទូទៅឃើញ មាននៅតាមកន្លែងប្រកបអាជីវកម្មបិទជិត ដូចជា ផ្ទះបន ឬសណ្ឋាគារតូចៗនៅ តាមទីក្រុង ឬរមណីយដ្ឋានធំៗរបស់ថៃ។

ជាញឹកញាប់ ក្មេងស្រីៗតែងត្រូវបានគេចាត់ទុកថាមានចេតនាក្នុងការចូលរួម ប្រព្រឹត្ត ពីព្រោះពួកគេព្យាយាមរត់គេចចេញពីអាជ្ញាធរយ៉ាងសកម្ម រាល់ពេលមានការឆ្មក់ចូលឆែកឆេរម្តងៗ។[៤៧] ទោះបីជាយ៉ាងណា ពួកគេទំនងជាគ្រាន់តែភ័យខ្លាចការចាប់ខ្លួនប៉ុណ្ណោះ។ នៅក្នុងករណីទាំងនេះ វាជាការលំបាកបំផុតសម្រាប់ នគរបាល និងអង្គការ NGOs ក្នុងការផលិតភ័ស្តុតាងអំពីការកេងប្រវ័ញ្ច និងការ ជួញដូរមនុស្ស។

ក្មេងស្រីជាច្រើនដែលធ្វើការនៅក្នុងបនពេស្យាចារ ពុំប្រាប់អត្តសញ្ញាណពួកគេថាជាជនរងគ្រោះឡើយ ហើយបដិសេធមិនចូលរួមនៅក្នុងដំណើរការស៊ើបអង្កេត ដោយ ទុកឲ្យស្រេចលើការផ្តន្ទាទោសទៅលើអ្នកជួញដូរមនុស្ស អ្នកគួរជ្រើសរើស និងម្ចាស់ផ្ទះបនប៉ុណ្ណោះ។ នគរបាលមិនអាចផ្តល់ឋានៈ ឬស្ថានភាពដល់ជនរងគ្រោះបានឡើយ ប្រសិនបើពួកគេមិនចង់បានវាទេនោះ។ ជាលទ្ធផល ការផ្តន្ទាទោសត្រូវបាននាំទៅ កាន់តុលាការក្រោមច្បាប់ដែលពាក់ព័ន្ធនឹងកិច្ចការពារកុមារ ការរំលោភបំពានក្នុង គ្រួសារ ឬពលកម្មខុសច្បាប់ ដោយកាត់បន្ថយការយល់ឃើញអំពីការកើតមានឡើងនូវការជួញដូរផ្លូវភេទក្នុងស្រុក។

> *បញ្ហានោះគឺ ឧស្សាហកម្មផ្លូវភេទ។*
> *វាគឺជាផ្នែកមួយនៃទេសចរណ៍ ដូច្នេះវានឹងនៅតែមានជានិច្ច*
> *ហើយតែងត្រូវបានគេ*
> *ចាត់ទុកថាជាចៅកែធំៗនៃពលកម្មដែលមាន*
> *ការជួញដូរមនុស្ស ពីព្រោះវាងាយស្រួលសម្គាល់*
> *ដោយអ្នកដឹងច្បាស់ពីកន្លែងដែលត្រូវទៅរកវា។*
>
> បុគ្គលិកកាន់សំណុំរឿងសម្រាប់កុមារកុលសម្ព័ន្ធភ្នំ ប្រទេសថៃ

## Tok khiew (ការលក់ក្មេងស្រីទៅឲ្យផ្ទះបន)

នៅពាក់កណ្តាលទសវត្សរ៍ឆ្នាំ ១៩៩០ មានរបាយការណ៍ជាច្រើនអំពីបាតុភូតមួយនៅក្នុងប្រទេសថៃដែលគេហៅថា tok khiew ដែលបកប្រែមកថា "ការប្រមូលផលទាំងនៅខ្ចី" ដែលមានន័យថា ការដាក់បញ្ចាំស្រូវនៅខ្ចីដើម្បីបានប្រាក់កម្ចី។[៤៨]

នៅអំឡុងវិបត្តិសេដ្ឋកិច្ចថៃ កសិករជាច្រើនមានភាពក្រីក្រជាខ្លាំងក្នុងការឧបត្ថម្ភ ចិញ្ចឹមគ្រួសារពួកគេខណៈពេលពួកគេរង់ចាំរហូតដល់ស្រូវទុំ។ ពួកគេត្រូវតែដាក់ បញ្ចាំដំណាំរបស់ខ្លួនទៅឲ្យអ្នកផ្តល់ប្រាក់កម្ចីក្នុងមូលដ្ឋាន ដែលជាមធ្យោបាយក្នុង ការសងបំណុលរបស់ពួកគេបន្តិចម្តងៗ។ ពាក្យថា tok khiew ត្រូវបានប្រើប្រាស់ជា ច្រើនទសវត្សរ៍ដើម្បីគូសបញ្ជាក់អំពីភាពលំបាកវេទនារបស់កសិករនៅភាគខាងជើង ប្រទេសថៃ ដែលពឹងផ្អែកទៅលើកសិកម្មដើម្បីចិញ្ចឹមជីវិត។[៤៩]

ក្រោយវិបត្តិសេដ្ឋកិច្ចអាស៊ីនៅឆ្នាំ ១៩៩៧ សេដ្ឋកិច្ចថៃកាន់តែធ្លាក់ចូលទៅក្នុងវិបត្តិថែមទៀត ហើយកសិករអស់សង្ឃឹមកាន់តែខ្លាំង។ ពួកគេចាប់ផ្តើមដាក់បញ្ចាំកូនស្រីរបស់ពួកគេជំនួសឲ្យដំណាំរបស់ពួកគេ ដើម្បីជាការដោះដូរជាមួយនឹងទំនិញជាសម្ភារៈផ្សេងៗ ឬជាការបង់រំលោះប្រាក់កម្ចី។[៥០]

ក្មេងស្រី ដែលខ្លះមានអាយុត្រឹមតែ ១២ ឆ្នាំប៉ុណ្ណោះ ត្រូវបានបញ្ជូនឲ្យទៅធ្វើការនៅក្នុងផ្ទះបននៅទូទាំងប្រទេសថៃ ដោយធ្វើការដើម្បីសងបំណុលឪពុកពួកគេ ឬជួយដល់ការចិញ្ចឹមជីវិត របស់គ្រួសារពួកគេ។ រូបភាពនៃពលកម្មភ្ជាប់កាតព្វកិច្ចអនុវត្តបែបនេះ ពុំអាចបែរកែញែកឲ្យខុសគ្នាពីភាពជាទាសករបានឡើយ។

នៅឆ្នាំ ១៩៩៤ ក្រសួងការងារ និងសុខុមាលភាពសង្គម (MLSW) បានដោះស្រាយបញ្ហាពេស្យាចារ និង "ការជួញដូរ" "សាច់មនុស្ស" (ពាក្យ "ការជួញដូរមនុស្ស" នៅពុំទាន់ប្រើប្រាស់នៅឡើយទេ)។ មាន ការប៉ាន់ស្មានថា ក្មេងស្រីប្រមាណជា ១,៥០០ នាក់មកពីឈៀងរ៉ៃ ដែលជាខេត្តមួយនៅភាគខាងជើងប្រទេសថៃ ដែលមានចំនួនស្ត្រីសរុប ៦០០,០០០ នាក់ ស្ថិតក្នុងហានិភ័យដែលត្រូវលក់ទៅកាន់បន ពេស្យាចារ។[៥១] តួលេខនេះ គឺផ្អែកទៅលើការប៉ាន់ស្មានដែលបានផ្តល់ជូន MLSW ដោយគ្រូបង្រៀនរបស់ ក្មេងស្រី ២,០០០ នាក់ ដែលគេដឹងថាត្រូវបានដាក់បញ្ចាំដោយ tok khiew។

សេដ្ឋកិច្ចរបស់ថៃបានរីកចម្រើនឡើងយ៉ាងឆាប់រហ័ស ចាប់តាំងពីទសវត្សរ៍ឆ្នាំ ១៩៩០ មក ហើយការអនុវត្តន៍ជាទូទៅ នូវ tok khiew មានការស្រុតចុះ។ ទោះជាយ៉ាងណា ផ្នត់គំនិតនេះនៅតែមាន ហើយគ្រួសារខ្លះនៅតែចាត់ទុកថាវាជាការអនុវត្តន៍ដែលអាចទទួលយកបាន។

## ការជួញដូរកុមារកុលសម្ព័ន្ធភ្នំ

ពាក្យថា "កុលសម្ព័ន្ធភ្នំ" ប្រើសម្រាប់បរិយាយអំពីក្រុមជនជាតិដើមភាគតិចដែលរស់នៅតាមភ្នំនានានៅ ភាគខាងជើង និងភាគឦសានប្រទេសថៃ ដោយមានភាសា វប្បធម៌ និងជំនឿរបស់ពួកគេ។[៥២] ប្រវត្តិនៃ ការធ្វើចំណាកស្រុករបស់ពួកគេចាប់ផ្តើមមកជាង ២,០០០ ឆ្នាំកន្លងមកហើយ។ ក្នុងសម័យបច្ចុប្បន្ននេះ ក្រុមដែលមានដើមកំណើតទើប ភូមា និងចិន បានចំណាកស្រុកមកកាន់ប្រទេសថៃ។

ក្រុមកុលសម្ព័ន្ធជនជាតិដើមទាំងនេះ ជាទូទៅតែងតែឃើញមានទីជម្រកនៅតំបន់ភាគខាងជើងខេត្ត ឈៀងម៉ៃ មេហុងសន ឈៀងរ៉ៃ និង តាក។ បើតាមប្រវត្តិសាស្ត្រ សហគមន៍កុលសម្ព័ន្ធភ្នំបង្កឲ្យមានការគំរាមកំហែង ឬបញ្ហាតិចតួចសម្រាប់រដ្ឋាភិបាលថៃ។ កន្លងមក មានការយកចិត្តទុកដាក់ចំពោះវត្តមាន របស់ពួកគេដោយសារតែចម្ការអាភៀនរបស់ពួកគេ ដែលធ្វើឲ្យខូចខាតព្រៃឈើដ៏ធំរបស់ថៃ ដែល បណ្តាលឲ្យមានគោលការណ៍ទប់ស្កាត់គ្រឿងញៀន ដែលធ្វើឲ្យការដាំដុះអាភៀនគឺជាអំពើខុសច្បាប់។

ទោះបីជាការងារអង្គការ NGOs និងរដ្ឋាភិបាលដែលលើកទឹកចិត្តឲ្យសហគមន៍កុលសម្ព័ន្ធភ្នំដាំដំណាំ និងរុក្ខជាតិផ្សេងជំនួសវិញក៏ដោយ ការលុបបំបាត់ដ៏ឆាប់រហ័សនូវផលិតកម្មអាភៀនពី "តំបន់ត្រីកោណ មាស" បណ្តាលឲ្យមានអស្ថេរភាព និងខ្សត់ខ្សោយហិរញ្ញវត្ថុក្នុងចំណោមប្រជាជនដែលជាកុលសម្ព័ន្ធភ្នំ មួយចំនួន។[៥៣] ជាមួយនឹងឱកាសនៅមានកម្រិតសម្រាប់ការបង្កើតប្រាក់ចំណូល គ្រួសារកុលសម្ព័ន្ធភ្នំជា ច្រើនត្រូវស្វែងរកការងារនៅតាមបណ្តាទីក្រុងរបស់ថៃ។

កុមារកុលសម្ព័ន្ធភ្នំជាច្រើន ដែលធ្លាក់ខ្លួនក្លាយជាជនរងគ្រោះនៃការជួញដូរមនុស្ស ត្រូវបាននាំយកមកពី តំបន់ភ្នំដ៏ធំល្វឹងល្វើយនៅតាមបណ្តោយព្រំដែនថៃ-មីយ៉ាន់ម៉ា។ បច្ចុប្បន្ននេះ មានត្រឹមតែ ៥១% នៃ កុមារកុលសម្ព័ន្ធភ្នំប៉ុណ្ណោះ ដែលបានចុះឈ្មោះចូលរៀននៅថ្នាក់បឋមសិក្សា ដែលផ្ទុយពីមធ្យមភាគ ជាតិ ៨៧%។ មានក្មេងប្រុសត្រឹមតែ ៣៥.៦% និងក្មេងស្រី ២៩% ប៉ុណ្ណោះ ដែលបន្តការសិក្សាទៅថ្នាក់ មធ្យមសិក្សា។

> *ពុំមានព័ត៌មានពិត្រប្រាកដអំពីបញ្ហានៃការជួញដូរផ្លូវភេទក្នុងស្រុកទេ។*
> *ខ្ញុំប្រាកដថាវាកំពុងកើតមានច្រើន ប៉ុន្តែគ្រាន់តែពុំមាន*
> *ព័ត៌មាននៅទីនោះតែប៉ុណ្ណោះ។ ពុំមាននរណាម្នាក់បាន*
> *ស្រាវជ្រាវអំពីបញ្ហានេះទេ...ខ្ញុំមិនគិតថាពួកគេកំពុងស្វែងរក*
> *នៅកន្លែងដែលត្រឹមត្រូវទេ។*
>
> បុគ្គលិកអង្គការ NGO ខេត្តឈៀងម៉ៃ

ជាលទ្ធផល ២៥% នៃក្រុមកុលសម្ព័ន្ធភ្នំពុំចេះអាន និងសរសេរ ដែលផ្ទុយពីមធ្យមភាគជាតិដែលមានត្រឹមតែ ២% ប៉ុណ្ណោះ។[៥៤]

ភាពក្រីក្រ គឺជាចលករដ៏សំខាន់មួយនៃការជួញដូរកុមារនៅទូទាំងអាស៊ីអាគ្នេយ៍។ ៦៤% នៃគ្រួសារ កុលសម្ព័ន្ធភ្នំនៅខេត្តមេហុងសន រស់នៅក្រោមបន្ទាត់ភាពក្រីក្រ ( តិចជាង ២ ដុល្លារក្នុង មួយថ្ងៃ ) ដែលមាន ២៣% នៃចំនួនប្រជាជនសរុបនេះកំពុងតែរស់នៅក្នុងភាពក្រីក្រ តោកយ៉ាកជាទីបំផុត ( តិចជាង ១ ដុល្លារក្នុងមួយថ្ងៃ )។[៥៥]

គ្រួសារដែលរស់នៅក្នុងភាពក្រីក្រ មានមូលហេតុជាច្រើនស្រមាប់ការទទួលទៅតាមវិធីរបស់អ្នកជួញដូរ។ ពួកគេត្រូវការលុយទាំងអស់សង្ឃឹម ឬចង់ជឿថា វាគឺជាប្រយោជន៍ល្អបំផុតស្រមាប់កូនពួកគេ ដែលត្រូវទៅជាមួយអ្នកជួញដូរ ពីព្រោះកូនពួកគេនឹងមាន ការងារធ្វើរកលុយបាន ហើយមានឱកាសកាន់តែប្រសើរក្នុងជីវិត។ ជាញឹកញាប់ ពួកគេប្រាប់រឿងសម្ងាត់ដល់កូន ដោយដឹងថាជាក្មេងដែលទៅរស់នៅជាមួយអ្នកដទៃ ដែលជា វិធីតមួយគត់ស្រមាប់កុមារដទៃទៀតក្នុងការចិញ្ចឹមជីវិត។

ច្បាប់បច្ចុប្បន្ន ធ្វើការរឹតបន្តឹងទៅលើការផ្លាស់ទីដោយសេរីរបស់ពួកកុលសម្ព័ន្ធភ្នំនៅក្នុងប្រទេសថៃ។ ពួកកុលសម្ព័ន្ធជាច្រើន ខ្វះអត្តសញ្ញាណ និងឯកសារមូលដ្ឋានដែលមានន័យថា ពួកគេមិនអាចចាកចេញពីតំបន់កំណត់របស់ពួកគេបានទេឡើយ។ ប្រជាជនកុលសម្ព័ន្ធភ្នំ ជាញឹកញាប់តែងតែភ័យខ្លាចក្នុងការផ្លាស់ទីចេញពីតំបន់រឹតបន្តឹងរបស់ពួក គេ ហើយនឹងងាយរងគ្រោះប្រសិនបើពួកគេល្មើស។ ជាទូទៅ សមាជិកនៃក្រុមជនជាតិភាគតិចឯកោទាំងនេះ មានអារម្មណ៍ថាងាយស្រួលក្នុងការចាកចេញព្រៃសុកកំណត់របស់ពួកគេ ប្រសិនបើមានជំនួយ។ ត្រង់នេះគឺជាកន្លែងដែលមេខ្យល់ចូលមក៖ ស្រមបស្រមួលការរត់ពន្ធ ការផ្លាស់ទី ឬជួញដូរបុរស ស្រ្តី និងកុមារដោយខុសច្បាប់។

ប្រព័ន្ធមេខ្យល់នៅប្រទេសថៃ ក៏អាចត្រូវបានគេមើលឃើញថាមានដូចគ្នានៅក្នុងប្រទេសកម្ពុជា មីយ៉ាន់ម៉ា និងឡាវ។ វិធីរបស់មេខ្យល់គឺធ្វើឲ្យគ្រួសារមានភាពអស់សង្ឃឹម កេងប្រវ័ញ្ចភាពងាយរងគ្រោះ និងភាពខ្វះឯកសាររបស់ពួកគេ ដោយធានារ៉ាប់រងដល់គ្រួសារ ថាពួកគេអាចរកការងារ ឬការអប់រំបន្តស្រមាប់កូនៗពួកគេនៅក្នុងទីប្រជុំជន និងទីក្រុងនានារបស់ថៃ។ កុមារកុលសម្ព័ន្ធភ្នំជាច្រើន ភាគច្រើនជាក្មេងស្រី ត្រូវបានគេជួញដូរទៅក្នុងឧស្សាហកម្មផ្លូវភេទ។

យោងតាមអង្គការប្រឆាំងការជួញដូរមួយនៅឈៀងរ៉ៃ៖

*"មានឈ្មួញកណ្តាល ដែលជួយស្រមបស្រមួលការដឹកជញ្ជូនក្មេងស្រីនោះពីសហគមន៍នោះដោយផ្ទាល់ទៅកាន់ ម៉ាម៉ាសាន ( មេបន )។ នៅផ្ទះបននោះ ម៉ាម៉ាសាន គ្រប់គ្រងក្មេងស្រីនោះ។ ជាធម្មតា ម៉ាម៉ាសាន ក៏ជាជនរងគ្រោះពីការជួញដូរផងដែរ។"*[៥៦]

ជាមួយនឹងការជួញដូរក្នុងប្រទេសការលំបាកមួយគឺការតាមចាប់ឈ្មួញកណ្តាលនេះ ដែលជាធម្មតាគឺជាម៉ាម៉ាសាន ដែលត្រូវបានចាប់ខ្លួន ជាជាងមេខ្យល់។

ក្មេងស្រីកុលសម្ព័ន្ធជាច្រើន ដែលត្រូវបានជួញដូរទៅក្នុងឧស្សាហកម្មផ្លូវភេទ ក្រមចាកចេញពីខេត្តរបស់ពួកគេណាស់។ គេអាចឃើញមានពួកគេនៅតាមផ្ទះបននៅឈៀងរ៉ៃ និងឈៀងម៉ៃ។ ការធ្វើបែបនេះគឺដើម្បីឲ្យមានភាពងាយស្រួលក្នុងការដឹកជញ្ជូនជនរងគ្រោះចេញពីសហគមន៍បុរាណដើមរបស់ពួកគេ ហើយមិនសូវត្រូវឲ្យមានការងារច្រើន ស្រមាប់មេខ្យល់ដែលទាក់ទងម៉ាម៉ាសានជាប្រចាំ ដើម្បីឲ្យបំពេញកូតានៅក្នុងផ្ទះបន។[៥៧]

ដើម្បីកាត់បន្ថយភាពងាយរងគ្រោះរបស់ក្មេងស្រីកុលសម្ព័ន្ធភ្នំ អង្គការជាច្រើនដែលធ្វើការនៅទីនោះ ដើម្បីទទួលបានឯកសារបញ្ជាក់អត្តសញ្ញាណស្រមាប់កុមារជនជាតិដើម។ អត្តសញ្ញាណប័ណ្ណ ដែលផ្តល់ដោយរដ្ឋាភិបាលថៃ ធានាថាបុគ្គលម្នាក់នោះត្រូវបានចុះបញ្ជីនៅក្នុងមូលដ្ឋានទិន្នន័យថៃ ទោះបីជាសញ្ជាតិរបស់ពួកគេពុំត្រូវបានកំណត់ថាជាជនជាតិថៃក៏ដោយ។ ទោះបីជាយ៉ាងណា ការនេះពុំបានផ្តល់សិទ្ធិពលរដ្ឋដល់ក្មេងស្រីកុលសម្ព័ន្ធឡើយ វាផ្តល់ឲ្យពួកគេនូវកំណត់ត្រាក្នុងមូលដ្ឋានទិន្នន័យ និងប្រព័ន្ធតាម ដានដែលអាចជួយកាត់បន្ថយភាពងាយរងគ្រោះរបស់ពួកគេ និងបង្កើនលទ្ធភាពពួកគេក្នុងការស្ទាក់ចាប់ដោយនគរបាល ខណ:ពេលកំពុងផ្លាស់ទីដោយអ្នកជួញដូរ។ នៅប្រទេសថៃភាគខាងជើង អង្គការជាច្រើនកំពុងប៉ុនប៉ងកសាងសាលារៀនស្រមាប់កុមារកុលសម្ព័ន្ធភ្នំ ដែលជាកិច្ចប្រឹងប្រែងមួយផ្តល់សិទ្ធិទទួលបានការអប់រំមូលដ្ឋានដល់ពួកគេ។

នេះគួរតែជារបាំងការពារមួយប្រឆាំងនឹងការជួញដូរ ប៉ុន្តែជាអកុសល សាលារៀនមួយ ចំនួនមានទីតាំងនៅកណ្តាលទីប្រជុំជន ដើម្បីបម្រើជូនភូមិជាច្រើន ហើយត្រូវឲ្យសិស្សត្រូវធ្វើដំណើរ ជួនកាលចេញក្រៅតំបន់ដែលពួកគេអាចធ្វើដំណើរបាន ដែលធ្វើ ឲ្យពួកគេមានហានិភ័យបន្ថែមពីការស្ទាក់ចាប់ដោយអ្នកជួញដូរ ឬដោយនគរបាល។

កិច្ចសប្រាបតិបត្តិការរបស់នគរបាល ក្នុងការតាមចាប់មេខ្យល់ និងសង្គ្រោះកុមារ គឺជាបញ្ហាមួយដែលបានរាយការណ៍ដោយអ្នកអនុវត្តនៅគ្រប់សទាប់វណ្ណ:។ ប្រភពមួយបានរាយការណ៍មកថា៖

*"ដោយសារអំពើពុករលួយក្នុងចំណោមមន្ត្រីនគរបាល និងរឿងដែលថាភាគច្រើននៃផ្ទះបនទាំងនេះត្រូវបានកាន់កាប់ដោយមន្ត្រី [នគរបាល] មានឋានន្តរ:សក្តិខ្ពស់ ដែលជួញដូរកុមារទៅកាន់ផ្ទះបន ធ្វើឲ្យបញ្ហានេះស្ទើរតែមិនអាចដោះស្រាយបាន។"* [៥៨]

នៅក្នុងករណីទាំងនេះ ការស៊ើបអង្កេតគឺដើម្បីបញ្ឈប់ការជួញដូរ ហើការងារនេះធ្វើឡើងដោយ អាជ្ញាធរតែម្យ៉ាងគត់។ កុមារដែលត្រូវបានកំណត់អត្តសញ្ញាណថាជាជនរងគ្រោះពីការជួញដូរ មនុស្ស អាចត្រូវបានបញ្ជូនទៅកាន់ទីជម្រករដ្ឋាភិបាលសម្រសប ហើយនឹងត្រូវបានការពារក្រោមពិធីសារដែលបានគូសបញ្ជាក់ដោយ MSDHS។ ក្នុងករណីផ្សេងទៀត នគរបាលដឹងពីអ្វីដែល កំពុងកើតឡើងនៅក្នុងផ្ទះបន ប៉ុន្តែពុំមានចេតនាក្នុងការស៊ើបអង្កេតយ៉ាងសកម្ម លុះត្រាតែមាន ការគំរាមកំហែងពីការស៊ើបអង្កេត ឬការយកចិត្តទុកដាក់របស់ប្រព័ន្ធផ្សព្វផ្សាយអន្តរជាតិ។ ចាប់ តាំងពីមានការផ្លាស់ទីរបស់ថៃទៅកាន់ចំណាត់ថ្នាក់ទី ៣ ក្នុងរបាយការណ៍ TIP ហើយបន្ទាប់មក ត្រឡប់ទៅកាន់បញ្ជីតាមដាន មានមហិច្ឆតាយ៉ាងខ្លាំងក្នុងការផ្សព្វផ្សាយជាសាធារណ: ដើម្បីបង្ហាញប្រាប់សហគមន៍អន្តរជាតិថា ប្រទេសថៃមានការចូលរួមប្រកបដោយថាមពលនៅក្នុងការ ប្រយុទ្ធប្រឆាំងនឹងការជួញដូរមនុស្ស។

*"ក្នុងន័យមូលដ្ឋានទិន្នន័យកណ្តាលស្រមាប់ករណីជួញដូរ MSDHS មានសិទ្ធិផលិតមូលដ្ឋានទិន្នន័យមួយ ដែលពួកគេបានចាប់ផ្តើម ប៉ុន្តែក្រោយមកទៀតស្ងាត់ឈឹង។ យើងមានរបាយការណ៍មួយដែលប្រមូលចំនួនសរុបនៃ ករណីជួញដូរមនុស្សពីនគរបាលភូមិន្ទថៃ និង DSI ហើយបានចងក្រងវា បញ្ចូលគ្នា។ ប្រសិនបើអ្នកសួរខ្ញុំថាតើនគរបាលបង្កើតតួលេខនេះតាមរបៀប ណានោះ វាបានមកពីទម្រង់បែបបទមួយឈ្មោះ ផសថស ០១ ។ ទម្រង់បែប បបទនេះ គឺស្រមាប់តកត្រាតាករណីជួញដូរមនុស្សមកពីប៉ុស្តិ៍នគរបាល នីមួយៗនៅជុំវិញប្រទេសថៃ ហើយបន្ទាប់មកវាត្រូវបានបញ្ជូនទៅឲ្យគេ បញ្ចូលគ្នាជាមួយនឹងចំនួនសរុបដែល MSDHS មាន។ ប៉ុន្តែ MSDHS នៅ តែមិនទទួលបានជោគជ័យនៅក្នុងការចាប់ផ្តើមមូលដ្ឋានទិន្នន័យកណ្តាល ណាមួយឡើយ។ នគរបាលរក្សាការតាមដានសំណុំរឿង ទោះបីជាសំណុំរឿងនោះត្រូវបានដាក់ជូនមេធាវី ដែលជាអ្នកសម្រេចថាតើ ត្រូវបញ្ជូនសំណុំរឿងនោះទៅកាន់តុលាការដែរ ឬយ៉ាងណាក៏ដោយ។ យើងអាចគិតថាវាជាការ ជួញដូរ ប៉ុន្តែនៅទីបំផុតវាគឺជាសេចក្តីសម្រេចរបស់តុលាការ។*

*តើពួកគេរំពឹងថាយើងត្រូវបញ្ចូលគ្នានូវតួលេខទាំងអស់នេះដោយរបៀប ណា នៅពេលដែលគ្មានប្រព័ន្ធណាមួយស្រមាប់ដាក់ជាក្រុមជាមួយគ្នានូវ ទិន្នន័យដែលទទួលបានពីភាគីនីមួយៗរបស់យើងនោះ? ទោះជាយ៉ាង ណា តួលេខនៅក្នុងទីជម្រកមិនត្រូវគ្នានឹងតួលេខដែលយើងមានទេ ពីព្រោះពួកគេពុំរាប់ចំនួនជនរងគ្រោះដែលមិនស្ថិតនៅក្នុងទីជម្រកឡើយ គឺពួកគេពឹងផ្អែកទាំងស្រុងទៅលើចំនួនជនរងគ្រោះដែលពួកគេមានតែ ប៉ុណ្ណោះ [ដែលត្រូតស៊ីគ្នាជាមួយនឹងជនរងគ្រោះពីការរំលោភបំពាន]។ មានជនរងគ្រោះជាច្រើននាក់ ដែលមិនចង់រស់នៅក្នុងទីជម្រក។ មាន សំណុំរឿងមួយចំនួនដែលស្ថិតក្នុងការិយាល័យអន្តោប្រវេសន៍ ដែលត្រូវបានបញ្ជូនទៅកាន់តែមន្ត្រីនគរបាលក្នុងមូលដ្ឋានតែប៉ុណ្ណោះ។ គ្មាននរណាម្នាក់អាចបញ្ជាក់អះអាងតួលេខណាមួយបានទេឡើយ កំណត់ត្រា ដែលយើងមានសុទ្ធតែនៅលើក្រដាសទាំងអស់។ នៅទីបំផុត នគរបាលគឺជាអ្នកទទួលបន្ទុកលើមូលដ្ឋានទិន្នន័យនេះ។*

នគរបាលភូមិន្ទថៃ ក្រុងបាងកក





"មានឈ្មួញកណ្ដាល ដែលជួយសម្របសម្រួល ការដឹកជញ្ជូនក្មេងស្រីនោះពីសហគមន៍នាង ដោយផ្ទាល់ទៅកាន់ ម៉ាម៉ាសាន។ នៅផ្ទះបននោះ ម៉ាម៉ាសាន គ្រប់គ្រងក្មេងស្រីនោះ។ ជាធម្មតា ម៉ាម៉ាសាន ក៏ជាជនរងគ្រោះពីការជួញដូរផងដែរ។"

ប្រធានអង្គការ NGO នៅឈៀងរ៉ៃ



# ជំពូក ៣៖ ការជួញដូរព្រីបេទសកម្ពុជា*

*

# ប្រទេសថៃ

## សាវតា

ប្រទេសថៃបាន ទាក់ទាញពលករចំណាកស្រុកមកពីប្រទេសកម្ពុជាចាប់តាំងពីទសវត្សរ៍ឆ្នាំ ១៩៩០ មកម្លេះ ហើយមានចំនួនជនជាតិខ្មែរជាច្រើនដែលធ្វើការនៅ ក្នុងប្រទេសនេះ ទាំងស្របច្បាប់ និងខុសច្បាប់។ នៅឆ្នាំ ២០១៤ ជនជាតិខ្មែរជាង ៨៨០,០០០ នាក់ ត្រូវបានចុះបញ្ជីថាជាកម្មករចំណាកស្រុកនៅប្រទេសថៃ។ ទោះជាយ៉ាងណា កម្មករទាំងនេះ គ្រាន់តែតំណាងឲ្យ ៥% នៃប្រជាជនខ្មែរដែល ស្ថិតនៅក្នុងប្រទេសថៃប៉ុណ្ណោះ។

នៅក្នុងការប៉ុនប៉ងទប់លំហូរឥតឈប់ឈរនៃជនចំណាកស្រុកកម្ពុជាចូលទៅក្នុង ប្រទេសថៃ រដ្ឋាភិបាលថៃបានស្វែងរកការរារាំងជនចំណាកស្រុកសក្តានុពល ដោយរឹតបន្តឹងជនជាតិខ្មែរឲ្យចូលទៅក្នុងឧស្សាហកម្មទាំងឡាយណា ដែលផ្តល់ តែការងារមានប្រាក់ឈ្នួលទាប ដែលត្រូវបានចាត់ទុកថាកខ្វក់ គ្រោះថ្នាក់ និង ថោកទាប។[៦០]

មានកុមារកម្ពុជារាប់ពាន់នាក់ ដែលត្រូវបានដកហូតពីបញ្ជីជាតិ និងគ្មានភាពជា ពលរដ្ឋយ៉ាងមានប្រសិទ្ធភាព។ នៅក្នុងចំនួនអ្នកដែលមិនអាចមើលដឹងបាននេះ គឺជាកុមារដែលមកតាមឪពុកម្តាយពួកគេចូលក្នុងប្រទេសថៃ ក៏ដូចជាកុមារដែល ឆ្លងដែនតែម្នាក់ឯងដោយមានការស្រមបស្រមួលពីមេខ្យល់ ឬអ្នករត់ពន្ធ។ មាន វិសាលភាពធំធេងសម្រាប់ការជួញដូរមនុស្ស។

ចាប់ពីឆ្នាំ ១៩៧៥-៧៩ ប្រទេសកម្ពុជាត្រូវបានកាន់កាប់ដោយរបបខ្មែរក្រហម ជា របបអមនុស្សធម៌មួយ ដែលសម្លាប់ដោយការប្រល័យពូជសាសន៍ធ្ងន់ធ្ងរ និង បំផ្លិចបំផ្លាញសង្គមជាតិ។ ក្រោមរបបអំណាចផ្តាច់ការរបស់ ប៉ុល ពត ប្រជាជន កម្ពុជាប្រមាណ ២-៣ លាននាក់ ត្រូវបានធ្វើឃាតនៅក្នុងអំពើសម្លាប់រង្គាលដែល ដឹកនាំដោយរដ្ឋ និងដោយឥទ្ធិពលនៃអំណាចផ្តាច់ការរំលោភបំពាន។៦១ ប្រទេស កម្ពុជាត្រូវបានបន្តកាន់កាប់ដោយវៀតណាម ដែលកងកម្លាំងប្រដាប់អាវុធរបស់ ប្រទេសនេះបានផ្តួលរំលំរបប ប៉ុល ពត ដោយជោគជ័យនៅឆ្នាំ ១៩៧៩។

ក្រោយពីសង្គ្រាមស៊ីវិល និងអស្ថិរភាពនយោបាយអស់រយៈពេលរាប់ទសវត្សរ៍ កម្ពុជាបន្តតស៊ូលំបាកជាមួយនឹងភាពក្រីក្រដ៏លើសលប់ និងឱកាសសេដ្ឋកិច្ចនៅ មានក្រមិតនៅក្នុងប្រទេសរបស់ខ្លួន។ ជនជាតិខ្មែរចំណាកស្រុកទៅធ្វើការនៅ ប្រទេសថៃ ដែលទទួលបានប្រាក់កម្រៃតិចតួចបំផុតដល់ត្រឹមតែ ៣,០០០ ថៃបាត ក្នុងមួយខែ (២-៣ ដុល្លារ ក្នុងមួយថ្ងៃ)។

ភាពក្រីក្រគឺជាកត្តាលីករដ៏សំខាន់មួយ ដែលនាំឲ្យមានការធ្វើចំណាកស្រុកដោយ គ្មានសុវត្ថិភាពពីប្រទេសកម្ពុជាទៅកាន់ប្រទេសថៃ។ ឱកាសអប់រំនៅមានក្រមិត អំពើហិង្សាក្នុងគ្រួសារ ជីវភាពគ្រួសារប្រែប្រួលក្របល់ និងសហគមន៍ដែលមានការ ធាតើពីសង្គម ក៏ជាកត្តាសំខាន់ៗផងដែរ។ ដោយសារមានឱកាសការងារតិចតួច សម្រាប់គ្រួសារដែលរស់នៅជិតតំបន់ព្រំដែន ប្រទេសថៃជាពន្លឺនៃក្តីសង្ឃឹម។

ប្រជាជនខ្មែររាប់មិនអស់ ឆ្លងដែនចូលទៅកាន់ប្រទេសថៃជារៀងរាល់ថ្ងៃ ដែលមានការទាក់ទាញពីការដឹងថាមានភាពសម្បូរសប្បាយ និងឱកាសនៅក្នុងប្រទេសនេះ។ នៅក្នុងភូមិអូរឬស្សី ខេត្តស្វាយរៀង ៩៥% នៃក្មេងជំទង់ត្រូវបានគេ រាយការណ៍មកថា មានឪពុក ឬម្តាយ ឬទាំងឪពុកម្តាយធ្វើការនៅប្រទេសថៃ។ ក្មេងជំទង់ម្នាក់បាននិយាយថា *"ម្នាក់ៗស្ទើតែចង់ទៅប្រទេសថៃ មានការងារធ្វើ នៅប្រទេសថៃ។ នៅទីនេះគ្មានការងារអ្វីធ្វើទេ។"*[៦២]

ប្រវត្តិសាស្ត្រដ៏ល្វីងជូរចត់របស់កម្ពុជា ដក់ជាប់ជានិច្ចនៅក្នុងដួងចិត្តរបស់មនុស្ស ពេញវ័យកម្ពុជាជាច្រើននាក់។ ពួកគេរិះរកគ្រប់វិធីដើម្បីគេចផុតពីការស្លាប់ដែល បានបង្កើតជាវប្បធម៌មួយដែលបណ្តាលឲ្យមានការជួញដូរមនុស្ស។ ការអប់រំហាក់ដូចជាពុំត្រូវបានឲ្យតម្លៃឡើយ។ មនុស្សពេញវ័យភាគច្រើន ដែលខ្លួនពួកគេ ពុំទទួលបានការអប់រំដោយសារតែសង្គ្រាម ផ្តោតតែតម្រង់គត់ទៅលើភាពអាចរស់រានមានជីវិតបានប៉ុណ្ណោះ។ *"ទោះបីជាយើងបានរៀនសូត្រកើដោយ តើក្រោយមកមានការងារអ្វីសម្រាប់ឲ្យពួកយើងធ្វើទៅ? តើមានន័យអ្វីទៅ?"* នេះគឺជាការចោទសួររបស់មនុស្សពេញវ័យម្នាក់មកពីភូមិមួយនៃខេត្តស្វាយរៀង ប្រទេសកម្ពុជា។[៦៣]

សៀវភៅ គឺជាក្តីកង្វល់ដ៏ចម្បង និងសំខាន់ជាងអ្វីផ្សេងទៀតទាំងអស់របស់ពួកគេ។ ការរៀនសូត្របានតិចតួចផ្តួបផ្សំនឹងភាពក្រីក្រជាទីបំផុត មានភាពព្រងើយកន្តើយជាច្រើន ដែលមិនអាចកេកំហុសឃើញ ចំពោះស្ថានភាពរបស់ពួកកុលសម្ព័ន្ធគំនៅប្រទេសថៃ ហើយបានលើកទឹកចិត្តឲ្យមានប្រព័ន្ធជួញដូរកុមារដ៏ទំនើប ដែលភាគច្រើនពុំមានបង្ហាញ នៅក្នុងស្ថិតិណាមួយរបស់រដ្ឋាភិបាលឡើយ។

## ប្រទេសកម្ពុជាក្នុងនាមជាប្រទេសប្រភពដើម

មជ្ឈមណ្ឌលសិចតេប៉ាយប៉ែត (PTC) រាយការណ៍មកថា លំនាំនៃការជួញដូរកុមារមកពី ប្រទេសកម្ពុជាទៅកាន់ប្រទេសថៃ ពុំមានការរាលដាលទៅកាន់តំបន់ព្រំដែនឡើយ។ តាមការរាយការណ៍ពីអ្នកដែលត្រឡប់មកប្រទេសកំណើតវិញពីប្រទេសថៃ បានបញ្ជាក់ ថា ៨០-៩០% នៃជនរងគ្រោះជាកុមារ មកពីខេត្តបន្ទាយមានជ័យ (ប៉ោយប៉ែត) និងស្រុក អូរជ្រៅ។ នៅក្នុងតំបន់ទាំងនេះ មានផ្លូវក្រៅផ្លូវការរាប់មិនអស់ចូលទៅកាន់ប្រទេសថៃ ដែលកាត់តាមព្រៃ វាលស្រែ និងផ្លូវតាមភ្នំ។

ជាង ៩០% នៃជនរងគ្រោះកុមារដែលគេឃើញនៅប៉ាត់តាយ៉ាតែមួយ ត្រូវបានកំណត់ អត្តសញ្ញាណថាមានគេមកទទួល ឬលក់ដូរមកពីប៉ោយប៉ែត។[៦៤]

ប៉ោយប៉ែត ដែលធ្លាប់ជាជីតត្របេយោជន៍ក្រោយសង្គ្រាម បច្ចុប្បន្ននេះបានក្លាយជាទី ប្រជុំជនដ៏មានតម្លៃ ភាគច្រើនគឺដោយសារតែមានចំណាកស្រុកយ៉ាងខ្លាំងចូលទៅកាន់ ប្រទេសថៃ។ ជាមួយនឹងកត្តានេះ និងការបើកកាស៊ីណូជាច្រើននៅក្នុងក្រុង ប៉ោយប៉ែត ធ្លាប់ត្រូវបានប្រកាសដោយរដ្ឋាភិបាលថាជា "តំបន់សេដ្ឋកិច្ចនាពេលអនាគត"។[៦៥] បុគ្គលិកសង្គមកិច្ចមួយរូបបានអះអាងថា *"គ្មាននរណាម្នាក់មានប្រភពកំណើតមកពីប៉ោយប៉ែតនេះទេ ពោលគឺគ្រួសារពួកគេផ្លាស់ទីលំនៅមកទីនេះក្នុងទសវត្សរ៍ចុងក្រោយនេះ ពីព្រោះពួកគេចង់ទៅធ្វើការនៅប្រទេសថៃ។"*[៦៦]

ប៉ោយប៉ែតមានច្រកខុសច្បាប់ជាង ២០ ដែលឆ្លងចូលទៅកាន់ប្រទេសថៃ។ ច្រកជាច្រើន ស្ទើតែងាយស្រួលឆ្លងកាត់ ហើយគ្មាននគរបាលយាម។ កិច្ចប្រឹងប្រែងដោយអង្គការ អន្តរជាតិនានាដែលធ្វើការនៅគ្រប់រសទាប់វណ្ណៈ យូរៗម្តងដឹកនាំឲ្យមានការរឹតបន្តឹង សន្តិសុខនៅតាមបណ្តោយព្រំដែនប៉ោយប៉ែត ដែលធ្វើឲ្យការផ្លាស់ទីចូលទៅកាន់ ប្រទេសថៃជួបការលំបាក។[៦៧] នៅអំឡុងពេលនេះ ជនជាតិខ្មែរអាចធ្វើដំណើរក្នុងចម្ងាយ បួនដប់គីឡូម៉ែត្រទៅកាន់ទីប្រជុំជនតូចនៅតាមព្រំដែនមួយទៀតគឺស្រុកម៉ាឡៃ ដែលមានច្រកព្រំដែនខុសច្បាប់ជាង ១០ ដែលស្ទើរតែគ្មានសន្តិសុខទាល់តែសោះ។ នៅស្រុក ម៉ាឡៃ មានការរាយការណ៍មកថា ពួកគេអាចបង់លុយ ៥០០ រៀល ទៅឲ្យមន្ត្រីខ្មែរមួយ ចំនួន ដើម្បីឆ្លងដែនដោយខុសច្បាប់ចូលទៅផ្សារថៃ។

យោងតាមអ្នកលក់នៅតាមចិញ្ចើមថ្នល់ម្នាក់ ដែលធ្វើការនៅស្រុកម៉ាឡៃ៖

*"នៅទីនេះងាយស្រួលចូលទៅប្រទេសថៃណាស់។ មានផ្លូវជាច្រើននៅពីក្រោយផ្ទះអ្នក ស្រុក ហើយនេះក៏ជាកន្លែងដែលទំនិញខុសច្បាប់ជាច្រើនចេញចូលផងដែរ។ វាហាក់ដូច ជាវិធីមួយក្នុងការចូលទៅកាន់ប្រទេសថៃ និងអ្នកដែលមានបំណងចង់ជួយអ្នក។"*[៦៨]

ជារៀងរាល់ថ្ងៃ មានជនជាតិខ្មែរជាង ២០,០០០ នាក់ ឆ្លងដែនចេញចូលប្រទេសថៃដើម្បី ទៅរកស៊ី ធ្វើការសំណង់ និងធ្វើការនៅផ្សាររុងក្លឿ។ ក្នុងចំណោមពួកគេ មានកុមាររាប់រយនាក់ឆ្លងដែនចូលទៅសុំទាននៅផ្សារថៃ។ ពួកគេគឺជាចំណែកដ៏ងាយរងគ្រោះពីមនុស្សល់ ដែលនាំពួកគេចូលទៅកាន់កន្លែងផ្សេងៗនៃប្រទេសថៃដើម្បីសុំទាន ឬប្រកបរបរផ្លូវភេទ។[៦៩]

កុមារកម្ពុជាស្ថិតក្នុងចំណោមក្រុមងាយរងគ្រោះ ដែលត្រូវបានគេជួញដូរចូលទៅក្នុងប្រទេសថៃ។ បុគ្គលិកដែលធ្វើការនៅក្នុងទីជ្រកមករបស់រដ្ឋសម្រាប់ជនរងគ្រោះពីការជួញ ដូរនៅប្រទេសថៃបានកំណត់ថា ជនជាតិខ្មែរហាក់ដូចជាងាយរងគ្រោះជាពិសេស ដោយ សារតែកាលៈទេសៈ និងជីវភាពក្រីក្ររបស់ពួកគេ។ កុមារភាគច្រើនមកពីភូមិ និងតំបន់អាណាធិបតេយ្យដែលរស់នៅក្នុងស្ថានភាពក្រីក្រ និងខ្វះខាត ដោយទទួលបានទឹកស្អាត ការអប់រំ ការគាំពារសុខភាព និងអាហារូបត្ថម្ភមូលដ្ឋានតិចតួចប៉ុណ្ណោះ។[៧០]

តំបន់ចំនួនពីរ ដែលគេតែងតែចាប់ពង្រត់កុមារ ឬជួលកុមារពីឪពុកម្តាយពួកគេដើម្បីឲ្យ ទៅសុំទាននៅប្រទេសថៃគឺ តំបន់អនាធិបតេយ្យប៉ាលីឡៃ និងតំបន់អាណាធិបតេយ្យដី ស។ តំបន់អនាធិបតេយ្យទាំងពីរនេះ គឺជាទីជ្រមកសម្រាប់កុមារជាង ៣០០ នាក់[៧២] ដែលរស់នៅប្រកបដោយហានិភ័យយ៉ាងខ្លាំងពីការជួញដូរ និងកេងប្រវ័ញ្ច។

ភាគច្រើននៃកុមារទាំងនេះ រស់នៅជាមួយយាយតាពួកគេ ចំណែកឪពុកម្តាយពួកគេធ្វើ ការនៅប្រទេសថៃ។ កុមារទាំងនេះពុំបានចូលរៀនទេ ហើយចំណាយពេលយប់ថ្ងៃនៅ តាមចិញ្ចើមថ្នល់សុំទាននៅជុំវិញបារ និងកាស៊ីណូក្នុងស្រុក។ ខណៈដែលមានសាលា រៀននៅជិតៗ ក៏នៅតែត្រូវបង់ថ្លៃឈ្នួលដែលគ្រួសារពួកគេពុំមានលទ្ធភាពបង់ និងពុំមាន ចេតនាបង់ ជាពិសេសដោយសារតែការផ្តល់តម្លៃទាបលើការអប់រំ ដោយសារតែឪពុកម្តាយពុំបានទទួលការអប់រំដែរ។ ការនេះធ្វើឲ្យកុមារត្រូវនៅក្រៅសាលា ហើយនៅតាម ចិញ្ចើមថ្នល់ ឬនៅតាមការដ្ឋាន ដែលពួកគេក្លាយទៅជាចំណីដ៏ងាយស្រួលសម្រាប់អ្នក ជួញដូរមនុស្ស។

## ផ្លូវជួញដូរចេញពីប្រទេសកម្ពុជាទៅកាន់ប្រទេសថៃ

សម្រាប់គ្រួសារជាច្រើនដែលរស់នៅក្នុងជីវភាពយ៉ាប់យ៉ឺនបំផុត ការទទួលបានលិខិត ឆ្លងដែនដើម្បីធ្វើដំណើរដំណើរទៅធ្វើការនៅប្រទេសថៃដោយស្របច្បាប់ មានតម្លៃថ្លៃ ហើយទាមទារឲ្យធ្វើដំណើរទៅកាន់រាជធានីភ្នំពេញសម្រាប់ដំណើរការវែងឆ្ងាយ មាន លក្ខណៈជាការិយាល័យធិបតេយ្យ និងចំណាយអស់លុយច្រើន។ សម្រាប់គ្រួសារដែលរស់នៅតាមបណ្តោយព្រំដែនថៃ-កម្ពុជា ការធ្វើដំណើរត្រូវចំណាយពេលប្រហែលប្រាំបី ម៉ោង។ ទោះបីជាមានលិខិតឆ្លងដែនក៏ដោយ ជនជាតិខ្មែរត្រូវបានរារាំងពីការឆ្លងដែនដោយស្របច្បាប់។ មន្ត្រីអន្តោប្រវេសន៍ភាគច្រើន កេងប្រវ័ញ្ចលើភាពងាយរងគ្រោះ និងក ង្វះការរៀនសូត្ររបស់ពួកគេ ដោយទាមទារសំណូកសម្រាប់ជំនួយឯកសារដោយឥត គិតថ្លៃ។[៧៣]

ជម្រើសបន្ថែមមួយផ្សេងទៀតសម្រាប់ជនជាតិខ្មែរដែលរស់នៅតាមបណ្តោយព្រំដែនគឺ ការទទួលបានប័ណ្ណឆ្លងដែនដែលត្រូវបានបង្កើតនៅក្នុងស្រុក និងមានតម្លៃទាប។[៧៤] ទោះជាយ៉ាងណា វាហាក់ដូចជាគ្មានន័យសោះ ព្រោះតែការចំណាយពេលវេលាយូរ និង លុយកាក់ច្រើនសម្រាប់បង់ថ្លៃឯកសារស្របច្បាប់ ខណៈដែលមានមធ្យោបាយរាប់មិនអស់ក្នុងការឆ្លងដែនដោយមិនអស់លុយ។

គ្រាន់តែប៉ោយប៉ែតមួយ មានច្រកឆ្លងកាត់ខុសច្បាប់ ឬក្រៅផ្លូវការជាង ២០ កន្លែងចូល ទៅកាន់ប្រទេសថៃ។ ច្រកឆ្លងកាត់ក្រៅផ្លូវការនេះមានព្រៃ វាលស្រែ ស្ទឹង អូរ និងថែមទាំង មានច្រកទ្វារតូចៗចេញមកពីកាស៊ីណូនៅក្នុងក្រុងទៀតផង។ ច្រកចេញចូលព្រំដែន ខុសច្បាប់ទៅកាន់ប្រទេសថៃ មានឈ្មោះហៅក្រៅដូចជា ផ្កា ឬឪឡឹកជាដើម។ យោង តាមក្មេងជំទង់ម្នាក់ “*ឈ្មោះទាំងនេះមានការផ្លាស់ប្តូរជានិច្ច ហើយតែងតែមានបន្ថែម កន្លែងឆ្លងកាត់ថ្មីៗជានិច្ច។ មានភាពងាយស្រួលក្នុងការចូលទៅប្រទេសថៃ តាមធម្មតា ខ្ញុំប្រើផ្កា ជួនកាលមិនអស់លុយ ហើយជួនកាលត្រូវបង់ ២០ បាត។*”[៧៥]

ជាទូទៅ កុមារធំៗតែងតែចូលទៅកាន់ប្រទេសថៃតែម្នាក់ឯង ដោយស្វែងរកការងារធ្វើ ហើយនៅទីបំផុតធ្លាក់ចូលក្នុងស្ថានភាពដែលមានការកេងប្រវ័ញ្ច។ កុមារតូចៗ ជាពិសេសក្មេងស្រី ជាទូទៅចូលទៅកាន់ប្រទេសថៃដោយមានជំនួយពីមេខ្យល់។ កុមារ ដែលចូលទៅកាន់ប្រទេសថៃជាមួយមេខ្យល់ ជាធម្មតាគឺជាកុមារដែលធ្លាប់ត្រូវបានគេលក់ដូរ ជួលចេញមកដោយឪពុកម្តាយពួកគេ ឬចាប់ពង្រត់ដោយមេខ្យល់ដែលកំណត់គោលដៅតំបន់អាណាធិបតេយ្យ និងភូមិនានានៅប៉ោយប៉ែត។[៧៦]

> “*ភាពក្រីក្រ បង្ខំឪពុកម្តាយឲ្យលក់ដូរកូនខ្លួនឯង។ ឪពុកម្តាយមួយចំនួនដឹងថា នៅទីបំផុតកូនពួកគេនឹងទៅជាយ៉ាងណា ប៉ុន្តែប្រសិនបើមានកូនណាម្នាក់អាចផ្តល់លុយបានខ្លះនោះ ពួកគេហ៊ានប្រថុយឲ្យកូននោះទៅ។*”
>
> **បុគ្គលិកកាន់សំណុំរឿង ក្រុងប៉ោយប៉ែត**

មេខ្យល់ជាច្រើនដែលជួញដូរកុមារដោយខុសច្បាប់ចូលទៅកាន់ប្រទេសថៃ ត្រូវបានគេរាយការណ៍មកថា ប្រើច្រកឆ្លងកាត់ឪឡឹក។ នៅទីនេះ គេនិយាយដោយឥតភ័ស្តុតាងថា មេខ្យល់អាចជាបង់លុយឲ្យមន្ត្រីនគរបាល ២០ បាត ដើម្បីចូលទៅកាន់ប្រទេសថៃតាមទ្វារតូចមួយ ដែលនាំទៅកាន់ផ្សារថៃដ៏មមាញឹកមួយ។ នៅទីនេះ កុមារត្រូវបានគេនាំទៅកាន់កន្លែងផ្សេងៗនៃប្រទេសថៃ។[៧៧] បុគ្គលិកដែលមកពីអង្គការ NGOs នៅកម្ពុជា ពុំអាចចូលទៅជិតច្រកឆ្លងកាត់នេះបានទេ ពីព្រោះមានការឃ្លាំមើលយ៉ាងតឹងរឹងដោយនគរបាល។

## តួនាទីរបស់ឪពុកម្តាយនៅក្នុងការជួញដូរកុមារកម្ពុជា

ច្បាប់ស្តីពីសិទ្ធិកុមារដែលនៅមានកម្រិតរបស់កម្ពុជា ធ្វើឲ្យកុមារពុំត្រូវបានការពារដោយ ច្បាប់បានគ្រប់គាន់ឡើយ។ វាពុំមែនជារឿងប្លែកទេ ដែលឪពុកម្តាយកុមារកម្ពុជាចូលរួម នៅក្នុងការជួញដូរកូនខ្លួនឯងនោះ។ នៅក្នុងសេណារីយ៉ូមួយចំនួន ឪពុកម្តាយនឹង “ជួល” ឬលក់ដូរកូនរបស់ខ្លួនទៅឲ្យមេខ្យល់ម្នាក់ក្នុងតម្លៃប្រហែល ១,៥០០ - ៣,០០០ ថៃ បាត។[៧៨] នេះគឺជារឿងទូទៅច្រើនជាងការដែលអ្នកជួញដូរចាប់ពង្រត់កុមារ។ កុមារដែលងាយរងគ្រោះបំផុតពីការបោកប ញ្ឆោតតាមវិធីនេះ គឺជាកុមារដែលសុំទាននៅក្នុងផ្សាររុងក្លឿនៅតាមព្រំដែនក្នុងទឹកដីថៃ។

នៅក្នុងករណីមួយចំនួន ឪពុកម្តាយដែលជាជនចំណាកស្រុករស់នៅប្រទេសថៃ នាំកូន ពួកគេទៅសុំទាននៅតាមចិញ្ចើមថ្នល់ជាមួយពួកគេនៅពេលយប់។ ប្រសិនបើអាជ្ញាធរថៃចាប់ពួកគេ ឪពុកម្តាយអាចត្រូវបានចាប់ខ្លួន និងដាក់ពន្ធនាគារ ចំណែកកុមារត្រូវបញ្ជូនត្រឡប់ទៅកាន់ប្រទេសកម្ពុជាវិញ គឺទៅកាន់ទីជ្រមករបស់រដ្ឋាភិបាលកម្ពុជា ដែលពួកគេ ត្រូវស្នាក់នៅទីនោះ រហូតទាល់តែដល់ពេលដែលអាចរកទីកន្លែងស្នាក់នៅបានសមរម្យ ផ្សេងពីកន្លែងនេះ។[៧៩] ជួនកាល កុមារនឹងត្រូវនៅក្នុងទីជ្រមកនោះអស់រយៈពេលរាប់ខែ ឬ រាប់ឆ្នាំ រហូតដល់ពេលពួកគេមានអាយុច្រើនល្មមដែលអាចចាកចេញបាន។

ឪពុកម្តាយកុមារកម្ពុជាមួយចំនួន ចាត់ទុកកូនៗពួកគេថាជាការវិនិយោគ ហើយមើលឃើញតម្លៃតិចតួចពីការបញ្ជូនកូនឲ្យទៅរៀនសូត្រ។ ឪពុកម្តាយខ្លួនឯងក៏តែងតែជាជន រងគ្រោះពីការជួញដូរ និងកេងប្រវ័ញ្ចផងដែរ ហើយបានចាប់ផ្តើមធ្វើ



## ឧទាហរណ៍អំពីសហគមន៍ផ្សេងៗនៅកម្ពុជា[៨៤]

### ភូមិទី ១

ភូមិនេះភាគច្រើនមានតែមនុស្សចាស់ៗ។ មនុស្សពេញវ័យភាគច្រើនដែលមានអាយុ ២០-៥០ ឆ្នាំ បានទៅធ្វើការនៅថៃ ដោយទុកកូនឲ្យយាយតាមើលថែ។ ដោយមានទីតាំងនៅជាប់នឹងច្រកឆ្លងដែនខុសច្បាប់ ធ្លាប់មានករណីជួញដូរក្មេងស្រីទៅប្រទេសថៃជាច្រើនករណី។ មេខ្យល់ជនជាតិថៃទៅកាន់ភូមិនោះជាញឹកញាប់។ ករណីភាគច្រើន យាយតា ឬសមាជិកគ្រួសារបង់លុយឲ្យមេខ្យល់ ២,០០០ បាត ដើម្បីនាំកុមារទៅធ្វើការនៅថៃ និងអត្រាបន្ថែមទៀត ប្រសិនបើពួកគេចង់ឲ្យមេខ្យល់នោះយកប្រាក់ចំណូលរបស់កូនត្រឡប់មកផ្ទះវិញជាប្រចាំ។ ភាគច្រើននៃកុមារទាំងនោះ នៅទីបំផុតធ្វើជាអ្នកសុំទាននៅតាមចិញ្ចើមថ្នល់ ចំណែកក្មេងស្រីធ្វើការជាស្រីពេស្យាចារ។

### ភូមិទី ២

ភូមិនេះ នៅទីជនបទដាច់ស្រយាល ខ្វះសាលារៀនរដ្ឋ។ សាលារៀនក្រៅប្រព័ន្ធបានបង្កើតដោយអ្នកដឹកនាំសហគមន៍ ដើម្បីផ្តល់ការអប់រំកម្រិតមូលដ្ឋានដល់កុមារ។ កុមារភាគច្រើនរស់នៅជាមួយយាយតា ដែលមិនចេះអាន និងសរសេរ និងគ្មានការអប់រំ។ កុមារនៅទីនេះ ងាយរងគ្រោះពីព្រោះពួកគេនៅដាច់ស្រយាល ហើយអាចទទួលបានត្រឹមតែការមូលដ្ឋានដែលចាំបាច់បន្តិចបន្តួច។ ដោយសារតែពួកគេពុំត្រូវបានចុះឈ្មោះនៅសាលារដ្ឋ ពុំមាននរណាម្នាក់កត់ចំណាំពួកគេឡើយ ប្រសិនបើពួកគេបាត់ខ្លួន។ កុមារមានអារម្មណ៍ថាឯកា ធុញទ្រាន់ និងស្វាគមន៍ឱកាសនាំទៅកាន់ប្រទេសថៃ ដែលជាកន្លែងដែលពួកគេអាចធ្វើការ និងទទួលបានបទពិសោធន៍ជីវិតថ្មី និងទំនើប

### ភូមិទី ៣

មានច្រកឆ្លងកាត់ព្រំដែនខុសច្បាប់មួយ នៅចំកណ្តាលភូមិ។ មេភូមិធ្លាប់ធ្វើជាអ្នកផ្គត់ផ្គង់ដ៏ធំនូវកុមារកម្ពុជាទៅកាន់ប្រទេសថៃ។ គាត់ដើរប្រមូលលុយពីគ្រួសារក្រីក្រ សម្រាប់បង់ពន្ធ។ គ្រួសារដែលមិនមានលទ្ធភាពបង់ អាចលក់កូនពួកគេឲ្យគាត់ជំនួសវិញ។គាត់លក់កុមារភាគច្រើនឲ្យក្រុមមេជើងកាង និងបណ្តាញអ្នកសុំទាននៅប្រទេសថៃ ប៉ុន្តែរក្សាទុកក្មេងស្រីមួយចំនួនសម្រាប់បម្រើនៅក្នុងគ្រួសារ និងបម្រើផ្លូវភេទ។ ដោយមានការចាប់ខ្លួន និងដាក់ពន្ធនាគារគាត់ ការជួញដូរកុមារក្មេងៗមានការថយចុះ ប៉ុន្តែនៅតែមាន។ ជនជាតិខ្មែរជាច្រើនធ្វើដំណើរទៅធ្វើការនៅប្រទេសដោយខុសច្បាប់ ដែលភាគច្រើនយកកូនទៅជាមួយពួកគេ។

ការនៅវ័យក្មេងខ្ចី។ ក្មេងជំទង់ម្នាក់នៅភូមិអូរឫស្សីបានពន្យល់ថា *“ឪពុកខ្ញុំវាយខ្ញុំពីព្រោះខ្ញុំចង់ទៅរៀន។ គាត់មិនយល់ថាហេតុអ្វីបានជាខ្ញុំចង់ទៅរៀនទេ គាត់ចង់ឲ្យខ្ញុំធ្វើការរកលុយឲ្យគាត់។”*[៨០]

មនុស្សពេញវ័យជាច្រើននៅប៉ោយប៉ែត តស៊ូលំបាកជាមួយនឹងបាក់កម្ចី និងបំណុល ហើយពុំមើលឃើញពីអត្ថប្រយោជន៍នៃការសន្សំប្រាក់ពីចំណូលរបស់ពួកគេ ដើម្បីសង បំណុលរបស់ពួកគេវិញឡើយ។ បុគ្គលិកផ្នែកសង្គមកិច្ចម្នាក់នៅប៉ោយប៉ែតបានអះអាង ថា *“ឪពុកម្តាយមិនសងបំណុលដោយប្រើចំណូលរបស់ខ្លួនទេ ពីព្រោះបំណុលនោះគឺ ស្រមាប់កូនពួកគេជាអ្នកសង។”*[៨១]
នៅក្នុងករណីមួយចំនួន កុមារដែលបានធ្វើមាតុភូមិ និវត្តន៍ដោយជោគជ័យ និងបានទៅរួមរស់ជាមួយក្រុមគ្រួសារពួកគេម្តងទៀតក្រោយពីត្រូវបានជួញដូរទៅកាន់ប្រទេសថៃ ទាក់ទងមេខ្យល់ និងជួញដូរខ្លួនឯងពីព្រោះពួកគេរង សម្ពាធយ៉ាងខ្លាំងឲ្យរកលុយ ហើយមានការភ័យខ្លាចក្នុងការត្រឡប់ទៅផ្ទះវិញដោយដៃ ទទេ។[៨២]

បន្ថែមពីលើនេះទៀត ដោយសារខ្វះផែនការគ្រួសារ និងខ្វះការអប់រំនៅតាមព្រំដែន គ្រួសារជាច្រើនមានកូនរហូតដល់ ១០ នាក់ ដែលពួកគេពុំមានលទ្ធភាពចិញ្ចឹមបាន។ ម្តាយម្នាក់ក្នុងចំណោមម្តាយប្រាំបីនាក់នៅប៉ោយប៉ែត ដែលគេឃើញសុំទានជាមួយកូន អាយុ ៤ ឆ្នាំរបស់គាត់នៅជុំវិញកាស៊ីណូនៅពេលយប់ បាននិយាយថា៖
*“ខ្ញុំមានកូន ៨ នាក់ ដែលពួកគេពីរនាក់កំពុងធ្វើការនៅថៃ ខ្ញុំមិនដឹងថានៅកន្លែងណាទេ។ ខ្ញុំដឹងថាពួកគេនឹងត្រឡប់មកវិញ។ កូនម្នាក់នៅថៃ ហើយបានត្រឡប់មកវិញកាលពី ប៉ុន្មានខែមុននេះ។ ខ្ញុំចង់បញ្ជូនកូនម្នាក់ទៀតដែរ [ចង្អុលទៅកាន់កូនអាយុ ៤ ឆ្នាំ] ប៉ុន្តែប្តីខ្ញុំ ចង់ឲ្យខ្ញុំទុកកូននេះ ជាជាងការលក់សាច់ឈាមរបស់គាត់។”* [៨៣]

ស្រមាប់គ្រួសារទាំងនេះ ការជួលកូនគឺជាមធ្យោបាយរួចផុតពីស្ថានភាពគ្រោះថ្នាក់។ ភាពក្រីក្ររ៉ាំរ៉ៃ បង្ខំឲ្យឪពុកម្តាយមិនអាចធ្វើតាមការសម្រេចចិត្តបែបនេះបានទេ។

ប៉ុន្តែ ការអនុវត្តន៍បែបនេះ គឺជាការផ្តល់កម្លាំងបន្ថែមដល់ប្រព័ន្ធជួញដូរមនុស្ស។

## ប្រព័ន្ធមេខ្យល់កម្ពុជា

ការជួញដូរកុមារពីកម្ពុជាទៅកាន់ប្រទេសថៃ ពាក់ព័ន្ធនឹងប្រព័ន្ធមេខ្យល់ដ៏ទំនើបដែល មានការជួយគាំទ្រពីបណ្តាញអ្នកជួញដូរមនុស្សដ៏ស្មុគស្មាញ។ ដោយសារតែមាន ឱកាសការងារតិចតួច និងបរិយាកាសសេដ្ឋកិច្ចគ្មានស្ថិរភាពនៅប៉ោយប៉ែត ប្រជាជន ភាគច្រើនយល់ថាពួកគេមានការពាក់ព័ន្ធនឹងអាជីវកម្ម និងបណ្តាញជួញដូរមនុស្ស ដោយពុំបានដឹងខ្លួន។ ចំពោះអ្នកខ្លះ ការជួយគេឆ្លងព្រំដែនដោយខុសច្បាប់ គឺជាសេវា ស្រមាប់គ្រួសារក្រីក្រដែលត្រូវការការងារនៅប្រទេសថៃ។ ចំពោះអ្នកខ្លះទៀត នេះគឺជា អាជីវកម្មដ៏សំខាន់ ដែលប្រាក់ចំណូលមានច្រើនជាងការងារតូចតាចផ្សេងទៀតទាំងអស់ដែលពាក់ព័ន្ធនឹងការចាប់ខ្លួន និងផ្តន្ទាទោស។

ខណ:ដែលការចាប់ព្រងត់ និងការចាប់ជំរិតមួយចំនួនកើតឡើងនៅក្នុងទ្រីបជុំជនតាម ព្រំដែនរបស់កម្ពុជា កុមារកម្ពុជាដែលត្រូវបានជួញដូរភាគច្រើនត្រូវបានជួលមកពីឪពុក ម្តាយពួកគេដោយមេខ្យល់ម្នាក់។ មេខ្យល់សាងទំនាក់ទំនងជិតស្និទ្ធជាមួយអ្នករស់នៅ តំបន់អនាធិបតេយ្យ និងភូមិនានា ហើយក្នុងករណីមួយចំនួនសាងទំនាក់ទំ

> “អ្នកក្រគប់គងក្រុងបរិញ្ញលើកុមារតាមវិធីជាច្រើន។ ជម្រើសនៃ ឧស្សាហកម្មដែលកុមារចូលទៅ គឺអាស្រ័យទៅលើអាយុរបស់កុមារនោះ។ ប្រសិនបើកុមារមានអាយុ ១-២ ឆ្នាំ គេតែងតែឃើញពួកគេដើរ សុំទាន។ នៅពេលដែលកុមារលែងរកចំណូលគ្រប់គាន់ស្រមាប់ពួកគេបានទេនោះ ពួកគេលក់ដូរកុមារនោះទៅឲ្យអ្នកក្រគប់គងបន្ទាប់។”
>
> **ប្រធានអង្គការ NGO នៅប៉ាត់តាយ៉ា**

នឹងជាមួយ នគរបាល និងអាជ្ញាធរអន្តោប្រវេសន៍ក្នុងស្រុក។[៨៥] ជាទូទៅ មេខ្យល់ត្រូវផ្តោតលើគ្រួសារដែលមានកូនច្រើន ដោយកេងប្រវ័ញ្ចលើភាពក្រីក្រ និងភាពចាំបាច់បំពេញតាម សេចក្តីត្រូវការរបស់កូនពួកគេ។

មេខ្យល់មួយចំនួន ជួលកុមារដោយផ្ទាល់ពីឪពុកម្តាយ ដោយសន្យាប្រគល់កុមារនោះមកវិញនៅពេលចប់កិច្ចសន្យាការងារ ឬសកម្មភាពក្រៅផ្លូវការ។៨៦ ឪពុកម្តាយមានចេតនា អនុញ្ញាតឲ្យនាំកូនពួកគេទៅកាន់ប្រទេសថៃ ដោយឈរលើលក្ខខណ្ឌមួយដែលថា នៅទី បំផុតកូនពួកគេនឹងត្រូវបានប្រគល់ឲ្យមកវិញ មិនត្រឹមតែមានសុវត្ថិភាពប៉ុណ្ណោះទេ ថែមទាំង ទទួលបានការរៀនសូត្រកាន់តែប្រសើរថែមទៀតជាមួយនឹង “បទពិសោធន៍ការងារ”។ វាគឺជារឿងដែលត្រូវជជែកវែកញែកគ្នាថាតើ ឪពុកម្តាយបានដឹងពីក្រមិតដែលកូនពួកគេត្រូវ បានគេកេងប្រវ័ញ្ចនៅពេលពួកគេនៅប្រទេសថៃដែរឬទេ។

មេខ្យល់ដទៃទៀតទិញយកកុមារតែម្តង ដោយពុំចាំបាច់សន្យាថានឹងប្រគល់ឲ្យមកវិញឡើយ។ ពួកគេលួងលោមឪពុកម្តាយ ឬយាយតារបស់កុមារថា ពួកគេនឹងជួយដល់ កុមារព្រមទាំងគ្រួសារទាំងមូលផងដែរ។ ពួកគេនឹងអនុញ្ញាតឲ្យផ្ញើប្រាក់ចំណូលមួយ ផ្នែករបស់កុ

> *នៅក្នុងករណីជាច្រើន វាមានភាពងាយស្រួលក្នុងការចាប់អ្នកគ្រប់គ្រងជាងចាប់មេខ្យល់។ នោះគឺដោយសារតែគេដឹងថា អ្នកគ្រប់គ្រងភាគច្រើនគឺជាជនជាតិវៀតណាម។ ជាទូទៅ កុមារត្រូវមានទូរស័ព្ទមួយគ្រឿងតាមជាប់ខ្លួន ហើយទូរស័ព្ទនោះបិទការហៅចេញ ដើម្បីកុំឲ្យពួកគេហៅចេញ ប៉ុន្តែអាចទទួលការហៅចូលបាន។ ពួកគេមិនត្រូវបានអនុញ្ញាតឲ្យនិយាយជាមួយនរណាម្នាក់លើសពី ២ នាទីឡើយ។ អ្នកនឹង មិនឃើញពួកគេនៅឆ្ងាយពីអ្នកគ្រប់គ្រងរបស់ពួកគេឡើយ។ នៅក្នុងករណីមួយចំនួន នៅពេលនគរបាលរកឃើញកុមារ ពួកគេអាចយកកុមារទៅកាន់ប៉ុស្តិ៍នគរបាល ហើយនៅពេលអ្នកគ្រប់គ្រងហៅទូរស័ព្ទមក ពួកគេប្រាប់ថា កុមារនោះមានគ្រោះថ្នាក់ ហើយអ្នកគ្រប់គ្រងនោះមកទទួលកុមារ។ ពួកគេដោះសារគ្រប់បែបយ៉ាងតាមដែលអាចធ្វើបាន ដើម្បីចាប់អ្នកគ្រប់គ្រង។ ផ្នែកនេះងាយស្រួលជាងការចាប់មេខ្យល់ ដែលជាធម្មតាមានមូលដ្ឋាននៅប៉ោយប៉ែត។ ជាអកុសល យើងដឹងពីកន្លែងដែលមេខ្យល់ភាគច្រើនរស់នៅ សូម្បីកូនក្មេងក៏ដឹងដែរ។ នៅក្នុងករណីមួយចំនួន កូនក្មេងជួញដូរខ្លួនឯង កុមារម្នាក់ដែលមានអាយុ ១០ ឆ្នាំ ចង់ទៅធ្វើការនៅប្រទេសថៃ ដូច្នេះគាត់ទៅផ្ទះអ្នកជួញដូរដោយផ្ទាល់ ដែលជាអ្នកលក់គាត់ទៅឲ្យអ្នកគ្រប់គ្រងម្នាក់។*
>
> **បុគ្គលិកកាន់សំណុំរឿង នៅប៉ាត់តាយ៉ា**

មារនោះមកកាន់ក្រុមគ្រួសារជារៀងរាល់ខែ ទោះជាយ៉ាងណាការធ្វើបែបនេះត្រូវឲ្យមានការគិតថ្លៃបន្ថែម។[៨៧]

នៅប៉ោយប៉ែត នាយកគ្រប់គ្រងទីជម្រកជនរងគ្រោះពីការជួញដូរមួយរូបបាន អះអាងថាៈ

*“ប្រព័ន្ធមេខ្យល់ នៅតែសកម្មជានិច្ចនៅប៉ោយប៉ែត ពីព្រោះពួកគេគ្រប់គ្រងបានចាប់ខ្លួនកុមារស្ថិតក្រោមការបង្ខិតបង្ខំ ហើយតែងតែភ័យខ្លាច ដូច្នេះពួកគេការពារអត្តសញ្ញាណរបស់មេខ្យល់។ ”* [៨៨]

នៅក្នុងករណីជួញដូរមនុស្សភាគច្រើន ដែលបានកត់តាដោយមជ្ឈមណ្ឌលគ្រួសារថ្មី មេ ខ្យល់ពាក់ព័ន្ធនឹងដំណើរការជួញដូរទាំងស្រុង។ មេខ្យល់នាំកុមារចេញពីគ្រួសារពួកគេ ដឹកជញ្ជូនពួកគេ ហើយប្រគល់ពួកគេដោយផ្ទាល់ទៅកាន់គោលដៅ ដោយពុំមានការប្រគល់និងទទួលនៅព្រំដែនឡើយ។ នៅពេលកុមារមកដល់គោលដៅចុងក្រោយរបស់ពួកគេនៅប្រទេសថៃ ពួកគេនឹងត្រូវបានប្រគល់ទៅឲ្យអ្នកគ្រប់គ្រងក្នុងស្រុកម្នាក់ ជាទូទៅជាជនជាតិវៀតណាម ឬខ្មែរ។[89]
តាមការរាយការណ៍មកថា មានបណ្តាញមេខ្យល់វៀតណាមនៅប៉ោយប៉ែត ដែលធ្វើការជាមួយអ្នកទំនាក់ទំនង និងអ្នកគ្រប់គ្រងវៀតណាមនៅប្រទេសថៃ និងម៉ាឡេស៊ី។ កុមារដែលត្រូវបានជួញដូរមកពីប៉ោយប៉ែត ទីបំផុតនៅប៉ាត់តាយ៉ា ដែលនៅទីនោះអ្នកគ្រប់គ្រងជនជាតិវៀតណាម រកការងារឲ្យពួកគេធ្វើ ឬមើលការខុសត្រូវក្រុមអ្នកសុំទានដែលមានការរៀបចំ។ ពួកគេធ្វើដំណើរកាត់តាមប្រទេសថៃជាមួយមេខ្យល់ជនជាតិខ្មែរ ឬថៃ ដែលបន្ទាប់មកលក់ពួកគេទៅឲ្យអ្នកគ្រប់គ្រងក្នុងស្រុក ពេលដល់ប៉ាត់តាយ៉ា។[៩០]

អ្នកគ្រប់គ្រង ទទួលបន្ទុកឃ្លាំមើលជនរងគ្រោះកុមារ ដោយធានាថា ពួកគេមិនរត់គេចទៅឆ្ងាយ ហើយមិនមាននគរបាលមកទទួល។ នៅទីសាធារណៈ ពួកគេដើរតួធ្វើហាក់ដូចជាឪពុកម្តាយ ឬសមាជិកគ្រួសាររបស់កុមារដែលត្រូវបានជួញដូរ ប៉ុន្តែក្នុងតថភាពជាក់ស្តែង ពួកគេអាចរំលោភបំពានទៅលើកុមារដែលពួកគេគ្រប់គ្រង។ ជនរងគ្រោះដែលជាកុមារកម្ពុជា ត្រូវបានគេឃើញលក់ផ្កានៅកោះសាមុយបានអះអាងថា ប្រសិនបើនាងមិនអាចលក់ផ្កាអស់ទេនោះ អ្នកគ្រប់គ្រងនឹងបង្ខំឲ្យនាងស៊ីផ្កាដែលនៅសល់នោះ ដើម្បីជាការដាក់ទណ្ឌកម្មនាង និងជាការប្រដៅមេរៀនដល់នាង។[៩១]

អង្គការ NGOs បានរាយការណ៍អំពីភាពលំបាកក្នុងការអន្តរាគមន៍ ជាពិសេសនៅពេលព្យាយាមរាយការណ៍អំពើមេខ្យល់ និងអ្នកគ្រប់គ្រងប្រាប់អាជ្ញាធរ។ មានការរាយការណ៍មកទៀតថា ក្រុមជួញដូរអាចរួមមានទាំងមន្ត្រីកម្ពុជា ឬសមាជិកគ្រួសាររបស់ពួកគេផង ដែរ។ បុគ្គលិកផ្នែកសង្គមកិច្ចមួយរូបបានពន្យល់ថា មូលហេតុដែលចាប់មេខ្យល់មិនបានមករហូតនោះគឺថា *“ពីព្រោះពួកគេភាគច្រើនគឺជាមន្ត្រីនគរបាល ឬជាប្រពន្ធរបស់ នគរបាល ដូច្នេះហើយពួកគេមានអ្នកចាំការពារជានិច្ច។”*[៩២]

## កុមារកម្ពុជានៅប្រទេសថៃ

ជនរងគ្រោះពីការជួញដូរកម្ពុជា ភាគច្រើនគេឃើញដើរសុំទាននៅតាមតំបន់នានាដូចជា ប៉ាត់តាយ៉ា កោះសាមុយ បាងកក រ៉ាក់ណង និងភូកេត ជាដើម។[៩៣] នគរបាលភូមិន្ទថៃបានរាយការណ៍មកថា គេតែងតែឃើញកុមារកម្ពុជាដើរសុំទាននៅប៉ាត់តាយ៉ា រ៉ាក់យ៉ង និងបាងកក ជាពិសេសក្រោយពេលចប់រដូវប្រមូលផល ដើម្បីរកលុយបន្ថែមទៀត។[៩៤]

កុមារមួយចំនួន ត្រូវបានគេជួញដូរយកទៅតែម្នាក់ឯងពីប្រទេសកម្ពុជា កុមារដទៃទៀតគឺ ជាកុមារមកពីគ្រួសារចំណាកស្រុកដែលធ្វើការនៅប្រទេសថៃ។ កុមារទាំងនេះក៏ស្ថិតក្នុង ហានិភ័យដែលមានបណ្តាញអ្នកជួញដូរក្នុងស្រុកមកទទួលផងដែរ។ ឧទាហរណ៍ នៅ ប៉ាត់តាយ៉ា មានសហគមន៍ពលករកម្ពុជាចំណាកស្រុកទាំងស្របច្បាប់ និងខុសច្បាប់ជា ច្រើនកន្លែង។ ដោយសារភ័យខ្លាចគេនិរទេសមកវិញ កុមារទាំងនោះពុំចូលរៀនឡើយ។ ជាលទ្ធផល គេតែងតែឃើញពួកគេនៅត្រៃត្រតតាមការដ្ឋានសំណង់ និងដើរម្នាក់ឯង តាមចិញ្ចើមថ្នល់។ ជួនកាលកុមារទាំងនេះ ត្រូវបានមកទទួលដោយបណ្តាញអ្នកសុំទាន នៅតាមបណ្តោយផ្លូវឆ្នេរសមុទ្រ ( Beach Road ) និងផ្លូវដើរ ( Walking Street ) ដែលជា ទីតាំងល្បីល្បាញខាងពេស្យាចារ និងទេសចរណ៍ផ្លូវភេទនៅប៉ាត់តាយ៉ា។ ប្រសិនបើកុមារបាត់ខ្លួន ក្រមានឪពុកម្តាយណាមករកជំនួយពីនគរបាលដើម្បីជួយតាមរកពួកគេណាស់ ដោយសារពួកគេខ្លាចការផាកពិន័យ និងនិរទេសចេញ។[៩៥]

នៅក្នុងករណីមួយចំនួន ឪពុកម្តាយចំណាកស្រុកខុសច្បាប់មួយចំនួន គឺជាអ្នកជួញដូរកូនខ្លួនឯង។ នៅប៉ាត់តាយ៉ា នៅជុំវិញសហគមន៍ជនចំណាកស្រុកកម្ពុជា គេអាចឃើញ មានឪពុកម្តាយផ្សព្វផ្សាយលក់កូនស្រីឲ្យបម្រើសេវាផ្លូវភេទ ដែលជាវិធីមួយសម្រាប់ ឪពុកម្តាយដែលធ្វើការនៅក្នុងការដ្ឋានសំណង់ ដើម្បីរកប្រាក់ចំណូលបន្ថែមពីកូនដែលធំ ពេលដែលមិនត្រូវសុំទាននៅតាមចិញ្ចើមផ្លូវទេ។[៩៦]

ភាគច្រើននៃកុមារដែលគេឃើញសុំទាននៅប្រទេសថៃគឺជាកុមារកម្ពុជា។[៩៧] មូលនិធិកញ្ចក់សង្គម ( Mirror Foundation ) ដែលធ្វើការដើម្បីលុបបំបាត់កុមារអនាថា និងសុំទាននៅប្រទេសថៃអះអាងថា ៩០% នៃកុមារសុំទានដែលពួកគេធ្វើការជាមួយ សុទ្ធតែមកពីប្រទេសកម្ពុជា ហើយកុមារកម្ពុជាជាង ១,០០០ នាក់ កំពុងដើរសុំទាននៅប្រទេសថៃជារៀងរាល់ថ្ងៃ។[៩៨]

នៅប្រទេសថៃ ការសុំទានត្រូវបានគេមើលឃើញថាជាបញ្ហាភាពក្រីក្រ ហើយធ្វើឲ្យមានការអាណិតអាសូរពីជនជាតិថៃ និងភ្ញៀវទេសចរណ៍ ដែលមានអារម្មណ៍ថាត្រូវផ្តល់លុយឲ្យអ្នកសុំទានទាំងនោះ ជាពិសេសកុមារ។ ផ្នត់គំនិតអាណិតអាសូរនេះជំរុញកម្លាំងដល់ឧស្សាហកម្មកុមារសុំទាន និងបង្កើននូវត្រូវការរកកុមារ ដែលបណ្តាលឲ្យមេខ្យល់ជ្រើស រើសក្មេងៗកាន់តែច្រើនថែមទៀតពីកម្ពុជា។ យោងតាមការបោះឆ្នោតស្ទង់មតិអំពីកុមារសុំទានដែលធ្វើឡើងដោយ MSDHS បានឲ្យដឹងថា ៦៥% នៃប្រជាជនថៃដែលគេបានសម្ភាសន៍បាននិយាយថា ពួកគេមានអារម្មណ៍អាណិតអាសូរ នៅពេលពួកគេឃើញកុមារសុំទាន ហើយឲ្យលុយពួកគេខ្លះ។[៩៩] ការនេះជួយព្រងឹងដល់ឥរិយាបថពុទ្ធសាសនិកជន និងវប្បធម៌ក្នុងតំបន់ នៅពេលការគាំទ្រដល់កុមារទាំងនេះគឺជារូបភាពនៃការធ្វើបុណ្យទាន។

កុមារតូចៗមានហានិភ័យ ជាពិសេសត្រូវបានជួញដូរឲ្យទៅសុំទាននៅប្រទេសថៃ។ តែតែតឲ្យ ផ្កាពួកគេដើរលក់ឲ្យភ្ញៀវទេសចរណ៍នៅតាមផ្សារ ឬនៅក្នុងបារភ្លើងពណ៌ក្រហមនៅក្នុងស្រុក។ នៅពេលពួកគេកាន់តែធំជាងនេះ ពួកគេអាចត្រូវបានបង្ខំឲ្យគ្រប់គ្រងក្មេងតូចៗជាងពួកគេ ឬ ផ្លាស់ទីទៅកាន់ការងារដែលកាន់តែខ្លាំងជាងនេះ។[១០០]



“ខ្ញុំមានកូន ៨ នាក់ ដែលពួកគេគពីរនាក់កំពុងធ្វើការនៅថៃ
ខ្ញុំមិនដឹងថានៅកន្លែងណាទេ។ ខ្ញុំដឹងថាពួកគេនឹងត្រឡប់មកវិញ។
ខ្ញុំចង់បញ្ជូនកូនម្នាក់ទៀតដែរ ប៉ុន្តែប្តីខ្ញុំចង់ឲ្យខ្ញុំទុកកូននេះ
ជាជាងការលក់សាច់ឈាមរបស់គាត់។”

ម្តាយម្នាក់ នៅប៉ោយប៉ែត

នៅពេលពេទ្យក្រុងសៀមរាបនិងមួយចំនួនទៀត ពួកគេ តែងតែត្រូវបានផ្ដល់ឱ្យចូលទៅក្នុងឧស្សាហកម្មផ្លូវភេទ។ នៅប៉ាត់តាយ៉ា គេតែងតែ ជួលពួកគេឱ្យធ្វើការនៅតាមហាងម៉ាស្សា ដែលជាធម្មតាគឺជាជួរមុខស្រមាប់ផ្ទះបន។[១០១]

និន្នាការមួយផ្សេងទៀតគឺ ការប្រើប្រាស់សម្លៀកបំពាក់សិស្សសាលាថៃ ដើម្បីបោកបញ្ឆោតអ្នកឆ្លងកាត់ឱ្យបរិច្ចាគលុយស្រមាប់គេម្រោងសាលារៀន។ សិស្សសាលាជាច្រើនអង្គុយធុងសុំឱ្យគេបរិច្ចាគវិភាគទានស្រមាប់សាលារៀននៅបាងកក តាមពិតទៅជាក្មេងជំទង់កម្ពុជា ពុំត្រូវបានចាត់ទុកថា "គួរឱ្យស្រឡាញ់" គ្រប់គ្រាន់ស្រមាប់ដើរសុំទានទេ។ ពួកគេស្លៀកពាក់ឯកសណ្ឋានសិស្សសាលាថៃ ពួកគេអាចគេចចេញពីការចាប់អារម្មណ៍របស់នគរបាលភូមិន្ទៃថៃ ហើយតែងតែទៅឆ្ងាយដោយដើរសុំទាននៅតាមបណ្ដាទីក្រុងធំៗ ដែលអាចមានទាំងនៅខាងមុខហាងធំៗ និងនៅមុខប៉ុស្ដិ៍នគរបាលថៃមទៀតផង។[១០២]

កុមារដើរសុំទានជាសាធារណៈបំផុត ខណៈដែលត្រូវបានចាត់ទុកថាគួរឱ្យរំខាននោះ ពុំ មែនជាបញ្ហាដែលពាក់ព័ន្ធនឹងការជួញដូរទេ ដែលមានន័យថា ជនរងគ្រោះពុំត្រូវបានគេដឹងពីអត្តសញ្ញាណឡើយ។ ជារៀងរាល់ឆ្នាំ ជនចំណាកស្រុកខុសច្បាប់ជាង ១០,០០០ នាក់ ដែលគេឃើញដើរសុំទានត្រូវបានគេរាយការណ៍មកថាត្រូវបាននាំទៅកាន់មណ្ឌលជនគ្មានទីជម្រកនន្ទបុរី។ មជ្ឈមណ្ឌលនេះ ពុំមែនស្រមាប់ការជួញដូរជនរងគ្រោះដែលរងការលើកបំពានទេ ប៉ុន្តែស្រមាប់អ្នកដែលបំពានទៅលើច្បាប់ស្ដីពីការគ្រប់គ្រងការសុំទានឆ្នាំ ១៩៤១ (ថ្មីៗនេះជំនួសដោយច្បាប់ស្ដីពីការគ្រប់គ្រងអ្នកសុំទានឆ្នាំ ២០១៦)។ បុរស ស្ត្រី និងកុមារទាំងនេះ ទីបំផុតត្រូវបាននិរទេសជាជនចំណាកស្រុកខុសច្បាប់។ ពួកគេមិនដែលត្រូវបានកំណត់អត្តសញ្ញាណ ឬកត់ត្រាថាជាជនរងគ្រោះពីការជួញដូរមនុស្សទេ។[១០៣]

## ការធ្វើមាតុភូមិនិវត្តន៍ជនរងគ្រោះកម្ពុជា

ក្រសួងការងារ សង្គមកិច្ច បណ្ដុះបណ្ដាលវិជ្ជាជីវៈ និងយុវនីតិសម្បទា អះអាងថាបាន បង្កើតនូវយន្តការធ្វើមាតុភូមិនិវត្តន៍ប្រកបដោយចីរភាពមួយ ដែលផ្ដល់ជូននូវសេវាបញ្ជូន និងសមាហរណកម្មប្រកបដោយសុវត្ថិភាពដល់ជនរងគ្រោះកុមារ។ ប្រព័ន្ធនេះធានាថា កុមារដែលត្រូវបានកំណត់អត្តសញ្ញាណថាជាជនរងគ្រោះពីការជួញដូរ ត្រូវបានធ្វើមាតុភូមិនិវត្តន៍តាមច្រកឆ្លងកាត់ព្រំដែនស្របច្បាប់ តាមរយៈមជ្ឈមណ្ឌលសំចតរបស់រដ្ឋនៅប៉ោយប៉ែត (PTC)។

នៅពេលដំណើរការដោយ PTC កុមារនឹងត្រូវបានបញ្ជូនត្រឡប់មកស្រុកកំណើតវិញ ដោយផ្ដល់ជូននូវការវាយតម្លៃលើគ្រួសារថា មានសុវត្ថិភាពក្នុងការបញ្ជូនមកវិញ។ ម៉្យាងវិញទៀត ពួកគេនឹងត្រូវបានផ្ទេរឆ្ពោះទៅកាន់ទីជម្រកផ្សេងៗទៀត ដើម្បីចាប់ផ្ដើមការស្ដារនីតិសម្បទា និងសមាហរណកម្មជាបន្តបន្ទាប់ចូលទៅក្នុងសង្គមវិញ។ ដំណើរការ នេះទាមទារឱ្យមានកិច្ចសហប្រតិបត្តិការរវាងរដ្ឋាភិបាលថៃ និងកម្ពុជា ហើយវាមានគូសបញ្ជាក់នៅក្នុង MoU ស្ដីពីការបង្កើតមជ្ឈមណ្ឌលសំចត និងទទួលស្រមាប់ជនរងគ្រោះពីការជួញដូរ និងក្រុមងាយរងគ្រោះផ្សេងៗ ដែលមានចុះហត្ថលេខាដោយប្រទេសទាំងពីរនៅឆ្នាំ ២០១៦។[១០៤]
កុមារដែលមិនត្រូវបានកំណត់អត្តសញ្ញាណថាជាជនរងគ្រោះពីការជួញដូរ ជាញឹកញាប់ ត្រូវបាននិរទេសជាជនចំណាកស្រុកខុសច្បាប់។ ពួកគេត្រូវបាននគរបាលយកមកប្រគល់ដោយផ្ទាល់នៅព្រំដែនកម្ពុជា ដោយពុំមាននរណាម្នាក់មកចាំទទួល ឬផ្ដល់ការឧបត្ថម្ភគាំទ្រដល់ពួកគេឡើយ។ មេខ្យល់រង់ចាំឱ្យកុមារឆ្លងព្រំដែនមកសិនមុននឹងជួញដូរពួកគេម្ដងទៀត។ ភាគច្រើននៃកុមារដែលត្រូវបាននិរទេសចេញជាជនចំណាកស្រុក ខុសច្បាប់ដោយពុំមានការសើបអង្កេតតឹមត្រូវណាមួយ តាមពិតទៅគឺជាជនរងគ្រោះពីការជួញដូរ ហើយប្រព័ន្ធអនុញ្ញាតឱ្យពួកគេត្រូវបានប្រគល់ជូនមេខ្យល់វិញដោយផ្ទាល់ ដែលជាអ្នកជួញដូរពួកគេតាំងពីដើមមក។[១០៥]

កុមារជាច្រើនដែលត្រូវបានមេខ្យល់ជួលពីឪពុកម្ដាយរបស់ពួកគេ ត្រឡប់មកវិញតាមច្រកព្រំដែនខុសច្បាប់តែមួយ ដូចគ្នានឹងច្រកដែលពួកគេបានប្រើប្រាស់ក្នុងការចូលទៅប្រទេសថៃ ដោយពុំមានឱកាសទទួលបានការស្ដារនីតិសម្បទា ការឧបត្ថម្ភគាំទ្រក្នុងការស្ដារសេដ្ឋកិច្ចឡើងវិញ ឬសមាហរណកម្មឡើយ។ ការនេះក៏បង្កើតបាននូវគម្លាតដ៏ធំនៅក្នុងទិន្នន័យដែលអាចរកបានអំពីករណីជួញដូរមនុស្ស។ ប្រសិនបើកុមារដែលត្រូវ បានជួញដូរពុំធ្លាប់ត្រូវបានគេកំណត់អត្តសញ្ញាណ ចុះបញ្ជី និងធ្វើមាតុភូមិនិវត្តន៍ជាផ្លូវការតាមរយៈ PTC ទេនោះ ការជួញដូរពួកគេពុំមានកត់សម្គាល់នៅក្នុងប្រព័ន្ធទេ ដែលធ្វើ ឱ្យវិសាលភាពនៃស្ថានភាពជួញដូរកុមារនៅកម្ពុជាមិនអាចកំណត់បរិមាណបាន។

## កិច្ចការពារ និងទប់ស្កាត់ស្រមាប់កុមារកម្ពុជា

ច្បាប់ជាតិកម្ពុជាស្ដីពីការជួញដូរមនុស្សគឺ ច្បាប់ស្ដីពីការបង្ក្រាបការជួញដូរមនុស្ស និងការកេងប្រវ័ញ្ចផ្លូវភេទ ត្រូវបានឆ្លងដោយរដ្ឋសភាជាតិនៅឆ្នាំ ២០០៧។ ច្បាប់នេះពុំគោរព តាមនិយមន័យជាសាកលស្ដីពីការជួញដូរមនុស្ស ដែលមាននៅក្នុងពិធីសារ Palermo ឡើយ ហើយខ្វះបទបញ្ញត្តិដែលបានផ្ដល់ជាអនុសាសន៍ស្រមាប់ការពារជន រងគ្រោះ។ នៅឆ្នាំ ២០១០ កម្ពុជាបានបង្កើតនូវក្រមព្រហ្មទណ្ឌថ្មីមួយ ដែលមិនបាននិយាយជាពិសេសអំពីការជួញដូរមនុស្សឡើយ ប៉ុន្តែបង្កើតនូវបទបញ្ញត្តិទាំងឡាយស្រមាប់ផ្ដន្ទាទោស 'ការយកអនីតិជនចេញដោយខុសច្បាប់' ដែលអាចត្រូវបានអនុវត្តទៅលើ ទិដ្ឋភាពនៃការជួញដូរមនុស្សមួយចំនួន។[១០៦]

> *ជាញឹកញាប់ យើងបានរង់ចាំកុមារនៅព្រំដែននៅប៉ោយប៉ែត ពីព្រោះជួនកាលកុមារត្រូវគេយកមកទម្លាក់នៅការិយាល័យអន្តោប្រវេសន៍ ជំនួសឱ្យនៅ PTC។ ពួកគេមិនទៅមើលថែកុមារទាល់តែសោះ។ នៅក្នុងការិយាល័យអន្តោប្រវេសន៍ មានអ្នកជួញដូរនៅរង់ចាំទទួលកុមារនោះម្ដងទៀត។ យើងបញ្ជូនលិខិតស្នាម និងរូបថតរបស់កុមារទៅកាន់ PTC ដើម្បីឱ្យបុគ្គលិកមណ្ឌលអាចទទួលកុមារជាផ្លូវការ។ ទោះបីជាបែបនេះក៏ដោយ អ្នកជួញដូរនឹងនៅទីនោះដែរ ដើម្បីទទួលកុមារមុនពេលបុគ្គលិករបស់ PTC មកដល់។*
>
> **បុគ្គលិកអង្គការ NGO នៅប៉ោយប៉ែត**

កង្វះផ្នែកច្បាប់នៅកម្ពុជាមានន័យថា ការទទួលខុសត្រូវក្នុងការកំណត់អត្តសញ្ញាណជនរងគ្រោះពីការជួញដូរ តែងតែធ្លាក់ទៅលើរដ្ឋាភិបាលថៃ ក្នុងការធ្វើសេចក្ដីសម្រេចក្រោមច្បាប់របស់ខ្លួន។ យោងតាមច្បាប់ប្រឆាំងការជួញដូរមនុស្សឆ្នាំ ២០០៨ របស់ថៃ MSDHS ត្រូវការពារជនរងគ្រោះគ្រប់ជាតិសាសន៍នៅទីជម្រករបស់ពួកគេ រហូតទាល់តែមានការចាត់វិធានការចាំបាច់ស្រមាប់ការធ្វើមាតុភូមិនិវត្តន៍ជាផ្លូវការ។

ប្រសិនបើកុមារពុំត្រូវបានកំណត់អត្តសញ្ញាណថា ជាជនរងគ្រោះពីការជួញដូរទេនោះ ពួកគេពុំត្រូវបានកត់ត្រានៅក្នុងប្រព័ន្ធមូលដ្ឋានទិន្នន័យណាមួយឡើយ ហើយអត្ថប្រយោជន៍ល្អបំផុតរបស់ពួកគេក៏ពុំត្រូវបានកំណត់ ឬពិចារណាដែរ។ នៅពេលដែលត្រូវបាននិរទេស ការគាំទ្រ សុខុមាលភាព និងការស្ដារនីតិសម្បទាដល់ជនរងគ្រោះ ជាបន្ទុករបស់អង្គការ NGOs ដែលមានបទដ្ឋានវិជ្ជាជីវៈខុសប្លែកគ្នាច្រើនបំផុត។[១០៧]

អង្គការ NGOs ជាច្រើនធ្វើការជាសម្ព័ន្ធ ដើម្បីការពារកុមារ និងកូនៗរបស់ឪពុកម្ដាយចំណាកស្រុកពីការជួញដូរ។ អង្គការ XP Missions ធ្វើការដើម្បីជួយឧបត្ថម្ភគាំទ្រដល់ នគរបាលក្នុងការកំណត់អត្តសញ្ញាណកុមារ ដែលអាចត្រូវបានជួញដូរចូលទៅកាន់ ប្រទេសថៃ ឬអ្នកដែលមានហានិភ័យពីការត្រូវបានជួញដូរនៅពេលអនាគត។ អង្គការ នេះធ្វើការយ៉ាងជិតស្និទ្ធជាមួយមជ្ឈមណ្ឌលមេត្តាករុណានៅប៉ាត់តាយ៉ា ដែលជួយនៅ ក្នុងដំណើរការរៀបចំឯកសារដើម្បីធានានូវការធ្វើមាតុភូមិនិវត្តន៍ដោយសុវត្ថិភាព។ នៅទីក្រុងបាងកក មូលនិធិកញ្ចក់សង្គម (Mirror Foundation) មានឯកទេសនៅក្នុងសំណុំរឿងក្ដីកុមារសុំទាន និងផ្ដោតការយកចិត្តទុកដាក់លើភាពងាយរងគ្រោះរបស់កុមារកម្ពុជា។

នៅពេលកុមារធ្វើមាតុភូមិនិវត្តន៍ត្រឡប់ទៅកាន់ប្រទេសកម្ពុជាវិញ តាមរយៈមជ្ឈមណ្ឌលសំចតប៉ោយប៉ែត (PTC) មានទីជម្រកជាច្រើនស្រមាប់កុមារដែលពុំមានលទ្ធភាពអាច វិលត្រឡប់ទៅកាន់ក្រុមគ្រួសារពួកគេវិញ។ PTC មាននៅផែនការបើកដំណើរការទីជម្រក ផ្ទាល់របស់ខ្លួនដើម្បីចៀសវាងការប្ដូរកន្លែងជនរងគ្រោះកុមារឥតឈប់ឈរ។ NGOs មានវត្តមានយ៉ាងខ្លាំងនៅប៉ោយប៉ែត ហើយអង្គការជាច្រើនជួលបុគ្គលិកផ្នែកសង្គមកិច្ចនៅតំបន់នោះ ដើម្បីពិនិត្យតាមដានសហគមន៍នៅតាមបណ្ដោយព្រំដែន និងវាយតម្លៃហានិភ័យនៃការជួញដូរកុមារ។

ប៉ោយប៉ែត ដែលជាតំបន់ប្រភពចម្បងស្រមាប់កុមារកម្ពុជាដែលត្រូវបានជួញដូរចូលទៅកាន់ប្រទេសថៃ ត្រូវការការគាំទ្របន្ថែមលើការប្រឆាំងនឹងការជួញដូរមនុស្ស ជាពិសេសគឺផ្នែកកិច្ចការពារ។ ខណៈដែលមានទីជម្រក និងសាលារៀននៅក្នុងភូមិជុំវិញនោះ វាហាក់ ដូចជាមានការងារទប់ស្កាត់ដែលមានប្រសិទ្ធភាពតិចតួច ដូចជា អង្គភាពចល័តប្រឆាំងការជួញដូរ ដែលប្រតិបត្តិការនៅក្នុងតំបន់មួយចំនួនរបស់ថៃ។ អង្គភាពស្រដៀងគ្នាដែលប្រតិបត្តិការនៅតាមទីប្រជុំជន និងភូមិនានានៅតាមព្រំដែនខ្មែរ អាចមានប្រសិទ្ធភាព បំផុតនៅក្នុងការលើកកម្ពស់ការយល់ដឹង និងការពារកុមារពីការជួញដូរ។[១០៨]

## ឧបសគ្គនៅក្នុងការប្រយុទ្ធប្រឆាំងនឹងការជួញដូរកុមារកម្ពុជា

ត្រម្រូវការកុមារសុំទាននៅប្រទេសថៃ នៅតែមានជាប់ជានិច្ច ដោយសារតែអាជីវកម្មនេះ នៅតែមានស្ថេរភាព។ ការផ្ដល់ការអាណិតអាសូរពីជនជាតិថៃ និងភ្ញៀវទេសចរណ៍បរទេសធ្វើឲ្យ "ក្រុមម៉ាហ្វីយ៉ាសុំទាន" រីកចម្រើននៅក្នុងគោលដៅទេសចរណ៍ធំៗ។ កិច្ច ខិតខំប្រឹងប្រែងមិនស៊ីសង្វាក់គ្នារបស់អាជ្ញាធរ បានធ្វើឲ្យមេខ្យល់អាចធ្វើឲ្យតិចនិចរបស់ពួកគេកាន់តែប្រសើរឡើង ដោយដំឡើងកន្លែងជាច្រើន ដែលយើងមើលឃើញថាជាប្រព័ន្ធវិលជុំសម្រាប់កុមារ។ កន្លងមក កុមារសុំទាននៅតែមួយកន្លែងពេញមួយថ្ងៃ។ បច្ចុប្បន្ននេះ ដើម្បីចៀសវាងការតាមចាប់ពីនគរបាល កុមារត្រូវបានគេផ្លាស់ប្ដូរកន្លែងវិល ជុំតលបយឈរពីកន្លែងមួយទៅកន្លែងមួយទៀតពេញមួយថ្ងៃ។[១០៩]

ការកំណត់អត្តសញ្ញាណជនរងគ្រោះគឺជារឿងដែលពិបាកក្រៃលែង។ ការរកភស្តុតាងដែលបង្ហាញពីការកេងប្រវ័ញ្ច គឺជាផ្នែកដ៏លំបាកជាងគេបំផុតនៅក្នុងការស៊ើបអង្កេតករណីជួញដូរជាសក្ដានុពល។ ដោយសារតែកុមារកម្ពុជាតែងតែត្រូវបានគេលក់ដូរជួល ឬឃើញដើរសុំទានជាមួយឪពុកម្ដាយរបស់ពួកគេជាញឹកញាប់នោះ ជានិច្ចកាល នគរបាលពុំអាចចាប់បានភស្តុតាងដែលបង្ហាញថា កុមារនោះត្រូវបានគេកេងប្រវ័ញ្ចបាន ឡើយ ដូច្នេះគេគ្រាន់តែស្គាល់ពួកគេថាជាជនចំណាកស្រុកខុសច្បាប់ ជាជាងកុមារដែលត្រូវបានគេជួញដូរ ហើយត្រូវបាននិរទេសចេញដោយពុំមានឋានៈជាជនរងគ្រោះ។

ប្រសិនបើកុមារណាម្នាក់កំពុងដើរសុំទានជាមួយមនុស្សពេញវ័យ នគរបាលមិនអាចដឹង បានឡើយថាតើមនុស្សពេញវ័យនោះគឺជាឪពុក ឬម្ដាយរបស់កុមារនោះ ឬថាតើកុមារនោះគឺជាជនរងគ្រោះដែរឬទេ។ ការពិនិត្យតាម DNA គឺជាវិធីតែមួយគត់ដើម្បីបង្ហាញជាចុងក្រោយឲ្យដឹងពីភាពជាឪពុកម្ដាយ។ ការពិនិត្យតាមវិធីនេះត្រូវចំណាយអស់លុយ ច្រើន ដូច្នេះនគរបាលតែងតែជំនួសការពិនិត្យនេះដោយធ្វើការវាយតម្លៃដោយផ្អែកទៅលើរូបរាងខាងក្រៅ។ ដោយមិនអាចចៀសផុត វិធីសាស្ត្រនេះបណ្ដាលឲ្យមានការកំណត់អត្តសញ្ញាណខុសអំពីជនរងគ្រោះសក្ដានុពល ហើយជាលទ្ធផលមានករណីជាច្រើនពុំត្រូវបានស៊ើបអង្កេត។[១១០]

អត្រាដ៏ខ្ពស់នៃការជួញដូរម្ដងទៀត ធ្វើឲ្យមានវដ្ដនៃការជួញដូរ និងកេងប្រវ័ញ្ចកុមារយ៉ាងពុករលួយ។ ដូច្នេះហើយ នៅទីបំផុតកុមារជាច្រើនដែលត្រូវបានជួញដូរបានក្លាយទៅជាមេខ្យល់ដោយខ្លួនឯង ពីព្រោះនេះគឺជាការរកស៊ីតែម្យ៉ាងគត់ដែលពួកគេចេះ។ យោងតាមបុគ្គលិកកាន់សំណុំរឿងនៅប៉ោយប៉ែត "*កុមារទាំងនេះពុំបានមើលឃើញថាពួកគេកំពុងត្រូវបានគេកេងប្រវ័ញ្ចទេ ពីព្រោះទាំងអស់នេះគឺជាអ្វីដែលពួកគេធ្លាប់បានដឹង។ ពួកគេនឹងបន្តវដ្ដនេះ នៅពេលពួកគេមានអាយុច្រើនជាងនេះ ហើយក៏គ្មានដំណោះស្រាយដែរ។*"[១១១]
កង្វះខាតមូលដ្ឋានទិន្នន័យកណ្ដាល ធ្វើឲ្យមានការលំបាកក្នុងការកំណត់អត្តសញ្ញាណកុមារដែលធ្លាប់ត្រូវបានគេជួញដូរ។ កម្ពុជាពុំមានប្រព័ន្ធចុះបញ្ជីពលរដ្ឋរឹងមាំដូចថៃទេ ដូច្នេះក្រោយពីនគរបាលសង្គ្រោះកុមារកម្ពុជា ពួកគេត្រូវតែតាមដានកុមារដោយប្រើ ឈ្មោះ ដែលធ្វើឲ្យមានការខាតបង់ពេលវេលា និងធនធានច្រើន។ ដំណើរការនេះ ជាញឹកញាប់បណ្ដាលឲ្យមានកំហុសផ្សេងៗ ដែលនាំទៅរកការជួញដូរកុមារម្ដងទៀត។

មេខ្យល់ប្រាប់កុមារឲ្យប្ដូរឈ្មោះពួកគេ រាល់ពេលពួកគេឆ្លងដែនចូលទៅកាន់ប្រទេសថៃ និងត្រឡប់មកកាន់ប្រទេសកម្ពុជាម្ដងៗតាមរយៈ PTC។ ការធ្វើបែបនេះគឺដើម្បីចៀសវាងការតាមចាប់ខ្លួន និងរារាំងកិច្ចខិតខំប្រឹងប្រែងក្នុងការកត់ត្រា និងតាមដានករណីជួញដូរមនុស្ស។[១១២]
អារម្មណ៍លាយឡំនឹងភាពក្រីក្រ និងភាពអស់សង្ឃឹមរបស់សហគមន៍ទាំងឡាយនៅកម្ពុជា គឺជាឧបសគ្គធំបំផុតដែលរារាំងដល់ការប្រយុទ្ធប្រឆាំងនឹងការជួញដូរមនុស្សទៅកាន់ប្រទេសថៃ។ កង្វះឱកាស និងការងារនៅកម្ពុជាមានន័យថាសូម្បីតែកុមារដែលពុំត្រូវបានជួញដូរនៅវ័យក្មេង និងមានឱកាសបានចូលរៀនក៏ដោយ ក៏មានឱកាសតិចតួច បំផុតក្នុងការទទួលបានការងារដែលមានប្រាក់ឈ្នួល។ ការធ្វើការនៅប្រទេសថៃ

> *កុមារទាំងនេះពុំបានមើលឃើញថាពួកគេកំពុងត្រូវបានគេកេងប្រវ័ញ្ចទេ ពីព្រោះទាំងអស់នេះគឺជាអ្វីដែលពួកគេធ្លាប់បានដឹង។ ពួកគេនឹងបន្តវដ្ដនេះ នៅពេលពួកគេមានអាយុច្រើនជាងនេះ ហើយក៏គ្មានដំណោះស្រាយដែរ។*
>
> **មន្ត្រីអង្គការ NGO នៅប៉ោយប៉ែត**

ទោះបីជាត្រូវគេជួញដូរក៏ដោយ ត្រូវបានគេមើលឃើញថាជាចំណង់ចំណូលចិត្តរបស់ពួកគេ។ ប្រព័ន្ធនេះមានន័យថា ការអប់រំមានតែម្លតិចតួច ឬគ្មានទាល់តែសោះនៅក្នុងផ្នែកមួយនេះរបស់កម្ពុជា ហើយនេះគឺជាបញ្ហាដ៏ធំសម្រាប់កុមារតូចៗ ដែលបង្កើន ហានិភ័យសម្រាប់ពួកគេដោយសារការជួញដូរទៅកាន់ការងារខុសច្បាប់។

ខណៈដែលតម្រូវការកុមារនៅប្រទេសថៃមានកម្រិតខ្ពស់ខ្លាំង ភាពងាយស្រួល និងឆន្ទៈនៃសង្វាក់ផ្គត់ផ្គង់នៅកម្ពុជា ធ្វើឲ្យកុមារកម្ពុជាក្លាយទៅជាក្រុមមួយដែលងាយរងគ្រោះបំផុតពីការស្វែងរកប្រភពជនរងគ្រោះ។

> *កុមារត្រូវបានបង្ខំឲ្យចេះផ្លាស់ប្ដូរឈ្មោះរបស់ខ្លួនជានិច្ច ហើយដោយគ្មានមូលដ្ឋានទិន្នន័យកណ្ដាល ប្រវត្តិរូបរបស់ពួកគេត្រូវបានកត់ត្រាតែនៅក្នុងអង្គការនីមួយៗនៅក្នុងខេត្តនីមួយៗប៉ុណ្ណោះ។ ដូច្នេះ ប្រសិនបើអ្នករកឃើញកុមារនៅក្នុងខេត្តមួយផ្សេងទៀត អ្នកពុំដឹងថាតើកុមារនោះធ្លាប់ត្រូវបានគេជួញដូរពីមុនមកដែរឬទេ។*
>
> **បុគ្គលិកកាន់សំណុំរឿង នៅបាងកក**

## ការជួញដូរកុមារកម្ពុជាទៅម៉ាឡេស៊ីតាមប្រទេសថៃ

ដូចគ្នានឹងប្រទេសថៃដែរ ប្រទេសម៉ាឡេស៊ីមានសេដ្ឋកិច្ចដ៏មានសន្ទុះ និងត្រូវការកម្លាំងពលកម្មដែលមានតម្លៃថោក។ ទោះបីជាម៉ាឡេស៊ីពុំមានព្រំដែនជាប់ជាមួយកម្ពុជាក៏ ដោយ ជនចំណាកស្រុកបានរកឃើញវិធីទៅធ្វើការនៅក្នុងប្រទេសនេះទាំងដោយស្រប ច្បាប់ និងដោយខុសច្បាប់។

នៅឆ្នាំ ២០០៨ គម្រោងអន្តរភ្នាក់ងារ នៃអង្គការសហប្រជាជាតិ លើការជួញដូរមនុស្ស (UNIAP) បានរាយការណ៍មកថា ជនរងគ្រោះកម្ពុជាចំនួន ២៨ នាក់ ត្រូវបានធ្វើមាតុភូមិនិវត្តន៍មកពីប្រទេសម៉ាឡេស៊ី។ របាយការណ៍ជាបន្តបន្ទាប់មកពីក្រសួងការបរទេសសហរដ្ឋអាមេរិកយល់ស្របគ្នាថា ប្រទេសថៃបានបម្រើជាចំណុចសំចតសម្រាប់ជួញដូរជនជាតិខ្មែរទៅកាន់ប្រទេសម៉ាឡេស៊ី អស់រយៈពេលជាច្រើនឆ្នាំកន្លងមកហើយ ដោយមានរបាយការណ៍ផ្លូវការអំពីជនរងគ្រោះកុមារកម្ពុជា ដែលត្រូវបានគេរកឃើញនៅប្រទេស ម៉ាឡេស៊ីកាលពីឆ្នាំ ២០០៥។[១១៣]

បុគ្គលិកសង្គមកិច្ចមួយរូប ដែលធ្វើការនៅតាមព្រំដែនថៃ-កម្ពុជា បានអះអាងថា៖

"*ការជួញដូរកុមារទៅកាន់ប្រទេសម៉ាឡេស៊ី ពុំមែនជារឿងថ្មីឡើយ។ បញ្ហានេះបានកើតឡើងមួយរយៈកាលកន្លងមកហើយ។ ខ្ញុំមិនដឹងថាតើពួកគេទៅកាន់កន្លែងណានៅប្រទេសម៉ាឡេស៊ីទេ។ ប្រហែលជាពួកគេទៅកាន់តំបន់ទេសចរណ៍ហើយមើលទៅ។*"[១១៤]

ជាទូទៅ កុមារកម្ពុជាត្រូវបានគេសន្យាថានឹងជួយរកការងារនៅក្នុងវិស័យផ្ដល់សេវានៅប្រទេសថៃ ប៉ុន្តែក្រោយមកទៀតពួកគេត្រូវបានបង្ខំឲ្យទៅធ្វើការនៅតាមបនពស្សាចារក្នុងប្រទេសម៉ាឡេស៊ី។ [១១៥] ដោយមិនអាចចៀសវាងបាន បណ្ដាញជួញដូរចាប់ផ្ដើមនៅប៉ោយប៉ែត ហើយជាទូទៅត្រូវចំណាយពេលពីរបីថ្ងៃនៅទីក្រុងបាងកក ដើម្បីទទួលបាន ឯកសារសម្រាប់ធ្វើដំណើរចូលទៅក្នុងប្រទេសម៉ាឡេស៊ី។

កុមារកម្ពុជាជាច្រើន ត្រូវបានគេរាយការណ៍មកថា ពួកគេត្រូវបានគេជួញដូរចូលទៅក្នុង ប្រទេសម៉ាឡេស៊ីដោយមានជំនួយពីមេខ្យល់ជនជាតិវៀតណាម។ មេខ្យល់វៀតណាម មានទំនាក់ទំនងទូលំទូលាយនៅប្រទេសថៃ និងម៉ាឡេស៊ី ហើយជាញឹកញាប់ពួកគេរៀបចំឲ្យមានការឈប់សំចត និងគ្រប់គ្រងកុមារកម្ពុជាដែលត្រូវជួញដូរចូលទៅក្នុងប្រទេសម៉ាឡេស៊ី។ នៅឆ្នាំ ២០១៤ មណ្ឌលសំចតប៉ោយប៉ែត (PTC) បានទទួលកុមារអាយុ ១២-១៨ ឆ្នាំ ដែលត្រូវបានធ្វើមាតុភូមិនិវត្តន៍ទៅកាន់ទីជម្រករបស់ពួកគេ រួមទាំងជនរងគ្រោះដែលត្រូវបានធ្វើមាតុភូមិនិវត្តន៍មកពីប្រទេសម៉ាឡេស៊ី និងថៃផងដែរ។[១១៦]



# ជំពូក ៤៖ ការជួញដូរព្រីបេទសមីយ៉ាន់ម៉ា

## សាវតារ

កម្មករចំណាស្រុកភូមា បង្កើតបានជាចំណែកដ៏ធំនៃកម្លាំងពលកម្មថៃ ជាពិសេសនៅក្នុងឧស្សាហកម្មសំណង់ និងនេសាទ។ មានជនចំណាកស្រុកភូមាប្រមាណ ៣ លាននាក់ដែលកំពុងរស់នៅប្រទេសថៃ។១១៧ គេប៉ាន់ស្មានថា ពួកគេបង្កើតបាន ប្រហែល ៩% នៃផលិតផលក្នុងស្រុកសរុប (GDP) របស់ថៃ ប៉ុន្តែតួលេខនេះត្រូវ តែយកមកផ្ទៀងផ្ទាត់ដោយប្រយ័ត្ន ពីព្រោះចំនួននៃកម្មករដែលពុំបានចុះឈ្មោះ គ្រាន់ តែជាការប៉ាន់ស្មានប៉ុណ្ណោះ។ ជនជាតិភូមាកាន់តែច្រើនទំនងជាចូលមកកាន់ ប្រទេសថៃ ដោយមានការបន្ធូរបន្ថយនៅព្រំដែន តាមការស្នើសុំរបស់អាស៊ាន និង ដោយមានប្រាក់ឈ្នួលថ្លៃជាងសម្រាប់កម្មករចំណាកស្រុក។

ការធ្វើចំណាកស្រុករបស់ជនជាតិភូមា ចូលទៅក្នុងប្រទេសថៃ គឺជាការឆ្លើយតបទៅនឹងការធ្លាក់ចុះនៃសេដ្ឋកិច្ចភូមាបានមួយផ្នែក បន្ទាប់ពីមានការគ្រប់គ្រងដោយយោធា និងសង្គ្រាមស៊ីវិលអស់រយៈពេលជាងហាសិបឆ្នាំមក។ ភាពក្រីក្រជាទូទៅដែលបណ្ដាលមកពីជម្លោះ បានបន្សល់នូវការបំផ្លិចបំផ្លាញកសិកម្ម ហេដ្ឋារចនាសម្ព័ន្ធ និងអាជីវកម្មស្របច្បាប់របស់ភូមា។ ភាពក្រីក្រ គឺជាកត្តាលីករដ៏សំខាន់ សម្រាប់ការធ្វើចំណាកស្រុក និងការជួញដូរខុសច្បាប់ទាំងអស់ ព្រោះតែអវត្តមាននៃការអប់រំ។ ក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ រដ្ឋាភិបាលមីយ៉ាន់ម៉ាបានចំណាយរហូតដល់ ៤.៨% នៃ GDP ទៅលើវិស័យការពារជាតិ និងចំណាយត្រឹមតែ 0.៦% ប៉ុណ្ណោះលើវិស័យអប់រំ។[១១៨]
ធនាគារពិភពលោកបានរាយការណ៍មក
ថា នៅឆ្នាំ ២០១២ សិស្សរៀនថ្នាក់ទី ៣ ចំនួន ៩% នៅក្រុងយ៉ាងហ្គូន មិនចេះអានពាក្យណាមួយម៉ាត់សោះ។[១១៩]

ទោះបីជាមានប្រព័ន្ធចុះបញ្ជីឈ្មោះនៅនឹងកន្លែងកើតក៏ដោយ ជនជាតិភូមាជាច្រើនបានចូលទៅកាន់ប្រទេសថៃ ដោយពុំមានការរាប់បញ្ចូលនៅក្នុងប្រព័ន្ធរបស់ថៃឡើយ ជាពិសេសកុមារ។ សហគមន៍ដ៏រឹងមាំ បានចងសម្ព័ន្ធគ្នារវាងជនចំណាកស្រុកភូមានៅទីក្រុង និងខេត្តពីររបស់ថៃដូចជា មេសត រ៉ាក់ណង ភូកេត សាមុតសាខន ចាត់វិធានការតិចតួចក្នុងការកាត់បន្ថយភាពងាយរងគ្រោះនៃកូនៗរបស់ពួកគេ។ តាមការប៉ាន់ស្មាន ប្រជាជនភូមាដែលមិនបានចុះបញ្ជីឈ្មោះនៅថៃចំនួន ៥00,000 នាក់ ហាក់ដូចជាមិនអាចមើលឃើញ ហើយមានហានិភ័យខ្ពស់ពីការជួញដូរ។

ជនចំណាកស្រុកភូមាត្រូវចំណាយលុយ ២,៦៨0 បាត ដើម្បីចុះឈ្មោះធ្វើការងារនៅការិយាល័យចុះបញ្ជីក្នុងស្រុក និងលុយចំនួន ៣,១៨0 បាតបន្ថែមទៀត ប្រសិនបើពួកគេធ្វើការនៅក្នុងឧស្សាហកម្មនេសាទ។ កុមារដែលទៅតាមឪពុកម្ដាយរបស់ពួកគេត្រូវបង់លុយ ២៦៥ បាត សម្រាប់កុមារម្នាក់ដែលមានអាយុក្រោម ៧ ឆ្នាំ និង ១,៦៨0 បាត សម្រាប់កុមារម្នាក់ដែលមានអាយុចាប់ពី ៧ ឆ្នាំឡើងទៅ។

កញ្ចប់ចុះបញ្ជីសម្រាប់កុមាររួមមានដូចជា ប័ណ្ណចុះបញ្ជី ‘ស្ថានភាពជាអ្នកទៅតាមឪពុកម្ដាយ’ ដែលគួរតែការពារពួកគេពីការធ្វើមាតុភូមិនិវត្តន៍ទៅកាន់ប្រទេសមីយ៉ាន់ម៉ា និងកញ្ចប់គាំពារសុខភាពមូលដ្ឋាន។ កុមារចំណាកស្រុកដែលបានចុះបញ្ជីឈ្មោះថាជាជនអន្តោប្រវេសន៍ និងមានអាយុស្របច្បាប់ យោងតាមច្បាប់ការពារពលករឆ្នាំ ២០១០ អាចធ្វើការងារ និងសកម្មភាពងាយៗ រួមមានដូចជាសេវាបម្រើតាមផ្ទះជាដើម។[១២០]

កម្មករភូមាជាច្រើននៅប្រទេសថៃ ចុះឈ្មោះតែខ្លួនពួកគេប៉ុណ្ណោះ ពីព្រោះការចុះឈ្មោះគ្រួសារពួកគេទាំងមូលមានតម្លៃថ្លៃពេក។[១២១] ដូច្នេះហើយទើបបន្សល់នូវកុមាររាប់រយនាក់ពុំត្រូវបានរាប់បញ្ចូលដោយប្រព័ន្ធចុះបញ្ជីរបស់ថៃ ហើយជាចំណីដ៏ងាយស្រួល និងមានសក្ដានុពលសម្រាប់មេខ្យល់ ជាពិសេសដោយសារតែពួកគេខ្វះឯកសារសម្គាល់អត្តសញ្ញាណជាជនជាតិថៃ។

ការជួញដូរពីប្រទេសមីយ៉ាន់ម៉ា កើតឡើងក្នុងបរិបទនៃការធ្វើចំណាកស្រុកទ្រង់ទ្រាយធំ ទាំងក្នុងប្រទេស និងឆ្លងដែនចូលទៅក្នុងប្រទេសថៃ។ របាយការណ៍ជាច្រើនបានផ្ដល់ភស្តុតាងថា ជាងមួយភាគបីនៃប្រជាជនមីយ៉ាន់ម៉ា បានធ្វើ ចំណាកស្រុកមកពីទីជនបទទៅកាន់តំបន់ប្រជុំជន ដែលមានទីក្រុងនានារបស់ថៃជាគោលដៅចម្បងរបស់ពួកគេ។[១២២]

> *កម្មករកម្មការីរោងចក្រភាគច្រើននៅប្រទេសថៃ មកពីតាមភូមិនានានៅមីយ៉ាន់ម៉ា។ កាលពីខែមុន ខ្ញុំបានទៅលេងភូមិព្ធរបស់ខ្ញុំ។ វាជាភូមិធំមួយ ដែលមានទីតាំងនៅតាមមាត់ទន្លេស៊ីតាង (Sittaung)។ មានផ្ទះចំនួន ២០ ខ្នងនៅជុំផ្ទះរបស់ពួខ្ញុំ។ នៅតាមផ្ទះមានសល់តែមនុស្សចាស់ៗ និងក្មេងតូចៗប៉ុណ្ណោះ។ វាហាក់ដូចជាចម្លែក។ ខ្ញុំបានសួរថាតើពួកគេទៅណាអស់ហើយ។ មនុស្សវ័យជំទង់ និងមនុស្សពេញវ័យទាំងអស់ ដែលអាចធ្វើការសុទ្ធតែធ្វើការនៅទីក្រុងបាងកកទាំងអស់ ឬនៅកន្លែងណាមួយផ្សេងទៀតក្នុងប្រទេសថៃ។*
>
> **បុគ្គលិកអង្គការសហគមន៍នៅមេសត**

## ប្រទេសមីយ៉ាន់ម៉ាក្នុងនាមជាប្រទេសប្រភពដើម

កុមារភាគច្រើនដែលត្រូវបានជួញដូរមកពីរដ្ឋការ៉ែន ដែលចូលមកតាមច្រកមីយ៉ាវ៉ាត់ឌី ដែលជាទីក្រុងនៅតាមព្រំដែនមួយ នៅជិតនឹងមេសតនៅភាគខាងថៃ។[១២៣] កុមារភាគច្រើនដែលត្រូវបានជួញដូរមកពីមីយ៉ាន់ម៉ា ប្រើប្រាស់ចកមេសតជាចំណុតសំចត មុនពេលបន្តដំណើរតាមផ្លូវគោកទៅកាន់គោលដៅចុងក្រោយរបស់ពួកគេ គឺនៅតាមបណ្ដា ទីក្រុងធំៗរបស់ថៃ។

នៅក្នុងតំបន់មេសតែតមួយ មានសហគមន៍ជនជាតិភូមាងាយរងគ្រោះជាច្រើន ដែលក៏ អាចនឹងត្រូវបានគេជួញដូរទៅកាន់ទីប្រជុំជនធំៗផងដែរ។ សហគមន៍អ៊ីស្លាមប៊ុមរុង (Islambumrung) ដែលហៅម្យ៉ាងទៀតថា □តំបន់អនាធិបតេយ្យបង់ក្លាដេស□ គឺជា ទីជម្រកសម្រាប់កុមមូស្លីមភូមាជាច្រើននាក់ ដែលពុំត្រូវបានទទួលស្គាល់ដោយរ ដ្ឋាភិបាលថៃ ឬរដ្ឋាភិបាលមីយ៉ាន់ម៉ា ហើយបានតាំងទីលំនៅនៅក្នុងតំបន់ អនាធិបតេយ្យមួយនៅជាយក្រុងនៃតំបន់មេសត។ ប្រជាចនភាគច្រើននៅក្នុង សហគមន៍នេះ មកពីតំបន់ប៊ុតធីឌួង (Buthiduang) ដែលមានមួយចំនួនតូចមកពី ស៊ីតវី (Sittwe) និងមួងដាវ (Muangdaw)។[១២៤]

នៅរ៉ាក់ណង កុមាររងគ្រោះពីការជួញដូរជាច្រើននាក់មកពីទីប្រជុំជនមួយឈ្មោះ ម៉ាក់រ៉ង (Marang) នៅតំបន់តានីនថារីយី (Tanintharyi) ដែលស្ថិតនៅចម្ងាយ ៣-៤ គីឡូម៉ែត្រ ពីប៉ុស្តិ៍ត្រួតពិនិត្យព្រំដែនរ៉ាក់ណង។[១២៥]

## ផ្លូវជួញដូរពីចេញពីប្រទេសមីយ៉ាន់ម៉ាទៅកាន់ប្រទេសថៃ

ការិយាល័យកណ្ដាលនៃអង្គការ UN-ACT នៅទីក្រុងបាងកក បានរាយឈ្មោះច្រកឆ្លងកាត់ព្រំដែនធំៗ ដែលខុសច្បាប់សម្រាប់ឲ្យជនជាតិភូមាផ្លាស់ទីចូលទៅកាន់ប្រទេសថៃ ដូចជា៖ កេងទុង/តាជីលេខ (Kengtung/Tachileik) ទៅកាន់មែសច្រកមីយ៉ាវ៉ាត់ឌីទៅ កាន់មេសត និងច្រកខាវធួងទៅកាន់រ៉ាក់ណង។[១២៦]

យោងតាមនគរបាលអន្តោប្រវេសន៍ខេត្តតាក មេសតគឺជាចំណុចសំចតដ៏សំខាន់ សម្រាប់កុមារដែលឆ្លងចូលទៅក្នុងប្រទេសថៃពីមីយ៉ាន់ម៉ា ដែលត្រូវបានជួញដូរ ឬមិនជួញដូរ។ នៅមេសត វាជារឿងសាមញ្ញដែលឆ្លងចូលទៅថៃពីច្រកមីយ៉ាវ៉ាត់ឌី។ នៅលើ ទន្លេមគឺជាស្ពានមិត្តភាព ដែលតភ្ជាប់មីយ៉ាវ៉ាត់ឌី និងច្រកមេសត។ នៅទីនេះ ពលរដ្ឋ ភូមាអាចឆ្លងចូលទៅក្នុងប្រទេសថៃដោយស្របច្បាប់ ដោយមានឯកសារត្រឹមត្រូវ។ ទោះជាយ៉ាងណា ចុះទៅផ្នែកខាងក្រោមនៃទន្លេមមានចំណុចឆ្លងកាត់ខុសច្បាប់ជា ច្រើន ដែលគ្រប់គ្រងដោយយោធាភូមាជាច្រើន ហើយទាល់តែបង់ប្រាក់សំណូកទើប អាចឆ្លងកាត់បាន។ បណ្ដាញខុសច្បាប់ដែលប្រើប្រាស់ក្នុងការជួញដូរពលរដ្ឋភូមាចូល ទៅក្នុងប្រទេសថៃ ហើយអាចជាផ្លូវដូចគ្នាតែមួយដែលបានប្រើប្រាស់ក្នុងការជួញដូរ គ្រឿងញៀន និងអាវុធ ពីព្រោះជាញឹកញាប់ប្រចកទាំងនេះត្រូវបានធ្វើជាចំណុចសំចត ស្របច្បាប់ “បណ្ដោះអាសន្ន” ដោយមន្ត្រីគយនៅទន្លេភាគខាងថៃ។[១២៧]

ដើម្បីចូលប្រទេសថៃកាត់តាមចំណុចទាំងនេះ ម្នាក់ៗត្រូវបង់លុយ ២0-៥00 បាតឲ្យអាជ្ញាធរទទួលបន្ទុកច្រកនីមួយៗ។[128] គេអាចឃើញមានទូករាប់មិនអស់ដែលដឹកជន ជាតិភូមាទៅមកកាត់តាមព្រំដែននោះ។ ដូចគ្នានៅកម្ពុជាដែរ ជានិច្ចកាលតែងតែមាន មធ្យោបាយក្នុងការចូលទៅក្នុងប្រទេសថៃ ហើយចំណាយមិនខ្ពស់ពេកទេ។

ទោះជាយ៉ាងណា ការចាកចេញពីតំបន់ព្រំដែន និងការចូលទៅក្នុងប្រទេសថៃភាគកណ្ដាលត្រូវចំណាយអស់លុយច្រើនជាងនេះ។ កុមារភូមាភាគច្រើនចូលប្រទេសថៃ

តាមផ្លូវភាគខាងជើង (មែស មេសត និងឈៀងរ៉ៃ) ហើយត្រូវបាននាំដើរកាត់ព្រៃភ្នំនៅ ខាំផែងផេត មុននឹងត្រូវបានដឹកជញ្ជូនទៅកាន់តំបន់ផ្សេងទៀតក្នុងប្រទេសថៃ។[១២៩]

ដោយចាប់ផ្ដើមនៅមេសត ដែលជាចំណុចសំចត ឬចំណុចប្រភពស្រាប់កុមារភូមា មានប្រព័ន្ធដឹកជញ្ជូនមួយដែលគេយល់ជាទូទៅ ហើយវាខុសៗគ្នាអាស្រ័យទៅលើចំនួនទឹកប្រាក់ ដែលកុមារ ឬមេខ្យល់មាន។ នៅក្នុងករណីភាគច្រើន ឡានដឹកបន្លែត្រូវបានប្រើប្រាស់ដើម្បីដឹកកុមារមកពីមេសត ឆ្ពោះទៅកាន់ចំណុចផ្សេងៗជាច្រើនទូទាំងប្រទេសថៃ។[១៣០]

មានការរាយការណ៍មកថា ស្រមាប់លុយប្រហែល ១៨,០០០ បាត គេអាចបើកជូនកុមារ ដោយមានមន្ត្រីនគរបាល នៅក្នុងរថយន្តដែលមិនមានដាក់ផ្លាកសម្គាល់ ហើយឆ្លងកាត់ ប៉ុស្តិ៍ត្រួតពិនិត្យអន្តោប្រវេសន៍ទាំងអស់បកបដោយសុវត្ថិភាព ដោយគ្មាននរណាសួរនាំ អ្វីឡើយ។ ស្រមាប់លុយ ១៥,០០០ បាត កុមារនោះអាចត្រូវបានដាក់នៅក្រោមប្រអប់ ឬ កេសដាក់បន្លែនៅក្នុងរថយន្តដឹកទំនិញ ហើយនឹងត្រូវចេញពីរថយន្តនោះ និងធ្វើដំណើរ ដោយថ្មើរជើងមួយភ្លេតៗដើម្បីគេចពីការចាប់ខ្លួននៅត្រង់ប៉ុស្តិ៍ត្រួតពិនិត្យរបស់នគរបាល ថៃ។ ស្រមាប់កុមារ ឬមេខ្យល់ដែលមានលុយ ៦,០០០ បាត ទិញផ្លូវដែលមានការការពារ តិចតួចបំផុតទៅកាន់ទីក្រុងធំៗក្នុងប្រទេសថៃ ការដើរកាត់ព្រៃភ្នំ និងភូមិសាស្ត្រគ្រោះ ថ្នាក់រយៈពេល ៤-៥ ថ្ងៃ ដោយគេចពីប៉ុស្តិ៍ត្រួតពិនិត្យនៅតាមផ្លូវនោះ។[១៣១] មន្ត្រីអន្តោប្រវេសន៍នៅខេត្តតាកបានអះអាងថា វាមានការលំបាកក្នុងការរារាំងមិនឲ្យកុមារ និងអ្នកជួញដូរធ្វើដំណើរដោយថ្មើរជើង ដោយសារតែព្រៃឈើផ្ដល់នូវការការពារ និងលាក់កំបាំងបាន ល្អបំផុត។[១៣២]

រ៉ាក់ណង ដែលស្ថិតនៅភាគខាងត្បូងនៃប្រទេសថៃ ក៏បម្រើជាច្រកចូលទៅក្នុងប្រទេសថៃតាមផ្លូវទឹកផងដែរ។ ជនរងគ្រោះដែលមកដល់រ៉ាក់ណង អាចស្នាក់នៅប្រទេសថៃបាន ប៉ុន្តែវាក៏ជាចំណុចសំចតស្រមាប់អ្នកដែលត្រូវបានជួញដូរទៅកាន់ប្រទេសម៉ាឡេស៊ីផងដែរ។[១៣៣] ការឆ្លងកាត់បែបនេះ ទាមទារឲ្យមានការធ្វើដំណើរដោយទូកកាត់តាមខាវធួង ដែលគេហៅជាភាសាថៃថា កោះសង។ រ៉ាក់ណង ដូចគ្នានឹងមេសតែដរ មានចំនួនប្រជា ជនភូមាដែលច្រើនជាងចំនួនប្រជាជនថៃ។ រ៉ាក់ណង មានស្រុកចំនួនប្រាំ ដែលស្រុក នីមួយៗសុទ្ធតែនៅជិតព្រំដែនភូមា។ ស្រុកមួយគឺស្រុកក្រាប៊ុរី ស្ថិតនៅចម្ងាយជិតល្មម នឹងអាចឲ្យប្រជាជនមីយ៉ាន់ម៉ាឆ្លងព្រំដែនដោយថ្មើរជើង នៅអំឡុងពេលលំនាចសមុទ្រ។

## ប្រព័ន្ធមេខ្យល់ភូមា

បណ្ដាញជួញដូរដែលផ្លាស់ទីកុមារពីមីយ៉ាន់ម៉ាទៅថៃ មានភាពស្មុគស្មាញ ដោយសារតែគ្រួសារចំណាកស្រុកភូមា ដែលចូលទៅកាន់ប្រទេសថៃមានចំនួនច្រើន។ ការជួញដូរឆ្លងដែនពីមីយ៉ាន់ម៉ា ពឹងផ្អែកទៅលើកិច្ចសហប្រតិបត្តិការរវាងមេខ្យល់ថៃ និងភូមា។ មេធាវីផ្នែកសិទ្ធិមនុស្សភូមាមួយរូបបានពន្យល់ថា៖

*"បើគ្មានការជួយជ្រោមជ្រែងពីមេខ្យល់ថៃទេនោះ មេខ្យល់ភូមាមិនអាចធ្វើបែបនេះបានទេ [ជួញដូរកុមារ] ពីព្រោះ [មេខ្យល់ភូមា] ពុំមានការជួយទំនុកបម្រុងច្រើនពីអាជ្ញាធរឡើយ។"*[១៣៤]

នៅក្នុងករណីភាគច្រើន មេខ្យល់ភូមាសម្របសម្រួលការឆ្លងព្រំដែន បន្ទាប់មកប្រគល់កុមារឲ្យទៅមេខ្យល់ថៃ ដែលយកកុមារនោះទៅប្រគល់ឲ្យថៅកែថៃនៅក្នុងឧស្សាហកម្ម ដែលពួកគេនឹងត្រូវធ្វើការ។ ជាទូទៅ មេខ្យល់ថៃនាំយកកុមារទៅកាន់កន្លែងធ្វើការ ប៉ុន្តែមេខ្យល់ភូមាដែលបានជ្រើសរើស ឬនាំយកកុមារនោះមក តែងតែទាក់ទងជាមួយក្រុមគ្រួសារកុមារ។[១៣៥]

កុមារចំណាកស្រុកដែលបាននៅក្នុងប្រទេសថៃរួចហើយនោះ ឧទាហរណ៍ កុមារដែលមកពី សហគមន៍អ៊ីស្លាមប៊ុមរុង ជាធម្មតាត្រូវបានដឹកដោយមេខ្យល់ ពីរនាក់ ដែលជាទូទៅគឺជាជនជាតិភូមា៖ មេខ្យល់ម្នាក់គឺជាអ្នកនាំពួកគេទៅកាន់គោលដៅរបស់ពួកគេ ហើយមេខ្យល់ម្នាក់ទៀតគឺជាអ្នកដឹកពួកគេ នៅក្នុងទីក្រុង។ បណ្ដាញនេះមិនសូវមានភាពស្មុគស្មាញឡើយ ដែលទាមទារឲ្យមានមេខ្យល់តិចគ្នាស្រមាប់ដឹកនាំ និងដឹកជញ្ជូនកុមារ ដោយសារពុំចាំបាច់មានការសម្របសម្រួលឆ្លងព្រំដែនឡើយ។

មេខ្យល់ដែលរកប្រភពកុមារបានមកពីមីយ៉ាន់ម៉ា ជាទូទៅធ្លាប់បានធ្វើការនៅប្រទេសថៃអស់រយៈពេលជាច្រើនឆ្នាំ ហើយនៅទីបំផុតប្រកបរបរជួញដូរមនុស្ស ដែលជារឿយៗពុំានដឹងច្បាស់ថាការងារដែលពួកគេកំពុងតែធ្វើគឺជាឧក្រិដ្ឋកម្មឡើយ។

បុគ្គលិកសង្គមកិច្ចនៅមេសតបានអះអាងថា *"ជាធម្មតា មេខ្យល់ភូមាទៅកាន់សហគមន៍ជនក្រីក្រនៅមីយ៉ាន់ម៉ា ហើយអួតអំពីបទពិសោធន៍ការងាររបស់ពួកគេនៅប្រទេសថៃ។"*[១៣៦] ជាទូទៅ ពួកគេទៅជួបឪពុកម្ដាយដោយផ្ទាល់ ហើយប្រាប់ពួកគេអំពីប្រភេទការងារ ដែលកូនៗពួកគេអាចធ្វើបានដើម្បីរកលុយយកមកឲ្យគ្រួសារ។ វាត្រូវបានផ្ដល់តម្លៃថាជាឱកាសការងារដ៏សំខាន់ ហើយជារឿយៗឪពុកម្ដាយតែងតែនឹកស្រមៃថា កូនពួកគេនឹងបានបង្កើនចំណេះដឹង និងបទពិសោធន៍ការងារ។[១៣៧]

ខុសព្រីប្រព័ន្ធមេខ្យល់កម្ពុជា នៅមីយ៉ាន់ម៉ាមានករណីទិញដូរ ឬជួលកុមារពីឪពុកម្ដាយ ឬយាយតាតិចជាង។

សូម្បីតែជនជាតិភូមា ដែលធ្វើដំណើរដោយមានលិខិតឆ្លងដែនបណ្ដោះអាសន្ន និងមានឯកសារបញ្ជាក់អត្តសញ្ញាណត្រឹមត្រូវហើយក៏ដោយ ក៏អាចធ្លាក់ខ្លួនក្លាយជាជនរងគ្រោះដោយសារមេខ្យល់ផងដែរ។ លិខិតឆ្លងដែនបណ្ដោះអាសន្ន ផ្ដល់សិទ្ធិដល់ជនចំណាកស្រុកភូមាវិលយក្នុងរហូតដល់ ៦ ឆ្នាំ នូវការស្នាក់នៅរយៈពេលពីរឆ្នាំនៅ ប្រទេសថៃ។ បុគ្គលិកអង្គការ NGO ភូមាមួយរូបបានអះអាងថា៖

*"មេខ្យល់នឹងចូលខ្លួនមក នៅពេលជនជាតិភូមាទៅពន្យារលិខិតឆ្លងដែនបណ្ដោះអាសន្នរបស់ពួកគេ។ ពួកគេនឹងផ្ដល់តម្រូវការក្លែងក្លាយមួយ ដោយប្រក្លាយឯកសារដែលមានសុពលភាពត្រឹមត្រូវទៅជាឯកសារក្លែងក្លាយ ដែលពួកគេមិនអាចប្រើប្រាស់ម្ដងទៀតបានឡើយ។ តាមបទពិសោធន៍របស់ខ្ញុំផ្ទាល់ ជាង ៩០% នៃជនចំណាកស្រុកភូមា (ដែលយើងធ្វើការជាមួយ) បានធ្លាក់ខ្លួនក្លាយជាជនរងគ្រោះដោយសារល្បិចកលនេះ។"*[១៣៨]

ប្រព័ន្ធមេខ្យល់នៅរ៉ាក់ណង មានលក្ខណៈខុសគ្នាពីនេះ។ ទោះបីជាមានការអះអាងថា ការជួញដូរនៅតំបន់រ៉ាក់ណងមានការថយចុះហើយក៏ដោយអង្គការ UN-ACT បានកំណត់អត្តសញ្ញាណផ្លូវពីតំបន់ខាវធួងទៅកាន់រ៉ាក់ណង ថាជាផ្លូវមួយក្នុងចំណោមផ្លូវកំពូលទាំងបី ស្រមាប់ជួញដូរឆ្លងដែនពីប្រទេសមីយ៉ាន់ម៉ាទៅកាន់ប្រទេសថៃ។ បុគ្គលិក ចុះមូលដ្ឋាននៅរ៉ាក់ណងបានរាយការណ៍ថា បញ្ហាធំជាងគេបំផុតនៅទីនោះ លែងជាបញ្ហាជួញដូរមនុស្សទៀតហើយ ប៉ុន្តែជាបញ្ហារត់ពន្ធមនុស្សទៅវិញទេ។[១៣៩]

ការមានការយល់ច្រឡំជាទូទៅចំពោះនិយមន័យនៃការរត់ពន្ធ និងការជួញដូរ ហើយពាក្យទាំងនេះ ត្រូវបានប្រើប្រាស់ជំនួសឲ្យគ្នាទៅវិញទៅមក។ ភាពខុសគ្នាធំជាងគេគឺថា ការរត់ពន្ធពាក់ព័ន្ធនឹងការយល់ព្រមពីបុគ្គលដែលនឹងត្រូវផ្លាស់ទីចូលទៅក្នុងប្រទេសមួយផ្សេងទៀត។ មាននែតមនុស្សពេញវ័យប៉ុណ្ណោះដែលអាចផ្ដល់ការយល់ព្រមបែបនេះ បាន ហើយក្រប្រហែលជាបានបង់លុយស្រមាប់ការធ្វើដំណើររបស់ពួកគេផងដែរ។ កុមារមិនអាចផ្ដល់ការយល់ព្រមបានឡើយ ដូច្នេះកុមារដែលធ្វើដំណើរតែម្នាក់ឯងឆ្លងកាត់ព្រំដែន ជានិច្ចកាលត្រូវបានចាត់ថ្នាក់ថាជាកុមារដែលត្រូវបានជួញដូរ។

*"ជួនកាលឪពុកម្ដាយប្រាប់បងប្អូនជីដូនមួយ ឬសាច់ញាតិណាម្នាក់ផ្សេងទៀតរបស់ពួក គេឲ្យប្រគល់កូនដែលពុំមានឯកសារត្រឹមត្រូវទៅឲ្យសាច់ញាតិណាម្នាក់ផ្សេងទៀត ដែលធ្វើការនៅរ៉ាក់ណង។ តាមធម្មតា សាច់ញាតិនោះនឹងជួលនរណាម្នាក់ឲ្យជួយសម្របសម្រួលការធ្វើដំណើរនេះ។ មេខ្យល់ភូមាជាច្រើនរង់ចាំនៅព្រំដែនខាងថៃ ឬនៅកោះសង។ ពួកគេរង់ចាំនៅកំពង់ផែ ធ្វើជាផឹកកាហ្វេ រកមើលអ្នកដែលមើលទៅដូចជាវង្វេងផ្លូវ ឬរកមើលកុមារដែលធ្វើដំណើរតែម្នាក់ឯង។"*[១៤០]

នៅរ៉ាក់ណង ក៏មានករណីទាំងឡាយដែលអ្នករត់ពន្ធដឹកជញ្ជូនដោយខុសច្បាប់នូវជនចំណាក ស្រុកភូមាដែលមករកការងារធ្វើនៅប្រទេសថៃផងដែរ។ ដើម្បីគេចពីអាជ្ញាធរ អ្នករត់ពន្ធនឹងធ្វើ ការទាក់ទងដោយផ្ទាល់ជាមួយមេខ្យល់ភូមាម្នាក់ ដែលជាអ្នកប្រាប់អ្នករត់ពន្ធអំពីកន្លែងដែលត្រូវ យកកប៉ាល់ចូលផែ។ នៅកន្លែងនេះ មេខ្យល់នឹងកេងប្រវ័ញ្ចឱកាសដោយល្បួងជនចំណាកស្រុក ខុសច្បាប់ឲ្យបានច្រើនតាមដែលអាចធ្វើបាន ដើម្បីរកការងារឲ្យពួកគេធ្វើ។

ការិយាល័យ MSDHS ខេត្តនៅរ៉ាក់ណង បានអះអាងថា ទាំងនេះគឺជាករណីរត់ពន្ធ។ ទោះជា យ៉ាងណា កុមារដែលធ្វើដំណើរតែម្នាក់ឯងត្រូវតែកំណត់អត្តសញ្ញាណនៅក្នុងឧទាហរណ៍ទាំង នេះ ថាជាជនរងគ្រោះពីការជួញដូរ ពីព្រោះកុមារមិនអាចផ្ដល់ការយល់ព្រមឲ្យខ្លួនពួកគេត្រូវបាន ដឹកជញ្ជូនដោយអ្នករត់ពន្ធបានឡើយ។ នៅក្នុងករណីមនុស្សពេញវ័យ ប្រសិនបើមានការបោក បញ្ឆោតណាមួយនៅក្នុងការចរចាររវាងមេខ្យល់ និងបុគ្គលដែលនឹងត្រូវបានរត់ពន្ធ (មុនពេលធ្វើ ដំណើរមកកាន់ ឬនៅពេលមកដល់ប្រទេសថៃ) នោះ រឿងក្ដីនេះនឹងផ្លាស់ប្ដូរពីការរត់ពន្ធមនុស្ស ទៅជាការជួញដូរមនុស្សវិញ។[១៤១]

## តួនាទីរបស់ឪពុកម្ដាយនៅក្នុងការជួញដូរកុមារភូមា

កុមារជាច្រើននៅអាស៊ីអាគ្នេយ៍ ត្រូវបានចិញ្ចឹមឲ្យធំដឹងក្ដីឡើងជឿថា ពួកគេមានទំនួលខុសត្រូវក្នុង ការជួយដល់គ្រួសារតាមគ្រប់វិធីដែលអាចធ្វើបាន

ដើម្បីបង្កើត្របាក់ចំណូលបន្ថែម និងសង "បំណុល" ជំនួសឪពុកម្តាយរបស់ពួកេគ ជាការតបស្នងចំេពាះឪពុកម្តាយែដលបានចិញ្ចឹមបីបាច់ ពួកេគ។ ដោយសារែតមានជំេនឿែបបេនះេហើយ វាគឺជាេរឿងទូេទៅស្រមាប់ឪពុកម្តាយ និងែថមទាំងកូនពួកេគផងែដរ ែដលត្រូវេដើរតួនៅក្នុងការជួញដូរេនាះ។ វាអាចជាបញ្ហាប្រឈមមួយក្នុងការ ពន្យល់ប្រាប់កុមារែដលជាជនរងេគ្រាះថាពួកេគត្រូវបានេគជួញដូរ េហើយវាជាឧក្រិដ្ឋកម្ម។ វារឹតែត មានការលំបាកជាងេនះេទៀតក្នុងការបញ្ចុះបញ្ចូលឪពុកម្តាយឲ្យេរួមគំនិតេនៅក្នុងការជួញដូរ កូនខ្លួនឯង។

កិច្ចសហ្របតិបត្តិការរវាងរដ្ឋាភិបាលៃថ និងមីយ៉ាន់ម៉ា បេង្កើតប្រព័ន្ធគ្រប់គ្រងអេន្តាប្រេវសន៍មួយ ែដលបុគ្គលិកសង្គមកិច្ច ត្រូវបានចាត់តាំងឲ្យេធ្វើការវាយតៃម្លេទៅេលើហានិភ័យសក្តានុពលៃនការ ជួញដូរកុមារម្តងេទៀត ដោយេប្រើឧបករណ៍វាយតៃម្លគ្រួសារតាមបទដ្ឋានមួយ។ ទោះជាយ៉ាងណា ប្រព័ន្ធេនះមានបញ្ហាប្រឈមផ្ទាល់របស់វា។ យោងតាមមន្ត្រីនៅការិយាល័យអេន្តាប្រេវសន៍ខេត្ត តាក បានឲ្យដឹងថា កុមារមិនងាយនឹងផ្តល់ភ័ស្តុតាងែដលអាចនាំឲ្យមានការចាប់ខ្លួនឪពុកម្តាយ េគេឡើយ។ េលើសេពីេនះ ការចាប់ខ្លួនឪពុកម្តាយេធ្វើឲ្យស្ថានភាពរបស់កុមារកាន់ែតលំបាក យ៉ាប់យឺនែថមេទៀត។

ដូចគ្នានឹងឪពុកម្តាយេនៅកម្ពុជាែដរ ឪពុកម្តាយជាេ្រចើនមានេចតនាចង់ឲ្យកូនពួកេគេទៅប្រេទសៃថ ជាមួយេមខ្យល់ េពីេ្រពាះពួកេគមានទំនុកចិត្តថា កូនពួកេគនឹងត្រឡប់មកផ្ទះវិញេដាយមានលុយ កាក់ និងមានចំេណះដឹងប្រេសើរជាងមុន។១៤២ ទោះជាយ៉ាងណា មិនដូចគ្នានឹងកម្ពុជាេឡើយ កុមារ ក្រមត្រូវបានេគ "ជួល" ណាស់ ប៉ុន្តែគាត់ែតយកេទៅដោយសន្យាថា ពួកេគនឹងត្រឡប់មកវិញ ប៉ុណ្ណោះ។ េនៅក្នុងករណីជាេ្រចីន កុមារពុំបានវិលត្រឡប់មកផ្ទះវិញេទ។ ផ្ទុយមកវិញ ពួកេគេដើររក ការងារេធ្វើដូចមនុស្សេពញវ័យេនៅប្រេទសៃថ។

ប្រធានភូមិេនសហគមន៍អុីស្លាមប៊ុមរុងេនៅេមសត បានរាយការណ៍មកថា ជាេរឿយៗឪពុកម្តាយមក ពីមីយ៉ាន់ម៉ាត្រង់មកកាន់តំបន់អនាធិបេតយ្យ េដើម្បីតាមដានកូនៗពួកេគ។[១៤៣] ការយល់ដឹងជាទូេទៅក្នុងចំេណាមគ្រួសារចំណាកស្រុកភូមាគឺថា កូនេក្មងត្រូវបានេគជួញដូរែតេនៅ េពលែដលពួកេគត្រូវបានេគចាប់រំេលាភេតទៅែតប៉ុណ្ណោះ។ េនៅក្នុងែកសែហ្នករបស់គ្រួសារចំណាក ស្រុកភូមា កុមារែដលចង់េធ្វើការ ដោយមិនខ្វល់ថាការេកងប្រវ័ញ្ចមានក្រមិតប៉ុណ្ណាេទ ពុំត្រូវបានេគ ជួញដូរេឡើយ។

> **គេ្រប់ខ្ញុំថា ខ្ញុំនឹងបានជួបកូនខ្ញុំម្តងេទៀត។ ខ្ញុំពុំដឹងថាកូនខ្ញុំេនៅឯណា េហើយត្រូវទាក់ទងេទៅេគដោយរេបៀបណាេទ។ ខ្ញុំែថមទាំងមិនដឹងថាត្រូវេទៅរកេមខ្យល់ែដលនាំេគេទៅេនាះតាមរេបៀបណាេទ។**
>
> **ម្តាយជនរងេគ្រាះពីការជួញដូរ េនៅមីយ៉ាវ៉ាត់ឌី**

ម្តាយជនចំណាកស្រុកភូមាម្នាក់ ែដលេធ្វើការេនៅសាលាេរៀនស្រមាប់ជនចំណាកស្រុកេនៅេមសត បានអះអាងថា កុមារជាេ្រចីនេទៅប្រេទសៃថតាមឆន្ទៈដោយេសរីរបស់ពួកេគ៖

*"ខ្ញុំគិតថា ប្រសិនេបើកុមារចង់េធ្វើការេនាះ កុមារនឹងេទៅដោយខ្លួនឯង។ េនះមិនែមនជាការជួញដូរេទ។ កុមារជាេ្រចីនឈប់េរៀនេនៅេពលពួកេគមានអាយុ ១៥ ឆ្នាំ។ ពួកេគេចញពីេមសត េហើយរកេមធ្យាបាយចូលេទៅក្នុងប្រេទសៃថ ជាធម្មតាេទៅតាមឡានដឹកបែន្ល។ ពួកេគទទួលបានប្រាក់កម្ចីពីនរណាម្នាក់ េហើយចុងេក្រាយត្រូវសងវាេទៅឲ្យេគវិញ។ កូនប្រុសខ្ញុំេធ្វើែបបេនះ ឥឡូវេនះគាត់កំពុងេធ្វើការេនៅេលីទូកេនសាទេដើម្បីរក ប្រាក់សងបំណុលស្រមាប់ការេធ្វើដំេណីររបស់គាត់។ "*[១៤៤]

## កុមារភូមាេនៅប្រេទសៃថ

កុមារមកពីេមសត ជាពិេសសសហគមន៍អុីស្លាមប៊ុមរុង ជាធម្មតាត្រូវបាននាំយកេទៅកាន់ទីក្រុងបាងកក េដើម្បីេដើរលក់ផ្កាេនៅតាមតំបន់េទសចរណ៍នានាក្នុងទីក្រុង។ វាមានភាព ងាយស្រួលក្នុងការេមើលេឃើញកុមារទាំងេនះ ែដលពួកេគរត់េនៅជុំវិញផ្លូវខាវសាន ( Khao Sarn ) ែដលល្បីខាងេរឿងមិនល្អរបស់ទីក្រុងបាងកក េដើរលក់ផ្កាកូលាប និងមានអន្តរកម្មជាមួយេភ្ញៀវេទសចរណ៍រហូតដល់យប់ៗេជ្រៅ។ មានកុមារមូស្លីមភូមាចេន្លាះពី ៥០០-៦០០ នាក់ េដើរលក់ផ្កាកូលាបេនៅទូទាំងប្រេទសៃថ។[១៤៥]

ករណីមួយ ែដលបានទទួលការយកចិត្តទុកដាក់ពីអន្តរជាតិេក្រាយពីការធ្លាក់ចុះចំណាត់ថ្នាក់របស់ៃថមកេនៅចំណាត់ថ្នាក់ទី ៣ របស់ក្រសួងការបរេទសសហរដ្ឋអាេមរិកគឺ ការឆ្មក់ចូលចាប់ក្រុមជួញដូរមនុស្សមួយក្រុមេនៅបាងកក។ េនៅក្នុងការឆ្មក់ចូលេនាះ នគរបាលអាចចាប់អ្នកគ្រប់គ្រងម្នាក់ ែដលទទួលខុសត្រូវចំេពាះកុមារភូមាែដលត្រូវបានេគជួញដូរ ឲ្យេទៅលក់ផ្កាកូលាបេនៅតាមផ្លូវខាវសាន។១៤៦ សរុបឲ្យខ្លីមក បន្ទាប់ពីការឆ្មក់ចូលចាប់េនះ កុមារទាំងេនាះហាក់ដូចជាបាត់ខ្លួនអស់។ ពីរបីែខេក្រាយមក ការយកចិត្តទុកដាក់របស់ ប្រព័ន្ធផ្សព្វផ្សាយមានការផ្លាស់ប្តូរ េហើយកុមារត្រឡប់េទៅកាន់ទីតាំងែដដល និងបន្តការ េដើរលក់ផ្កាកូលាបេទៀត។

កុមារែដលមកដល់រ៉ាក់ណង ជាេរឿយៗែតងែតជិះរថយន្តប្រេភទ Transit េទៅកាន់ប្រេទស ម៉ាេឡស៊ី។ កុមារទាំងឡាយែដលេនៅែតស្ថិតក្នុងប្រេទសៃថ ជាញឹកញាប់ែតងែតេធ្វើដំេណីរ េទៅកាន់ទីក្រុងបាងកក េដើម្បីេធ្វើការេនៅតាមសណ្ឋាគារ ឬេទៅសាមុតសាខេនេដើម្បីេធ្វើការ េនៅេលីទូកេនសាទ ឬេរាងចក្រេកៃច្នប្រេត។ កុមារែដេទៀត េធ្វើដំេណីរេទៅភាគខាងត្បូង គឺ េទៅកាន់ស៊ុងខ្លា ស៊ូរ៉ាតថានី និងភូេកត េដើម្បីរកការងារស្រេដៀងគ្នាេនះេនៅក្នុងឧស្សាហកម្ម េនសាទ ឬេនៅតាមចម្ការេកៅស៊ូ ឬេនៅការដ្ឋានសំណង់។ ទោះបីជាមនុស្សជាេ្រចីនបានស ន្មត់ថា េនៅរ៉ាក់ណងបញ្ហាចម្បងគឺ ពលកម្មកុមារេនៅតាមកំពង់ែផ និងេនៅក្នុងឧស្សាហកម្ម េនសាទ ក៏មានេពស្យាចារកុមារជាេ្រចីនផងែដរ។ េក្មងស្រីជាេ្រចីន ជាទូេទៅអាយុចេន្លាះ ១៥ និង ១៧ ឆ្នាំ េធ្វើការេនៅក្នុងបារ និងផ្ទះបេនេនៅរ៉ាក់ណង។[១៤៧]

## ការេធ្វើមាតុភូមិនិវត្តន៍កុមារែដលត្រូវបានេគជួញដូរត្រឡប់េទៅប្រេទសមីយ៉ាន់ម៉ាវិញ

យោងតាមមាត្រា ៣៣ ៃនច្បាប់ប្រឆាំងការជួញដូរមនុស្សរបស់ៃថ ( Anti-Trafficking in Persons Act B.E. 2551 ) េនៅេពលែដលកុមារត្រូវបានកំណត់អត្តសញ្ញាណថាជាជន រងេគ្រាះរួចេហើយ ពួកេគនឹងត្រូវបានបញ្ជូនេទៅកាន់ទីជ្រករបស់រដ្ឋាភិបាល ែដលត្រូវបាន អនុញ្ញាតឲ្យដំេណីរការេដើម្បីការពារពួកេគមុនេពលេធ្វើមាតុភូមិនិវត្តន៍។ េនៅទីជ្រកេនះ កុមារត្រូវផ្តល់សក្ខីភាព និងភ័ស្តុតាងអ្វីក៏ដោយែដលចាំបាច់េដើម្បីបេង្កីតបានជាសំណុំេរឿង មួយេនៅតុលាការៃថ។ [១៤៨]

ដំេណីរការច្បាប់ ទាមទារឲ្យរដ្ឋាភិបាលៃថសហការជាមួយរដ្ឋាភិបាលមីយ៉ាន់ម៉ា ដោយ ែចករំែលកទិន្នន័យសំណុំេរឿងក្តីតាមរយៈប្រព័ន្ធជីវៃម៉្រតមួយ។ MOU រវាងប្រេទសៃថ និង មីយ៉ាន់ម៉ា គឺជាអនុស្សរណៈែតមួយរវាងបណ្តាប្រេទសជិតខាងទាំងបី ែដលទាមទារឲ្យភាគីទាំងសងខាងសហ្របតិបត្តិការ េដើម្បីបេង្កីតនូវលក្ខណៈវិនិច្ឆ័យរួមេនៅក្នុងការកំណត់អត្តសញ្ញាណជនរងេគ្រាះពីការជួញដូរមនុស្ស ដោយបង្ហាញពីក្តីកង្វល់របស់ មីយ៉ាន់ម៉ា ចំេពាះការកំណត់អត្តសញ្ញាណពលរដ្ឋរបស់ខ្លួនឲ្យបានត្រឹមត្រូវ។

េនៅេពលមានការបញ្ជាក់អះអាងអំពីសញ្ជាតិរបស់ជនរងេគ្រាះ ដំេណីរការេធ្វើមាតុភូមិ និវត្តន៍ជាផ្លូវការនឹងចាប់េផ្តីម។[១៤៩]

ការេធ្វើមាតុភូមិនិវត្តន៍ េកីតេឡីងតាមរយៈច្រកព្រំដែនសបច្បាប់ែដលេចញពីេមសត ឆ្ពោះេទៅកាន់មីយ៉ាវ៉ាត់ឌី។ េនៅេពលេទៅដល់មីយ៉ាវ៉ាត់ឌីេហើយ ការិយាល័យកិច្ចសហ ប្រតិបត្តិការព្រំដែនទទួលបន្ទុកការប្រឆាំងអំេពីជួញដូរមនុស្ស ( BCATIP ) នឹងទទួល កុមារ េហើយដឹកជញ្ជូនពួកេគេទៅកាន់ទីជ្រកសំចតមីយ៉ាវ៉ាត់ឌី។[១៥០]

េនៅេពលកុមារបានឈានេទៅដល់ជ្រកសំចតមីយ៉ាវ៉ាត់ឌីេហើយ ការប្រាស្រ័យទាក់ទងគ្នារវាងអាជ្ញាធរៃថ និងមីយ៉ាន់ម៉ាត្រូវបញ្ចប់។ េមធាវីភូមាម្នាក់បានពន្យល់ថា៖

*"េនៅេពលមកដល់ទីជ្រក កុមារនឹងទទួលបានការវាយតៃម្លបឋម េហើយបន្ទាប់មកមានអ្នកអមដំេណីរេទៅកាន់ទីជ្រកម៉ូឡាំយីន* ( Mawlamyine ) *េក្រាយរយៈេពលមួយយប់។ េនៅេពលមកដល់ក្នុងទីជ្រកម៉ូឡាំយីនេហើយ កុមារេនាះអាចស្នាក់េនៅ ឬចាកេចញតាមបំណងរបស់ពួកេគ។"*[១៥១]

ទោះបីជា BATWC អះអាងថា ក្រសួងសុខុមាលភាពសង្គមេនៅមីយ៉ាន់ម៉ាត្រូវែតេធ្វើការតាមដានគ្រួសារេទៅេលីកុមារម្នាក់ៗ ( កុមារមានេសរីភាពក្នុងការចាកេចញេទៅកាន់ទីជ្រកទីពីរេទៀត ) ដូេច្នះេគមិនអាចធានាបានថា ពួកេគនឹងត្រូវបានេធ្វើសមាហរណកម្មជាមួយក្រុមគ្រួសារពួកេគម្តងេទៀតេឡីយ។១៥២ ប្រសិនេបើកុមារេជ្រីសេរីសចាកេចញពួក េគអាចេដើរត្រឡប់េក្រាយេទៅកាន់េមខ្យល់ផ្ទាល់ ឬប្រឈមនឹងហានិភ័យក្នុងការចាក

ចេញ និងត្រូវបានមេខ្យល់ផ្សេងទៀតមកទទួលយក។

ភស្តុតាងដែលមានកម្រិតនៃរបាយការណ៍ និងទិន្នន័យតាមដានគ្រួសារ រក្សាមិនឲ្យ ប្រសិទ្ធភាពនៃប្រព័ន្ធតាមដានគ្រួសារត្រូវបានវាស់ស្ទង់។ ភស្តុតាងបានផ្តល់ជាយោបល់ ថា កុមារមានសេរីភាពក្នុងការដើរហើរតាមជម្រើសរបស់ពួកគេ នៅពេលពួកគេមកដល់ក្នុងប្រទេសមីយ៉ាន់ម៉ា ហើយបច្ចុប្បន្ននេះនៅពុំមាននីតិវិធីតាមដានដែលត្រូវដោយអាជ្ញាធរថៃនៅឡើយទេ។

ប្រជាជនប្រហែល ៤០០ នាក់ ត្រូវបាននិរទេសត្រឡប់មកពីតំបន់មេសតទៅកាន់ប្រទេសមីយ៉ាន់ម៉ាវិញជារៀងរាល់ថ្ងៃ។[១៥៣] ដំណើរការពិនិត្យឯកសារអ្នកដែលត្រូវនិរទេស ចេញត្រូវបានធ្វើឡើងយ៉ាងឆាប់រហ័សនៅពេលព្រឹក ដោយសារសម្ពាធទៅលើមន្ត្រីអន្តោប្រវេសន៍ ដែលត្រូវផ្លាស់ទីបជនឲ្យបានឆាប់រហ័ស។[១៥៤] ការធ្វើបែបនេះផ្តល់នូវ ពេលវេលាតិចតួចក្នុងការកំណត់អត្តសញ្ញាណកុមារ ដែលអាចជាជនរងគ្រោះពីការជួញ ដូរ។ ទោះជាយ៉ាងណាអង្គការ NGOs ក្នុងស្រុកមួយចំនួនធ្វើការជាមួយការិយាល័យអន្តោប្រវេសន៍ ដើម្បីពិនិត្យមើលកុមារដែលកំពុងត្រូវបាននិរទេស និងវាយតម្លៃថាតើមានជនរងគ្រោះពីការជួញដូរក្នុងចំណោមពួកគេដែរឬទេ។

កុមារដែលមិនត្រូវបានកំណត់អត្តសញ្ញាណថាជាជនរងគ្រោះពីការជួញដូរ ត្រូវបាននិរទេសចេញជាយេប្រើបណ្តាញ និងនីតិវិធីដូចគ្នាដែលបានប្រើប្រាស់សម្រាប់ជនអន្តោប្រវេសន៍ខុសច្បាប់ពេញវ័យ។ សម្រាប់កុមារមួយចំនួន ជាជាងការនិរទេសពួកគេចេញតាមផ្លូវស្ពានមិត្តភាព កុមារទាំងនេះអាចត្រូវបាននិរទេសតាមច្រករបៀងខុសច្បាប់ដូចគ្នានឹងពេលដែលពួកគេចូលក្នុងប្រទេសថៃដែរ។ នៅភាគីខាងថៃ ច្រករបៀងទាំងនេះត្រូវបានធ្វើ ឲ្យមានលក្ខណៈស្របច្បាប់ជាបណ្តោះអាសន្នក្រោមច្បាប់ពន្ធគយ ប៉ុន្តែនៅភាគីខាង ភូមាវិញ វានៅតែជាច្រកផ្លូវខុសច្បាប់ចូលទៅក្នុងប្រទេសថៃដដែល។[១៥៥] កុមារដែលត្រូវបាននិរទេសចេញ នឹងមានអាជ្ញាធរទាំងឡាយនៅចាំទទួល ដែលអាជ្ញាធរទាំងនោះគឺជា អ្នកគ្រប់គ្រងច្រកព្រំដែនដែលពួកគេបានឆ្លងកាត់។ នៅមីយ៉ាវ៉ាត់ឌី ជាធម្មតាគឺយាជកាកែរេនវ៉ូឡង់ (Karen Benevolent) ប្រជាធិបតេយ្យ (DKBA)។ អ្នកដែលត្រូវបាននិរទេសចេញ ត្រូវតែបង់លុយសំណូកនៅច្រកទ្វារដើម្បីទទួលបានការអនុញ្ញាតត្រឡប់ទៅកាន់ប្រទេសមីយ៉ាន់ម៉ាវិញ។ អ្នកដែលពុំមានលទ្ធភាពបង់លុយសំណូកសម្រាប់ការចូលទៅម្តងទៀតទេនោះ នឹងត្រូវបញ្ជូនទៅកាន់មណ្ឌលឃុំខ្លួនបណ្តោះអាសន្ន រហូត ទាល់តែមាននរណាម្នាក់អាចបង់លុយសម្រាប់ការដោះលែងពួកគេ ដែលជាញឹកញាប់គឺ ជាមេខ្យល់ដែលបាននាំពួកគេចូលក្នុងប្រទេសថៃ។

មានការចោទប្រកាន់ថា ប្រសិនបើកុមារមិនអាចទាក់ទងមេខ្យល់ដែលមានបំណងបង់ពិន័យទេនោះ DKBA នឹងស្វែងរកមេខ្យល់ជំនួសឲ្យពួកគេវិញ។ ការចោទប្រកាន់មួយចំនួនបានផ្តល់ជាយោបល់ថា DKBA មានការពាក់ព័ន្ធនៅក្នុងការលក់ដូរកុមារទៅកាន់ ការដ្ឋានសំណង់នៅតាមព្រំដែនភាគីខាងភូមា។[១៥៦] ប្រព័ន្ធនេះគឺជាការជំរុញបន្ថែមសម្រាប់ការជួញដូរជនរងគ្រោះឡើងវិញ ហើយវដ្តនេះនឹងចាប់ផ្តើមម្តងទៀត។

យោងតាមការិយាល័យជនអន្តោប្រវេសន៍ខេត្តតាក មានកំពង់ផចំនួន ២២ កន្លែងនៅទន្លេមេ ដែលអាចប្រើប្រាស់ដោយនគរបាលអន្តោប្រវេសន៍។[១៥៧] ស្ពានមិត្តភាពគឺជា ច្រកឆ្លងព្រំដែនស្របច្បាប់តែមួយគត់។ ច្រករបៀងផ្សេងៗត្រូវបានអនុញ្ញាតជា បណ្តោះអាសន្នក្រោមច្បាប់ស្តីពីពន្ធគយ ដើម្បីនាំចូល និងនាំចេញទំនិញទៅមកប្រទេស មីយ៉ាន់ម៉ា។ មន្ត្រីមួយរូបបានពន្យល់ប្រាប់ថា៖

*"នៅពេលយើងនិរទេសជនចំណាកស្រុកខុសច្បាប់ យើងមានមនុស្សជាង ៤០០ នាក់។ យើងមិនអាចនិរទេសពួកគេតាមស្ពានបានទេ ពីព្រោះរដ្ឋាភិបាលភូមាពុំបានចាត់ទុក មនុស្សដ៏ច្រើនទាំងនេះថាជាពលរដ្ឋឡើយ ដូច្នេះយើងត្រូវតែនិរទេសពួកគេចេញទៅតាមកំពង់ផទាំងនេះ។"* [១៥៨]

កំពង់ផែដែលត្រូវបានប្រើប្រាស់សម្រាប់ការនិរទេស ឈ្មោះថា ច្រកលេខ ១៣ នៅភាគីខាងថៃ និងច្រកលេខ ៩៩៩ នៅភាគីខាងភូមា។ កុមារភូមាដែលរស់នៅតំបន់មេសតបានកំណត់ថាច្រកលេខ ៩៩៩ គឺជាកំពង់ផមួយដែលពួកគេនឹងត្រូវបានឃុំខ្លួន ប្រសិនបើពួកគេត្រូវបញ្ជូនត្រឡប់ទៅកាន់ប្រទេសមីយ៉ាន់ម៉ាវិញ។[១៥៩]

ពុំមានកំណត់ត្រាណាមួយត្រូវបានរក្សា ពាក់ព័ន្ធនឹងកុមារដែលត្រូវបាននិរទេសតាមវិធីនេះឡើយ ដូច្នេះនៅពេលនិរទេស ពុំមានប្រព័ន្ធតាមដានណាមួយដើម្បីពិនិត្យឲ្យដឹងថាតើជននោះបានចូលប្រទេសថៃម្តងទៀតដែរឬទេ។ ស្រដៀងគ្នានេះដែរ នៅប្រទេសថៃប្រសិនបើកុមារដែលត្រូវបានជួញដូរ បាននធ្វើសមាហរណកម្មដោយជោគជ័យជាមួយក្រុមគ្រួសារពួកគេវិញ ពុំមានដំណើរការតាមដាននៅនឹងកន្លែង ដើម្បីរារាំងការជួញដូរកុមារម្តងទៀតឡើយ។

ខណៈដែលមេសត ត្រូវបានកំណត់ថាជាចំណុចធ្វើមាតុភូមិនិវត្តន៍ផ្លូវការតែមួយគត់រវាងមីយ៉ាន់ម៉ា និងថៃ មានករណីជម្រើសពីរបី ដែលជនរងគ្រោះធ្លាប់ត្រូវបានគេធ្វើមាតុភូមិនិវត្តន៍តាមកោះសងនៅរ៉ាក់ណង។ អង្គការ NGOs មួយចំនួន
កំពុងតែប៉ុនប៉ងធ្វើឲ្យរ៉ាក់ណង ក្លាយជាចំណុចធ្វើមាតុភូមិនិវត្តន៍ផ្លូវការមួយសម្រាប់ជនរងគ្រោះ។ ទោះជាយ៉ាងណា ដើម្បីធ្វើមាតុភូមិនិវត្តន៍កុមារណាម្នាក់ចេញពីចំណុចនេះ កុមារនោះត្រូវតែមានអ្នកអម ដំណើរជាមួយតាមទូកឆ្លងទៅកាន់កោះសង ហើយនេះគឺជាប្រទាព្រាបទង់គ្នាផ្នែក ធនធានរបស់រដ្ឋាភិបាល។[១៦០]

## កិច្ចការពារ និងទប់ស្កាត់សម្រាប់កុមារភូមា

នៅឆ្នាំ ២០០៤ មីយ៉ាន់ម៉ា បានក្លាយជាប្រទេសទីមួយនៅក្នុងតំបន់ទន្លេមេគង្គ ដែលចុះហត្ថលេខាលើពិធីសារ Palermo ។ មួយឆ្នាំក្រោយមក មីយ៉ាន់ម៉ាបានអនុម័តច្បាប់ស្តីពីការជួញដូរមនុស្សគ្រប់ជ្រុងជ្រោយរបស់ខ្លួនគឺ ច្បាប់ប្រឆាំងការជួញដូរមនុស្ស។ ច្បាប់របស់មីយ៉ាន់ម៉ា បានកំណត់និយមន័យនៃការជួញដូរថាជា ការលក់ ការទិញ ការខ្ចី ការជួល ការជ្រើសរើស ដឹកជញ្ជូន ការផ្ទេរ ឬការទទួលមនុស្ស។ មានបទបញ្ញត្តិដែលដាក់ពិន័យទៅលើការបន្លំឯកសារស៊ុំកូន រៀបអាពាហ៍ពិពាហ៍ និងការក្លែងបន្លំឯកសារ (ជាពិសេសសម្រាប់កុមារ) ក្នុងគោលបំណងជួញដូរកុមារឆ្លងកាត់ព្រំដែន។ ជំពូក VI មានបទបញ្ញត្តិទាំងឡាយ ជាពិសេសសម្រាប់ស្ត្រី កុមារ និងយុវវ័យ។[១៦១]

ទោះជាយ៉ាងណា ច្បាប់ជាតិពិបាកក្នុងការអនុម័តប្រើប្រាស់នៅព្រំដែនភាគីខាងភូមា ដែលសង្គមស៊ីវិលស្ថិតក្នុងសភាពព្រកទ្បាប់ចាក់ ហើយអំណាចត្រូវបានបែងចែកគ្នារវាងស្ថាប័នស៊ីវិលពុករលួយពាលគឺ យោធាជាតិ និង DKBA ។ សមត្ថភាពរដ្ឋាភិបាលភូមានឹងត្រូវការព្រងឹងបន្ថែម មុនពេលពួកគេអាចដោះស្រាយប្រកបដោយប្រសិទ្ធភាពជាមួយនឹងកុមារដែលត្រូវបានជួញដូរ។

នៅភាគីខាងថៃ មានអង្គការ NGOs ជាច្រើនដែលធ្វើការនៅគ្រប់សទាប់វណ្ណៈ ដើម្បីជួយការពារកុមារដែលធ្លាប់ត្រូវបានគេជួញដូរ ឬកំពុងប្រឈមមុខនឹងហានិភ័យនៃការជួញដូរ។ នៅមេសត អង្គការអន្តរជាតិ ធ្វើការដើម្បីកាត់បន្ថយភាពងាយរងគ្រោះរបស់កុមារដែលកំពុងប្រឈមនឹងហានិភ័យ (ឧ. កូនៗរបស់ជនចំណាកស្រុក ដែលគ្មានឯកសារស្រប ច្បាប់ ឬឋានៈជាអ្នកមកតាមឪពុកម្តាយ) ដោយទទួលបាននូវឯកសារបញ្ជាក់អត្ត សញ្ញាណត្រឹមត្រូវដែលមានទម្រង់ជាអត្តសញ្ញាណប័ណ្ណលេខ ១៣ ខ្ទង់។[១៦២]

គ្លីនិកមេសត និងគណៈកម្មការដើម្បីការពារ និងលើកកម្ពស់សិទ្ធិកុមារ (CPPCR) ជួយឪពុកម្តាយចំណាកស្រុកឲ្យទទួលបានសំបុត្រកំណើត សម្រាប់កុមារភូមាដែលកើតនៅប្រទេសថៃ។ ការមានសំបុត្រកំណើត ធ្វើឲ្យកុមារភូមាអាចទទួលបានការអប់រំ និង ការគាំពារសុខភាពក្រមិតមូលដ្ឋានពីរដ្ឋាភិបាលថៃនៅពេលអនាគត។[១៦៣] កុមារភាគច្រើនត្រូវបានកត់ត្រា និងចុះបញ្ជីឈ្មោះដោយគ្លីនិក ប៉ុន្តែប្រសិនបើដំណើរការនេះពុំត្រូវបានធ្វើចប់សព្វគ្រប់ក្នុងរយៈពេល ១៥ ថ្ងៃ ក្រោយពេលកើត ឬសម្រាប់កុមារដែលគ្លីនិកពុំបាន ដឹង (ឧ. កុមារដែលកើតនៅផ្ទះ) ការទទួលខុសត្រូវត្រឹមត្រូវផ្ទេរទៅឲ្យ CPPCR វិញ។

ហាក់ដូចជាមានអង្គការតិចតួចប៉ុណ្ណោះ ដែលធ្វើការនៅគ្រប់សទាប់វណ្ណៈដើម្បីការពារកុមារងាយរងគ្រោះនៃសហគមន៍អ៊ីស្លាមប៊ុមរុងដ៏ជាច្រសយាល។ អង្គការ NGOs បានបង្កើត សាលារៀនមួយនៅក្នុងតំបន់អនាធិបតេយ្យនោះ
ប៉ុន្តែវាលែងមានមូលនិធិជំនួយ ហើយ ត្រូវបង្ខំចិត្តបិទទ្វារ។ ការបិទទ្វារសាលា ធ្វើឲ្យកុមារនៅក្នុងសហគមន៍នេះងាយរងគ្រោះ ជាទីបំផុត។ ជាលទ្ធផល កុមារអ៊ីស្លាមប៊ុមរុងជាច្រើនត្រូវបានគេឃើញដើរសុំទាននៅ តាមចិញ្ចើមផ្លូវ ដែលជាការបង្កើននូវគ្រោះថ្នាក់ថែមទៀតពីការចាប់ពង្រត់ដោយអ្នកជួញ ដូរ។[១៦៤]

មានកិច្ចប្រឹងប្រែងយកចិត្តទុកដាក់នៅភាគីថៃដោយអង្គការ NGOs ក្នុងកិច្ចការពារកុមារ។

អង្គការ NGOs ខ្លះឆ្លងចូលទៅក្នុងប្រទេសមីយ៉ាន់ម៉ា ដើម្បីផ្តល់ការបណ្តុះបណ្តាលសហគមន៍ មូលដ្ឋាន និងលើកកម្ពស់យល់ដឹងអំពីការជួញដូរ ដោយបង្រៀនឲ្យឪពុកម្តាយឲ្យចេះ ប្រយ័ត្នប្រយែងជាមួយនឹងមេខ្យល់។

មីយ៉ាន់ម៉ា ក្នុងនាមជាប្រទេសប្រភពដើមមួយ មានស្ថាប័នតិចតួចនៅនឹងកន្លែងសម្រាប់ការពារកុមារពីការជួញដូរ ឬដំណើរការស្តារនីតិសម្បទា និងធ្វើមាតុភូមិនិវត្តន៍ប្រកបដោយប្រសិទ្ធភាព ដើម្បីជួយដល់កុមារក្នុងការវិលត្រឡប់ពីប្រទេសថៃវិញដើម្បីកសាងជីវិតពួកគេសារជាថ្មី និងគេចចេញពីការជួញដូរមនុស្សម្តងទៀត។

## ឧបសគ្គនៅក្នុងការប្រយុទ្ធប្រឆាំងនឹងការជួញដូរកុមារពីមីយ៉ាន់ម៉ា

ស្ថាប័នដែលធ្វើការក្នុងប្រទេសថៃ ដើម្បីប្រយុទ្ធប្រឆាំងនឹងការជួញដូរកុមារពីមីយ៉ាន់ម៉ា ប្រឈមនឹងបញ្ហាលំបាកជាច្រើន។ នគរបាលភូមិន្ទថៃ បានរាយការណ៍មកថា ពួកគេពុំមានអ្នកបកប្រែគ្រប់គ្រាន់ដើម្បីជួយសម្រួលដល់នគរបាល និងមន្ត្រីអន្តោប្រវេសន៍ដើម្បីធ្វើការស៊ើបអង្កេត និងការងារសំណុំរឿង។ របាយការណ៍បង្ហាញឲ្យឃើញថា អ្នកបកប្រែ តែងតែបកប្រែមិនស្របគ្នា ហើយអ្នកបកប្រែដែលអង្គការ NGOs បញ្ជូនមក តែងតែបកប្រែលំអៀងសាច់រឿងដែលពួកគេកំពុងបកប្រែ។[១៦៦] សច្ចៈភាពអំពីការផ្តល់សក្ខីភាពរបស់ជនរងគ្រោះ ពឹងផ្អែកទាំងស្រុងលើគុណភាពនៃការបកប្រែដែលបានផ្តល់ជូន។ ការបកប្រែខុស អាចធ្វើឲ្យការស៊ើបអង្កេតទាំងមូលខុស ហើយមិនអាចផ្តន្ទាទោសបាន។

និយមន័យទាំងឡាយនៅក្នុងច្បាប់ស្តីពីការជួញដូររបស់ភូមា និងច្បាប់ស្តីពីការជួញដូររបស់ថៃមានភាពខុសគ្នា ហើយការនេះប៉ះពាល់ដល់របៀបដែលសំណុំរឿងក្តីត្រូវបានគេ យល់ដឹង និងដោះស្រាយនៅលើពំដែនទាំងសងខាង។ នេះគឺជារឿងជាក់ស្តែងនៅក្នុង ការនិរទេសជនរងគ្រោះកុមារ ក្រោមឋានៈជាជនរងគ្រោះកុមាររបស់ជនចំណាក្រស្រុក ខុសច្បាប់។  នៅមីយ៉ាន់ម៉ា គេចាត់ទុកកុមារថាត្រូវបានគេជួញដូរដោយប្រវត្តិ ប្រសិនបើ ពួកគេមានអាយុក្រោម ១៥ ឆ្នាំ ហើយកំពុងធ្វើការនៅប្រទេសថៃ។ នៅពេលមន្ត្រីថៃ និរទេសកុមារទាំងនេះថាជាជនចំណាក្រស្រុកខុសច្បាប់ ដោយពុំមានឋានៈជាជនរង គ្រោះ មន្ត្រីភូមាមិនអាចដឹងបានថាតើពួកគេត្រូវការការធ្វើសមាហរណកម្មម្តងទៀតដែរឬ ទេ។ ប្រសិនបើពួកគេត្រូវបាននិរទេសក្នុងនាមជាជនរងគ្រោះនោះ រដ្ឋាភិបាលភូមាអាចជាកន្លែងដែលជួយការពារពួកគេបានប្រសើរជាង។[១៦៧]

កុមារដែលត្រូវបាននិរទេសចេញក្នុងនាមជាជនចំណាក្រស្រុកខុសច្បាប់ ដោយគ្មានការស៊ើបអង្កេត និងត្រួតពិនិត្យឲ្យបានត្រឹមត្រូវ ពុំត្រូវបានកត់ត្រាក្នុងប្រព័ន្ធអន្តោប្រវេសន៍ឡើយ ហើយភាពងាយរងគ្រោះរបស់ពួកគេនឹងកើនឡើងរហូតដល់ចប់ដំណើរការនិរទេសទាំងស្រុង។

ឧបសគ្គមួយក្នុងចំណោមឧបសគ្គធំៗបំផុត ដែលប្រឈមដោយនគរបាលគឺ ការបញ្ចុះបញ្ចូលឲ្យរងគ្រោះសហការជាមួយនឹងការស៊ើបអង្កេត។ ទាល់តែមានការសហការពីជនរងគ្រោះទើបនគរបាលអាចរកភ័ស្តុតាងបញ្ជាក់ពីការជួញដូរ និងការរកប្រវ័ញ្ចបាន។ បើ គ្មានភ័ស្តុតាងបញ្ជាក់ទេនោះ នគរបាលមិនអាចសាងសំណុំរឿងសម្រាប់ការជួញដូរមនុស្សបានឡើយ។

ជនរងគ្រោះមួយចំនួន មិនមានអត្តសញ្ញាណជាជនរងគ្រោះទេ ហើយមានអារម្មណ៍ថាស្ថានភាពរបស់ពួកគេគឺជាអ្វីដែលកើតឡើងជាធម្មតា។ អ្នកដទៃទៀតរងរបួសផ្លូវចិត្ត ហើយចង់វិលត្រឡប់ទៅមីយ៉ាន់ម៉ាវិញ។ ករណីជួញដូរមនុស្សអាចជារឿងវែងឆ្ងាយ និងត្រូវចំណាយពេលវេលា។ ដោយសារបែបនេះហើយ ទាំងជននរងគ្រោះ និងនគរបាលពុំត្រូវបានគេមើលឃើញថាជំរុញឲ្យមានការផ្តន្ទាទោសការជួញដូរឡើយ។ ករណីជាច្រើន មកពីមីយ៉ាន់ម៉ា ត្រូវចំណាយពេលយូរស្មើនឹងពីរដងនៃករណីដែលមកពីប្រទេសកម្ពុជា និងឡាវ ពីព្រោះអាជ្ញាធរនីមួយៗត្រូវតែបំពេញដំណើរការបញ្ជាក់សុពលភាពថ្នាក់ជាតិ ដោយរដ្ឋាភិបាលមីយ៉ាន់ម៉ាសម្រាប់ជនរងគ្រោះ។

ភាពនៅជិតគ្នារវាងប្រទេសថៃ និងមីយ៉ាន់ម៉ា មានន័យថាមាន "ចំណុចខ្សោយ" រាប់មិនអស់ដែលមិនអាចពិនិត្យតាមដាននៅតាមមាត់សមុទ្ររបស់ថៃបានទេ។ នៅរ៉ាក់ណង មានផ្លូវជាច្រើនសម្រាប់ចូលប្រទេសថៃដោយខុសច្បាប់គឺទៅតាម ក្រាប៊ី ស្រុកឡាអ៊ុន ឬ ម៉ាលីវ៉ាន់។ នៅក្រាប៊ី នៅពេលទឹកជំនោរស្រកចុះអស់ មនុស្សនាំគ្នាដើរចូលប្រទេសថៃ។ នៅរ៉ាក់ណងខាងត្បូង មានឆកសមុទ្រដែលម្នាក់អាចចតទូករបស់ពួកគេ ហើយដើរ ចូលទៅក្នុងទឹកដីថៃដោយផ្ទាល់។ ពុំមានការឃ្លាំមើលនៅតាមកន្លែងទាំងនេះឡើយ ហើយ ប្រជាជនមកពីមីយ៉ាន់ម៉ាអាចផ្លាស់ទីចូលទៅក្នុងប្រទេសថៃដោយសេរី និងគ្មានការតាមចាប់ខ្លួនឡើយ។[១៦៨]

## ការជួញដូរកុមាររ៉ូហ៊ីងយ៉ាទៅកាន់ម៉ាឡេស៊ីតាមប្រទេសថៃ

រ៉ូហ៊ីងយ៉ា (Rohingya)  គឺជាក្រុមប្របជាជនឥស្លាមឥណ្ឌូ-អារ្យ៉ាន (Indo-Aryan) មកពីប្រទេសមីយ៉ាន់ម៉ា ដែលទាមទារសិទ្ធិជាម្ចាស់ស្រុកនៃរដ្ឋរ៉ាក់ឃីន (Rakhine) ។ អ្នកប្រវត្តិសាស្តភូមា ក៏ដូចជារដ្ឋាភិបាលភូមា បានទទូចអះអាងថា ពួកគេបានផ្លាស់ទីមកពី ប្រទេសបង់ក្លាដេសនៅអំឡុងពេលអង់គ្លេសគ្រប់គង។ ពាក្យ  Rohingya ក្លាយមកពី ពាក្យ "rohang" ដែលជាឈ្មោះចាស់របស់រដ្ឋរ៉ាក់ឃីន ដែលជនជាតិរ៉ូហ៊ីងយ៉ាធ្លាប់បានរស់នៅអស់ពេលជាច្រើនសតវត្សរ៍។ ទោះបីជាមានប្រវត្តិសាស្ត្រយូរលង់បែបនេះក៏ដោយ គេតែងនិយមហៅពួករ៉ូហ៊ីងយ៉ាថា "Bengali" ដែលផ្តល់ជាយោបល់ថាពួកគេមិនមែនជាជនជាតិភូមា ហើយក៏ពុំធ្លាប់ជាជនជាតិភូមាដែរ ប៉ុន្តែជាជនចំណាក្រស្រុកខុសច្បាប់។

ក្រោយពីមានឯករាជ្យភាពពីអង់គ្លេសនៅឆ្នាំ ១៩៤៨ ពួករ៉ូហ៊ីងយ៉ាដែលមកពីរដ្ឋរ៉ាក់ឃីន បានរួមចំណែកយ៉ាងខ្លាំងក្លានៅក្នុងដំណើរការកសាងជាតិ គ្រីគាន់តែដើម្បីឲ្យពួកគេត្រូវ បានចាត់ទុកថាជាបរទេសនៅក្នុងរដ្ឋសម័យទំនើបរបស់មីយ៉ាន់ម៉ា។ ពួករ៉ូហ៊ីងយ៉ា បាន និងកំពុងទាមទារសុំសិទ្ធិជាពលរដ្ឋនៅមីយ៉ាន់ម៉ាតាំងពីទសវត្សរ៍ឆ្នាំ ១៩៧០ មកម្លេះ ហើយបានរួចផុតពីការប៉ុនប៉ងដកពួកគេចេញ ដោយប្រើគោលនយោបាយក្នុងស្រុក។ ការប៉ុនប៉ងរបស់រដ្ឋាភិបាលភូមា ដើម្បីរុញច្រានពួករ៉ូហ៊ីងយ៉ាចេញក្រៅប្រទេស បានធ្វើឲ្យមានលំហូរយ៉ាងលឿនឥតឈប់ឈរនៃជនអន្តោប្រវេសន៍ចេញពីរដ្ឋរ៉ាក់ឃីន និងចូលទៅប្រទេសមួយចំនួនដូចជា ថៃ ម៉ាឡេស៊ី ឥណ្ឌូនេស៊ី និងបង់ក្លាដេស។[១៦៩]

ក្នុងចំណោមលំហូរជនអន្តោប្រវេសន៍ទាំងនេះ បណ្តាញជួញដូរផ្សេងៗត្រូវបានបង្កើត ឡើងដើម្បីសង្កត់សង្កិននៅលើស្ថានភាពលំបាកនៃពួករ៉ូហ៊ីងយ៉ាដែលងាយរងគ្រោះ។

នៅឆ្នាំ ២០០១ ពួករ៉ូហ៊ីងយ៉ាបានបង្កើតនូវចំណងជើងធំជាប់កំណត់ត្រាលើកទីមួយរបស់ខ្លួននៅប្រទេសថៃ នៅពេលដែលរបាយការណ៍មួយបានអះអាងថា ទាហានជើង ទឹកថៃប្រព្រឹត្តមិនគប្បីទៅលើពួករ៉ូហ៊ីងយ៉ាដែលរកឃើញនៅលើទូក។១៧០ការធ្វើចំណាកស្រុកនៅដំណាក់កាលដំបូងតាមសមុទ្រនេះ មានភាពរីកចម្រើនទៅមុខដោយារកត្តាសេដ្ឋកិច្ច។

បុរសជនជាតិរ៉ូហ៊ីងយ៉ាជាច្រើននាក់ ដែលមានអាយុចាប់ពី ១៨ ឆ្នាំឡើងទៅ  សុខចិត្តធ្វើការធ្វើចំណាក្រស្រុកទៅប្រទេសម៉ាឡេស៊ី ដើម្បីរកការងារធ្វើ។ ប្រទេសម៉ាឡេស៊ីមានតម្រូវការពលករគ្មានជំនាញជាច្រើន ហើយដែលគេដឹងថាជាឋានសួគ៌ដ៏មានសុវត្ថិភាពសម្រាប់ពួករ៉ូហ៊ីងយ៉ា។ ខណៈដែលព័ត៌មានអំពីជីវិតថ្មីរបស់ពួកគេនៅម៉ាឡេស៊ីដឹងឮដល់រដ្ឋរ៉ាក់ឃីន មានពួករ៉ូហ៊ីងយ៉ាជាច្រើននាក់ទៀតត្រូវបានលើកទឹកចិត្តឲ្យធ្វើដំណើរដោយខ្លួនឯង ដែលបណ្តាលឲ្យមានការធ្វើចំណាក្រស្រុកជាទ្រង់ទ្រាយធំទៅកាន់ប្រទេសម៉ាឡេស៊ីតាមផ្លូវទឹករបស់ប្រទេសថៃ។

មេខ្យល់បានកេងប្រវ័ញ្ចលើបវត្តិជោគជ័យនេះ ដើម្បីល្បួងលួងលោមមនុស្សឲ្យឡើងលើទូករបស់ពួកគេ ដោយសន្យាថានឹងនាំពួកគេទៅដល់ប្រទេសម៉ាឡេស៊ីតែម្តង។ នៅទីបំផុតការធ្វើចំណាក្រស្រុកដំណាក់កាលទីពីរបានកើតឡើង ដែលបន្តរហូតមកដល់ សព្វថ្ងៃនេះ ដែលពាក់ព័ន្ធនឹងស្ត្រី និងក្មេងស្រីមិនគ្រប់អាយុ ដែលសង្ឃឹមថានឹងបានទៅរួមរស់ជាមួយឪពុក បង ឬប្អូនប្រុស ពូឬអ៊ុំប្រុស ព្រមទាំងប្តី ដែលកំពុងធ្វើការនៅប្រទេសម៉ាឡេស៊ី។[១៧១]





“ ពួកគេចេញពីមេសត ហើយរកមធ្យោបាយចូលទៅក្នុង ទីក្រុងបាងកក ជាធម្មតាទៅតាមឡានដឹកបន្លែ។ ពួកគេ ទទួលបានប្រាក់កម្ចីពីនរណាម្នាក់ ហើយចុងក្រោយ ត្រូវសងវាទៅឲ្យគេវិញ។ កូនប្រុសខ្ញុំធ្វើបែបនេះ ឥឡូវនេះគាត់កំពុងធ្វើការនៅលើទូកនេសាទដើម្បី រកប្រាក់សងបំណុលសម្រាប់ការធ្វើដំណើររបស់គាត់។”

អ្នកភូមិនៅមីយ៉ាវ៉ាត់ឌី

ថ្មីៗនេះ ព្រឹត្តិការណ៍មួយបានបញ្ឆេះឲ្យមានផ្កាភ្លើងដ៏ធំមួយនៅក្នុងការធ្វើចំណាកស្រុកជា បន្តបន្ទាប់របស់ពួករ៉ូហ៊ីងយ៉ាមកពីប្រទេសមីយ៉ាន់ម៉ា។ នៅខែឧសភា ឆ្នាំ ២០១២ បុរស មូស្លីមចំនួនបីនាក់ត្រូវបានចោទប្រកាន់ពីបទរំលោភសេពសន្ថវៈ និងធ្វើឃាតស្ត្រីពុទ្ធ សាសនិកម្នាក់។ ការចោទប្រកាន់នេះបានបង្កើននូវភាពតានតឹងដែលធ្លាប់មានពីមុនមករវាងពុទ្ធសាសនិកនៅរ៉ូហ៊ីងយ៉ា និងរ៉ាក់ឃីន។ អំពើហិង្សាបានរីករាលដាលនៅភូមិភាគខាងជើងនៃរដ្ឋរ៉ាក់ឃីន ហើយបានរួមចំណែកនាំឲ្យមានការដុតបំផ្លាញផ្ទះរាប់ពាន់ខ្នង ដែលបណ្តាលឲ្យស្លាប់ពួករ៉ូហ៊ីងយ៉ាជាង ១០០ នាក់។[១៧២]

ក្រោយពីមានការរីករាលដាលអំពើហិង្សានៅឆ្នាំ ២០១២ ពួករ៉ូហ៊ីងយ៉ារាប់ពាន់នាក់បានដុះស្លាបហោះហើរចេញពីប្រទេសមីយ៉ាន់ម៉ា ដែលធ្វើឲ្យមណ្ឌលឃុំខ្លួនជនអន្តោប្រវេសន៍របស់ថៃត្រូវពេញណែន ហើយបន្សល់នូវជម្រើសពីរបីសម្រាប់ប្រទេសថៃ។ ប្រទេសពុំមែនជាប្រទេសហត្ថលេខីនៃអនុសញ្ញាជនភៀសខ្លួនឆ្នាំ ១៩៥១ ឬពិធីសារឆ្នាំ ១៩៦៧ របស់វាឡើយ ហើយក៏ពុំមានក្របខ័ណ្ឌផ្តល់សិទ្ធិជ្រកកោនចាំបាច់ដើម្បីឧបត្ថម្ភគាំទ្រដល់ការហូរចូលជនភៀសខ្លួនដ៏គំហុកបែបនេះដែរ (អង្គការ UNHCR ប្រចាំនៅប្រទេស ថៃ)។ អ្នកសង្កេតការណ៍មួយរូបបានចោទប្រកាន់ថា៖

*“នៅពេលបានឡើងលើទូកហើយ ពួកគេឆ្លងកាត់តាមដែនទឹករបស់ថៃ។ ទាហាននៅជើងទឹករបស់ថៃ តែងតែឃាត់កប៉ាល់ឲ្យឈប់ ហើយស្នើសុំការសូកប៉ាន់លុយខ្លះដើម្បីឲ្យពួក គេបន្តការធ្វើដំណើរទៅទៀតបាន។ អ្នកដែលគ្មានលទ្ធភាពបង់លុយសំណូកត្រូវបាននាំ យកទៅកាន់មណ្ឌលឃុំខ្លួនជនអន្តោប្រវេសន៍នៅប្រទេសថៃ ខណៈដែលអ្នកដែលនៅ សេសសល់ទំនងជាត្រូវបាននាំទៅកាន់ជំរុំនៅព្រំដែនខាងប្រទេសម៉ាឡេស៊ី។ ”*[១៧៣]

ដំណើរការនេះ មានបង្ហាញជារូបភាពនៅទំព័រទី ៤៥។ តួលេខដំបូងមួយទៀតបាន អះអាងថា៖

*“ពួករ៉ូហ៊ីងយ៉ាជាច្រើននាក់ ស្នាក់នៅក្នុងមណ្ឌលឃុំខ្លួនរយៈពេលយូរ មុនពេលត្រូវបានគេចាប់ថាស្ថានការណ៍នៅមីយ៉ាន់ម៉ាបានថយចុះភាពតានតឹង ហើយអាចបញ្ជូនពួកគេឲ្យវិលត្រឡប់ទៅស្រុកកំណើតវិញបាន។ ក្នុងសភាពជាក់ស្តែង អាជ្ញាធរគ្រាន់តែយកពួកគេទៅប្រគល់ឲ្យអ្នកជួញដូរមនុស្ស ដែលរង់ចាំពួកគេនៅសមុទ្រ ដែលចាត់ទុកពួកគេជាចំណាប់ខ្មាំង។ ”*[១៧៤]

ខណៈដែលប្រទេសថៃមិនអាចមានកន្លែងផ្ទុកពួករ៉ូហ៊ីងយ៉ា នៅក្នុងមណ្ឌលឃុំខ្លួនរបស់ពួកគេ ហើយប្រទេសមីយ៉ាន់ម៉ាបដិសេធមិនទទួលយកពួករ៉ូហ៊ីងយ៉ាវិញ ប្រទេសថៃត្រូវស្ថិតនៅក្នុងស្ថានភាពដ៏លំបាក។ សកម្មជនបានផ្តល់ជាយោបល់ថា ដោយសារកត្តានេះហើយទើបនាំឲ្យប្រទេសថៃអនុម័ត “ផែនការឆ្លាស់” ដើម្បីដោះស្រាយបញ្ហាទាំងឡាយរបស់ពួករ៉ូហ៊ីងយ៉ាដែលកំពុងនៅក្នុងប្រទេសនេះស្រាប់។[១៧៥]

របាយការណ៍របស់ប្រព័ន្ធផ្សព្វផ្សាយ បានលេចធ្លាយកាលពីពេលថ្មីៗនេះ បានបង្ហាញឲ្យឃើញនូវជំរុំលាក់ខ្លួននៅក្នុងព្រៃជ្រៅ នៅតាមបណ្តោយព្រំដែនថៃ/ម៉ាឡេស៊ី។ គេនិយាយថា នៅទីនេះអ្នកជួញដូរទាមទារលុយលោះខ្លួនពីអ្នកដែលមានសាច់ញាតិតាំងទីលំនៅដោយជោគជ័យនៅម៉ាឡេស៊ី។ នៅភូកេត ពួករ៉ូហ៊ីងយ៉ាជាច្រើននាក់ មិនមានលទ្ធភាពសូកប៉ាន់បានទេ ពួកគេនៅក្មេងៗពេក ឬពុំមានគ្រួសារ ដែលជាលទ្ធផលពួកគេត្រូវបានលក់ទៅឲ្យទូកនេសាទ។[១៧៦]

កាលពីមុន មេខ្យល់ទាមទារឲ្យគ្រួសារបង់លុយចំនួន ១,២០០,០០០ MMK (លុយខ្នាត់មីយ៉ាន់ម៉ា) សម្រាប់ការដោះលែងសាច់ញាតិរបស់ពួកគេ។ បច្ចុប្បន្ននេះ ដោយសារមេខ្យល់មានកំណើនទ្រព្យសម្បត្តិ ពួកគេអនុញ្ញាតឲ្យសាច់ញាតិបង់លុយជាបីដំណាក់កាលដាច់ដោយឡែកពីគ្នា។[១៧៧]

គេនិយាយថា ដំណើរការនេះគឺជាលទ្ធផលនៃគោលនយោបាយដែលបានបង្កើតឡើងដោយនគរបាលភូមិន្ទថៃហៅថា “ជម្រើសទីពីរ” ដើម្បីលុបបំបាត់ការឃុំខ្លួនពួករ៉ូហ៊ីងយ៉ា ណែនណាន់តាន់តាប់នៅក្នុងមណ្ឌល ដែលពួកគេមិនអាចនិរទេសត្រឡប់ទៅកាន់ប្រទេសមីយ៉ាន់ម៉ាវិញបាន។ បច្ចុប្បន្ននេះ មាន “ជំរុំចំណាប់ខ្មាំង” នៅតាមបណ្តោយព្រំដែនថៃ/ម៉ាឡេស៊ី។[១៧៨]

យោងតាមមជ្ឈមណ្ឌលការពារសិទ្ធិមនុស្ស ដែលធ្វើការដើម្បីធ្វើមាតុភូមិនិវត្តន៍ជនរងគ្រោះរ៉ូហ៊ីងយ៉ាបានឲ្យដឹងថា កុមារជាច្រើនដែលរកឃើញនៅលើទូកនេសាទថៃនេះ ពុំធ្លាប់បានស្វែងរកការភៀសខ្លួននៅប្រទេសម៉ាឡេស៊ីឡើយ ប៉ុន្តែត្រូវបានលួងលោម ដោយអ្នកជួញដូរមកពីមីយ៉ាន់ម៉ាផ្ទាល់ ដោយសន្យាថានឹងផ្តល់ការងារឲ្យធ្វើ។ ក្មេងប្រុសអាយុ ១៤ ឆ្នាំម្នាក់ ត្រូវគេសន្យាថាផ្តល់ការងារមានប្រាក់ឈ្នួល នៅម៉ាឡេស៊ី ហើយមេខ្យល់ប្រាប់ថា ការធ្វើដំណើររបស់គាត់នឹងមិនអស់លុយកាក់ អ្វីឡើយ។ មេខ្យល់ទាំងនេះ ទទួលបានលុយឈ្នួលសម្រាប់ការនាំបុរសម្នាក់ៗទៅ ប្រគល់ឲ្យទូក ហើយនឹងបោកបញ្ឆោតក្មេងប្រុសឲ្យគិតថា ពួកគេកំពុងតែ ជ្រើសរើសកម្មករសម្រាប់ការងារដែលមានប្រាក់ឈ្នួល។[១៨០]

“ជាង ៨០% នៃជនរងគ្រោះនៅលើទូកទាំងនេះ ជាកុមារដែលមានអាយុក្រោម ១៨ ឆ្នាំ។

ភាគច្រើននៃពួកគេសុទ្ធតែមកម្នាក់ឯង ពីព្រោះភាគច្រើននៃឪពុកម្តាយរបស់ពួកគេមិននៅរស់ទេ។  ពួកគេងាយនឹងត្រូវបានលួងលោមដោយមេខ្យល់ឲ្យឡើងលើទូក។”[១៨១]

ភាគច្រើននៃបុរស ស្ត្រី និងកុមាររ៉ូហ៊ីងយ៉ា ចូលទៅប្រទេសថៃតាមខេត្តផាងង៉ា ឬខេត្តសាធុន ដែលជាកន្លែងទូកចូលចត។ នៅពេលរកឃើញករណីទាំងនេះ អ្នកដែលត្រូវបានគេរត់ពន្ធត្រូវបាននិរទេសចេញ។ ប៉ុន្តែពួកគេងាយស្រួលក្នុងការរកផ្លូវត្រឡប់ទៅឡើងទូក និងដើររកការងារធ្វើនៅម៉ាឡេស៊ី ដែលធ្វើឲ្យពួកគេមានហានិភ័យពីការជួញដូរម្តងទៀត។ ជាធម្មតា ការនិរទេសគឺតាមរ៉ាក់ណង និងខាវធួង។ រ៉ាក់ណងនៅតែជាចំណុចចេញចូលដ៏សកម្មសម្រាប់ពួករ៉ូហ៊ីងយ៉ា ដែលចូលមកកាន់ប្រទេសថៃ ប៉ុន្តែមិនសូវសកម្មដូចផាងង៉ា និងសាធុនទេ។

រដ្ឋាភិបាលបានបដិសេធថាពួករ៉ូហ៊ីងយ៉ាមិនត្រូវបានគេជួញដូរឡើយ រហូតទាល់តែរក ឃើញរណ្តៅសាកសពជាច្រើនកន្លែងនៅតាមបណ្តោយព្រំដែនម៉ាឡេស៊ី។ ជាទូទៅ នាយកដ្ឋានស៊ើបអង្កេតពិសេស (DSI) ចាត់ទុកថាពួករ៉ូហ៊ីងយ៉ាងគឺជាមនុស្សដែលត្រូវបានគេរត់ពន្ធ។ មន្ត្រីម្នាក់បានអះអាងថា *“ពួកគេត្រូវបាននាំចូលមកប្រទេសថៃដោយខុសច្បាប់ ហើយត្រូវបានរត់ពន្ធបន្តទៅកាន់ម៉ាឡេស៊ី។ ខ្ញុំសន្និដ្ឋានថា ពួកគេមួយចំនួនអាចជាជនរងគ្រោះនៃការជួញដូរ ប៉ុន្តែយើងត្រូវតែស៊ើបអង្កេតករណីនីមួយៗដើម្បីឲ្យដឹងច្បាស់។ ”*[១៨២]

ដរាបណាមីយ៉ាន់ម៉ាបដិសេធមិនផ្តល់សិទ្ធិពលរដ្ឋដល់ពួកគេ គ្មានអ្វីមួយផ្លាស់ប្តូរទេ។ បុរស ស្ត្រី និងកុមារនឹងនៅតែបន្តត្រូវបានមេខ្យល់មកទទួល និងបញ្ជូនទៅឆ្ងាយទៅកាន់ជំរុំជួញដូរមនុស្ស។



# ផែនទីជួញដូរពួករ៉ូហ៊ីងយ៉ា





# ជំពូក ៥៖
# ការជួញដូរពីប្រទេសឡាវ

# ប្រទេសឡាវ

## សាវតារ

សាធារណរដ្ឋប្រជាមានិតឡាវ (ឡាវ) ជាប្រទេសដែលមានប្រាក់ចំណូលទាបក្រោមមធ្យម ដែលមានប្រជាជនចំនួន ៦.៧ លាននាក់។[១៨៣] ជាមួយនឹងអស្ថេរភាពនៃរូបិយប័ណ្ណ គីប របស់ប្រទេសឡាវ (LAK) ការវិនិយោគសេដ្ឋកិច្ច និងការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធសាធារណៈ រងការខូចខាតធំធេង ទោះបីជាប្រទេសនេះមាន ធនធានធម្មជាតិច្រើនសន្ធឹកសន្ធាប់ក៏ដោយ។

ម្ភៃបីភាគរយនៃប្រជាជនឡាវ រស់នៅក្រោមបន្ទាត់ភាពក្រីក្រថ្នាក់ជាតិ ហើយជាង ៦០% រស់នៅជាមួយនឹងប្រាក់ចំណូលតិចជាង ៣.១០ ដុល្លារក្នុងមួយថ្ងៃ។[១៨៤] ស្ថានភាពនៅពុំទាន់មានការរីកចម្រើនជាដុំកំភួននៅឡើយទេ ដែលធ្វើឲ្យឡាវមានគុណវិបត្តិនៅក្នុង AEC ពីព្រោះមានការទាក់ទាញវិនិយោគិនតិចតួចចូលមកកាន់ប្រទេសនេះ។ ដូចគ្នានឹងប្រទេសកម្ពុជា និងមីយ៉ាន់ម៉ាដែរ ចលនាចូលទៅកាន់ប្រទេសថៃហាក់ដូចជាដំណោះស្រាយដ៏មានមានការទាក់ទាញសម្រាប់ដោះស្រាយភាពក្រីក្រ ភាពគ្មានការងារធ្វើ និងកង្វះឱកាស ដែលជាហេតុធ្វើឲ្យមានការធ្វើចំណាកស្រុកទ្រង់ទ្រាយធំរបស់កម្មករ ទាំងស្របច្បាប់ និងខុសច្បាប់។ ដោយមានភាសា និងវប្បធម៌ស្រដៀងគ្នានឹងថៃ ប្រជាជនមកពីប្រទេសឡាវយល់ឃើញថាមានភាពងាយស្រួលក្នុងការប្រឡូកចូលសង្គមថៃ ហើយជាញឹកញាប់ប្រព័ន្ធអន្តោប្រវេសន៍ថៃពុំអាចចាប់ពួកគេបានឡើយ។

ដូចគ្នានឹងករណីកុមារដែលមកពីមីយ៉ាន់ម៉ាដែរ មានមហិច្ឆតាដ៏ខ្លាំងក្លាក្នុងការចូលទៅកាន់ប្រទេសថៃដើម្បីរកលុយ ដែលបណ្តាលឲ្យកុមារត្រូវធ្លាក់ទៅក្នុងការលួងលោមបោកបញ្ឆោតរបស់អ្នកជួញដូរ។ នាយកការិយាល័យអង្គការ UN-ACT ប្រចាំនៅប្រទេសឡាវបានអះអាងថា *"យើងមិនអាចបន្ទោសការជួញដូរ កុមារដោយសារតែភាពក្រីក្រទៀតបានទេឡើយ ពេលវេលាបានផ្លាស់ប្តូរហើយ។ កុមារចង់ធ្វើការ ពួកគេចង់ផ្លាស់ទី។"*[១៨៥]

កាលពីមុន ករណីជួញដូរក្នុងប្រទេសមកពីតំបន់ជនបទទៅកាន់ទីក្រុងធំៗនៅក្នុងប្រទេសឡាវ ទទួលបានការយកចិត្តទុកដាក់តិចតួច។ ប៉ុន្តែកំណើនដើមនៃការធ្វើចំណាកស្រុកឆ្លងដែន និងកំណើនការយកចិត្តទុកដាក់ពីអន្តរជាតិទៅលើការជួញដូរមនុស្សបានបង្ខំឲ្យឡាវប្រឈមមុខនឹងបញ្ហា។ ប៉ុន្តែដោយសារតែគ្មានច្បាប់ ប្រឆាំងនឹងការជួញដូរប្រកបដោយការតាំងចិត្តនៅនឹងកន្លែងនោះ ឡាវយល់ឃើញថាខ្លួនឯងពិការ នៅពេលនិយាយអំពីរឿងប្រយុទ្ធប្រឆាំងនឹងការជួញដូរមនុស្ស ទាំងក្នុងប្រទេសនិងឆ្លងដែនចូលទៅកាន់ប្រទេសថៃ។

រហូតដល់ឆ្នាំ ២០០៥ ឡាវពុំមាននិយមន័យច្បាប់អំពីការជួញដូរ ឬមធ្យោបាយ ច្បាស់លាស់ក្នុងការផ្តន្ទាទោសមេខ្យល់នៅក្នុងប្រទេសប្រកបដោយប្រសិទ្ធភាពនៅឡើយទេ។ និយមន័យអំពីការជួញដូរមនុស្ស ព្រមទាំងការផ្តន្ទាទោសសម្រាប់ជនដែលត្រូវបានគេឃើញថាធ្វើអំពើជួញដូរ ត្រូវបានដាក់បញ្ចូលទៅក្នុងមាត្រា ១៣៤ នៃក្រមព្រហ្មទណ្ឌ។១៨៦ ដូចគ្នាដែរ នៅឆ្នាំ ២០០៥ រដ្ឋាភិបាលឡាវបានបង្កើតអង្គភាពប្រឆាំងការជួញដូរឡាវ (LAPTU) ដែលមានអង្គភាពប្រឆាំងការ ជួញដូរថ្នាក់ខេត្តចំនួនប្រាំមួយខេត្ត ត្រូវបានបង្កើតឡើងនៅឆ្នាំបន្តបន្ទាប់ៗក្រោយមកទៀត ដើម្បីសម្របសម្រួលដល់ការប្រតិបត្តិច្បាប់ក្នុងស្រុក។

ឡាវបានណែនាំច្បាប់ដំបូងរបស់ខ្លួន គឺច្បាប់ប្រឆាំងការជួញដូរនៅខែកុម្ភៈ ឆ្នាំ ២០១៦ ។ គេនៅពុំទាន់បានឃើញមានឥទ្ធិពលអ្វីមួយទៅលើសមត្ថភាពរបស់ឡាវក្នុងការកំណត់អត្តសញ្ញាណ និងផ្តន្ទាទោសករណីជួញដូរនៅឡើយទេ។

## ប្រទេសឡាវក្នុងនាមជាប្រទេសប្រភពដើម

ដោយសារតែកង្វះច្បាប់ប្រឆាំងការជួញដូរពីមុនៗនៅក្នុងប្រទេសឡាវ និងការ យល់ច្រឡំទៅលើអ្វីដែលបង្កើតបានជាករណីជួញដូរនោះ ការប្រមូលទិន្នន័យពុំមានប្រសិទ្ធភាពទេ។១៨៧ នៅចន្លោះឆ្នាំ ២០០១ និង ២០១៤ ជនរងគ្រោះពីការជួញ ដូរចំនួន ២,២១៧ នាក់ ត្រូវបានធ្វើមាតុភូមិនិវត្តន៍ទៅកាន់ប្រទេសឡាវវិញ ដែល ក្នុងនោះ ១,៨៧២ (៨៤.៥%) នៃជនរងគ្រោះទាំងនេះគឺជាកុមារអាយុក្រោម ១៨ ឆ្នាំ។ គ្រាន់តែក្នុងឆ្នាំ ២០១៤ មួយ ជនរងគ្រោះមិនគ្រប់អាយុចំនួន ១១៣ នាក់ ត្រូវ បានគេធ្វើមាតុភូមិនិវត្តន៍។[១៨៨] កុមារដែលជាជនរងគ្រោះពីការជួញដូរអាចត្រូវបានតាមដានរហូតដល់បណ្តាសហគមន៍នានាដែលនៅឆ្ងាយដាច់ស្រយាលទូទាំងប្រទេស។ របាយការណ៍អំពីជនរងគ្រោះដែលបានធ្វើមាតុភូមិនិវត្តន៍ដែលបានធ្វើបច្ចុប្បន្នភាពកាលពីខែមុនបានបង្ហាញឲ្យដឹងថា នៅចន្លោះឆ្នាំ ២០០១ និងឆ្នាំ ២០១៤ តំបន់កំពូលៗទាំង ៥ ដែលកុមារត្រូវបានជួញដូរទៅកាន់រួមមាន៖ សាវ៉ាន់ណាខេត (៦៤៥ នាក់) ចំប៉ាសាក់ (២៨៧ នាក់) សារ៉ាវ៉ាន់ (២៧១ នាក់) សាលាក្រុងវៀងច័ន្ទ (២៣៥ នាក់) និងក្រុងវៀងច័ន្ទ (១៤៤ នាក់)។[១៨៩]

> *តំបន់ជនបទទាំងអស់នៅប្រទេសឡាវ សុទ្ធតែងាយរងគ្រោះ និងមានហានិភ័យពីការជួញដូរ។ ខេត្តនៅជាប់ព្រំដែនមានជនចំណាកស្រុកជាច្រើន ប៉ុន្តែជាទូទៅពួកគេចូលទៅដោយងាយស្រួលដោយពុំមានឯកសារឡើយ។ យើងឃើញជនរងគ្រោះជាច្រើនដែលបានធ្វើមាតុភូមិនិវត្តន៍ទៅតំបន់ដែលកាន់តែដាច់ស្រយាលក្នុងប្រទេស។*
>
> បុគ្គលិកអង្គការ NGO អន្តរជាតិប្រចាំនៅប្រទេសឡាវ

## ផ្លូវជួញដូរពីប្រទេសឡាវទៅកាន់ប្រទេសថៃ

មិនដូចគ្នានឹងប្រទេសកម្ពុជា និងមីយ៉ាន់ម៉ាទេ ជនរងគ្រោះកុមារភាគច្រើនដែលមកពីប្រទេសឡាវចូលប្រទេសថៃ ដោយមានឯកសារស្របច្បាប់តាមរូបភាពមួយចំនួន។ ការចូលដោយស្របច្បាប់ទៅក្នុងប្រទេសថៃ ទាមទារឲ្យមានលិខិតឆ្លងដែន ដែលផ្តល់ សិទ្ធិឲ្យពលរដ្ឋឡាវចូលដោយស្របច្បាប់រយៈពេល ៣០ ថ្ងៃ។ ក្មេងស្រីឡាវភាគច្រើន ដែលត្រូវបានគេកេឃើញថាមានគេជួញដូរនៅក្នុងឧស្សាហកម្មផ្លូវភេទ បានឆ្លងព្រំដែនតាមប៉ុស្តិ៍ត្រួតពិនិត្យព្រំដែនអន្តរជាតិដោយមានលិខិតឆ្លងដែនឬសៀវភៅឆ្លងដែន។ក្មេងស្រីដទៃទៀតចូលតាមច្រកព្រំដែនតាមទម្លាប់ ឬប្រពៃណី ដោយមានតែសៀវភៅឆ្លងដែនប៉ុណ្ណោះ។ សៀវភៅឆ្លងដែន ផ្តល់សិទ្ធិចូលស្របច្បាប់រយៈពេល ៣ ថ្ងៃ ២ យប់ ហើយពុំទាមទារឲ្យមានលិខិតឆ្លងដែនអ្វីឡើយ។ មានសៀវភៅឆ្លងដែនពីរប្រភេទ សៀវភៅមួយមានសុពលភាពសម្រាប់តែការទៅមួយលើក ហើយសៀវភៅមួយទៀតមានសុពលភាពរយៈពេលមួយឆ្នាំ ដែលអនុញ្ញាតឲ្យទៅបានច្រើនលើក។[១៩០]

កុមារដែលគ្មានសៀវភៅឆ្លងដែន ឬកុមារដែលធ្វើដំណើរជាមួយមេខ្យល់ ចូលប្រទេសថៃដោយខុសច្បាប់ ដោយគេចពីច្រកព្រំដែន និងប៉ុស្តិ៍ត្រួតពិនិត្យស្របច្បាប់។ ពួកគេអាចឆ្លងចូលទៅប្រទេសថៃដោយថ្មើរជើង ឬដោយទូកកាត់តាមទន្លេមេគង្គ ដែលបង្កើតបានជាព្រំដែនរវាងប្រទេសឡាវ និងថៃ។

កុមារដែលឆ្លងចូលដោយស្របច្បាប់ ជាទូទៅតែងតែស្នាក់នៅយូរជាងរយៈពេល ៣០ ថ្ងៃក្នុងទិដ្ឋាការរបស់ពួកគេ។ ក្មេងស្រីមិនគ្រប់អាយុជាច្រើន ចូលប្រទេសថៃដោយស្របច្បាប់ ហើយបន្ទាប់មកបន្តការស្នាក់នៅដោយខុសច្បាប់ ក្រោយពីបានតាំង ទីលំនៅក្នុងទីក្រុងធំណាមួយរបស់ថៃ។ នៅក្នុងករណីខ្លះ ពលរដ្ឋឡាវចូលទៅតាមរយៈពេលសុពលភាព ៣០ ថ្ងៃ ធ្វើការរយៈពេល ២៩ ថ្ងៃ រួចហើយត្រឡប់មកកាន់ប្រទេសឡាវវិញ ដើម្បីចូលប្រទេសថៃរយៈពេលបន្ថែម ៣០ ថ្ងៃម្តងទៀត។

ចំនួនមនុស្សពេញវ័យដែលចូលប្រទេសថៃ ដោយមានទិដ្ឋាការការងារដែលមានការទទួលស្គាល់ពីក្រសួងការងារ និងសុខុមាលភាពសង្គមឡាវ (MoLSW) មានការកើនឡើងបន្តិចម្តងៗ។ ទោះជាយ៉ាងណា រដ្ឋាភិបាលឡាវ មិនអនុញ្ញាតឲ្យកុមារអាយុក្រោម ១៨ ឆ្នាំធ្វើការនៅបរទេសឡើយ ដូច្នេះពលរដ្ឋឡាវទាំងអស់ដែលមានអាយុក្រោម ១៨ ឆ្នាំនិងកំពុងធ្វើការសុទ្ធតែខុសច្បាប់ ហើយជាការរំលោភបំពានទៅលើការអនុញ្ញាត។ របាយការណ៍បានផ្តល់ជាយោបល់ថា ជាង៣ភាគបួននៃកម្មករឡាវនៅថៃ គឺជាក្មេងស្រីមិនគ្រប់អាយុ ដែលចូលមកប្រទេសថៃដោយមានឯកសារស្របច្បាប់ជារូបភាពមួយចំនួន បន្ទាប់មកពួកគេបន្តការស្នាក់នៅរហូតដល់ផុតរយៈពេលដែលបានអនុញ្ញាត។ ជាទូទៅ ក្មេងស្រីទាំងនេះពាក់ព័ន្ធនឹងពេស្យាចារ។[១៩១]

ផ្លូវជួញដូរដ៏ពេញនិយមពីឡាវចូលទៅថៃគឺ ណងខៃ ឬឈៀងរ៉ៃ។[១៩២] ទោះជាយ៉ាងណា យោងតាមបុគ្គលិកអង្គការ NGO មួយប្រចាំនៅក្នុងរាជធានីវៀងច័ន្ទ បានឲ្យដឹងថា

ផ្លូវចូលទៅ ប្រទេសថៃតែងតែមានការផ្លាស់ប្ដូរជានិច្ច។

*"កាលពីមុនរបស់ជនអាចឆ្លង [ចូលប្រទេសថៃ] ដោយមិនចាំបាច់មានឯកសារ ប៉ុន្តែ ឥឡូវពួកគេអាចទទួលបានសៀវភៅឆ្លងដែនមានសុពលភាព ៣ ថ្ងៃ ដែលអនុញ្ញាតឲ្យ ពួកគេធ្វើដំណើរក្នុងរយៈចម្ងាយមានកម្រិតមួយនៅប្រទេសថៃ។ កុមារក៏ដូចគ្នាដែរ។ ប្រសិនបើពួកគេមិនមានលិខិតឆ្លងដែនទេនោះ ពួកគេអាចចូលទៅបានដោយសៀវភៅ ឆ្លងដែនរយៈពេល ៣ ថ្ងៃដែរ ដែលជាវិធីងាយបំផុត ហើយជាចុងក្រោយពួកគេធ្វើដំណើរ ទូទាំងប្រទេសថៃ ជួនកាលដោយមានជំនួយពីមេខ្យល់ដែលពួកគេបានជួបនៅព្រំដែន។ នៅទីបំផុតពួកគេស្ថិតក្នុងស្ថានភាពងាយរងគ្រោះ ដែលច្បាស់ជានឹងនាំទៅរកការជួញ ដូរ និងកេងប្រវ័ញ្ចកាន់តែខ្លាំងថែមទៀត។ "[១៩៥]*

## ប្រព័ន្ធមេខ្យល់ឡាវ

ប្រព័ន្ធមេខ្យល់តាមប្រពៃណី មាននៅនឹងកន្លែងដើម្បីជួយសម្របសម្រួលការជួញដូរកុមារពីតំបន់ក្រីក និងទីជនបទនៃប្រទេសឡាវចូលទៅក្នុងប្រទេសថៃ។ ប្រភពមួយនៅទីក្រុងវៀងច័ន្ទបានអះអាងថា មេខ្យល់តែងតែចូលទៅប្រទេសឡាវក្នុងនាមជាភ្ញៀវទេសចរណ៍។ បន្ទាប់មក ពួកគេអាចចូលទៅកាន់ភូមិងាយរងគ្រោះដោយផ្ទាល់ ហើយ ស្វែងរកកុមារដើម្បីបំពេញតម្រូវការ ស្រមាប់សង្វាក់ផ្គត់ផ្គង់នៅប្រទេសថៃ។[១៩៦] ជាទូទៅ មេខ្យល់គឺជាមនុស្សម្នាក់ដែលសហគមន៍ស្គាល់ ហើយនៅទីបំផុតចាប់ផ្ដើមជឿទុកចិត្ត។ មេខ្យល់ទាំងនេះបង្កើតទំនាក់ទំនងជិតស្និទ្ធជាមួយក្រុមគ្រួសារ ហើយនៅក្នុងករណី មួយចំនួនមេខ្យល់គឺជាសាច់ញាតិ។

បុគ្គលិកកាន់សំណុំរឿងមួយរូបបានពន្យល់ថា៖

*"ម្នាក់ៗសុទ្ធតែមានមនុស្សទំនាក់ទំនងដែលពួកគេស្គាល់ ប្រសិនបើពួកគេចង់ស្វែងរកការងារធ្វើនៅប្រទេសថៃ។ ពួកគេទាក់ទងមេខ្យល់នេះ ហើយជួយរៀបចំអ្វីៗគ្រប់យ៉ាង។ មេខ្យល់នេះគឺជាអ្នកដែលស្វែងរកកម្មករកុមារនៅតាមសហគមន៍ជាប្រចាំសយាល។"[១៩៧]*

នៅក្នុងការធ្វើដំណើរតាមគំនិតផ្ដួចផ្ដើមរបស់ខ្លួន កុមារចំណាកស្រុក ដែលជាទូទៅគឺជាក្មេងស្រីជំទង់ តែងតែចូលទៅប្រទេសថៃជាមួយមិត្តភក្តិរបស់ពួកគេ។ ពួកគេធ្លាក់ទៅក្នុងកណ្ដាប់ដៃរបស់មេខ្យល់ ដែលធ្វើល្បិចជាជួយពួកនាងជាមួយនឹងឯកសារធ្វើដំណើរ ដែលនាំទៅរកការសុំឲ្យមេខ្យល់ជួយរកការងារឲ្យធ្វើ។ បញ្ហានេះអាចកើតឡើងនៅព្រំដែនទាំងសងខាងរបស់ឡាវ-ថៃ។ បុគ្គលិកអង្គការ NGO នៅទីក្រុងវៀងច័ន្ទ

> **វាមានភាពងាយស្រួលស្រមាប់មេខ្យល់ថៃក្នុងការចូលទៅឡាវក្នុងនាមជាភ្ញៀវទេសចរណ៍ម្នាក់។ បន្ទាប់មក ពួកគេអាចចូលទៅកាន់ភូមិងាយរងគ្រោះដោយផ្ទាល់ ហើយស្វែងរកកុមារដើម្បីបំពេញតម្រូវការ ស្រមាប់សង្វាក់ផ្គត់ផ្គង់របស់ពួកគេ។**
>
> បុគ្គលិកអង្គការ NGO នៅទីក្រុងវៀងច័ន្ទ

## តួនាទីរបស់ឪពុកម្ដាយនៅក្នុងការជួញដូរកុមារឡាវ

ក្មេងជំទង់ឡាវជាច្រើនធ្វើការសម្រេចចិត្តក្នុងការចូលទៅប្រទេសថៃតែម្នាក់ឯង ដើម្បីស្វែងរកការងារធ្វើ។[១៩៨] ការចូលប្រទេសថៃពីប្រទេសឡាវពុំមែនជារឿងពិបាកដូចប្រទេសជិតខាងដទៃទៀតទេ ដូច្នេះមានចលនាឈប់ឈរចូលទៅក្នុងប្រទេសថៃ។ អ្វីដែលជា ការពិតស្រមាប់ពន្ធគយក្នុងតំបន់គឺថា មានឧទាហរណ៍អំពីឪពុកម្ដាយដែលលើកទឹក ចិត្តឲ្យកូនទៅរកការងារធ្វើនៅប្រទេសថៃ ដើម្បីបង្កើតប្រាក់ចំណូលបន្ថែមស្រមាប់ គ្រួសារ។

ប្រាកដណាស់ មានសម្ពាធតិចតួចលើកុមារឡាវក្នុងការទៅធ្វើការទាំងនៅវ័យក្មេងខ្ចី។ ក្រុមគ្រួសារអាចលើកទឹកចិត្តឲ្យកូនពួកគេចំណាកស្រុក ប៉ុន្តែពួកគេមិនបង្ខំឲ្យពួកគេទៅ ឬទទួលការសម្ពាធដូចដែលគេធ្លាប់បានឃើញនៅក្នុងគ្រួសារថៃ កុលសម្ព័ន្ធភ្នំ កម្ពុជា និងភូមាឡើយ។១៩៩ ទោះជាយ៉ាងណា មានការរាយការណ៍អំពីករណីដែលឪពុកម្ដាយមិនអាចមានលទ្ធភាពចិញ្ចឹមបីបាច់កូនពួកគេ ហើយធ្វើឲ្យពួកគេត្រូវចាកចេញពីគ្រួសារ និងរស់នៅក្នុងភាពម្ចាស់ការទាំងនៅក្មេងខ្ចី ជាជាងការដែលយើងឃើញជាទូទៅនៅតាមបណ្ដាប្រទេសផ្សេងៗក្នុងតំបន់។[២០០]

## កុមារឡាវនៅប្រទេសថៃ

ដោយសារមានភាពស្រដៀងគ្នាផ្នែកភាសា និងវប្បធម៌ កុមារឡាវមានភាពងាយស្រួលក្នុងការចូលប្រឡុកក្នុងសង្គមថៃ ហើយមិនសូវឯកោដូចកុមារចំណាកស្រុកជនជាតិភូមា និងកម្ពុជាទេ។ ពលរដ្ឋឡាវ ពិបាកក្នុងការកំណត់អត្តសញ្ញាណ ពីព្រោះគេអាចច្រឡំជាមួយនឹងជនជាតិថៃ។ ជាលទ្ធផល ការជួញដូរជនរងគ្រោះពីប្រទេសឡាវអាចឃើញមាននៅស្ទើរគ្រប់ទីកន្លែងក្នុងប្រទេសថៃ ដែលធ្វើការបម្រើថៅកែ និងឧស្សាហកម្មសម្បូរបែបជាច្រើន។ របាយការណ៍បញ្ជាក់ថា ជនរងគ្រោះឡាវមកពីភូមិភាគកណ្ដាល និងភាគខាងត្បូងនៃប្រទេសឡាវ ចូលចិត្តទៅធ្វើការនៅទីក្រុងបាងកក។

ក្មេងស្រីមិនគ្រប់អាយុ ដែលចូលមកតាមច្រកល្បច្បាប់កាត់តាមណុងខៃ ជាទូទៅតែងតែឃើញធ្វើការនៅណុងខៃ ឬបាងកក។ ក្មេងស្រីដែលមកពីប្រទេសឡាវក៏ឃើញធ្វើការ នៅក្នុងបារនៅខេត្តនានាក្នុងប្រទេសភាគខាងត្បូង ដែលផ្ដល់ជាយោបល់ថា ពុំមាន គោលដៅជាក់លាក់ស្រមាប់ជនរងគ្រោះឡាវ ហើយពួកគេទៅគ្រប់ទីកន្លែងដែលមាន តម្រូវការការងារ។

របាយការណ៍ស្ដីពីការជួញដូរមនុស្សឆ្នាំ ២០១៤ របស់ក្រសួងការបរទេសបញ្ជាក់ថា ជនរងគ្រោះឡាវជាច្រើនធ្វើការនៅក្នុងឧស្សាហកម្មផ្លូវភេទ។[២០១]
ព័ត៌មាននេះត្រូវបានអះអាង ដោយរបាយការណ៍ផ្លូវការស្ដីពីអ្នកដែលធ្វើមាតុភូមិនិវត្តន៍ ដែលបង្ហាញថា នៅឆ្នាំ ២០១៤ ក្មេងស្រីមិនគ្រប់អាយុជិត ១០០ នាក់ត្រូវបានធ្វើមាតុភូមិនិវត្តន៍ក្នុងនាមជាជន រងគ្រោះពីការជួញដូរផ្លូវភេទ ខណៈដែលក្មេងប្រុសមិនគ្រប់អាយុតិចតួចប៉ុណ្ណោះដែល ត្រូវបានធ្វើមាតុភូមិនិវត្តន៍។ ប្រហែល ៩៥% នៃជនរងគ្រោះដែលបានធ្វើមាតុភូមិនិវត្តន៍គឺ ជាស្ត្រី ដែល ៨០% នៃពួកគេសុទ្ធតែពុំគ្រប់អាយុ។[២០២]

នៅខែមករា ឆ្នាំ ២០១៥ អាជ្ញាធរថៃបានសង្គ្រោះក្មេងជំទង់ឡាវចំនួន ៧២ នាក់ (អាយុ ១៣-២០ ឆ្នាំ) ដែលឃើញធ្វើការជាពេស្យាចារនៅក្នុងបារខារ៉ាអូខេចំនួនបួននៅស្រុកសុងភីណង នៃខេត្តស៊ូផានប៊ុរី ភាគកណ្ដាលនៃប្រទេសថៃ។[២០៣]

ការជួយសង្គ្រោះនេះ ទាញចំណាប់អារម្មណ៍ និងក្ដីកង្វល់ពីប្រព័ន្ធផ្សព្វផ្សាយអន្តរជាតិទៅលើឧស្សាហកម្មផ្លូវភេទ ព្រមទាំងការកេងប្រវ័ញ្ចគ្មានមេត្តាទៅលើជនរងគ្រោះកុមារ។

ក្មេងស្រីឡាវមានតម្រូវការខ្ពស់នៅក្នុងឧស្សាហកម្មផ្លូវភេទ ពីព្រោះគេដឹងថាពួកគេមានរូបស្រមស់ទាក់ទាញទាំងភ្ញៀវថៃ និងភ្ញៀវបរទេស។ ក្មេងស្រីឡាវមានរូបសម្បត្តិខាងក្រៅ និងជំនាញភាសាដែលចាំបាច់ក្នុងការទាក់ទាញភ្ញៀវទាំងពីរប្រភេទ ដូច្នេះពួកគេមាន តម្រូវការខ្ពស់ ហើយងាយស្រួលក្នុងការដឹកជញ្ជូននៅទូទាំងប្រទេស។[២០៤]

ឧស្សាហកម្មផ្លូវភេទ ផ្ដល់ឲ្យនគរបាលនូវភ័ស្ដុតាងច្បាស់លាស់អំពីការកេងប្រវ័ញ្ច។ អំពើពេស្យាចារងាយស្រួលក្នុងការពិនិត្យតាមដាន ពីព្រោះជាទូទៅអាជ្ញាធរដឹងពីកន្លែងដែលត្រូវទៅរកមើលជនរងគ្រោះដែលជាក្មេងស្រីមិនគ្រប់អាយុ។ ក្មេងស្រីដែលបានសង្គ្រោះពីផ្ទះបន ផ្ដល់ភ័ស្ដុតាងដល់នគរបាលភូមិន្ទថៃស្រមាប់យកទៅផ្ដន្ទាទោសក្រោមច្បាប់ប្រឆាំងការជួញដូរមនុស្សឆ្នាំ ២០០៨។

ក្មេងប្រុសឡាវ ក៏ត្រូវបានជួញដូរទៅប្រទេសថៃផងដែរ ដើម្បីធ្វើការនៅក្នុងឧស្សាហកម្មប្រើកម្លាំង ទោះបីជាយ៉ាងណា ជាញឹកញាប់ពុំមានការរាយការណ៍ ឬឃើញពួកគេទេ។ វា អាចជានឹងកាន់តែពិបាកក្នុងការផ្ដន្ទាទោសអ្នកជួញដូរក្មេងប្រុស ពីព្រោះឧស្សាហកម្ម

> **ក្មេងស្រីឡាវ មានពណ៌សម្បុរស្បែកភ្លឺថ្លា ដែលធ្វើឲ្យពួកគេមើលទៅស្អាត។ ចរិកលក្ខណៈស្លូតបូតរបស់ពួកគេពិតជាមានភាពទាក់ទាញស្រមាប់បុរសជនជាតិថៃ។**
>
> ជនអនាមិកនៅទីក្រុងបាងកក

ដែលជួលពួកគេ (រោងចក្រ កសិកម្ម ទូកនេសាទ និងការងារតាមផ្ទះ) មិនងាយនឹងផ្តល់ភ័ស្តុតាងសំខាន់អំពីការកេងប្រវ័ញ្ចនោះឡើយ។[២០៥]

## ការធ្វើមាតុភូមិនិវត្តន៍កុមារដែលត្រូវបានជួញដូរត្រឡប់ទៅកាន់ប្រទេសឡាវវិញ

កុមារដែលត្រូវបានកំណត់អត្តសញ្ញាណថាជាជនរងគ្រោះពីការជួញដូរ នឹងត្រូវបានធ្វើ មាតុភូមិនិវត្តន៍ត្រឡប់ទៅកាន់ប្រទេសឡាវវិញ តាមទីជម្រកសំចតក្រុងវៀងច័ន្ទនៅតាមព្រំដែន។ អនុស្សរណៈយោគយល់រវាងឡាវ និងថៃ បានចែងថា កុមារគួរតែស្ថិតនៅក្នុងទីជម្រករយៈពេលអតិបរិមា ៧ ថ្ងៃ ខណៈដែលករណីនេះត្រូវបានរាយការណ៍ជូនក្រសួងសុខុមាលភាពសង្គម (ឡាវ) នៅថ្នាក់ខេត្ត ដើម្បីផ្តួចផ្តើមដំណើរការសមាហរណកម្មជនរងគ្រោះនោះ។

បច្ចុប្បន្ននេះ ពុំមានទីជម្រកនៅវៀងច័ន្ទដើម្បីទទួលជនរងគ្រោះបុរសដែលត្រូវបានធ្វើមាតុភូមិនិវត្តន៍ឡើយ គឺមានសម្រាប់តែស្ត្រីប៉ុណ្ណោះ។ រហូតមកទល់នឹងពេលថ្មីៗនេះ ពាក្យ □ការជួញដូរ□ ត្រូវបានអនុវត្តតែទៅលើជនរងគ្រោះជាស្ត្រី និងកុមារប៉ុណ្ណោះ ដោយ មានការយកចិត្តទុកដាក់តិចតួចទៅលើមនុស្សប្រុសពេញវ័យ។

មានទិន្នន័យដែលមានក្រមិត ដែលអាចរកបានដើម្បីបញ្ជាក់អះអាងអំពីភាពជោគជ័យនៃដំណើរការធ្វើមាតុភូមិនិវត្តន៍ ឬសមាហរណកម្ម មានព័ត៌មានបន្តិចបន្តួចអំពីអ្វីដែល កើតឡើងជាក់ស្តែងនៅព្រំដែនទាំងសងខាង និងការប្រាស្រ័យទាក់ទងដែលមានក្រមិតរវាងអាជ្ញាធរថៃ និងឡាវ។ កង្វះការសន្ទនា អាចរារាំងដល់ដំណើរការធ្វើសមាហរណកម្ម ពីព្រោះព័ត៌មានអំពីបរិវត្តិនៃសំណុំរឿង អំពីបទពិសោធន៍របស់កុមារនៅប្រទេសថៃ ពុំត្រូវបានបតល់ទៅឲ្យអាជ្ញាធរឡាវឡើយ។

## កិច្ចការពារ និងទប់ស្កាត់កុមារឡាវ

នៅខែកុម្ភៈ ឆ្នាំ ២០១៥ មន្ត្រីអន្តោប្រវេសន៍ថៃ បានឃាត់ខ្លួនក្មេងស្រីមិនគ្រប់អាយុជាង ១០០ នាក់ ដែលព្យាយាមចូលប្រទេសថៃដោយស្របច្បាប់តាមស្ពានមិត្តភាព។ មន្ត្រីអន្តោប្រវេសន៍មួយរូប ដែលធ្វើការនៅណងខៃ បានថ្លែងបញ្ជាក់ថា៖

*"ក្មេងស្រីនិយាយថា ពួកគេនឹងទៅធ្វើការនៅបាងកកជាមួយនរណាម្នាក់។ ពួកគេអាចនឹងមានហានិភ័យក្លាយទៅជាជនរងគ្រោះពីការជួញដូរមនុស្ស។ យើងខ្លាចថាពួកគេមិន ដឹងថាពួកគេត្រូវបានគេល្បួងឲ្យចូលទៅបម្រើសេវាផ្លូវភេទណាស់។ "*[២០៦]

ការចាត់វិធានការបានចាប់ផ្តើមនៅដើមឆ្ នាំ ២០១៥ ដែលកើតឡើងនៅព្រំដែនភាគីខាង ថៃ ដោយសា រតែមានចំនួនអនិតិជនច្រើនលើសលប់ដែលគ្មានអ្ន កអមដំណើរ ដែល ព្យាយាមចូលក្នុងប្រទេសថៃ ដោយគ្មានច្បាប់ និងកន្លែងដែលត្រូវទៅ។ ទោះបីជាការចាត់វិធានការនេះធ្វើឲ្យមានការភ្ញាក់ផ្អើលដល់មតិម ហាជនថៃក៏ដោយ ការយកចិត្តទុកដាក់ពីរបាយការណ៍ TIP របស់ក្រសួងការបរទេសសហរដ្ឋអាមេរិក ឬប្រព័ន្ធ ផ្សព្វផ្សាយផ្តាតការយកចិត្តទុកដាក់ទៅលើក្មេងស្រីជំទង់ ដែលត្រូវបានសង្គ្រោះពីតាមបារខារ៉ាអូខេនៅភាគកណ្តាលប្រទេសថៃ ក៏ទង្វើនេះគឺជាជំហានវិជ្ជមានឆ្ពោះទៅមុខមួយរបស់រដ្ឋាភិបាលថៃផងដែរ។

NGOs នៅប្រទេសឡាវ ធ្វើការដើម្បីផ្តល់ការអប់រំដល់កុមារអំពីគ្រោះថ្នាក់នៃការជួញដូរ ហើយជួយស្តារនីតិសម្បទាអ្នកដែលបានធ្វើមាតុភូមិនិវត្តន៍ ដោយធ្វើការដើម្បីលុប បំបាត់របួស្នាមផ្លូវចិត្តដែលនៅដក់ជាប់ក្នុងដួងចិត្តជនរងគ្រោះ នៅពេលពួកគេបានធ្វើមាតុភូមិនិវត្តន៍មកវិញ។

ពុំមានទិន្នន័យជារូបី ដែលពាក់ព័ន្ធនឹងការជួញដូរជនរងគ្រោះឡាវចូលទៅប្រទេសថៃម្តងទៀតទេឡើយ។ ទោះបីជាមានការប៉ុនប៉ងបង្កើតឱកាសបណ្តុះបណ្តាលវិជ្ជាជីវៈកាន់តែច្រើនក៏ដោយ ក្មេងស្រីជំទង់ជាច្រើនត្រឡប់មកភាពក្រីក្រដែលបានបន្សល់ទុក ប៉ុន្តែបានសាកល្បងរសជាតិថ្មីនៃភាពសម្បូរសប្បាយ សម្ភារៈនិយមនៅប្រទេសថៃ ហើយពួកគេ មានបំណងព្យាយាមចូលទៅកាន់ប្រទេសថៃម្តងទៀត។

## ឧបសគ្គនៅក្នុងការប្រយុទ្ធប្រឆាំងនឹងការជួញដូរកុមារពីឡាវទៅថៃ

វាហាក់ដូចជាមានការយល់ដឹងតិចតួចអំពីការជួញដូរ ជាពិសេសនៅតាមទីជនបទដាច់ស្រយាលរបស់ប្រទេសឡាវ។ បញ្ហាមួយក្នុងចំណោមបញ្ហាធំបំផុតសម្រាប់អង្គការ NGOs និង
ការិយាល័យរដ្ឋាភិបាលដូចគ្នានេះ គឺការយល់ដឹងអំពីច្បាប់ និងគោលនយោបាយនៅថ្នាក់ជាតិ និងការអនុវត្តន៍ច្បាប់ និងគោលនយោបាយទាំងនោះនៅគ្រប់សទាប់វណ្ណៈ។ មានគម្លាតដ៏ខ្លាំងរវាងបទដ្ឋានច្បាប់ និងបទបញ្ញា និងអ្វីដែលកើតឡើងនៅក្នុងតថភាពជាក់ស្តែង ហើយហាក់ដូចជាមានកង្វះការសើបអង្កេតតាមដានទៅលើករណីជួញដូរមនុស្ស។ ដូចគ្នាដែរ ក្នុងន័យកិច្ចការពារ ពុំមានការតាមដានបន្តទៀតទេឡើយ។[២០៧]

ភាពសុក្រិតនៃឯកសារបញ្ជាក់អត្តសញ្ញាណផ្លូវការ គឺជារឿងដែលត្រូវចោទសួរ។ នគរបាលភូមិន្ទថៃ បានចោទសួរថា នៅក្នុងករណីជាច្រើន
អាយុដែលផ្តល់នៅលើលិខិត ឆ្លងដែនពុំស៊ីគ្នាជាមួយនឹងរូបរាងខាងក្រៅ
របស់អ្នកកាន់លិខិតឆ្លងដែននោះសោះ។ ដោយសារតែវាជាឯកសារផ្លូវការរបស់ប្រទេស ហើយ ទើបការចោទសួរអំពីភាពសុក្រិតនៃ ព័ត៌មានដែលមានជាមួយរដ្ឋាភិបាលឡាវ អាចជាបញ្ហារសើបផ្នែកនយោបាយ។ កាលពី មុន បើគ្មានការទទួលបានឯកសារស្របច្បាប់ដោយងាយៗ ជាទូទៅនគរបាលធ្វើការ ត្រួតពិនិត្យល្អិតល្អន់ ដើម្បីជៀសវាងការក្លែងបន្លំអាយុរបស់ជនរងគ្រោះ។[២០៨]

បច្ចុប្បន្ននេះ សេវាបម្រើជនរងគ្រោះទាំងអស់នៅឡាវ ត្រូវបានផ្តល់ជូនស្ត្រី និងកុមារ។ មានសេវាមួយចំនួនតូចដែលជាចេដាយឡែកពីគ្នា ដើម្បីបំពេញតម្រូវការរបស់បុរស ដែលត្រូវបានធ្វើមាតុភូមិនិវត្តន៍ក្នុងនាមជាជនរងគ្រោះពីការជួញដូរ។ ខណៈដែលចំនួននៃជនរងគ្រោះជាបុរសនៅតែមានទាប បើប្រៀបធៀបជាមួយជនរងគ្រោះជាស្ត្រី ពុំមានប្រព័ន្ធណាមួយនៅនឹងកន្លែងសម្រាប់ការពារបុរសតាមវិធីណាមួយឡើយ។ បច្ចុប្បន្ននេះ ជនរងគ្រោះស្ត្រី និងបុរស ត្រូវបានដាក់នៅក្នុងទីជម្រកតែមួយ ដែលបង្កឲ្យមានការ រឹតត្បិតបន្ថែមនៅក្នុងដំណើរការស្តារ និងធ្វើសមាហរណកម្ម។

.

## ការជួញដូរកុមារឡាវទៅកាន់ប្រទេសម៉ាឡេស៊ីតាមប្រទេសថៃ

របាយការណ៍ TIP របស់ក្រសួងការបរទេសសហរដ្ឋអាមេរិកឆ្នាំ ២០១៤ បានបញ្ជាក់អះអាងថា ប្រទេសថៃនៅតែដើរតួជាប្រទេសសំចតសម្រាប់ក្មេងស្រីជំទង់ឡាវដែលត្រូវបានជួញដូរឲ្យទៅធ្វើការនៅក្នុងឧស្សាហកម្មផ្លូវភេទនៅម៉ាឡេស៊ី។២០៩ របាយការណ៍ពីអង្គការអន្តោប្រវេសន៍អន្តរជាតិ (IOM)
បានបង្ហាញឲ្យឃើញពីចំនួនដ៏ច្រើនគួរសមនៃជន រងគ្រោះឡាវមិនគ្រប់អាយុ ដែលធ្វើការនៅម៉ាឡេស៊ី ដើម្បីបម្រើសហគមន៍កម្មករចំណា ក ស្រុកឡាវ។[២១០]

វាជារឿងដែលមិនអាចទៅរួចឡើយ ក្នុងការប៉ាន់ស្មានពីចំនួនកុមារឡាវនៅម៉ាឡេស៊ី នៅក្នុងបនពស្យាចារ ឬនៅលើទូកនេសាទនៅដែនទឹករបស់ម៉ាឡេស៊ី។ ទិន្នន័យពី ការិយាល័យអន្តោប្រវេសន៍ថៃបានបង្ហាញថា នៅឆ្នាំ ២០១១ ពលរដ្ឋឡាវចំនួន ៤៨,០០០ នាក់ បានចំណាក្រស្រុកទៅកាន់ម៉ាឡេស៊ីកាត់តាមប្រទេសថៃ ដោយមានតែ ៤៦,០០០ នាក់ប៉ុណ្ណោះដែលវិលត្រឡប់ទៅកាន់ប្រទេសឡាវវិញ។[២១១]

ចាប់តាំងពីឆ្នាំ ២០១១ មក រដ្ឋាភិបាលឡាវ បានយកចិត្តទុកដាក់បន្ថែមទៅលើចំនួនក្មេងស្រីឡាវមិនគ្រប់អាយុ ដែលធ្វើដំណើរចេញទៅក្រៅប្រទេស ជាពិសេសទៅកាន់ប្រទេសម៉ាឡេស៊ី។ ក្មេងស្រីជាច្រើន ធ្លាប់ត្រូវបានគេរាយការណ៍មកថា "បាត់ខ្លួន" ឬ "ត្រូវបានគេលក់ដូរ" ក្រោយពីមានបទបញ្ញាថ្មីសម្រាប់ការពារពួកគេពីការរៀបការខុសច្បា ប់។ នៅពេលមកដល់ប្រទេសម៉ាឡេស៊ី ក្មេងស្រីត្រូវបានបង្ខំឲ្យទៅធ្វើការនៅបនពស្យា ចារ។[២១២]

ការធេចាកេនះ មានលក្ខណៈសកម្ម និងរីកសាយភាយយ៉ាងខ្លាំងក្នុងពេលបច្ចុប្បន្ន។ អង្គការជាច្រើន ដែលធ្វើការដើម្បីការពារក្រុងសីលភាពព្រហ្មចារី និងក្មេងស្រីឡាវពីការជួញដូរចូលទៅក្នុងឧស្សាហកម្មផ្លូវភេទ បានបញ្ជាក់អះអាងថា
ពួកគេបានឃើញក្មេងស្រី ឡាវជាច្រើននៅប្រទេសម៉ាឡេស៊ី ពីព្រោះមានតម្រូវការខ្ពស់ ដោយសារតែរូបស្រមស់ របស់ពួកគេ ហើយក៏ដោយសារតែពួកគេងាយស្រួលក្នុងការលួងលោមតាមរយៈការ សន្យាកេការងារឲ្យធ្វើផងដែរ។[២១៣]



# ជំពូក ៦៖
# សេចក្ដីសន្និដ្ឋាន និងអនុសាសន៍

†

# សេចក្ដីសង្ខេប

## តើប្រទេសថៃដើរតួជាប្រទេសប្រភព គោលដៅ និងឆ្លងកាត់ សម្រាប់ការជួញដូរកុមារដោយរបៀបណាខ្លះ?

